# លក្ខណសម្បត្តិ
# ព្រះជាម្ចាស់

## THE ATTRIBUTES OF GOD

និពន្ធដោយ៖

A.W. PINK

លក្ខណសម្បត្តិព្រះជាម្ចាស់

The Attributes of God
By: A. W. Pink

This edition in Khmer copyright 2022

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org
ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

បកប្រែដោយ៖ លោក ឈាង បូរ៉ា

ជំនួយការអ្នកបកប្រែ៖ លោក វែល ណាថាន

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ប៊ុន ធីម៉ូថេ, លោក ឯក សត្យា និងលោក ឯក ធីម៉ូថេ

សូមថ្លែងអំណរគុណចំពោះ៖ លោកស្រី ឡូញ ស្រី រដ្ឋ, លោក សួន ចាន់រួម, លោក អ៊ុន ជ័យរិទ្ធ, លោក ជួប ប៊ុនហាក់, លោកស្រី កែវ សិរីវុឌ្ឍី និងលោកស្រី ថាវ ប៊ុនរី

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួលឆ្នាំ២០១៤ (គកស), ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ (គគខ), ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វែល ណាថាន និងលោក ឯក ធីម៉ូថេ

For ordering information please visit:
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖
http://www.attributesofgodkhmer.com

បោះពុម្ពលើកទី១ ចំនួន៣.០០០ក្បាល គ.ស២០២២

# មាតិកា

អារម្ភកថា.......................................................................................៥
បុព្វកថា...........................................................................................៩
ព្រះដ៏ឯកអង្គ................................................................................ ១១
ការគ្រោងទុករបស់ព្រះ......................................................................២៥
ព្រះដ៏មានបញ្ញាញាណ.......................................................................៣៩
ព្រះដ៏ពេញដោយបុព្វញាណ.............................................................. ៥៣
ព្រះដ៏ឧត្តុង្គឧត្តម...............................................................................៧១
ព្រះដ៏មានអធិបតេយ្យភាព............................................................... ៨៥
ព្រះដែលមិនចេះប្រែប្រួល...............................................................១០១
ភាពបរិសុទ្ធរបស់ព្រះ ...................................................................១១៣
ព្រះដ៏មានសព្វានុភាព....................................................................១២៩
ព្រះដែលស្មោះត្រង់.........................................................................១៤៩
សេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ .....................................................១៦៥
ការអត់ធ្មត់របស់ព្រះជាម្ចាស់...........................................................១៧៧
ព្រះគុណរបស់ព្រះជាម្ចាស់................................................................១៩១
សេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់..................................................២០៩
សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់.....................................................២២៥

សេចក្ដីក្រោធរបស់ព្រះជាម្ចាស់..........................................២៤៣
ការសញ្ជឹងគិតអំពីព្រះជាម្ចាស់..............................................២៦១
កំណត់យោង ........................................................................២៧៧
ការអានបន្ថែមជាច្រើនទៀត..................................................២៧៨

# អារម្ភកថា

កណ្ឌគម្ពីរ យ៉ូប ២២:២១ បានចែងថា «ដូច្នេះ ចូរអ្នកផ្គាប់ផ្គុនទ្រង់ ហើយមានសេចក្ដីមេត្រីនឹងទ្រង់ចុះ នោះនឹងបានចម្រើនប្រយោជន៍ដល់ខ្លួន»។ កណ្ឌគម្ពីរ យេរេមា ៩:២៣-២៤ បានចែងថា «ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះថា កុំបីឲ្យអ្នកប្រាជ្ញអួតពីប្រាជ្ញារបស់ខ្លួនឡើយ ក៏កុំឲ្យមនុស្សខ្លាំងពូកែអួតពីកម្លាំងខ្លួន ឬអ្នកមាន អួតពីទ្រព្យសម្បត្តិរបស់ខ្លួនដែរ ឯអ្នកដែលអួត នោះត្រូវឲ្យអួតតែពីសេចក្ដីនេះវិញ គឺថាខ្លួនមានយោបល់ ហើយក៏ស្គាល់ដល់អញថា អញជាព្រះយេហូវ៉ាដែលប្រោសផ្សាយសេចក្ដីសប្បុរស សេចក្ដីយុត្តិធម៌ និងសេចក្ដីសុចរិតនៅផែនដី ដ្បិតអញរីករាយចិត្តចំពោះសេចក្ដីទាំងនោះហើយ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា»។ តម្រូវការដ៏ចម្បងរបស់មនុស្សលោកគឺ ការមានចំណេះដឹងខាងឯវិញ្ញាណរបស់ព្រះជាម្ចាស់ ដែលនាំឲ្យបានសេចក្ដីសង្គ្រោះ។

ការ យល់ ដឹង ឲ្យ បាន ជាក់លាក់ ពី ភាព ល្អ ឥត ខ្ចោះ របស់ព្រះជាម្ចាស់ដែលមានចែងនៅក្នុងព្រះគម្ពីរ គឺជាមូលដ្ឋានគ្រឹះដ៏ពិតនៃ

ការស្គាល់ព្រះអង្គ។ តើឲ្យយើងអាចដាក់ទំនុកចិត្ត និងបម្រើ ហើយថ្វាយបង្គំព្រះដែលយើងមិនស្គាល់បានដោយរបៀបណាទៅ! យើងខ្ញុំបានព្យាយាមរៀបរាប់ពីលក្ខណសម្បត្តិចម្បងៗដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់នៅក្នុងសៀវភៅនេះ។ ប្រសិនបើមិត្តអ្នកអានពិតជាចង់ទទួលបានអត្ថប្រយោជន៍ចេញពីការអានសៀវភៅនេះមែន នោះបងប្អូនចាំបាច់ត្រូវតែទទូចសូមអត្ថប្រយោជន៍ ទាំងនេះពីព្រះជាម្ចាស់ឲ្យអស់ពីចិត្ត ដើម្បីឲ្យបងប្អូនទទួលបានការបំផ្លាស់បំប្រែក្នុងជីវិត តាមរយៈការអនុវត្តសេចក្ដីពិតរបស់ទ្រង់នៅក្នុងបញ្ញាចិត្ត និងដួងចិត្តរបស់បងប្អូន។

បងប្អូនដឹងហើយថា យើងមិនអាចស្គាល់ព្រះជាម្ចាស់តាមរយៈតែព័ត៌មានដែលនិយាយពីទ្រង់ប៉ុណ្ណោះនោះទេ។ បើគ្រាន់តែជាព័ត៌មាន នោះមិនទាន់គ្រប់គ្រាន់ទេ យើងអាចស្គាល់ទ្រង់ច្បាស់ក្នុងព្រលឹងរបស់យើងបាន គឺតាមរយៈការថ្វាយខ្លួន ការចុះចូលនឹងអំណាចព្រះចេស្ដារបស់ទ្រង់ និងការយកបញ្ញត្តិដ៏បរិសុទ្ធរបស់ទ្រង់មកអនុវត្តក្នុងជីវិតរស់នៅរបស់យើង។ កណ្ឌគម្ពីរ ហូសេ ៦:៣ បានចែងថា «ចូរឲ្យយើងបានស្គាល់ព្រះយេហូវ៉ាចុះ ហើយមានព្យាយាមនឹងស្គាល់ទ្រង់តទៅ...»។ យ៉ូហាន ៧:១៧ «បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹង...»។ ដានីយ៉ែល ១១:៣២ «...តែ

ចំណែកពួកអ្នកទាំងប៉ុន្មានដែលស្គាល់ព្រះនៃខ្លួន គេនឹងមានចិត្តរឹងប៉ឹង...»។

# បុព្វកថា

ជំពូកនីមួយៗនៅក្នុងសៀវភៅនេះ ពីដើមអ្នកនិពន្ធបានចេញផ្សាយនៅក្នុងទស្សនាវដ្ដីប្រចាំខែដែលមានជាស៊េរីឈ្មោះថា *Studies in the Scriptures* ជាភាសាអង់គ្លេស។ អ្នកនិពន្ធសរសេរជាស៊េរីក្នុងគោលបំណង ដើម្បីកាត់ស្រាយព្រះបន្ទូល ហើយផ្គត់ផ្គង់អាហារខាងឯវិញ្ញាណដល់អស់អ្នកដែលស្រេកឃ្លាន។ មានគ្រីស្ទបរិស័ទដ៏សប្បុរសម្នាក់បានរ៉ាប់រងរាល់ការចំណាយលើការចងក្រងជំពូកទាំងអស់ក្នុងទស្សនាវដ្ដីនោះ ដើម្បីឲ្យលេចចេញជារូបរាងសៀវភៅឡើង។ សូមឲ្យសៀវភៅនេះបានជាព្រះពរដល់មិត្តអ្នកអានទាំងអស់។

— អេ. ដឹបលយូ. ភីងខ៍ (A. W. PINK)

ជំពូកទី១

# ព្រះដ៏ឯកអង្គ

ចំណងជើងនៃជំពូកនេះ ប្រហែលជាមិនទាន់បានបញ្ជាក់ច្បាស់ពីអត្ថន័យដ៏ពេញលេញនៃអត្ថបទនេះនៅឡើយទេ។ មូលហេតុដែលអត្ថន័យនៃអត្ថបទនេះមិនសូវមានភាពច្បាស់លាស់ចំពោះគ្រីស្ទបរិស័ទជាច្រើន គឺដោយសារតែសព្វថ្ងៃនេះ ពួកគេមិនបានយកចិត្តទុកដាក់ក្នុងការសញ្ជឹងគិតលើបុគ្គលិកលក្ខណៈដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់នៅឡើយ។ ហើយក្នុងចំណោមអស់អ្នកដែលអានព្រះគម្ពីររបស់ពួកគាត់តែបន្តិចបន្តួច ក៏កាន់តែមានមនុស្សតិចថែមទៀតមានចិត្តឆេះឆួលក្នុងការថ្វាយបង្គំទ្រង់ដែរ បើទោះជាពួកគេបានឃើញលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះរបស់ទ្រង់ក៏ដោយ។ មានគ្រីស្ទបរិស័ទជាច្រើនបានគិតថា ការដែលដឹងថាព្រះជាម្ចាស់មានប្រាជ្ញាញាណដ៏អស្ចារ្យ មានអំណាចចេស្ដាដ៏អស្ចារ្យ ប៉ុន្តែទ្រង់នៅតែមានសេចក្ដីមេត្តាករុណា គឺគ្រាន់តែជារឿងធម្មតាប៉ុណ្ណោះ។ ប៉ុន្តែតាមពិតទៅ នេះជាការពិបាកណាស់ក្នុងការដែលឲ្យគ្រីស្ទបរិស័ទរស់

នៅក្នុងសម័យកាលដ៏អាក្រក់នេះ យល់ពីលក្ខណសម្បត្តិដ៏ពិតរបស់ទ្រង់ឲ្យបានគ្រប់គ្រាន់ ហើយត្រឹមត្រូវ ទោះបើព្រះគម្ពីរបានសម្ដែងឲ្យឃើញក៏ដោយ។ មានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលទ្រង់ល្អឥតខ្ចោះ។ «ឱព្រះយេហូវ៉ាអើយ តើមានព្រះឯណាឲ្យដូចទ្រង់ តើមានអ្នកឯណាដែលមានសេចក្ដីបរិសុទ្ធដ៏វិសេសដូចទ្រង់ ដែលគួរសរសើរតម្កើងហើយក៏ធ្វើការអស្ចារ្យផង» (និក្ខមនំ ១៥:១១)។

## មិនទាន់មានអ្វីទាំងអស់

«កាលដើមដំបូងឡើយព្រះ» (លោកុប្បត្តិ ១:១)។ មានពេល (ប្រសិនបើយើងអាចហៅវាបានថាជា«ពេល») ដែលព្រះជាម្ចាស់គង់នៅតែមួយអង្គទ្រង់ ក្នុងភាពរួបរួមនៃភាពជាព្រះរបស់ព្រះអង្គ (ទោះបីជាព្រះអង្គគង់នៅជាព្រះត្រៃឯក ហើយបុគ្គលនីមួយៗសុទ្ធតែគង់នៅព្រមទាំងមានលក្ខណសម្បត្តិដូចៗគ្នា)។ «កាលដើមដំបូងឡើយព្រះ»។ មិនទាន់មានផ្ទៃមេឃនៅឡើយទេ ហើយផ្ទៃមេឃដែលមាននៅសព្វថ្ងៃនេះគឺជាកន្លែងដើម្បីសម្ដែងពីសិរីល្អរបស់ទ្រង់។ ឯផែនដីក៏ដូចគ្នាដែរ គឺមិនទាន់មានផែនដីដែលទ្រង់ត្រូវយកព្រះហឫទ័យទុកដាក់ទេ ហើយក៏គ្មានទេវតាច្រៀងសរសើរតម្កើងទ្រង់នៅពេលនោះដែរ។ រីឯសកលលោកដែលព្រះអង្គទ្រទ្រង់ដោយព្រះបន្ទូលដ៏មាន

ព្រះចេស្តារបស់ទ្រង់ ក៏ពុំទាន់មានដែរ (ហេព្រើរ ១:៣)។ នៅពេលនោះគឺមិនទាន់មានអ្វីទាំងអស់ សូម្បីតែមនុស្សម្នាក់ក៏មិនទាន់មានផងដែរ គឺមានតែព្រះជាម្ចាស់មួយអង្គប៉ុណ្ណោះ។ ព្រះអង្គមិនមែនទើបតែចាប់ផ្ដើមគង់នៅបានតែមួយថ្ងៃ មួយឆ្នាំ ឬសម័យកាលនោះទេ តែទ្រង់បានគង់នៅតាំងពីអស់កល្បរៀងមកម្ល៉េះ ពោលគឺមានទ្រង់តាំងតែពីអស់កល្បរៀងមកម្ល៉េះហើយ។ ទ្រង់មានអ្វីៗគ្រប់ទាំងអស់ ហើយទ្រង់មិនត្រូវការអ្វីទៀតឡើយ ព្រោះទ្រង់មានគ្រប់គ្រាន់ ហើយក៏ស្កប់ព្រះទ័យនឹងអ្វីដែលទ្រង់មានតាំងពីមុនមានពេលវេលានៃភាពអស់កល្បរៀងមកទៅទៀត។ ប្រសិនបើព្រះជាម្ចាស់ត្រូវការសកលលោកទេវតា ឬមនុស្សលោក នោះទ្រង់ប្រាកដជាបង្កើតពួកគេតាំងពីមុនភាពអស់កល្បមកម្ល៉េះ។ ការដែលព្រះជាម្ចាស់បង្កើតអ្វីៗទាំងអស់មកនោះ គឺមិនបានបន្ថែមអត្ថប្រយោជន៍អ្វីដល់ទ្រង់សោះឡើយ។ គ្មានអ្វីមួយដែលអាចបន្ថែម ឬបន្ថយសិរីល្អរបស់ព្រះជាម្ចាស់បានទេ ដ្បិតទ្រង់មិនចេះប្រែប្រួលសោះឡើយ (ម៉ាឡាគី ៣:៦)។

## ព្រះហឫទ័យនៃអធិបតេយ្យភាពរបស់ទ្រង់

ព្រះជាម្ចាស់មិនចាំបាច់ត្រូវបង្កើតអ្វីនោះទេ ទ្រង់បានសម្រេចព្រះទ័យបង្កើតរបស់ទាំងនោះមក ពីព្រោះទ្រង់សព្វព្រះហឫទ័យនឹង

បង្កើតពួកវាឡើងមក ហើយក៏មិនមានអ្វីដែលជំរុញឲ្យទ្រង់សម្រេចព្រះទ័យបង្កើតក្រៅតែពីព្រះអង្គទ្រង់ផ្ទាល់ និងអ្វីដែលទ្រង់សព្វព្រះហឫទ័យនោះទេ។ កណ្ឌគម្ពីរ អេភេសូរ ១:១១ បានថែងថាដ្បិត "ទ្រង់ធ្វើគ្រប់ការទាំងអស់តាមដែលគាប់ព្រះហឫទ័យទ្រង់"។ ទ្រង់បានសម្រេចព្រះទ័យបង្កើតរបស់ទាំងអស់នោះ គឺគ្រាន់តែដើម្បីបង្ហាញសិរីល្អរបស់ទ្រង់តែប៉ុណ្ណោះ។ ប្រហែលជាមានមិត្តអ្នកអានខ្លះឆ្ងល់ថា តើយើងបានរៀបរាប់លើសពីអ្វីដែលព្រះបន្ទូលបានចែងទុកហើយឬ? បើដូច្នេះមែន យើងសូមលើកយកក្រឹត្យវិន័យ និងស្មរបន្ទាល់មកធ្វើជាចម្លើយទូន្មាន៖ "ចូរនាំគ្នាក្រោកឡើង លើកតម្កើងព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា តាំងពីអស់កល្បរៀងមក រហូតដល់អស់កល្បរៀងទៅ!" (នេហេមា ៩:៥)។ ព្រះជាម្ចាស់មិនបានទទួលប្រយោជន៍អ្វីថែមទៀតចេញពីការថ្វាយបង្គំរបស់យើងនោះទេ។ ទ្រង់ក៏មិនត្រូវការការលើកតម្កើងសិរីល្អនៃព្រះគុណទ្រង់ចេញពីរាស្ត្រដែលទ្រង់បានសង្គ្រោះនោះដែរ ដ្បិតទ្រង់មានសិរីល្អគ្រប់គ្រាន់ក្នុងព្រះអង្គទ្រង់ផ្ទាល់រួចស្រេចទៅហើយ។ តើអ្វីទៅដែលបណ្ដាលឲ្យទ្រង់តម្រូវទុកពួកជ្រើសតាំងរបស់ទ្រង់ទុកជាមុនដើម្បីលើកតម្កើងសិរីល្អនៃព្រះគុណទ្រង់? កណ្ឌគម្ពីរ អេភេសូរ ១:៥ បានផ្ដល់ចម្លើយដល់យើងថា ទ្រង់បានតម្រូវទុក "តាមបំណង

ព្រះហឫទ័យទ្រង់»។

ក្នុងនាមជាអ្នកនិពន្ធ យើងខ្ញុំដឹងហើយថា ប្រធានបទនេះថ្មី ហើយមានលក្ខណៈប្លែកចំពោះមិត្តអ្នកអានជាច្រើន ដូច្នេះយើងខ្ញុំនឹងព្យាយាមពន្យល់ម្តងមួយៗបន្ថែមទៀត។ យើងនឹងលើកយកខគម្ពីរមកពន្យល់លើប្រធានបទថ្មីនេះ។ នៅចុងកណ្ឌគម្ពីរ រ៉ូម ១១ សាវ័ក ប៉ុល បានបញ្ចប់ការអះអាងដែលថា សេចក្តីសង្គ្រោះកើតឡើងដោយសារព្រះគុណរបស់ព្រះជាម្ចាស់តែមួយគត់ ដោយគាត់បានសួរថា «តើអ្នកណាបានស្គាល់គំនិតនៃព្រះអម្ចាស់ ឬធ្វើជាអ្នកជួយគំនិតទ្រង់បាន តើអ្នកណាបានថ្វាយដល់ទ្រង់ជាមុន នោះនឹងបានប្រគល់មកអ្នកនោះវិញ?» (រ៉ូម ១១:៣៤-៣៥)។ ខគម្ពីរនេះបានបញ្ជាក់ថែមទៀតថា យើងមិនអាចទៅបញ្ជាព្រះជាម្ចាស់បានទេ។ ការដែលព្រះជាម្ចាស់សង្គ្រោះយើង គឺទ្រង់មិនបានទទួលប្រយោជន៍អ្វីពីយើងឡើយ។ «ឬបើលោកសុចរិតវិញ នោះតើលោកបានបន្ថែមអ្វីដល់ទ្រង់ ឬទ្រង់ទទួលអ្វីពីដៃលោក អំពើអាក្រក់របស់លោកអាចនឹងធ្វើបង្ខូចដល់អ្នកដទៃបាន ជាមនុស្សដូចជាលោកដែរ ហើយសេចក្តីសុចរិតរបស់លោកនឹងមានប្រយោជន៍ដល់កូនរបស់មនុស្សដទៃបានដែរ» (យ៉ូប ៣៥:៧-៨)។ ប៉ុន្តែការទាំងអស់នេះមិនមានឥទ្ធិពលអ្វីលើព្រះជាម្ចាស់ទេ ដ្បិតក្នុងទ្រង់មានគ្រប់ទាំងព្រះពររួចទៅហើយ។

«ឯអ្នករាល់គ្នាក៏ដូច្នោះដែរ កាលណាអ្នករាល់គ្នាបានធ្វើតាមបង្គាប់គ្រប់ជំពូកហើយ នោះត្រូវរាប់ថា យើងជាបាវបម្រើឥតកំរៃដល់ម្ចាស់ទេ ដ្បិតយើងបានធ្វើត្រឹមតែការដែលយើងត្រូវធ្វើប៉ុណ្ណោះ» (លូកា ១៧:១០)។ ទោះបើយើងបានស្ដាប់បង្គាប់ព្រះជាម្ចាស់គ្រប់ជំពូកក៏ដោយ ក៏ទ្រង់មិនបានទទួលប្រយោជន៍អ្វីពីយើងដែរ។

លើសពីនេះទៅទៀត សូម្បីតែការមានព្រះជន្មរស់ឡើងវិញ ឬការមានសិរីល្អ ការប្រព្រឹត្ត ឬការរងទុក្ខរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង ក៏មិនបានបន្ថែមសេចក្ដីល្អអ្វីដល់ព្រះជាម្ចាស់ដែរ។ នេះគឺជាការពិត ហើយក៏អស្ចារ្យដែរ ព្រះយេស៊ូវបានសម្ដែងឲ្យយើងឃើញសិរីល្អរបស់ព្រះជាម្ចាស់ ប៉ុន្តែទ្រង់មិនបានបន្ថែមអ្វីដល់ព្រះជាម្ចាស់ទេ។ ដ្បិតទ្រង់ផ្ទាល់បានមានបន្ទូលហើយថា «ក្រៅពីទ្រង់ ទូលបង្គំរកសេចក្ដីល្អមិនបានឡើយ» (ទំនុកតម្កើង ១៦:២) ដូច្នេះ បើយោងតាមខគម្ពីរនេះ យើងត្រូវទទួលស្គាល់សេចក្ដីពិតនេះ ដោយមិនត្រូវមានការប្រឆាំងតវ៉ាអ្វីឡើយ។ ត្រង់ជំពូកនេះកណ្ឌគម្ពីរទំនុកតម្កើងបាននិយាយរៀបរាប់អំពីព្រះយេស៊ូវទាំងស្រុង។ សេចក្ដីសប្បុរស និងសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទបានប្រទានដល់ពួកបរិសុទ្ធរបស់ទ្រង់នៅលើផែនដីនេះ ប៉ុន្តែព្រះជាម្ចាស់ដ៏ឧត្តុង្គឧត្តមនៃយើង ទ្រង់ខ្ពង់ខ្ពស់លើសអ្វីទាំងអស់ ដ្បិតមានតែទ្រង់ទេជា «ព្រះដ៏មានពរ»

(ទំនុកតម្កើង ១៦:៣; ម៉ាកុស ១៤:៦១)។

វាគឺជាការពិតណាស់ដែលថា ព្រះជាម្ចាស់បានទទួលការគោរព និងការប្រមាថមើលងាយពីមនុស្សលោក ប៉ុន្តែពួកគេមិនបានគោរព ឬមើលងាយដល់លក្ខណសម្បត្តិដ៏ពិតរបស់ទ្រង់ទេ ពោលគឺប៉ះពាល់ត្រង់ថា ពួកគេគ្រាន់តែគោរព ឬមើលងាយដល់លក្ខណសម្បត្តិរបស់ទ្រង់ដែលលោកីយ៍បានឲ្យអត្ថន័យថា ព្រះជាម្ចាស់មានលក្ខណៈបែបនេះ ឬបែបនោះប៉ុណ្ណោះ។ អ្វីៗទាំងអស់ដែលទ្រង់បានបង្កើតមកតាមការគ្រោងទុក និងការសង្គ្រោះរបស់ទ្រង់ក៏បានថ្វាយសិរីល្អដល់ទ្រង់ដែរ ហើយនោះឯងគឺជាការពិត។ ដូច្នេះ ចូរកុំឲ្យយើងបដិសេធសេចក្តីពិតនេះឡើយ បើទោះជាមួយវិនាទីក៏មិនបានដែរ។ ប៉ុន្តែអ្វីៗដែលយើងខ្ញុំបានលើកឡើងនេះ គឺទាក់ទងនឹងការដែលទ្រង់សម្តែងសិរីល្អ និងការដែលយើងទទួលស្គាល់សិរីល្អរបស់ទ្រង់។ ដ្បិតប្រសិនបើព្រះជាម្ចាស់សព្វព្រះហឫទ័យនៅតែមួយអង្គឯង នោះទ្រង់ប្រាកដជាបន្តគង់នៅតែមួយអង្គឯងនៅអស់កល្បជានិច្ចហើយ ពោលគឺមិនចាំបាច់សម្តែងឲ្យអ្វីៗដែលទ្រង់បានបង្កើតមកឃើញពីសិរីល្អរបស់ទ្រង់នោះទេ។ ទោះបើទ្រង់ជ្រើសរើសបន្ត ឬមិនបន្តគង់នៅតែមួយអង្គឯងក៏ដោយ នោះគឺតាមតែព្រះហឫទ័យសម្រេចរបស់ទ្រង់តែប៉ុណ្ណោះ។ ទ្រង់មានព្រះពរដ៏ល្អឥតខ្ចោះនៅក្នុងទ្រង់តាំងពីមុនដែលទ្រង់បាន

បង្កើតមនុស្សលោកមកម្ល៉េះ។ តើអ្វីៗទាំងអស់ដែលទ្រង់បានបង្កើតមកមានប្រយោជន៍អ្វីខ្លះដល់ទ្រង់សព្វថ្ងៃនេះ? ចូររកចម្លើយនៅក្នុងកណ្ឌគម្ពីរ អេសាយ ៤០:១៥-១៨ «មើល អស់ទាំងសាសន៍ប្រៀបដូចជាទឹក១ដំណក់នៅក្នុងថាំង ហើយក៏រាប់ទុកដូចជាលម្អងធូលីនៅលើថាសជញ្ជីងដែរ មើល ទ្រង់លើកកោះទាំងប៉ុន្មានឡើង ដូចជារបស់យ៉ាងតិចតួច ឯព្រៃល្បាណូននោះមិនគ្រាន់នឹងដុត ហើយសត្វទាំងប៉ុន្មាននៅព្រៃនោះក៏មិនល្មមនឹងធ្វើជាតង្វាយដុតផង អស់ទាំងសាសន៍រាប់ដូចជាទទេសោះនៅចំពោះទ្រង់ ទ្រង់រាប់គេទុកដូចជាតិចជាងសូន្យទៅទៀត ហើយជាឥតប្រយោជន៍ផង។ ដូច្នេះ តើអ្នករាល់គ្នានឹងផ្ទឿបផ្ទឹមព្រះ ដូចជាអ្នកណា ឬប្រៀបទ្រង់នឹងភាពអ្វី»។ នេះហើយគឺជាលក្ខណៈនៃព្រះជាម្ចាស់របស់យើងនៅក្នុងព្រះគម្ពីរ ហើយទ្រង់នៅតែជា «ព្រះដ៏ពុំស្គាល់» ចំពោះអស់អ្នកដែលមិនយកចិត្តទុកដាក់ក្នុងការស្គាល់ទ្រង់ (កិច្ចការ ១៧:២៣)។ កណ្ឌគម្ពីរ អេសាយ ៤០:២២-២៣ បានចែងថាទ្រង់ «គឺ (ជា) ព្រះដែលគង់ពីលើរង្វង់ផែនដី ហើយមនុស្សនៅផែនដីប្រៀបដូចជាកណ្តូបវិញ គឺទ្រង់ដែលលាតផ្ទៃមេឃ ដូចជាលាតបារាំ ហើយសន្ធឹងទៅដូចជាត្រសាលសម្រាប់អាស្រ័យនៅ ទ្រង់ទម្លាក់ងារពួកអ្នកគ្រប់គ្រងឲ្យសូន្យទៅ ក៏ធ្វើឲ្យពួកចៅក្រមនៅផែនដីទៅជាឥតប្រយោជន៍

ដែរ»។ ជារឿយៗ មានព្រះវិហារជាច្រើនមិនបានបង្រៀនពីលក្ខណសម្បត្តិដ៏ពិតរបស់ព្រះជាម្ចាស់ឲ្យបានត្រឹមត្រូវទេ។

សេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរសញ្ញាថ្មី មិនខុសពីសេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរសញ្ញាចាស់ទេ។ ធ្វើដូចម្ដេចឲ្យខុសគ្នាទៅបាន បើព្រះជាម្ចាស់ជាអ្នកនិពន្ធកណ្ឌគម្ពីរទាំងពីរនេះ! ហេតុដូច្នេះហើយបានជាយើងឃើញថា “មានតែព្រះអង្គមួយគត់ដែលមានព្រះជន្មអមតៈ ព្រះអង្គគង់នៅក្នុងពន្លឺ ដែលគ្មាននរណាអាចចូលជិតបានឡើយ ហើយក៏គ្មានមនុស្សណាបានឃើញ និងអាចឃើញព្រះអង្គបានដែរ សូមលើកតម្កើងព្រះកិត្តិនាម និងព្រះចេស្ដារបស់ព្រះអង្គអស់កល្បជានិច្ច! អាម៉ែន!» (១ធីម៉ូថេ ៦:១៦ គខប)។ ព្រះជាម្ចាស់ពិតជាស័ក្ដិសមឲ្យយើងគោរព ថ្វាយបង្គំ និងស្រឡាញ់ទ្រង់មែន។ គ្មានឫទ្ធានុភាពណាអាចប្រៀបផ្ទឹមនឹងតេជានុភាពរបស់ព្រះជាម្ចាស់បានឡើយ។ មានតែទ្រង់មួយអង្គគត់ដែលមានលក្ខណៈឧត្ដុង្គឧត្ដម ហើយបរិសុទ្ធគ្មានគូប្រៀប។ ព្រះអង្គទ្រទ្រង់អ្វីៗទាំងអស់ តែទ្រង់មិនត្រូវការអ្វីៗទាំងនោះទេ។ ព្រះជាម្ចាស់ជាអ្នកប្រទានអ្វីៗទាំងអស់មក ហើយក៏គ្មាននរណាម្នាក់អាចធ្វើឲ្យព្រះជាម្ចាស់កាន់តែមានទ្រព្យសម្បត្តិជាងមុនបានដែរ ព្រោះទ្រង់មានគ្រប់ទាំងអស់រួចទៅហើយ។

## តាមរយៈការបើកសម្ដែង

យើងមិនអាចស្គាល់ព្រះជាម្ចាស់ដោយខ្លួនយើងបាននោះទេ លុះត្រាតែព្រះអង្គបើកសម្ដែងឲ្យយើងស្គាល់ទ្រង់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ និងតាមរយៈព្រះបន្ទូលរបស់ទ្រង់។ ជាការពិតណាស់ របស់សព្វសារពើទាំងអស់ដែលកើតមក សុទ្ធតែឆ្លុះបញ្ចាំងពីអ្នកបង្កើត ហេតុដូច្នេះហើយបានជាមនុស្សលោកមិនអាចដោះសាបាន (រ៉ូម ១:២០)។ ទោះជាយ៉ាងណាក្ដី ក៏យើងគួរតែឯកភាពនឹងសម្ដីរបស់លោក យ៉ូប ដែលគាត់បានលើកឡើងថា «នេះគ្រាន់តែជាស្នាព្រះហស្តដ៏តូចរបស់ព្រះអង្គ ហើយយើងក៏បានឮតែបន្តិចបន្តួចប៉ុណ្ណោះ ចំណែកឯឫទ្ធានុភាពដ៏ខ្លាំងក្លារបស់ព្រះអង្គវិញ តើនរណាអាចស្វែងយល់បាន?» (យ៉ូប ២៦:១៤)។ ការដែលពួកអ្នកជជែកវែកញែកការពារជំនឿគ្រីស្ទបរិស័ទបានអះអាងថា យើងអាចស្គាល់ព្រះជាម្ចាស់បានតាមរយៈការសម្លឹងមើលធម្មជាតិ នោះវាបង្កឲ្យមានបញ្ហាច្រើន ព្រោះការអះអាងបែបនោះមិនអាចពន្យល់ពីលក្ខណៈដ៏អស្ចារ្យនៃព្រះជាម្ចាស់បានទាំងស្រុងនោះទេ ដោយសារការអះអាងបែបនោះចេញមកពីគំនិតរបស់ពួកគេ មិនមែនមកពីព្រះគម្ពីរទេ។ ដូច្នេះ ប្រសិនបើពួកគេធ្វើបែបនេះ គឺពួកគេមិនបានធ្វើឲ្យមនុស្សមើលឃើញពីលក្ខណសម្បត្តិដ៏ឧត្តុង្គឧត្ដមរបស់ព្រះជាម្ចាស់ឡើយ។

អ្នកជជែកវែកញែកនោះបានលើកជាឧទាហរណ៍ថា៖ មានមនុស្សព្រៃម្នាក់រើសបាននាឡិកាដៃមួយ ពេលដែលគាត់ពិនិត្យមើលហើយ គាត់ក៏បានសន្និដ្ឋានថា នាឡិកានេះប្រាកដជាមានអ្នកផលិតវា។ នេះគឺជារឿងល្អមួយ ប៉ុន្តែបើយើងវិភាគឲ្យបានស៊ីជម្រៅជាងនេះទៀតថា ចុះបើមនុស្សព្រៃម្នាក់នោះអង្គុយចុះ ហើយព្យាយាមស្វែងយល់ពីលក្ខណសម្បត្តិនៃអ្នកផលិតនាឡិកានោះថា តើគាត់មានលក្ខណៈបែបណា គាត់ស្រឡាញ់អ្វី មានឥរិយាបថបែបណា មានជំនឿទៅលើអ្វី ចង់បានអ្វី និងមានសីលធម៌បែបណា? ការសួរបែបនេះ គឺជាការចង់ដឹងចង់យល់ពីលក្ខណសម្បត្តិរបស់អ្នកផលិត។ តើមនុស្សព្រៃម្នាក់នោះអាចប្រមូលព័ត៌មានឲ្យបានជាក់លាក់ពីអ្នកផលិតនាឡិកាដៃនោះបានដែរឬទេ បើគាត់គ្រាន់តែពិនិត្យមើលលើនាឡិកានោះ? តើគាត់អាចស្គាល់អ្នកផលិត ហើយនិយាយថា ខ្ញុំជាមិត្តរបស់អ្នកផលិតនោះបានដែរឬទេ? ការសួរបែបនេះគឺគ្មានអ្វីសំខាន់នោះទេ។ ចុះតើយើងអាចស្គាល់ព្រះជាម្ចាស់ដែលទ្រង់គង់នៅតាំងតែពីអស់កល្បរៀងមកបានដែរឬទេ? វាមិនអាចទៅរួចទេ! យើងមិនអាចស្គាល់ពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់នៃយើងនៅក្នុងព្រះគម្ពីរបានទេ លុះត្រាតែទ្រង់បានបើកសម្ដែងឲ្យយើងស្គាល់ទ្រង់ជាមុន។

យើងមិនអាចស្គាល់ព្រះជាម្ចាស់បានតាមរយៈបញ្ញារបស់យើងបានទេ ព្រោះ «ព្រះទ្រង់ជាវិញ្ញាណ» (យ៉ូហាន ៤:២៤) ដូច្នេះយើងអាចស្គាល់ទ្រង់បានតាមតែរយៈវិញ្ញាណប៉ុណ្ណោះ។ ប៉ុន្តែមនុស្សយើងបានធ្លាក់ក្នុងអំពើបាប និងបានដាច់ទំនាក់ទំនងខាងឯវិញ្ញាណ ហើយទៅសេពគប់ខាងសាច់ឈាមវិញ។ មនុស្សយើងលែងមានទំនាក់ទំនងខាងឯវិញ្ញាណជាមួយព្រះជាម្ចាស់បានទៀតហើយ សូម្បីតែបន្តិចក៏គ្មានដែរ។ មនុស្សយើងមិនអាចនឹងឃើញ ឬយល់ពីនគរនៃព្រះជាម្ចាស់បានទេ លុះត្រាតែយើងបានកើតជាថ្មី ពោលគឺចាកចេញពីសេចក្ដីស្លាប់មកកាន់ជីវិតថ្មី ចេញពីភាពងងឹតមកកាន់ពន្លឺ ទើបអាចទៅរួច (យ៉ូហាន ៣:៣; ១កូរិនថូស ២:១៤)។ យើងមិនអាច «មានរស្មីពន្លឺនៃដំណើរស្គាល់សិរីល្អរបស់ព្រះដែលនៅព្រះភក្ត្រនៃព្រះយេស៊ូវគ្រីស្ទ» បានទេ លុះត្រាតែព្រះវិញ្ញាណបរិសុទ្ធបំភ្លឺដួងចិត្តរបស់យើង មិនមែនតាមបញ្ញារបស់យើងឡើយ ហើយយើងក៏មិនអាចស្គាល់ព្រះអង្គបានពេញលេញតាមរយៈចំណេះដឹងរបស់យើងដែរ។ អ្នកដែលទើបជឿ ត្រូវការបន្តចម្រើនឡើងក្នុងព្រះគុណ និងក្នុងការស្គាល់ដល់ព្រះអម្ចាស់យេស៊ូវ (២ពេត្រុស ៣:១៨)។ ការអធិស្ឋាន និងគោលដៅចម្បងរបស់គ្រីស្ទបរិស័ទគឺ «ដើម្បីឲ្យបានដើរបែបគួរនឹងព្រះអម្ចាស់ ទាំងគាប់ចិត្តដល់មនុស្ស

ទាំងអស់ ឲ្យបានបង្កើតផលក្នុងគ្រប់ទាំងការល្អ ហើយឲ្យស្គាល់ព្រះកាន់តែច្បាស់ឡើង» (កូឡូស ១:៣)។

## ជំពូកទី២

# ការគ្រោងទុករបស់ព្រះ

ការគ្រោងទុករបស់ព្រះជាម្ចាស់គឺជាព្រះហឫទ័យ និងជាការសម្រេចដែលទាក់ទងនឹងព្រឹត្តិការណ៍នៅថ្ងៃអនាគត។ យើងខ្ញុំបានលើកឡើងថា ព្រះជាម្ចាស់មានការគ្រោងទុកតែម្ដងក្នុងការសម្រេចគម្រោងរបស់ទ្រង់ដូចដែលកណ្ឌគម្ពីរ រ៉ូម ៨:២៨ និងអេភេសូរ ៣:១១ បានលើកឡើងដែរ ពីព្រោះព្រះមត្តលុង[១]ដ៏គ្មានព្រំដែនរបស់ទ្រង់បានគ្រោងអ្វីៗទុកនៅថ្ងៃអនាគតមួយដងជាសម្រេច។ ប៉ុន្តែ វាអាចជួយឲ្យយើងយល់ពីការគ្រោងទុករបស់ព្រះអង្គបាន ប្រសិនបើយើងបែងចែកថា ទ្រង់មានការគ្រោងទុកច្រើន ពីព្រោះមនុស្សយើងមិនអាចយល់ពីព្រះតម្រិះដ៏គ្មានដែនកំណត់របស់ព្រះជាម្ចាស់បានទាំងស្រុងនោះទេ។ ការគ្រោងទុករបស់មនុស្សយើងទាក់ទងនឹងចំណេះដឹង គឺនៅមានដែនកំណត់នៅឡើយ។ នៅពេលដែលយើងទទួលបានព័ត៌មាន ឬព្រឹត្តិការណ៍ថ្មីៗណាមួយ នោះយើងនឹងមានប្រតិកម្ម ហើយនឹងផ្លាស់ប្ដូរការគ្រោងទុករបស់យើងឲ្យវាស៊ីគ្នាទៅនឹងគោល

បំណងរបស់យើងវិញ។ ប៉ុន្តែ ការគ្រោងទុកដ៏គ្មានដែនកំណត់របស់ព្រះជាម្ចាស់មិនមែនកើតម្តងមួយដំណាក់កាលៗនោះទេ ប៉ុន្តែ «គ្រប់ការដែលព្រះទ្រង់ធ្វើ នោះទ្រង់បានជ្រាប តាំងពីអស់កល្បរៀងមកម្ល៉េះ» (កិច្ចការ ១៥:១៨)។

## ការគ្រោងទុករបស់ព្រះ

ព្រះគម្ពីរមានចែងពីការគ្រោងទុករបស់ព្រះជាម្ចាស់នៅក្នុងខជាច្រើន ហើយរួមមានទាំងពាក្យពន្យល់ជាច្រើនទៀតផង។ កណ្ឌគម្ពីរ ទំនុកតម្កើង ២:៧ បានប្រើពាក្យ «ច្បាប់» ដើម្បីពន្យល់ពាក្យការគ្រោងទុករបស់ព្រះអង្គ។ល។ កណ្ឌគម្ពីរ អេភេសូរ ៣:១១ បានប្រើឃ្លា «តាមគំនិតសម្រេចតាំងពីអស់កល្បរៀងមក»។ កិច្ចការ ២:២៣បានប្រើឃ្លា «តាមរយៈគម្រោងការដែលបានកំណត់ទុក និងបុព្វញាណរបស់ព្រះ» (គកស)។ អេភេសូរ ១:៩ បានប្រើឃ្លា «សេចក្តីអាថ៌កំបាំងនៃព្រះហឫទ័យទ្រង់»។ ហើយកណ្ឌគម្ពីររ៉ូម ៨:២៨ក៏បានប្រើឃ្លាបន្ថែមទៀតថា «ស្របតាមបំណងដែលព្រះអង្គសព្វព្រះហឫទ័យសម្រេចទុក» (គកស)។ កណ្ឌគម្ពីរ អេភេសូរ ១:៩ បានហៅការគ្រោងទុករបស់ព្រះជាម្ចាស់ថាជា ផែនការ ឬគម្រោងការរបស់ព្រះអង្គ ដើម្បីសបញ្ជាក់ឲ្យយើងឃើញថា អ្វីៗដែល

ទ្រង់បានគ្រោងទុក គឺទ្រង់បានធ្វើឡើងដោយព្រះតម្រិះរបស់ទ្រង់។ ព្រះគម្ពីរបានហៅការគ្រោងទុករបស់ទ្រង់ថាជា បំណងព្រះហឫទ័យរបស់ទ្រង់ ដើម្បីបង្ហាញឲ្យឃើញថា មិនមាននរណាម្នាក់ត្រួតត្រាលើទ្រង់ឡើយ ប៉ុន្តែទ្រង់បានសម្រេចអ្វីៗទាំងអស់តាមព្រះទ័យរបស់ទ្រង់តែអង្គឯងគត់។ នៅពេលដែលបំណងចិត្តរបស់មនុស្សយើងធ្វើជាអ្នកត្រួតត្រាទង្វើរបស់ខ្លួន ភាគច្រើនយើងធ្វើតាមតែសន្ទុះចិត្ត និងគ្មានហេតុផល។ ប៉ុន្តែប្រាជ្ញាតែងតែសហការជាមួយនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលកើតឡើងតាមលំដាប់លំដោយ។ ហេតុដូច្នេះហើយបានជាព្រះគម្ពីរហៅការគ្រោងទុករបស់ព្រះជាម្ចាស់ថាជា «តម្រិះសម្រេចរបស់ព្រះដែលទ្រង់ធ្វើគ្រប់ការទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់» (អេភេសូរ ១:១១)។

ការគ្រោងទុករបស់ព្រះជាម្ចាស់ជាប់ទាក់ទងនឹងព្រឹត្តិការណ៍ទាំងអស់នៅពេលអនាគត គ្មានអ្វីមួយដែលថាមិនទាក់ទងឡើយ។ គ្រប់ទាំងព្រឹត្តិការណ៍ដែលបានកើតឡើងកាលពីអតីតកាល វាបានកើតឡើងដោយសារទ្រង់បានគ្រោងវាទុកតាំងពីមុនដែលទ្រង់បានបង្កើតពេលវេលាមកម្ល៉េះ។ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មានជាប់ទាក់ទងនឹងព្រឹត្តិការណ៍ទាំងអស់ ទោះបើតូចឬធំ ល្អឬអាក្រក់ក្តី។ ប៉ុន្តែ យើងក៏ត្រូវប្រុងប្រយ័ត្ននឹងគំនិតដែលថា បំណង

ព្រះហឫទ័យរបស់ព្រះជាម្ចាស់ជាប់ទាក់ទងនឹងការអាក្រក់ដែរ ពីព្រោះទោះបើទ្រង់ជាអ្នកអនុញ្ញាតឲ្យអំពើបាបកើតឡើងក៏ដោយ ក៏ទ្រង់មិនមែនជាមេផ្ដើមក្នុងការធ្វើបាបដែរ តែទ្រង់ជាមេផ្ដើមនៃការល្អវិញ។ ព្រះដ៏បរិសុទ្ធមិនបានបង្កើតអំពើបាបទេ តែទ្រង់អាចអនុញ្ញាតឲ្យវាកើតឡើងបាន។ ការគ្រោងទុករបស់ព្រះជាម្ចាស់មានលក្ខណៈទូលំទូលាយដូចនឹងការសោយរាជ្យរបស់ទ្រង់ដែរ ហើយការនោះគ្របដណ្ដប់របស់សព្វសារពើទាំងអស់ដែលទ្រង់បានបង្កើត និងគ្រប់ទាំងហេតុការណ៍។ ការគ្រោងទុករបស់ទ្រង់សបញ្ជាក់ឲ្យយើងឃើញពីការដែលព្រះអង្គយកព្រះទ័យទុកដាក់ចំពោះការស្លាប់ និងការរស់នៅរបស់យើង ទាំងនៅពេលបច្ចុប្បន្ន និងនៅពេលអនាគតដ៏អស់កល្បជានិច្ច។ នៅពេលដែលព្រះជាម្ចាស់ធ្វើគ្រប់ទាំងអស់តាមការគ្រោងទុកសម្រេចដែលគាប់ដល់ព្រះហឫទ័យទ្រង់ នោះទើបយើងអាចស្គាល់ការគ្រោងទុកសម្រេចរបស់ទ្រង់តាមរយៈអ្វីៗដែលទ្រង់ធ្វើបាន។ ដូចគ្នានេះដែរ យើងក៏អាចដឹងថាវិស្វករមានគម្រោងការសាងសង់បែបណាដែរ តាមរយៈការដែលយើងមើលអគារដែលបានសាងសង់ឡើងក្រោមការដឹកនាំរបស់គាត់។

ព្រះជាម្ចាស់មិនបានសព្វព្រះហឫទ័យបង្កើតមនុស្សលោកដោយទុកពួកគេចោលនៅលើផែនដី ហើយបោះបង់ពួកគេឲ្យរស់នៅ

ដោយខ្លួនឯង ឬក៏មិនមានអ្នកគ្រប់គ្រងគាត់នោះទេ។ ផ្ទុយទៅវិញ ទ្រង់បានគ្រោងគ្រប់កាលៈទេសៈទាំងអស់ទុកសម្រាប់បុគ្គលម្នាក់ៗ និងគ្រប់ទាំងព្រឹត្តិការណ៍ដែលកើតឡើងលើពិភពលោកយើងនេះ តាំងពីដើមដំបូងរហូតដល់ទីបញ្ចប់។ ព្រះអង្គមិនគ្រាន់តែមានការគ្រោងទុកក្នុងការបង្កើតច្បាប់ទូទៅសម្រាប់តែគ្រប់គ្រងលើលោកីយ៍នេះប៉ុណ្ណោះទេ ប៉ុន្តែទ្រង់បានអនុម័តឲ្យប្រើច្បាប់ទាំងនោះសម្រាប់គ្រប់កាលៈទេសៈទាំងអស់។ ទ្រង់បានកំណត់រាប់ថ្ងៃអាយុរបស់យើង ក៏ដូចជារាប់ចំនួនសក់ក្បាលរបស់យើងផងដែរ (ទំនុកតម្កើង ៩០:១២; ម៉ាថាយ ១០:៣០; លូកា ១២:៧)។ យើងអាចស្គាល់ទំហំនៃការគ្រោងទុកសម្រេចរបស់ព្រះជាម្ចាស់បានតាមរយៈផែនការដែលទ្រង់បានយកមកអនុម័ត។ ព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់លើអ្វីៗទាំងអស់ សូម្បីតែសត្វដែលគ្មានតម្លៃ និងព្រឹត្តិការណ៍ដែលមិនសូវសំខាន់ៗដែលមានដូចជា៖ ចាបធ្លាក់ងាប់លើដី និងការជ្រុះសក់ជាដើម។

## លក្ខណៈនៃការគ្រោងទុករបស់ព្រះ

ឥឡូវនេះ ចូរយើងចំណាយពេលសញ្ជឹងគិតពីលក្ខណៈនៃការគ្រោងទុកខ្លះៗរបស់ព្រះជាម្ចាស់ទាំងអស់គ្នា។

ទី១ ការគ្រោងទុករបស់ទ្រង់មានតាំងពីអស់កល្បរៀងមក និងរហូតអស់កល្បរៀងតទៅ។ ប្រសិនបើយើងគិតថា ការគ្រោងទុករបស់ព្រះជាម្ចាស់បានកើតឡើងក្នុងពេលវេលាណាមួយ នោះមានន័យថា យើងកំពុងគិតថា មានព្រឹត្តិការណ៍ថ្មីៗមួយចំនួនបានកើតឡើង ឬមានព្រឹត្តិការណ៍ ឬកាលៈទេសៈណាមួយដែលទ្រង់មិនបានស្គាល់បានកើតឡើង។ ការដែលយើងគិតដូច្នោះ មានន័យថា យើងបានបន្ទាបលក្ខណៈដ៏ឧដុង្គឧត្តមរបស់ព្រះឲ្យទៅជាព្រះដែលចាត់វិធានការបន្ទាប់ពីហេតុការណ៍ថ្មីៗបានកើតឡើង។ ការគិតបែបនេះមានន័យថា យើងចាត់ទុកប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ថា នៅមានព្រំដែននៅឡើយ ហើយក៏មានន័យថា ទ្រង់កំពុងតែចម្រើនប្រាជ្ញាញាណរបស់ទ្រង់តាមដំណាក់កាលនៃពេលវេលាផងដែរ។ ការដែលយើងមានគំនិតបែបនេះ គឺជាការប្រមាថដ៏ធំមួយចំពោះព្រះជាម្ចាស់។ បុគ្គលណាដែលជឿថា ការគ្រោងទុករបស់ព្រះជាម្ចាស់មានតាំងពីអស់កល្បរៀងមក ហើយជឿថាទ្រង់អាចជ្រាបពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល បុគ្គលនោះនឹងមិនប្រមាថដល់ទ្រង់ ហើយក៏មិនជឿលើគោលលទ្ធិខុសឆ្គងដែលថាការគ្រោងទុកសម្រេចរបស់ទ្រង់មានដំណាក់កាលទៅតាមពេលវេលានោះទេ។ ព្រះជាម្ចាស់ស្គាល់ពីព្រឹត្តិការណ៍នៅពេលអនាគត

ដែលនឹងកើតឡើងតាមរយៈការជ្រើសរើសរបស់មនុស្ស។ ព្រះអង្គបានសម្តែងការគ្រោងទុករបស់ទ្រង់ជាមុនជាច្រើនលើកច្រើនសាររួចមកហើយ នៅក្នុងការគ្រោងទុករបស់ទ្រង់ក៏មានទំនាយដែលសម្តែងឲ្យយើងដឹងពីភាពសព្វញ្ញូណដ៏នៅអស់កល្បរបស់ទ្រង់ដែរ។ បទគម្ពីរបានអះអាងថា ព្រះជាម្ចាស់បានជ្រើសតាំងអ្នកជឿព្រះគ្រីស្ទតាំងពីមុនទ្រង់បង្កើតផ្ទៃមេឃ និងផែនដីមកម្ល៉េះ ហើយទ្រង់ក៏បានប្រទានព្រះគុណដល់ពួកគេនៅក្នុងព្រះគ្រីស្ទដែរ (អេភេសូរ ១:៤; ២ធីម៉ូថេ ១:៩)។

ទី២ ការគ្រោងទុករបស់ទ្រង់មានពេញដោយប្រាជ្ញាញាណ។ ការដែលធ្វើដោយមានប្រាជ្ញា គឺតែងតែសម្រេចបានការល្អបំផុតនៅទីបញ្ចប់ ហើយក៏រមែងដើរក្នុងគន្លងដ៏ល្អផងដែរ។ យើងអាចឃើញប្រាជ្ញាញាណរបស់ព្រះជាម្ចាស់នៅក្នុងការគ្រោងទុករបស់ទ្រង់។ ព្រះជាម្ចាស់បានបង្ហាញឲ្យយើងឃើញព្រះប្រាជ្ញាញាណនៃការគ្រោងទុករបស់ទ្រង់ ហើយគ្រប់ទាំងភស្តុតាងនៃប្រាជ្ញាក្នុងការសម្រេចរបស់ទ្រង់ គឺជាភស្តុតាងនៃព្រះប្រាជ្ញាញាណពីការគ្រោងទុករបស់ទ្រង់ដែលកើតឡើងព្រមគ្នា។ អ្នកនិពន្ធកណ្ឌគម្ពីរ ទំនុកតម្កើង ១០៤:២៤ បានលើកឡើងថា “ឱព្រះអម្ចាស់អើយ ស្នាព្រះហស្តរបស់ព្រះអង្គមានច្រើនឥតគណនា ព្រះអង្គធ្វើការទាំងអស់នោះប្រកប

ដោយព្រះប្រាជ្ញាញាណ ផែនដីមានពោរពេញទៅដោយអ្វីៗសព្វសារពើដែលព្រះអង្គបានបង្កើតមក» (គខប)។ ជាការពិតណាស់ យើងគ្រាន់តែមានលទ្ធភាពសង្កេតមើលឃើញផ្នែកដ៏តូចមួយនៃស្នាព្រះហស្តរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ប៉ុន្តែយើងគួរតែបន្តសិក្សាដូចដែលយើងធ្លាប់ធ្វើនៅប្រធានបទផ្សេងៗទៀតដែរ ហើយទោះបើយើងមិនបានបន្តសង្កេតមើលពីស្នាព្រះហស្តរបស់ទ្រង់ទៀតក៏ដោយ ក៏យើងគួរតែសន្និដ្ឋានដោយសម្អាងលើការសង្កេតនៅត្រង់ផ្នែកតូចៗ និងលើអ្វីៗដែលយើងមិនទាន់ដឹង និងលើអ្វីដែលយើងបានដឹងហើយដែរ។ អស់អ្នកណាដែលមានឱកាសពិនិត្យមើលផ្នែកដ៏តូចណាមួយនៃដំណើរការរបស់គ្រឿងម៉ាស៊ីន ហើយទទួលស្គាល់ថាវាអស្ចារ្យ ក៏នឹងទទួលស្គាល់ថាផ្នែកផ្សេងទៀតក៏អស្ចារ្យដែរ។ ដូចគ្នានេះដែរ នៅពេលដែលយើងសង្ស័យមកលើការគ្រប់គ្រងរបស់ព្រះជាម្ចាស់ យើងគួរតែយកការគ្រប់គ្រងពីអតីតកាលរបស់ទ្រង់ដែលយើងធ្លាប់ឃើញមកកំសាន្តចិត្តយើង ហើយទប់ទល់នឹងការជំទាស់ណាមួយដែលយើងពិបាកនឹងពណ៌នាថាជាចំណុចល្អ ហើយឆ្លាតវៃ។ បន្ទាប់ពីយើងស្លាប់ទៅ ហើយចូលទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច នោះចូរឲ្យយើងបន្លឺសំឡេងឡើងថា «អើហ្ន៎ប្រាជ្ញា និងចំណេះដ៏បរិបូររបស់ព្រះជ្រៅណាស់តើ ឯព្រះតម្រិះរបស់

ទ្រង់ តើមានអ្នកណានឹងស្ទង់បាន ហើយផ្លូវទ្រង់ តើមានអ្នកណានឹងរកតាមបាន» (រ៉ូម ១១:៣៣)។

ទី៣ ព្រះជាម្ចាស់សម្រេចការគ្រោងទុករបស់ទ្រង់ទៅតាមព្រះហឫទ័យរបស់ទ្រង់ដោយសេរី «តើអ្នកណាបានស្ទង់ព្រះវិញ្ញាណនៃព្រះយេហូវ៉ា ឬបានបង្រៀនទ្រង់ដោយខ្លួនធ្វើជាអ្នកជួយប្រឹក្សា តើទ្រង់បានប្រឹក្សានឹងអ្នកណា ហើយអ្នកណាបានពន្យល់ទ្រង់ ឬបង្រៀនទ្រង់ក្នុងផ្លូវយុត្តិធម៌ ឬឲ្យទ្រង់មានចំណេះ ឬបង្ហាញផ្លូវនៃយោបល់ដល់ទ្រង់» (អេសាយ ៤០:១៣-១៤)។ ព្រះជាម្ចាស់គង់នៅតែព្រះអង្គឯង នៅពេលដែលទ្រង់គ្រោងបំណងព្រះហឫទ័យរបស់ទ្រង់ទុក គឺមិនមានឥទ្ធិពលពីខាងក្រៅណាមួយដែលបានជះឥទ្ធិពលមកលើការប្ដេជ្ញារបស់ទ្រង់ឡើយ។ ព្រះអង្គបានគ្រោងទុក ឬមិនបានព្រះតម្រិះឲ្យមានព្រឹត្តិការណ៍ណាមួយកើតឡើង ឬមិនកើតឡើងតាមតែព្រះហឫទ័យទ្រង់មួយព្រះអង្គឯងប៉ុណ្ណោះ។ ព្រះជាម្ចាស់សម្រេចការគ្រោងទុកទ្រង់តាមព្រះហឫទ័យទ្រង់ ពីព្រោះទ្រង់មានភាពឧដុង្គឧត្ដម ឯករាជ្យ និងមានអធិបតេយ្យភាពលើគ្រប់អ្វីៗដែលទ្រង់ធ្វើ។

ទី៤ ការគ្រោងទុករបស់ទ្រង់មានអំណាចដ៏ខ្ពង់ខ្ពស់បំផុត ហើយឥតល័ក្ខខ័ណ្ឌ។ ការគ្រោងទុករបស់ទ្រង់ប្រតិបត្តិឡើងដោយមិនពឹង

ផ្អែកលើលក្ខខណ្ឌដែលថា ប្រហែលជាអាចនឹងកើតឡើង ឬអាចនឹងមិនកើតឡើងនោះទេ។ គ្រប់ទាំងកាលៈទេសៈដែលទ្រង់បានគ្រោងទុក គឺបានសម្រេច ហើយទ្រង់ក៏បានគ្រោងទុកពីមធ្យោបាយទុកជាស្រេច ដើម្បីសម្រេចការគ្រោងទុកនោះដែរ។ ព្រះដែលបានគ្រោងទុកសេចក្តីសង្គ្រោះសម្រាប់រាស្ត្រដែលទ្រង់បានជ្រើសតាំង ទ្រង់ក៏បានគ្រោងទុកឲ្យពួកគេមានជំនឿផងដែរ (២ថែស្សាឡូនីច ២:១៣)។ “គំនិតសម្រេចរបស់អញនឹងស្ថិតស្ថេរនៅ អញនឹងធ្វើតាមបំណងចិត្តអញគ្រប់ប្រការ” (អេសាយ ៤៦:១០)។ វាមិនអាចទៅរួចទេ ប្រសិនបើគំនិតសម្រេចរបស់ទ្រង់ពឹងផ្អែកលើលក្ខខណ្ឌដែលថា អ្វីដែលទ្រង់គ្រោងទុកប្រហែលនឹងមិនកើតឡើងទេ។ ប៉ុន្តែព្រះជាម្ចាស់ “…បានតម្រូវយើងទុកជាមុន តាមតម្រិះសម្រេចរបស់ព្រះដែលទ្រង់ធ្វើគ្រប់ការទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់” (អេភេសូរ ១:១១)។

## ទំនួលខុសត្រូវរបស់មនុស្ស

ទោះបើព្រះបន្ទូលបានបង្រៀនថាការគ្រោងទុករបស់ព្រះជាម្ចាស់មិនចេះប្រែប្រួល និងមិនចេះផ្លាស់ប្តូរ... នោះយើងនឹងនៅឃើញដែរថា ព្រះបន្ទូលក៏បង្រៀនយ៉ាងសាមញ្ញផងដែរថា មនុស្សលោកនឹងត្រូវ

ទទួលខុសត្រូវ ហើយត្រូវតែឆ្លើយតបចំពោះទង្វើដែលខ្លួនបានប្រព្រឹត្ត ចំពោះព្រះអង្គ។ ហើយប្រសិនបើគំនិតរបស់យើងកើតឡើងដោយពឹងអាងលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះយើងនឹងទទួលស្គាល់ថា យើងជឿលើផ្នែកណាមួយនៃការគ្រោងទុករបស់ទ្រង់ ហើយក៏នឹងមិនបដិសេធផ្នែកណាផ្សេងទៀតដែរ។ យើងពិបាកនឹងដឹងណាស់ត្រង់ថា តើការគ្រោងទុករបស់ព្រះជាម្ចាស់បានឈានដល់ទីបញ្ចប់នៅត្រង់ណា ហើយថា តើទំនួលខុសត្រូវរបស់មនុស្សបានចាប់ផ្តើមនៅត្រង់ណា។ នៅពេលដែលយើងព្យាយាមយល់ពីព្រះជាម្ចាស់ និងមនុស្សក្នុងពេលតែមួយដែលមានការស្រេបគ្នា នោះវាពិបាកយល់ណាស់។ ការអធិស្ឋានដ៏ពិតប្រាកដរៀបរៀងដោយព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែការអធិស្ឋានដ៏ពិតក៏កើតចេញពីការស្រែកអំពាវនាវពីដួងចិត្តមនុស្សយើងផងដែរ។ គ្រប់ទាំងព្រះបន្ទូលគឺព្រះជាម្ចាស់បណ្តាលឲ្យតែងឡើង ប៉ុន្តែមនុស្សជាអ្នកសរសេររៀបរៀង ហើយព្រះវិញ្ញាណបរិសុទ្ធក៏មិនបានបញ្ជាពួកគេដូចមនុស្សយន្តនោះដែរ។ ព្រះគ្រីស្ទមានលក្ខណៈជាព្រះ១០០%ផង និងជាមនុស្ស១០០%ផង។ ទ្រង់សព្វញ្ញូញាណ ប៉ុន្តែទ្រង់នៅតែ “ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង” (លូកា ២:៥២)។ ទ្រង់មានពេញដោយព្រះចេស្តា ប៉ុន្តែ “ទ្រង់ត្រូវគេឆ្កាងដោយសេចក្តីកម្សោយ” (២កូរិនថូស ១៣:៤)។

ទ្រង់ជាមហាក្សត្រនៃជីវិត ប៉ុន្តែត្រូវសុគត (កិច្ចការ ៣:១៥)។ អ្វីៗទាំងអស់ខាងលើនេះមានពេញដោយអាថ៌កំបាំង ប៉ុន្តែយើងអាចទទួលយកការទាំងអស់នោះដោយគ្មានមន្ទិលសង្ស័យ។

ជារឿយៗ គេតែងតែលើកឡើងថា គ្រប់ចំណុចប្រឆាំងទាំងអស់ដែលគេលើកយកមកទាស់នឹងការគ្រោងទុកដ៏អស់កល្បរបស់ព្រះជាម្ចាស់ ក៏មានន័យថាគេទាស់នឹងភាពសព្វញ្ញូញ្ញាណដ៏អស់កល្បរបស់ទ្រង់ដែរ។

មិនថាព្រះជាម្ចាស់បានគ្រោងទុក ឬក៏មិនបានគ្រោងទុកនូវអ្វីៗទាំងអស់ដែលកើតឡើងជាយ៉ាងណាក៏ដោយ ក៏យើងនៅដឹងដដែលថាទ្រង់ជាព្រះ ដូច្នេះហើយបានជាទ្រង់ជ្រាបគ្រប់អ្វីៗទាំងអស់មុនដែលវាបានកើតឡើង។ យើងអាចដឹងដោយខ្លួនឯងថា ប្រសិនបើទ្រង់ជ្រាបគ្រប់អ្វីៗទាំងអស់ នោះទ្រង់អាចសម្រេចថា ឲ្យការទាំងនោះកើតឡើង ឬក៏មិនឲ្យកើតឡើងបាន។ នេះមានន័យថាទ្រង់ជាអ្នកគ្រោងឲ្យការទាំងនោះកើតឡើង ឬក៏មិនកើតឡើង។ ការគ្រោងឲ្យការទាំងនោះកើតឡើង គឺស្មើនឹងការសម្រេចចិត្តឲ្យការទាំងនោះកើតមានឡើង។[២]

ជាចុងក្រោយ សូមព្យាយាមសន្មត ហើយសញ្ជឹងគិតត្រឡប់មកវិញ។ ប្រសិនបើយើងបដិសេធចំពោះការគ្រោងទុករបស់

ព្រះជាម្ចាស់ នោះមានន័យថា យើងឯកភាពនឹងផ្នត់គំនិតរបស់លោកីយ៍នេះ ក៏ដូចជាឯកភាពនឹងអ្វីៗដែលពួកគេផ្ដោតការយកចិត្តទុកដាក់ទៅលើផងដែរ ហើយនេះក៏មានន័យថា គ្រប់អ្វីៗទាំងអស់កើតឡើងដោយចៃដន្យ ដោយមិនមានអ្នកគ្រោងទុក ឬកើតឡើងដោយព្រេងវាសនាដ៏ងងឹតងងុលនេះដែរ។ ប្រសិនបើយើងគិតបែបនោះ តើឲ្យចិត្ត និងគំនិតដ៏កំសត់របស់យើងមានភាពសុខសាន្ត មានការធានារ៉ាប់រង និងមានភាពស្រណុកសុខស្រួលយ៉ាងដូចម្ដេចបាន? តើឲ្យយើងទៅរកទីពឹងជ្រកនៅឯណាបាន នៅពេលដែលយើងកំពុងតែមានតម្រូវការ ឬមានបញ្ហា? រកមិនបានឡើយ! បើដូច្នោះមែន គឺមិនមានអ្វីប្រសើរជាងការដែលយើងរស់នៅក្នុងភាពងងឹតសូន្យសុង និងភាពអស់សង្ឃឹមដ៏រន្ធត់ដែលមិនជឿថាមានព្រះគង់នៅនោះទេ។ ឱ! មិត្តអ្នកអានរបស់ខ្ញុំអើយ! គួរឲ្យយើងថ្លែងអំណរគុណចំពោះព្រះចុះ ដ្បិតគ្រប់អ្វីៗទាំងអស់ គឺទ្រង់បានគ្រោងទុកដោយព្រះបញ្ញាញាណ និងក្ដីសប្បុរសដ៏គ្មានដែនកំណត់របស់ទ្រង់។ គួរឲ្យយើងសរសើរតម្កើង ហើយអរព្រះគុណដល់ព្រះជាម្ចាស់ដោយព្រោះការគ្រោងទុករបស់ទ្រង់ចុះ។ ដោយសារតែការគ្រោងទុកនោះហើយបានជា «យើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សម្រាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់

ហៅមកតាមព្រះតម្រិះទ្រង់» (រ៉ូម ៨:២៨)។ ចូរឲ្យយើងប្រកាសថា «ដ្បិតរបស់សព្វសាររពើបានកើតមកពីទ្រង់ ដោយសារទ្រង់ ហើយសម្រាប់ទ្រង់ សូមឲ្យទ្រង់បានសិរីល្អនៅអស់កល្បជានិច្ច អាម៉ែន» (រ៉ូម ១១:៣៦)។

ជំពូកទី៣

# ព្រះដ៏មានបញ្ញាញាណ

ព្រះជាម្ចាស់គឺជាព្រះដ៏សព្វញ្ញូញ្ញាណ។ ទ្រង់ជ្រាបគ្រប់អ្វីៗទាំងអស់ គ្រប់អ្វីៗដែលអាចនឹងកើតឡើង ព្រមទាំងអ្វីៗដែលពិតជាបានកើតឡើងផង។ ទ្រង់ជ្រាបគ្រប់ព្រឹត្តិការណ៍ និងរបស់សព្វសារពើទាំងអស់។ ទ្រង់ជ្រាបពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។ ទ្រង់ឈ្វេងយល់ពីរាល់គ្រប់អ្វីៗដែលមានជីវិតនៅស្ថានសួគ៌ ផែនដី និងនៅស្ថាននរកបានយ៉ាងជាក់ច្បាស់ និងយ៉ាងល្អិតល្អន់។ «ព្រះអង្គឈ្វេងយល់អ្វីៗដែលស្ថិតនៅក្នុងភាពងងឹត» (ដានីយ៉ែល ២:២២)។ ព្រះជាម្ចាស់ជ្រាបដឹងពីអ្វីៗទាំងអស់។ គ្មានអ្វីមួយអាចលាក់កំបាំងពីទ្រង់ ហើយក៏គ្មានអ្វីមួយដែលទ្រង់ភ្លេចដែរ។ យើងអាចពោលដូចអ្នកនិពន្ធកណ្ឌគម្ពីរ ទំនុកតម្កើង ១៣៩:៦ ដែលបានលើកឡើងថា «ការដឹងច្បាស់យ៉ាងនេះ ក៏អស្ចារ្យហួសល្បត់ទូលបង្គំ ហើយខ្ពស់ដល់ម្ល៉េះ បានជាទូលបង្គំឈោងមិនដល់សោះ»។ ព្រះបញ្ញាញាណរបស់ទ្រង់ល្អឥតខ្ចោះ។ ព្រះអង្គមិនដែលព្រះតម្រិះខុស ហើយក៏មិន

ដែលប្រែប្រួល ក៏មិនដែលទតរំលងអ្វីមួយដែរ។ «គ្មានអ្វីកើតមក ដែលទ្រង់ទតមិនឃើញនោះឡើយ គឺគ្រប់ទាំងអស់នៅជាអាក្រាត ហើយចំហនៅចំពោះព្រះនេត្រនៃព្រះដែលយើងរាល់គ្នាត្រូវរាប់រៀប ទាំងអស់ទូលថ្វាយទ្រង់» (ហេព្រើរ ៤:១៣)។ ពិតណាស់! ទ្រង់គឺជា ព្រះដែលយើង «ត្រូវរាប់រៀបទាំងអស់ទូលថ្វាយទ្រង់»។

កណ្ឌគម្ពីរ ទំនុកតម្កើង ១៣៩:២-៤ បានថែងថា «ព្រះអង្គជ្រាប ពេលណាដែលទូលបង្គំអង្គុយ ពេលណាដែលទូលបង្គំក្រោកឈរ ព្រះអង្គឈ្វេងយល់គំនិតរបស់ទូលបង្គំតាំងពីចម្ងាយ។ ព្រះអង្គជ្រាប ពេលណាដែលទូលបង្គំធ្វើការ ពេលណាដែលទូលបង្គំសម្រាក ហើយព្រះអង្គជ្រាបច្បាស់នូវអ្វីៗទាំងអស់ដែលទូលបង្គំប្រព្រឹត្ត។ ព្រះអម្ចាស់អើយ ពាក្យសម្ដីមិនទាន់ចេញពីមាត់ទូលបង្គំផង ព្រះអង្គជ្រាបសេចក្ដីដែលទូលបង្គំបម្រុងនឹងនិយាយនោះរួចស្រេច ទៅហើយ»។ ព្រះជាម្ចាស់នៃយើងដែលគេបានថែងទុកនៅក្នុង ព្រះគម្ពីរ គឺជាព្រះដ៏អស្ចារ្យបំផុត។ ដោយសារលក្ខណសម្បត្តិ នីមួយៗរបស់ព្រះជាម្ចាស់អស្ចារ្យ ដូច្នេះហើយបានជាយើងត្រូវតែ លើកតម្កើងទ្រង់ដោយចិត្តគោរពកោតខ្លាចព្រះអង្គ។ ដោយសារ យើងដឹងថាទ្រង់ជ្រាបនូវអ្វីៗទាំងអស់ នោះយើងគួរតែក្រាបចុះថ្វាយ បង្គំដោយស្រឡាញ់ទ្រង់បន្ថែមទៀត។ តែទោះបីជាយើងដឹងបែបនេះ

ក៏ដោយ ក៏យើងនៅតែមិនសូវចំណាយពេលសញ្ជឹងគិតពីលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះរបស់ទ្រង់ដដែល! តើនេះគឺដោយសារតែការសញ្ជឹងគិតពីលក្ខណសម្បត្តិរបស់ទ្រង់ ធ្វើឲ្យយើងរអៀសខ្លួនឬ?

នេះគឺជាសេចក្តីពិតដែលគួរឲ្យខ្លាចណាស់ ត្រង់ថាគ្មានអ្វីមួយដែលអាចលាក់បាំងពីព្រះជាម្ចាស់បានឡើយ! កណ្ឌគម្ពីរអេសេគាល ១១:៥ បានចែងថា “អញស្គាល់អស់ទាំងសេចក្តីដែលកើតក្នុងគំនិតរបស់ឯងរាល់គ្នាហើយ”។ ទោះបើយើងមិនអាចមើលទ្រង់ឃើញក៏ដោយ ក៏ប៉ុន្តែទ្រង់អាចទតមើលយើងឃើញដែរ។ គ្មានអំពើបាបណាមួយដែលអាចលាក់បាំងពីព្រះនេត្ររបស់ទ្រង់បានឡើយ ទោះបើស្ថិតក្នុងរាត្រីងងឹតសូន្យសុង ឬស្ថិតក្នុងគុកងងឹតក៏ដោយ។ ដើមឈើដែលស្ថិតក្នុងសួនច្បារអេដែនមិនអាចលាក់បាំងលោកអ័ដាម និងនាងអេវ៉ា ពីព្រះនេត្ររបស់ព្រះជាម្ចាស់បានឡើយ។ គ្មានបុគ្គលណាម្នាក់បានឃើញលោកកាអ៊ីន នៅពេលដែលគាត់ធ្វើឃាតប្អូនប្រុសរបស់ខ្លួនទេ ប៉ុន្តែព្រះជាម្ចាស់បានទតឃើញពីបទឧក្រិដ្ឋរបស់គាត់។ នាងសារ៉ា បានសើចឡកឡឺយតែម្នាក់ឯងនៅក្នុងត្រសាលរបស់ខ្លួន ប៉ុន្តែព្រះជាម្ចាស់បានឮសំណើចរបស់នាង។ លោកអេកាន បានលួចកប់មាសមួយដុំនៅក្នុងត្រសាលរបស់ខ្លួន ប៉ុន្តែព្រះជាម្ចាស់បានបង្ហាញឲ្យសាសន៍អ៊ីស្រាអែលឃើញ។

ស្តេចដាវីឌ ពិបាកក្នុងខ្លួន ហើយឈឺចាប់យ៉ាងខ្លាំងក្នុងការដែលទ្រង់ព្យាយាមលាក់បាំងអំពើទុច្ចរិតរបស់ខ្លួន ប៉ុន្តែមិនយូរប៉ុន្មានព្រះជាម្ចាស់បានចាត់ហោរាម្នាក់របស់ទ្រង់ឲ្យទៅនិយាយទៅកាន់ស្តេចដាវីឌថា "ឯងមនុស្សនោះគឺជាអង្គទ្រង់នេះហើយ" (២សាំយូអែល ១២:៧)។ ព្រះជាម្ចាស់បានមានបន្ទូលមកកាន់អ្នកសរសេរព្រះគម្ពីរ និងអ្នកអានថា "បាបឯងរាល់គ្នានឹងតាមឯងទាន់" (ជនគណនា ៣២:២៣)។

ប្រសិនបើមនុស្សលោកអាចដកភាពសព្វញ្ញូញាណរបស់ព្រះជាម្ចាស់ចេញបាន នោះពួកគេនឹងព្យាយាមដកវាចេញពីទ្រង់ជាមិនខាន។ ការនេះសបញ្ជាក់ឲ្យយើងឃើញថា "គំនិតខាងសាច់ឈាម នោះរមែងទាស់ទទឹងនឹងព្រះ" (រ៉ូម ៨:៧)។ ជាធម្មតា មនុស្សទុច្ចរិតតែងតែស្អប់ភាពល្អឥតខ្ចោះរបស់ព្រះជាម្ចាស់ ហើយពួកគេក៏ត្រូវតែទទួលស្គាល់ការស្អប់ខ្ពើមរបស់ខ្លួនឯងផងដែរ។ ពួកគេប្រាថ្នាមិនចង់ឲ្យមានអ្នកណាម្នាក់ដឹងពីអំពើបាបដែលខ្លួនបានប្រព្រឹត្ត ក៏មិនចង់ឲ្យមានអ្នកណាឆែកឆេរមើលដួងចិត្តខ្លួន ឬក៏មកវិនិច្ឆ័យលើទង្វើរបស់ពួកគេទេ។ ពួកគេតែងតែព្យាយាមរកគ្រប់វិធី ដើម្បីលុបបំបាត់ព្រះជាម្ចាស់ចេញពីគំនិតរបស់ពួកគេ "គេមិនពិចារណាក្នុងចិត្តថា អញនឹកចាំអស់ទាំងអំពើអាក្រក់របស់គេនោះទេ"

(ហូសេ ៧:២)។ កណ្ឌគម្ពីរ ទំនុកតម្កើង ៩០:៨ បានផ្តល់ហេតុផលដ៏ត្រឹមត្រូវថា អ្នកដែលបដិសេធព្រះគ្រីស្ទនឹងភ័យញាប់ញ័រនៅចំពោះព្រះភក្ត្រទ្រង់ ពីព្រោះ «ទ្រង់បានដាក់អស់ទាំងអំពើទុច្ចរិតរបស់យើងខ្ញុំនៅចំពោះទ្រង់ ព្រមទាំងអំពើបាបដែលយើងខ្ញុំប្រព្រឹត្តដោយលាក់កំបាំងឲ្យនៅក្នុងពន្លឺនៃព្រះភក្ត្រទ្រង់ផង»។

ប៉ុន្តែ ចំពោះអ្នកជឿវិញ ភាពពិតជាក់ស្តែងនៃភាពសព្វញ្ញូញាណរបស់ព្រះជាម្ចាស់ គឺជាសេចក្តីពិតដែលពោរពេញដោយការពេញចិត្តពេញថ្លើម។ នៅពេលដែលពួកគេអសមត្ថភាពក្នុងការដោះស្រាយអ្វីមួយនោះ ពួកគេនឹងលើកឡើងដូចលោក យ៉ូប ថា៖ «ព្រះជាម្ចាស់ជ្រាបច្បាស់នូវមាគ៌ាដែលខ្ញុំដើរ» (យ៉ូប ២៣:១០)។ ការដែលទ្រង់ជ្រាបច្បាស់ពីមាគ៌ារបស់យើង គឺជាអាថ៌កំបាំងដ៏អស្ចារ្យដែលពិបាកនឹងពន្យល់បាន។ នៅពេលដែលអ្នកជឿនឿយណាយហើយថមថយកម្លាំង នោះពួកគេអាចលើកទឹកចិត្តខ្លួនឯងដោយរម្លឹកថា «ទ្រង់ស្គាល់រាងកាយរបស់យើង ក៏នឹកចាំថា យើងគ្រាន់តែជាធូលីដីប៉ុណ្ណោះ» (ទំនុកតម្កើង ១០៣:១៤)។ នៅពេលដែលពួកគេមានមន្ទិលសង្ស័យ ពួកគេអាចពឹងផ្អែកលើលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ ដែលទ្រង់ជ្រាបគ្រប់ទាំងអស់ ដោយពោលថា «ឱព្រះអង្គអើយ សូមពិនិត្យមើលឲ្យបានស្គាល់ចិត្តទូលបង្គំផង សូមល្បងល

ឲ្យបានជ្រាបអស់ទាំងគំនិតនៃទូលបង្គំចុះ សូមទតមើលបើមានអំពើអាក្រក់ណានៅក្នុងទូលបង្គំ ហើយនាំទូលបង្គំតាមផ្លូវដ៏នៅអស់កល្បជានិច្ច» (ទំនុកតម្កើង ១៣៩:២៣-២៤)។ ការបរាជ័យដ៏កំសត់គឺៈ នៅពេលដែលទង្វើរបស់យើងក្បត់ពីឧត្តមគតិរបស់ខ្លួន និងលែងចង់ប្តូរផ្តាច់ជាមួយព្រះតទៅទៀត ក៏សួរខ្លួនឯងថា «តើយើងនៅស្រឡាញ់ទ្រង់ដែរឬទេ?» នោះយើងអាចលើកឡើងដូចជាសាវ័ក ពេត្រុស ថា «ព្រះអម្ចាស់អើយ ទ្រង់ជ្រាបគ្រប់ការទាំងអស់ គឺទ្រង់ជ្រាបថាទូលបង្គំពេញចិត្តនឹងទ្រង់ហើយ» (យ៉ូហាន ២១:១៧)។

ខាងក្រោមនេះគឺជាហេតុផលខ្លះៗដែលនឹងលើកទឹកចិត្តយើងឲ្យអធិស្ឋាន។

យើងមិនគួរបារម្ភថា ព្រះជាម្ចាស់នឹងមិនស្តាប់ការអធិស្ឋានរបស់មនុស្សសុចរិតនោះទេ ហើយយើងក៏មិនគួរបារម្ភថា ព្រះជាម្ចាស់មិនជ្រាប ឬមិនទតឃើញការដកដង្ហើមធំ និងទឹកភ្នែករបស់យើងនោះដែរ ពីព្រោះទ្រង់ជ្រាបគ្រប់ទាំងគំនិត និងបំណងចិត្តរបស់យើង។ យើងមិនគួរបារម្ភថា ព្រះជាម្ចាស់ស្តាប់មិនឮពាក្យអធិស្ឋានរបស់អ្នកជឿណាម្នាក់ក្នុងចំណោមអ្នកជឿជាច្រើន ដែលបានលើកសំណូមពរអធិស្ឋានដល់ទ្រង់ច្រើនបែបច្រើនយ៉ាង ជារៀងរាល់ពេលវេលា និងរៀងរាល់ថ្ងៃនោះទេ។ ព្រះអង្គព្រះសណ្តាប់ឮគ្រប់ទាំងសំណូម

ពរអធិស្ឋានរបស់យើងបាន ពីព្រោះព្រះបញ្ញាញាណរបស់ទ្រង់គ្មានព្រំដែនឡើយ ទោះបើមានសំណូមពរច្រើនប៉ុណ្ណាក៏ដោយ ក៏ទ្រង់អាចនៅជ្រាបបានគ្រប់ទាំងអស់ក្នុងពេលតែមួយបានដែរ។ ទោះបើភាសាមិនអាចរៀបរាប់ពីចំណង់ចំណូលចិត្តរបស់យើងបានក៏ដោយ ក៏វាមិនមែនជាបញ្ហាក្នុងការអធិស្ឋានរបស់យើងនោះដែរ ដ្បិតកណ្ឌគម្ពីរ អេសាយ ៦៥:២៤ បានចែងថា «គ្រានោះមុនដែលគេអំពាវនាវ នោះអញនឹងតបឆ្លើយ ហើយកាលគេកំពុងតែចេញសម្តីនៅឡើយ នោះអញនឹងស្តាប់ដែរ»។

## អតីតកាល និងអនាគតកាល

«ព្រះអម្ចាស់នៃយើងខ្ញុំទ្រង់ធំប្រសើរ ហើយមានឫទ្ធានុភាពក្រៃលែង ឯប្រាជ្ញាញាណរបស់ទ្រង់ក៏យល់គ្រប់ទាំងអស់» (ទំនុកតម្កើង ១៤៧:៥)។ ព្រះជាម្ចាស់មិនមែនគ្រាន់តែជ្រាបគ្រប់ព្រឹត្តិការណ៍ទាំងអស់នៅលើចក្រវាលទាំងមូលនេះដែលបានកើតឡើងពីអតីតកាល ឬតែបច្ចុប្បន្នកាលនេះប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ថែមទាំងជ្រាបគ្រប់អ្វីៗទាំងអស់ដែលនឹងកើតឡើងនៅពេលអនាគតទៀតផង ទោះបើតូចឬធំក្តី។ ការជ្រាបដឹងគ្រប់អ្វីៗទាំងអស់របស់ព្រះជាម្ចាស់អំពីអតីតកាល ក៏ដូចជាបច្ចុប្បន្នកាល និងអនាគតកាល គឺទ្រង់ជ្រាប

ដឹងយ៉ាងពេញលេញ។ ម្យ៉ាងវិញទៀត បើគ្មានព្រះជាម្ចាស់ទេ នោះព្រឹត្តិការណ៍នៅអនាគតក៏មិនអាចកើតឡើងបានដែរ ពីព្រោះវាត្រូវពឹងផ្អែកលើទ្រង់ទាំងស្រុង។ ប្រសិនបើមានអ្វីមួយកើតឡើងដោយឯកឯងក្រៅពីការគ្រោងទុករបស់ព្រះជាម្ចាស់ នោះមានន័យថា វាមិនបានពឹងផ្អែកលើទ្រង់ទេ ហើយនោះក៏មានន័យថា ព្រះជាម្ចាស់មិនមែនជាព្រះដ៏ឧត្តុង្គឧត្តមដែរ។

ការដែលព្រះជាម្ចាស់ជ្រាបដឹងពីអនាគត មិនមែនគ្រាន់តែជាការមើលឃើញពីអនាគតប៉ុណ្ណោះទេ ប៉ុន្តែវាកើតឡើងដោយសារវាជាប់ទាក់ទងនឹងបំណងព្រះហឫទ័យរបស់ទ្រង់ ព្រោះទ្រង់ជាព្រះដែលបង្កើតអនាគតកាលឲ្យមានឡើង។ ព្រះជាម្ចាស់ផ្ទាល់បានគ្រោងទុកគ្រប់អ្វីៗដែលនឹងកើតមានឡើង ហើយគ្រប់អ្វីៗដែលទ្រង់បានគ្រោងទុកនោះនឹងត្រូវកើតឡើងជាមិនខាន។ ដូចដែលព្រះបន្ទូលរបស់ទ្រង់បានអះអាងរួចមកហើយថា «ទ្រង់ធ្វើតាមតែព្រះហឫទ័យក្នុងពួកពលបរិវារនៃស្ថានសួគ៌ ហើយនៅកណ្ដាលពួកមនុស្សលោកផង ឥតមានអ្នកណាអាចនឹងឃាត់ទប់ព្រះហស្តទ្រង់ ឬនឹងទូលសួរទ្រង់ថា ទ្រង់ធ្វើអ្វីដូច្នេះបានឡើយ» (ដានីយ៉ែល៤:៣៥)។ ជាថ្មីម្ដងទៀត «នៅក្នុងចិត្តមនុស្ស តែងមានគំនិតគិតធ្វើជាច្រើនយ៉ាង មានតែដំបូន្មាននៃព្រះយេហូវ៉ាប៉ុណ្ណោះ ដែលនឹងស្ថិតស្ថេរនៅ»

(សុភាសិត១៩:២១)។ ព្រះបញ្ញាញាណ និងព្រះចេស្ដារបស់ព្រះជាម្ចាស់មានលក្ខណៈដូចគ្នាត្រង់ថា វានៅស្ថិតស្ថេរជានិច្ច។ ទ្រង់បានធានាថា ទ្រង់នឹងសម្រេចតាមអ្វីដែលទ្រង់បានគ្រោងទុក។ ការដែលថាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មិនអាចសម្រេចបាន គឺមិនអាចទៅរួចនោះទេ ហើយការដែលថាព្រះត្រៃឯកអាចមានបន្ទូលកុហក ក៏មិនអាចទៅរួចដែរ។

គ្មានអ្វីមួយនៅអនាគតដែលមិនមានលក្ខណៈប្រាកដប្រជានោះទេ ព្រោះវាចុះចូលក្រោមផែនការរបស់ព្រះជាម្ចាស់ ហើយផែនការរបស់ទ្រង់គឺប្រាកដប្រជា។ ការគ្រោងទុករបស់ព្រះជាម្ចាស់ មិនមែនសម្រេចឡើងតាមរយៈអ្វីៗដែលទ្រង់បានបង្កើត ឬត្រូវសុំការអនុញ្ញាតពីបុគ្គលណាម្នាក់ផ្សេងទៀតឡើយ សូម្បីតែមួយក៏គ្មានផង។ គ្មានព្រឹត្តិការណ៍ណាមួយនៅអនាគតដែលស្ថិតនៅក្នុងការសង្ស័យថា វានឹងកើតឡើងឬអត់ដោយសារគ្មានអ្នកណាដឹងនោះទេ «គ្រប់ការដែលព្រះទ្រង់ធ្វើ នោះទ្រង់បានជ្រាប តាំងពីអស់កល្បរៀងមក» (កិច្ចការ ១៥:១៨)។ អ្វីៗដែលព្រះជាម្ចាស់បានគ្រោងទុករួចហើយនោះ គឺមិនអាចបត់បែនបានឡើយ ដ្បិត «ទ្រង់មិនចេះប្រែប្រួលសូម្បីតែស្រមោលនៃសេចក្ដីផ្លាស់ប្រែក៏គ្មានដែរ» (យ៉ាកុប ១:១៧)។ ហេតុដូច្នោះហើយបានជាកណ្ឌគម្ពីរ វិវរណៈ ១:១ បានប្រាប់យើង

យ៉ាងច្បាស់ពី ព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅអនាគតថា «នេះជាការបើកសម្ដែងរបស់ព្រះយេស៊ូវគ្រីស្ទដែលព្រះបានប្រទានដល់ព្រះអង្គ ដើម្បីបង្ហាញឲ្យអ្នកបម្រើរបស់ព្រះអង្គបានឃើញពីអស់ទាំងហេតុការណ៍ដែលបន្តិចទៀតត្រូវកើតមាន ទ្រង់ក៏បានសម្ដែងឲ្យឃើញ ដោយចាត់ទេវតារបស់ព្រះអង្គមកជួបយ៉ូហាន ជាអ្នកបម្រើរបស់ព្រះអង្គ»។

គ្រប់ទាំងទំនាយដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់បង្ហាញពីព្រះប្រាជ្ញាញាណដ៏ល្អឥតខ្ចោះរបស់ទ្រង់។ ព្រះគម្ពីរសញ្ញាចាស់បានទាយទុកជាច្រើនអំពីប្រវត្តិសាស្ត្រអ៊ីស្រាអែល ហើយយើងក៏ឃើញដែរថា ទ្រង់បានបំពេញសម្រេចទំនាយទាំងនោះយ៉ាងពេញលេញនៅប៉ុន្មានសតវត្សរ៍ក្រោយមកនេះ។ ព្រះគម្ពីរសញ្ញាចាស់បានទាយអំពីកិច្ចការដែលព្រះគ្រីស្ទបានធ្វើនៅលើផែនដីនេះ ហើយក៏បានប្រាប់យើងអំពីការដែលព្រះជាម្ចាស់បំពេញសម្រេចទំនាយទាំងនោះយ៉ាងពេញលេញផងដែរ។ បទទំនាយបែបនេះបានសម្រេចតាមរយៈទ្រង់តែមួយអង្គប៉ុណ្ណោះ ព្រោះទ្រង់ជ្រាបពីពេលវេលាចុងក្រោយតាំងពីដើមដំបូងមកម្ល៉េះហើយព្រះប្រាជ្ញាញាណរបស់ទ្រង់គឺពឹងផ្អែកលើការដែលថា គ្រប់អ្វីៗដែលទ្រង់បានកំណត់ទុកប្រាកដជានឹងកើតឡើងមែន។ ជាមួយគ្នា ទាំងព្រះគម្ពីរសញ្ញាចាស់

និងសញ្ញាថ្មីគឺសុទ្ធតែបានប្រកាសអំពីកិច្ចការមួយចំនួនដែលនឹងកើតឡើងនៅពេលអនាគត ហើយកិច្ចការទាំងអស់នោះ «ត្រូវតែសម្រេច» ព្រោះព្រះជាម្ចាស់ដែលបានមានបន្ទូលប្រាប់អំពីការនោះទ្រង់បានព្រះតម្រិះទុកជាមុនហើយ (លូកា ២៤:៤៤)។

ចូរកុំច្រទំ្បថាព្រះបញ្ញាញាណ និងព្រះប្រាជ្ញាញាណ គឺជាអ្វីដែលនាំឲ្យមានកិច្ចការណាមួយកើតឡើងនោះឡើយ។ គ្រប់ការទាំងអស់ដែលបានកើតឡើង ឬដែលនឹងកើតឡើង គឺមិនមែនដោយសារតែព្រះជាម្ចាស់ជ្រាបពីការទាំងនោះប៉ុណ្ណោះទេ ព្រោះគ្រប់អ្វីៗទាំងអស់ដែលបានកើតឡើង សុទ្ធតែព្រះជាម្ចាស់បានគ្រោងឲ្យវាកើតឡើងតាមបំណងព្រះហឫទ័យរបស់ទ្រង់រួចទៅហើយ។ អ្នកណាដែលពិតជាជឿលើព្រះបន្ទូល អ្នកនោះនឹងច្បាស់ជាដឹងយ៉ាងប្រាកដថា គ្រប់រដូវកាលទាំងអស់នឹងបន្តកើតមានឡើងយ៉ាងរលូន រហូតទាល់តែប្រវត្តិសាស្ត្រនៃផែនដីនេះបានកន្លងផុតទៅ (លោកុប្បត្តិ ៨:២២) ប៉ុន្តែហេតុការណ៍ដែលកើតឡើងជាបន្តបន្ទាប់ គឺមិនមែនដោយសារបុគ្គលនោះដឹងពីហេតុការណ៍ដែលនឹងកើតឡើងនោះទេ។ ចូរកុំច្រទំ្បថា ព្រះបញ្ញាញាណរបស់ព្រះជាម្ចាស់កើតមានឡើងដោយសារកាលៈទេសៈដែលនៅជុំវិញទ្រង់នោះឡើយ តែផ្ទុយទៅវិញ គឺអ្វីៗទាំងអស់បានកើតឡើងតាមការគ្រោងទុកជាមុនរបស់

ទ្រង់។ ព្រះជាម្ចាស់បានជ្រាបដឹង ហើយក៏បានជ្រាបជាមុនរាប់រយឆ្នាំមុនអំពីការសុគតរបស់ព្រះរាជបុត្រាទ្រង់ដែរ គឺនៅពេលដែលទ្រង់បានយាងមកយកកំណើតជាមនុស្ស ហើយដោយសារនេះជាការគ្រោងទុកជាមុនរបស់ព្រះជាម្ចាស់ វាបង្ហាញថាទ្រង់បានរៀបចំឲ្យព្រះរាជបុត្រាដែលជាកូនចៀម មកសុគតតាំងពីមុនកំណើតពិភពលោកមកម៉្លេះ ដូចមានចែងទុកក្នុងកណ្ឌគម្ពីរ កិច្ចការ២:២៣ ថា «ព្រះអង្គនោះទ្រង់ត្រូវបញ្ជូនទៅ តាមការសម្រេច និងបុព្វញាណនៃព្រះ»។

តើយើងអាចអនុវត្តវិធីមួយចំនួនណានៅក្នុងជីវិតរបស់យើងបាន? ព្រះប្រាជ្ញាញាណដ៏គ្មានព្រំដែនរបស់ទ្រង់គួរធ្វើឲ្យយើងមានការស្ញប់ស្ញែងចំពោះព្រះជាម្ចាស់។ ព្រះជាម្ចាស់ពិតជាមានព្រះប្រាជ្ញាញាណខ្ពស់លើសអស់ទាំងអ្នកប្រាជ្ញនៅលើលោកនេះ។ ក្នុងចំណោមយើងរាល់គ្នា គ្មានអ្នកណាម្នាក់ដឹងថា ថ្ងៃនេះនឹងមានអ្វីខ្លះកើតឡើងនោះទេ ប៉ុន្តែព្រះជាម្ចាស់ជ្រាបគ្រប់អ្វីៗទាំងអស់ដែលនឹងកើតឡើងនៅពេលអនាគត។ យើងគួរតែស្ញប់ស្ញែងព្រះអង្គដោយចិត្តបរិសុទ្ធ ចំពោះព្រះប្រាជ្ញាញាណដ៏គ្មានព្រំដែនរបស់ទ្រង់។ គ្មានការណាមួយដែលយើងធ្វើ និយាយ ឬគិត ដែលអាចធ្វើឲ្យយើងគេចផុតពីភាពសព្វញ្ញូញាណរបស់ទ្រង់បានឡើយ។ កណ្ឌគម្ពីរ

សុភាសិត ១៥:៣ បានចែងថា «ព្រះនេត្រនៃព្រះយេហូវ៉ានៅគ្រប់អន្លើ ក៏ឃាមមើលឃើញទាំងអស់ ទោះទាំងការអាក្រក់ និងល្អផង»។ ប្រសិនបើយើងសញ្ជឹងគិតពីការនេះជាញឹកញាប់ នោះវានឹងប្តូរទិសផ្លូវនៃជីវិតយើង! យើងគួរតែនិយាយដូចនាង ហាកា ថា «ព្រះដ៏ទតឃើញ» ជាជាងការប្រព្រឹត្តិទង្វើដែលមិនមានសេចក្តីមេត្តា។ ការដែលគ្រីស្ទបរិស័ទយល់ថា ព្រះជាម្ចាស់ជ្រាបគ្រប់អ្វីៗទាំងអស់ដោយគ្មានព្រំដែន គួរតែជំរុញឲ្យពួកគេកាន់តែស្រឡាញ់ទ្រង់ថែមទៀត។ ដូច្នេះ យើងនឹងរស់នៅដោយទទួលស្គាល់ថា ទ្រង់ទតមើលឃើញជីវិតយើងតាំងពីដើមមកម្ល៉េះ។ ទោះបើទ្រង់ទតឃើញគ្រប់កំហុសរបស់ខ្ញុំ គ្រប់ទាំងអំពើបាបដែលខ្ញុំបានប្រព្រឹត្ត និងការបែកចេញពីទ្រង់ក៏ដោយ ក៏ទ្រង់នៅតែបើកព្រះហឫទ័យរង់ចាំទទួលខ្ញុំដែរ។ អូ! បើខ្ញុំបានដឹងបែបនេះហើយ ខ្ញុំគួរតែលុតជង្គង់ដោយស្ងប់ស្ងៀងហើយថ្វាយបង្គំព្រះអង្គចុះ។

ជំពូកទី៤

# ព្រះដ៏ពេញដោយ បុព្វញាណ

ប្រវត្តិសាស្ត្របានបង្ហាញឲ្យយើងដឹងថា មានមនុស្សជាច្រើន បានទាស់ប្រឆាំងនឹងលក្ខណសម្បត្តិដែលថា ព្រះទ្រង់ពេញដោយ បុព្វញាណ។ ប៉ុន្តែ តើមានសេចក្ដីពិតណាខ្លះនៅក្នុងព្រះគម្ពីរដែល មនុស្សមិនទាន់បានយកមកប្រើ ឬដកចេញពីទេវវិទ្យា និងក្នុងក្រុម ជំនុំ ដើម្បីតយុទ្ធនឹងការទាស់ប្រឆាំងបែបនេះ? ចំណុចមួយចំនួន នោះមានដូចជា៖ ភាពជាព្រះរបស់ព្រះគ្រីស្ទ ការប្រសូតតាមរយៈ ស្ត្រីព្រហ្មចារី ការសុគតជំនួសអំពើបាបយើង ការយាងមកជាលើក ទីពីររបស់ទ្រង់ ការរាប់អ្នកជឿជាសុចរិត ការញែកចេញជាបរិសុទ្ធ សុវត្ថិភាព ក្រុមជំនុំ រចនាសម្ព័ន្ធក្រុមជំនុំ អ្នកដឹកនាំ ការដាក់វិន័យ ក្រុមជំនុំ ពិធីជ្រមុជទឹក ពិធីលៀងព្រះអម្ចាស់ ក៏ដូចជាសេចក្ដីពិត មួយចំនួនទៀត មកប្រឆាំងនឹងគំនិតនោះ។ ទោះជាយ៉ាងនេះក្ដី ក៏

អ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះជាម្ចាស់មិនបានឈប់បង្រៀនសេចក្តីពិតទាំងនោះដែរ។ យើងមិនគួរឈប់បង្រៀនអំពីប្រធានបទដែលទាក់ទងនឹងបុព្វញាណ ឬការបម្រុងទុកជាមុនរបស់ព្រះជាម្ចាស់នោះទេ ពីព្រោះចំណុចនោះបាននាំឲ្យមានការជំទាស់គ្នាពីមុនៗនោះទេ ឬក៏ដោយសារតែយើងបារម្ភថាមានមនុស្សខ្លះលើកសម្តីថា យើងបានបង្កឲ្យមានជម្លោះឬ? ចូរកុំខ្លាចឲ្យសោះ ចូរឲ្យពួកគេប្រឆាំងចុះ ប្រសិនបើពួកគេចង់។ រីឯយើងវិញ យើងមានតួនាទីធ្វើជាស្មរបន្ទាល់តាមពន្លឺដែលព្រះជាម្ចាស់បានបើកសម្តែងដល់យើង។

## បណ្តេញកំហុសចេញ

មានចំណុចពីរយ៉ាងដែលទាក់ទងនឹងបុព្វញាណ ឬការបម្រុងទុកជាមុនរបស់ព្រះជាម្ចាស់ដែលមនុស្សជាច្រើនមិនសូវដឹងៈ ១) អត្ថន័យនៃពាក្យនេះ ២) វិសាលភាពរបស់ពាក្យនេះក្នុងព្រះគម្ពីរ។ ដោយសារមានមនុស្សជាច្រើនមិនសូវដឹងពីពាក្យនេះ ដូច្នេះហើយបានជាគ្រូអធិប្បាយ និងគ្រូបង្រៀនព្រះបន្ទូលងាយក្នុងការមិនបង្រៀនអំពីគោលជំនឿនេះបានយ៉ាងត្រឹមត្រូវ បើទោះជាត្រូវបង្រៀនដល់រាស្ត្ររបស់ព្រះជាម្ចាស់ក៏ដោយ។ ការមានជំនឿរឹងមាំ គឺជាវិធីតែមួយគត់ដែលអាចទប់មិនឲ្យយើងធ្លាក់ទៅក្នុងការបង្រៀនខុស

ឆ្គងបែបនេះ។ ជំនឿអាចរឹងមាំទៅបានអាស្រ័យលើការអធិស្ឋាន និង ការសិក្សាព្រះគម្ពីរដោយយកចិត្តទុកដាក់ ក៏ដូចជាការទទួលយក ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយចិត្តសុភាព។ ដូច្នេះ មានតែតាមវិធី ទាំងនេះទេ ដែលអាចជួយការពារយើងពីការទាស់ប្រឆាំងរបស់ពួក អ្នកទាស់ប្រឆាំងនឹងយើងបាន។ បច្ចុប្បន្ននេះមានមនុស្សមួយចំនួន កំពុងតែប្រើប្រាស់សេចក្ដីពិតនេះក្នុងលក្ខណៈខុសឆ្គង ដើម្បីបង្ខូច ហើយបដិសេធសេចក្ដីបង្រៀនដែលថា ព្រះជាម្ចាស់មានអធិបតេយ្យ ពេញទីក្នុងការសង្គ្រោះមនុស្សមានបាប។ មានអ្នកទាស់ប្រឆាំងជា ច្រើនបានបដិសេធពីការដែលថា ព្រះជាម្ចាស់ជាអ្នកបណ្ដាលឲ្យតែង បទគម្ពីរ ហើយក៏មានអ្នកវិទ្យាសាស្ត្រមួយចំនួនដែរ ដែលជឿថាគ្រប់ អ្វីៗទាំងអស់វិវត្តន៍ដោយខ្លួនឯង មិនមែនព្រះជាម្ចាស់ជាអ្នកបង្កើត នោះទេ។ ជាមួយគ្នា ក៏មានគ្រូក្លែងក្លាយមួយចំនួនបានបដិសេធ បុព្វញាណ និងការបម្រុងទុករបស់ព្រះជាម្ចាស់ដែរ ហើយពួកគេក៏ បានបង្រៀនដល់អ្នកផ្សេងទៀតថា ព្រះជាម្ចាស់មិនបានជ្រើសរើស មនុស្សឲ្យមានជីវិតអស់កល្បជានិច្ច ដោយឥតលក្ខខណ្ឌនោះទេ។

នៅពេលដែលគេនិយាយពីការដែលព្រះជាម្ចាស់តម្រូវមនុស្ស មួយចំនួនទុកជាមុន ទាក់ទងនឹងការដែលទ្រង់ជ្រើសរើសពួកគេ ឲ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ពេលនោះអារក្ស

សាតាំងក៏ចាត់មនុស្សមួយចំនួនឲ្យមកប្រកែកថា ការដែលទ្រង់ជ្រើសរើស គឺព្រោះតែទ្រង់មានបុព្វញាណ ឬបានបម្រុងទុកជាមុនរួចទៅហើយ។ ហើយនៅពេលដែលមនុស្សមួយចំនួននោះប្រើពាក្យបុព្វញាណ ឬការបម្រុងទុក ពួកគេក៏បានបង្ខូចអត្ថន័យដែលថាព្រះជាម្ចាស់បានទតឃើញថា មនុស្សមួយចំនួននឹងបន្ទន់ចិត្តជឿលើទ្រង់ជាងអ្នកផ្សេង ហើយពួកគេនឹងឆ្លើយតបយ៉ាងងាយក្នុងការដែលព្រះវិញ្ញាណបរិសុទ្ធប៉ះពាល់ចិត្តរបស់ពួកគេ។ ដូច្នេះ ទ្រង់ក៏បានជ្រើសរើសពួកគេជាមុនឲ្យទទួលសេចក្ដីសង្គ្រោះ ពីព្រោះទ្រង់ជ្រាបថា ពួកគេនឹងជឿលើទ្រង់។ ប៉ុន្តែ នេះជាសេចក្ដីបង្រៀនខុសឆ្គងទាំងស្រុង! សេចក្ដីបង្រៀនបែបនេះបដិសេធសេចក្ដីពិតដែលថា មនុស្សមិនអាចសង្គ្រោះខ្លួនឯងបានទេ ពីព្រោះសេចក្ដីបង្រៀនខាងលើនេះប្រកែកថា មានមនុស្សខ្លះជាមនុស្សល្អ។ សេចក្ដីបង្រៀនបែបនេះបានដកឯករាជ្យភាពពីព្រះជាម្ចាស់ ព្រោះវាធ្វើឲ្យការជ្រើសតាំងរបស់ទ្រង់ពឹងផ្អែកទៅលើការជ្រើសរើសរបស់មនុស្ស។ គឺជាការធ្វើឲ្យសេចក្ដីពិតត្រឡប់ត្រលិន ព្រោះវាលើកឡើងថា ព្រះជាម្ចាស់ជ្រាបថា មនុស្សមានបាបមួយចំនួននឹងជឿលើព្រះគ្រីស្ទ ហើយដោយសារទ្រង់ជ្រាបបែបនេះហើយ បានជាទ្រង់ជ្រើសតាំងពួកគេឲ្យទទួលបានសេចក្ដីសង្គ្រោះ។ ប៉ុន្តែ សេចក្ដីបង្រៀនបែបនេះផ្ទុយពីការបង្រៀនរបស់

ព្រះគម្ពីរ។ បទគម្ពីរបានអះអាងថា តាមរយៈអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ ទ្រង់បានជ្រើសរើសមនុស្សមួយចំនួនឲ្យទទួលព្រះគុណរបស់ទ្រង់ (កិច្ចការ ១៣:៤៨) ហេតុដូច្នេះហើយបានជាទ្រង់សន្មតថា ទ្រង់នឹងប្រទានជំនឿទុកជាអំណោយដល់ពួកគេ។ ទេវវិទ្យាខុសឆ្គងបង្រៀនថា បុព្វញាណ ឬការបម្រុងទុកជាមុនរបស់ព្រះជាម្ចាស់ទាក់ទងនឹងការដែលយើងជឿ គឺជាមូលហេតុដែលបណ្ដាលឲ្យទ្រង់ជ្រើសរើសយើងឲ្យទទួលសេចក្ដីសង្គ្រោះ។ ប៉ុន្ដែ ទេវវិទ្យាដែលត្រឹមត្រូវគឺ ការជ្រើសតាំងរបស់ព្រះជាម្ចាស់ជាហេតុ ហើយជំនឿរបស់យើងលើទ្រង់ជាផល។

## ការប្រកាសសេចក្ដីពិត

ចូរយើងផ្អាកការគិតបន្ដិចសិន ដើម្បីពន្យល់អត្ថន័យឲ្យពាក្យរបស់យើង មុនដែលយើងបន្ដពណ៌នាអំពីប្រធានបទដែលមានមនុស្សជាច្រើនមានការយល់ខុស។ តើពាក្យ “បុព្វញាណ ឬការបម្រុងទុក” មានន័យយ៉ាងដូចម្ដេច? “បុព្វញាណ” មានន័យថា “ការដឹង ឬការជ្រាបជាមុន ឬក៏ពីដើម”។ ហើយនេះ គឺជាអត្ថន័យនៃពាក្យបុព្វញាណ ដែលមនុស្សជាច្រើនតែងតែឲ្យនិយមន័យ។ ប៉ុន្ដែ យើងមិនត្រូវសន្និដ្ឋានឆាប់រហ័សពេកនោះទេ ហើយយើងក៏

មិនត្រូវពឹងលើវចនានុក្រមឲ្យធ្វើជាអ្នកកាត់សេចក្តីចុងក្រោយនោះដែរ ព្រោះអត្ថន័យពាក្យនេះមិនមានអ្វីទាក់ទងនឹងឫសពាក្យនោះទេ។ ប្រសិនបើយើងចង់យល់ពីអត្ថន័យពិត គឺយើងត្រូវតែមើលពីរបៀបដែលព្រះគម្ពីរបានប្រើពាក្យនេះ។ ការឃើញពីរបៀបដែលព្រះវិញ្ញាណបរិសុទ្ធប្រើពាក្យនេះនៅក្នុងបទគម្ពីរនិងតែងតែជួយឲ្យយើងយល់ពីអត្ថន័យពិត និងពីវិសាលភាពនៃពាក្យនេះ។ ប្រសិនបើយើងមិនព្យាយាមយល់ពាក្យនីមួយៗចេញពីព្រះបន្ទូលរបស់ព្រះអង្គទេ នោះយើងនឹងមានការយល់ច្រឡំ ហើយយល់ខុសលើពាក្យនេះជាមិនខាន។ មានមនុស្សជាច្រើនគិតថា គេបានយល់ពីអត្ថន័យនៃពាក្យមួយចំនួនដែលមាននៅក្នុងបទគម្ពីរ ប៉ុន្តែគេមានការយឺតយ៉ាវក្នុងការល្បងលអត្ថន័យរបស់ខ្លួនដោយប្រើវិជ្ជាសមោធាន។ ចូរយើងមើលចំណុចនេះថែមទៀត៖

ឧទាហរណ៍៖ ចូរយើងស្វែងយល់ពីអត្ថន័យនៃពាក្យ “សាច់ឈាម”។ មានមនុស្សជាច្រើនបានគិតថា គេបានយល់អត្ថន័យនេះ ហេតុដូច្នេះហើយបានជាគេរាប់ថា ការយកពេលវេលាមកវែកញែកពីរបៀបដែលបទគម្ពីរប្រើពាក្យនេះ គឺគ្មានប្រយោជន៍អ្វីទេ។ គេបានសន្មតយ៉ាងរហ័សថា ពាក្យនេះគឺមានន័យដូចទៅនឹងពាក្យ “រូបកាយ” ហេតុដូច្នោះហើយបានជាគេមិនស្វែងយល់ថែមទៀត

ទេ។ ប៉ុន្តែ តាមពិតទៅ បទគម្ពីរបានប្រើពាក្យ «សាច់ឈាម» លើស ពីអវយវៈនៃរូបរាងកាយទៅទៀត។ ប្រសិនបើយើងមិនបានមើលអត្ថន័យរបស់វាដោយប្រៀបធៀបអត្ថន័យនៃពាក្យនោះនៅគ្រប់កន្លែងដែលបទគម្ពីរប្រើដោយយកចិត្តទុកដាក់ ឬមិនព្យាយាមស្វែងយល់ក្នុងគ្រប់បរិបទនីមួយៗទេ នោះយើងមិនអាចយល់ពីអត្ថន័យនៃពាក្យនេះបានទាំងស្រុងឡើយ។ ចូរយើងស្វែងយល់ពីអត្ថន័យនៃពាក្យ «លោកីយ៍»។ អ្នកស្គាល់ព្រះគម្ពីរស្ទើរៗមួយចំនួនបានគិតថាពាក្យនេះគឺស្មើនឹងពាក្យមនុស្សលោក ហេតុដូច្នេះហើយបានជាគេកាត់ស្រាយខគម្ពីរខុស។ ចូរយើងស្វែងយល់អត្ថន័យនៃពាក្យ «ភាពអមតៈ»។ មនុស្សមួយចំនួនបានគិតថា គេមិនចាំបាច់ស្វែងយល់ពាក្យនេះទេ ពីព្រោះគេគិតថា ពាក្យនេះមានន័យថា «ព្រលឹងយើងមិនចេះស្លាប់»។ ឱមិត្តអ្នកអានរបស់យើងខ្ញុំអើយ! នេះគឺជារឿងល្ងីល្ងើ ហើយខុសឆ្គងខ្លាំងណាស់ ដែលយើងព្យាយាមឲ្យអត្ថន័យទៅលើពាក្យដែលជាប់ទាក់ទងនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយគំនិតរបស់យើងនោះ។ ប្រសិនបើមិត្តអ្នកអានចំណាយពេល ដើម្បីស្វែងយល់គ្រប់ទាំងខព្រះគម្ពីរដែលរៀបរាប់អំពីពាក្យ «ស្លាប់» និងពាក្យ «សេចក្តីមិនពុករលួយ» ដោយយកចិត្តទុកដាក់ នោះយើងនឹងឃើញថា ព្រះគម្ពីរមិនដែលប្រើពាក្យទាំងនេះទាក់ទងនឹងព្រលឹង

ឡើយ ប៉ុន្តែទាក់ទងនឹងរូបកាយវិញ។

ចូរយើងស្វែងយល់អត្ថន័យនៃពាក្យ «បុព្វញាណ ឬការបម្រុងទុក» ដូចដែលយើងបានស្វែងយល់អំពីពាក្យ «សាច់ឈាម លោកីយ៍ និងភាពអមតៈ» ផងដែរ។ យើងត្រូវតែស្វែងយល់អំពីគ្រប់ទាំងខគម្ពីរដែលរៀបរាប់ពីពាក្យនេះដោយយកចិត្តទុកដាក់ ជាជាងគ្រាន់តែគិតថា ពាក្យទាំងនេះមិនមានអត្ថន័យលើសពីការយល់ដឹងរបស់យើងនោះឡើយ។ ព្រះគម្ពីរសញ្ញាចាស់មិនដែលប្រើពាក្យ «បុព្វញាណ» ទេ ប៉ុន្តែ ព្រះគម្ពីរសញ្ញាចាស់បានប្រើពាក្យថា «ដឹង ស្គាល់ ជ្រាប» ជាច្រើនដង។ នៅពេលដែលព្រះជាម្ចាស់ប្រើពាក្យទាំងនេះ គឺទ្រង់សព្វព្រះហឫទ័យបង្ហាញការពេញចិត្តរបស់ទ្រង់ចំពោះបុគ្គលណាម្នាក់ ប៉ុន្តែមិនគ្រាន់តែជាការបង្ហាញអំពីការដែលទ្រង់ជ្រាបក្នុងព្រះតម្រិះរបស់ទ្រង់ប៉ុណ្ណោះទេ។ កណ្ឌគម្ពីរ និក្ខមនំ ៣៣:១៧ បានចែងថា «អញក៏ស្គាល់ឯងយ៉ាងជិតស្និទ្ធ»។ កណ្ឌគម្ពីរ ចោទិយកថា ៩:២៤ បានចែងថា «គឺចេះតែមានចិត្តរឹងចចេសចំពោះព្រះយេហូវ៉ាជានិច្ច តាំងតែពីថ្ងៃដែលអញទើបនឹងស្គាល់ឯងរាល់គ្នាមក»។ យេរេមា ១:៥ «មុនដែលអញបានជប់បង្កើតឯងនៅក្នុងពោះម្តាយ នោះអញស្គាល់ឯងហើយ»។ ហូសេ ៨:៤ «គេ...បានតាំងចៅហ្វាយឡើង តែអញមិនបានដឹងឡើយ»។ អេម៉ុស៣:២ «ក្នុងអស់ទាំងគ្រួនៅ

ផែនដី អញបានស្គាល់តែឯងរាល់គ្នាទេ»។ ខគម្ពីរទាំងនេះបង្ហាញថាពាក្យ “ស្គាល់” មានន័យថា ព្រះជាម្ចាស់បានស្រឡាញ់ ឬក៏បានជ្រើសតាំងមនុស្សទាំងនោះ។

ព្រះគម្ពីរសញ្ញាថ្មីក៏បានប្រើពាក្យ “ស្គាល់” ក្នុងអត្ថន័យដូចដែលព្រះគម្ពីរសញ្ញាចាស់បានប្រើផងដែរ។ ម៉ាថាយ ៧:២៣ បានចែងថា “នោះខ្ញុំនឹងនិយាយដោយត្រង់ថា អញមិនដែលបានស្គាល់ឯងរាល់គ្នាទេ»។ យ៉ូហាន ១០:១៤ “ឯខ្ញុំ ជាអ្នកគង្វាលល្អ ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ ហើយចៀមក៏ស្គាល់ខ្ញុំ»។ ១កូរិនថូស ៨:៣ “តែបើអ្នកណាស្រឡាញ់ព្រះ ទ្រង់ក៏ស្គាល់អ្នកនោះ»។ ២ធីម៉ូថេ ២:១៩ “ព្រះអម្ចាស់ទ្រង់ស្គាល់អស់អ្នកដែលជារបស់ផងទ្រង់»។

## ការផ្តល់អត្ថន័យលើពាក្យ «បុព្វញាណ»

នៅពេលដែលព្រះគម្ពីរសញ្ញាថ្មីប្រើពាក្យ “បុព្វញាណ” វាមានអត្ថន័យលើសជាង “ការស្គាល់” ទៅទៀត។ ប្រសិនបើយើងចំណាយពេលស្វែងយល់ពាក្យនេះនៅគ្រប់ទាំងខគម្ពីរដោយយកចិត្តទុកដាក់ នោះយើងនឹងឃើញថា ពាក្យនេះមិនទាក់ទងនឹងការដែលព្រះជាម្ចាស់ជ្រាបគ្រប់អ្វីៗដែលនឹងកើតឡើងនៅពេលអនាគតនោះទេ។ ព្រះគម្ពីរមិនដែលប្រើពាក្យ “បុព្វញាណ” ដើម្បីរៀបរាប់

ពីព្រឹត្តិការណ៍ ឬទង្វើទេ តែព្រះគម្ពីរតែងតែប្រើពាក្យនេះ ដើម្បីរៀបរាប់ពីមនុស្សវិញ។ វាទាក់ទងជាមួយការដែលស្គាល់បុគ្គលណាម្នាក់ មិនមែនមានន័យថាទ្រង់ស្គាល់ពីទង្វើរបស់អ្នកនោះទេ។ ជាភស្តុតាង យើងនឹងមើលរាល់គ្រប់ខគម្ពីរដែលបានប្រើឃ្លានេះ។

កណ្ឌគម្ពីរ កិច្ចការ ២:២៣ គឺជាកន្លែងដំបូងក្នុងព្រះគម្ពីរដែលបានប្រើប្រាស់ឃ្លានេះ «តាមរយៈគម្រោងការដែលបានកំណត់ទុក និងបុព្វញាណរបស់ព្រះ ព្រះអង្គនោះត្រូវបញ្ជូនមកអ្នករាល់គ្នា ហើយអ្នករាល់គ្នាបានឆ្កាង និងធ្វើគុតព្រះអង្គដោយសារដៃមនុស្សទទឹងច្បាប់» (គកស)។ ប្រសិនបើយើងអានខគម្ពីរនេះដោយយកចិត្តទុកដាក់ ហើយផ្ទៀងពីការដែលសាវ័ក ពេត្រុស រៀបចំពាក្យពេចន៍នោះយើងនឹងឃើញថា ខគម្ពីរនេះមិនបានរៀបរាប់ពីបុព្វញាណរបស់ព្រះជាម្ចាស់ទាក់ទងនឹងការឆ្កាងរបស់ព្រះយេស៊ូវទេ តែខគម្ពីរនេះកំពុងរៀបរាប់ពីបុគ្គលដែលត្រូវគេឆ្កាង «ព្រះអង្គនោះត្រូវបញ្ជូនមក»។

លើកទីពីរដែលព្រះគម្ពីរបានប្រើប្រាស់ពាក្យនេះគឺនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៨:២៩-៣០ «ដ្បិតអ្នកណាដែលទ្រង់បានស្គាល់ជាមុន នោះទ្រង់ក៏តម្រូវទុកជាមុន ឲ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ដើម្បីឲ្យព្រះរាជបុត្រាបានធ្វើជាបងច្បងគេក្នុងពួកបងប្អូនជាច្រើន ឯពួកអ្នកដែលទ្រង់បានតម្រូវទុកជាមុន នោះទ្រង់ក៏ហៅ ហើយ

ពួកអ្នកដែលទ្រង់បានហៅ...»។ ចូរកត់សម្គាល់ពាក្យដែលដើរតួជាសព្វនាមនៅក្នុងខគម្ពីរនេះ។ ខគម្ពីរនេះមិនបានបង្ហាញថា ទ្រង់បានដឹងអ្វីជាមុននោះទេ ប៉ុន្តែបានបង្ហាញពីបុគ្គលដែលទ្រង់បានស្គាល់។ ចំណុចនេះមិនទាក់ទងនឹងការចុះចូលនឹងឆន្ទៈទេ ហើយក៏មិនទាក់ទងនឹងជំនឿដែរ ប៉ុន្តែទាក់ទងនឹងបុគ្គលម្នាក់ៗវិញ។

កណ្ឌគម្ពីរ រ៉ូម ១១:២ បានចែងថា «ព្រះទ្រង់មិនបានបោះបង់ចោលរាស្ត្រទ្រង់ ដែលទ្រង់ស្គាល់ជាមុននោះទេ»។ ខគម្ពីរនេះក៏បញ្ជាក់ម្តងទៀតថា ការស្គាល់ជាមុនរបស់ព្រះអង្គ គឺសំដៅលើមនុស្សតែប៉ុណ្ណោះ។

ទីបី៖ ១ពេត្រុស១:២ចែងថា «ជាពួកអ្នករើសតាំងតាមបុព្វញាណនៃព្រះដ៏ជាព្រះវរបិតា»។ តើព្រះជាម្ចាស់បានជ្រើសតាំងអ្នកណា តាមបុព្វញាណនៃព្រះដ៏ជាព្រះវរបិតា? ខ១បានប្រាប់យើងថា «ពួកអ្នក» គឺសំដៅទៅលើ «បងប្អូនដែលបែកខ្ញែកគ្នា»។ ឧទាហរណ៍៖ អ្នកដែលត្រូវខ្ចាត់ខ្ចាយ គឺពួកសាសន៍យូដាដែលជាអ្នកជឿ។ ខគម្ពីរនេះក៏បង្ហាញយើងដែរថាសាវ័ក ពេត្រុស កំពុងតែរៀបរាប់អំពីអ្នកដែលព្រះជាម្ចាស់ស្គាល់ មិនមែនអំពីទង្វើដែលពួកគេនឹងធ្វើនោះទេ។

យោងតាមខគម្ពីរទាំងអស់នេះ (គ្មានខណាផ្សេងទៀតប្រើពាក្យនេះទេ) តើមានអ្នកណាអាចលើកយកខគម្ពីរផ្សេងមកនិយាយថា

ដោយសារព្រះជាម្ចាស់បានស្គាល់ពីទង្វើរបស់បុគ្គលណាម្នាក់ ដូចជាការដែលគេប្រែចិត្ត និងការដែលគេជឿជាដើម នោះហើយបានជាទ្រង់ជ្រើសតាំងពួកគេឲ្យទទួលបានសេចក្ដីសង្គ្រោះដែរឬទេ? ចម្លើយគឺ គ្មានមូលដ្ឋានណាដែលអាចបណ្ដាលឲ្យនរណាម្នាក់សន្និដ្ឋានបែបហេតុដូច្នោះបានទេ។ ព្រះបន្ទូលមិនដែលរៀបរាប់ថា ព្រះជាម្ចាស់មានបុព្វញាណអំពីការប្រែចិត្ត ឬជំនឿរបស់បុគ្គលណាម្នាក់នោះទេ។ ជាការពិតណាស់ ទ្រង់ពិតជាបានជ្រាបតាំងពីអស់កល្បរៀងមកម្ល៉េះ អំពីអស់អ្នកដែលនឹងប្រែចិត្ត ហើយជឿលើទ្រង់ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក៏ព្រះបន្ទូលមិនដែលលើកឡើងថា ការជ្រាបដឹងបែបនោះគឺជាគោលនៃ «បុព្វញាណ» របស់ព្រះជាម្ចាស់ដែរ។ សរុបមក អត្ថន័យនៃពាក្យ «បុព្វញាណ» គឺៈ ព្រះជាម្ចាស់ស្គាល់បុគ្គលម្នាក់ៗ។ ហេតុនេះហើយ ចូរយើង «នឹកចាំពីអស់ទាំងពាក្យត្រឹមត្រូវ» (២ធីម៉ូថេ ១:១៣)។

កណ្ឌគម្ពីរ កិច្ចការ ២:២៣ និង រ៉ូម ៨:២៩-៣០ បានបង្រៀនយ៉ាងច្បាស់ថា បុព្វញាណរបស់ព្រះជាម្ចាស់មិនមែនជាហេតុការណ៍នោះទេ ប៉ុន្តែមានហេតុផលមួយផ្សេងទៀតមុនបុព្វញាណរបស់ទ្រង់ ហេតុផលនោះគឺជាអធិបតេយ្យភាពនៃការគ្រោងទុកជាមុនរបស់ទ្រង់។ ព្រះជាម្ចាស់បានបញ្ជូនព្រះគ្រីស្ទមកតាមរយៈ ១) គម្រោង

ការដែលព្រះអង្គបានកំណត់ទុក និងតាមរយៈ ២) បុព្វញាណរបស់ទ្រង់ (កិច្ចការ ២:២៣)។ មូលដ្ឋាននៃបុព្វញាណរបស់ព្រះជាម្ចាស់គឺគម្រោងការ ឬការគ្រោងទុកជាមុនរបស់ទ្រង់។ កណ្ឌគម្ពីរ រ៉ូម ៨:២៩ ក៏បានរៀបរាប់ដូចកណ្ឌគម្ពីរកិច្ចការដែរ។ ខគម្ពីរនេះផ្ដើមដោយពាក្យថា «ដ្បិត» ដែលពាក្យនេះចង់ប្រាប់យើងឲ្យត្រឡប់ទៅមើលខគម្ពីរមុនៗ។ តើខគម្ពីរមុនៗបានរៀបរាប់អំពីអ្វីខ្លះ? ខគម្ពីរមុនៗបានរៀបរាប់ដូចតទៅនេះថា៖ «គ្រប់ការទាំងអស់ផ្សំគ្នា សម្រាប់សេចក្ដីល្អ... ដល់ពួកអ្នកដែលទ្រង់ហៅមក» (រ៉ូម ៨:២៨)។ សរុបសេចក្ដីមក បុព្វញាណរបស់ព្រះជាម្ចាស់ គឺអាស្រ័យលើផែនការ ឬក៏គម្រោងការរបស់ទ្រង់ (ទំនុកតម្កើង ២:៧)។

ព្រះជាម្ចាស់ជ្រាបដឹងនូវអ្វីៗទាំងអស់ដែលនឹងកើតឡើង ព្រោះទ្រង់ជាអ្នកដែលបានគ្រោងការទាំងនោះទុកជាមុន។ ការដែលលើកឡើងថា ព្រះជាម្ចាស់បានជ្រើសតាំង មកពីទ្រង់បានស្គាល់មនុស្សជាមុន នោះគឺជាការដែលយើងបំផ្លាស់អត្ថន័យនៃព្រះបន្ទូល ហើយចំណុចនោះមិនខុសពីការដែលយើងអូសឫស្សីបញ្ច្រាសចុងនោះទេ។ តាមពិតទៅ ទ្រង់បានជ្រាបជាមុន ព្រោះទ្រង់បានជ្រើសតាំងរួចទៅហើយ។ នេះមានន័យថា មនុស្សមិនមែនជាអ្នកជ្រើសតាំងទេ ប៉ុន្តែព្រះជាម្ចាស់ជាអ្នកដែលជ្រើសតាំងដោយអធិបតេយ្យភាព

របស់ទ្រង់។ ព្រះជាម្ចាស់បានគ្រោងទុកក្នុងអង្គទ្រង់ផ្ទាល់ ដើម្បីជ្រើសតាំងមនុស្សមួយចំនួន ហើយការដែលទ្រង់បានជ្រើសតាំងពួកគេ មិនមែនដោយសារពួកគេជាមនុស្សល្អ ឬបានធ្វើអ្វីល្អនោះទេ ប៉ុន្តែទ្រង់បានរើសតាំងពួកគេសម្រាប់អំណររបស់ទ្រង់តែមួយប៉ុណ្ណោះ។ ព្រះគម្ពីរមិនបានប្រាប់យើងពីហេតុផលនៃការដែលទ្រង់ជ្រើសតាំងអ្នកនេះ ឬអ្នកនោះទេ ប៉ុន្តែយើងអាចយល់បានថា “ហ្នឹងហើយ ព្រះវរបិតាអើយ ដ្បិតទ្រង់បានសព្វព្រះហឫទ័យយ៉ាងដូច្នោះ” (ម៉ាថាយ ១១:២៦)។ សេចក្តីពិតនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៨:២៩ គឺថាមុនកំណើតពិភពលោក ព្រះជាម្ចាស់បានជ្រើសតាំងមនុស្សមានបាបមួយចំនួន និងបានឲ្យពួកគេទទួលបានសេចក្តីសង្គ្រោះ (សូមអានបន្ថែមក្នុងកណ្ឌគម្ពីរ ២ថែស្សាឡូនីច ២:១៣)។ យើងអាចឃើញសេចក្តីពិតនេះយ៉ាងច្បាស់តាមរយៈការដែលសាវ័ក ប៉ុល បញ្ចប់ខគម្ពីរនេះថា “ទ្រង់ក៏តម្រូវទុកជាមុន ឲ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់...”។ ព្រះជាម្ចាស់មិនបានតម្រូវមនុស្សមួយចំនួនទុកជាមុនដោយព្រោះទ្រង់ដឹងថាពួកគេនឹង “ត្រឡប់” ទៅរកទ្រង់នោះទេ ផ្ទុយទៅវិញ គឺទ្រង់បានតម្រូវពួកគេទុកឲ្យ “ត្រឡប់” ទៅរកទ្រង់វិញ ព្រោះទ្រង់បានជ្រាបពីការនោះរួចទៅហើយ។ ការដែលពួកគេបានត្រឡប់ដូចជារូបអង្គនៃព្រះគ្រីស្ទ មិនមែនជាមូលហេតុ

នោះទេ ប៉ុន្តែមូលហេតុនោះគឺបុព្វញាណ និងការតម្រូវទុកជាមុនរបស់ទ្រង់វិញទេតើ។

ការដែលព្រះជាម្ចាស់ជ្រើសតាំងមនុស្សមានបាបណាម្នាក់ មិនមែនដោយសារទ្រង់ជ្រាបថា បុគ្គលនោះនឹងជឿលើទ្រង់នៅពេលអនាគតទេ។ យើងបានដឹងហើយថា គ្មានមនុស្សមានបាបណាម្នាក់នឹងជឿលើទ្រង់ឡើយ លុះត្រាតែទ្រង់ប្រទានឲ្យគេមានជំនឿជាមុនសិន។ ប្រសិនបើព្រះជាម្ចាស់មិនបានប្រទានឲ្យមនុស្សមានភ្នែកទេ នោះក៏គ្មាននរណាម្នាក់អាចនឹងមើលឃើញបានដែរ។ ភ្នែកគឺជាអំណោយទានមកពីព្រះជាម្ចាស់ ហើយការមើលឃើញគឺជាលទ្ធផលនៃការប្រើអំណោយទាននោះ។ ដូចគ្នានេះដែរ ជំនឿគឺជាអំណោយទានមកពីព្រះជាម្ចាស់ (អេភេសូរ ១:៨; ៩) ការជឿគឺជាលទ្ធផលនៃការប្រើអំណោយទានដែលមកពីទ្រង់។ ប្រសិនបើព្រះជាម្ចាស់ពិតជាបានជ្រើសតាំងមនុស្សមួយចំនួនឲ្យទទួលបានសេចក្តីសង្គ្រោះដោយសារពួកគេនឹងជឿនៅថ្ងៃណាមួយ នោះមានន័យថា ការជឿគឺជាអ្វីដែលមនុស្សជាអ្នកធ្វើ ហើយតាមរយៈការនេះ មនុស្សមានបាបដែលបានជឿនោះ ប្រាកដជាអាចអួតខ្លួនបានជាមិនខាន។ ប៉ុន្តែ កណ្ឌគម្ពីរ អេភេសូរ ២:៩ បានចែងយ៉ាងច្បាស់ហើយថា ការអួតខ្លួនបែបនេះមិនអាចទៅរួចបានទេ។

ព្រះបន្ទូលបានចែងយ៉ាងច្បាស់ថា ការដែលយើងជឿមិនទាក់ទងនឹងការប្រព្រឹត្តិនោះទេ។ គំនិតនេះក៏ជាភស្តុតាងមួយទៀតដែលបញ្ជាក់ថាគ្រីស្ទបរិស័ទគឺជារាស្ត្រ“ដែលជឿដោយព្រះគុណ” (កិច្ចការ ១៨:២៧)។ បើពួកគេពិតជាបានជឿ “ដោយព្រះគុណ” មែន នេះមានន័យថា ពួកគេមិនបានធ្វើអ្វីសម្រាប់ជំនឿរបស់ខ្លួនទេ ហើយបើដូច្នេះមែន ការដែលពួកគេជឿ ក៏មិនមែនជាមូលហេតុដែលនាំឲ្យព្រះជាម្ចាស់ជ្រើសតាំងពួកគេនោះដែរ។ ចូរចាំថា ការដែលព្រះជាម្ចាស់ជ្រើសតាំង គឺមិនមែនដោយសារមានអ្វីមួយនៅខាងក្នុងយើងឬមកពីយើងនោះទេ ប៉ុន្តែទ្រង់ជ្រើសតាំងដោយសារអធិបតេយ្យភាពនៃអំណាររបស់ទ្រង់តែមួយគត់។ កណ្ឌគម្ពីររ៉ូម១១:៥ បានចែងថាមាន “សំណល់សល់ដែលទ្រង់បានរើសតាំងដោយព្រះគុណ”។ ខគម្ពីរនេះបានបញ្ជាក់យ៉ាងច្បាស់ថា៖ ហេតុដែលព្រះជាម្ចាស់ជ្រើសតាំងយើង គឺដោយសារព្រះគុណរបស់ទ្រង់។ ព្រះគុណ គឺជាការដែលព្រះជាម្ចាស់រាប់យើងជាអ្នកសំណព្វរបស់ទ្រង់ ទោះបើយើងមិនគួរទទួលបានក៏ដោយ។ យើងមិនអាចទាមទារព្រះគុណពីព្រះជាម្ចាស់បានទេ ពីព្រោះយើងមិនស័ក្តិសមនឹងទទួលព្រះគុណរបស់ទ្រង់ឡើយ។

សរុបមកយើងត្រូវយល់ពីបទគម្ពីរដែលទាក់ទងនឹង

"បុព្វញាណ" របស់ព្រះជាម្ចាស់ឲ្យបានច្បាស់ ពីព្រោះវាជាការសំខាន់ណាស់។ ប្រសិនបើយើងយល់ខុសលើបុព្វញាណរបស់ព្រះជាម្ចាស់ នោះយើងនឹងមានគំនិតដែលមិនគោរពប្រតិបត្តិដល់ទ្រង់។ មនុស្សជាច្រើនមិនមានការយល់ដឹងបានត្រឹមត្រូវអំពីអត្ថន័យ "បុព្វញាណរបស់ព្រះ" ទេ។ ព្រះជាម្ចាស់មិនត្រឹមតែជ្រាបពីថ្ងៃចុងក្រោយតាំងពីអស់កល្បរៀងមកនោះទេ គឺទ្រង់ថែមទាំងមានផែនការទុកជាមុនទៀតផង ពោលគឺទ្រង់បានបំពេញផែនការ ព្រមទាំងបានតម្រូវអ្វីៗទាំងអស់ទុកជាមុនមករួចស្រេចទៅហើយ។ ដូចសុភាសិតមួយពោលថា៖ មានហេតុទើបមានផល។ ផែនការរបស់ព្រះជាម្ចាស់គឺជាការដែលនាំឲ្យទ្រង់ជ្រាបដឹងជាមុន។ ប្រសិនបើមិត្តអ្នកអានជាគ្រីស្ទបរិស័ទពិតមែន ចូរចងចាំថា លោកអ្នកជាគ្រីស្ទបរិស័ទដ៏ពិត ពីព្រោះព្រះគ្រីស្ទបានជ្រើសតាំងលោកអ្នកតាំងពីមុនកំណើតលោកីយ៍មកម្ល៉េះ (អេភេសូរ ១:៤) ហើយទ្រង់មិនបានជ្រើសតាំងលោកអ្នក ដោយសារទ្រង់បានជ្រាបដឹងជាមុនថា លោកអ្នកនឹងទទួលជឿលើទ្រង់នោះទេ ប៉ុន្តែផ្ទុយទៅវិញព្រះអង្គបានជ្រើសតាំងលោកអ្នក ដោយសារទ្រង់មានអំណរក្នុងការជ្រើសតាំងលោកអ្នក៖ ទ្រង់បានជ្រើសតាំងលោកអ្នក ទោះបីជានិស្ស័យពីធម្មជាតិរបស់លោកអ្នកនឹងមិនជឿលើទ្រង់ក៏ដោយ។ ហេតុដូច្នេះហើយ

បានជាយើងត្រូវថ្វាយគ្រប់ទាំងសិរីល្អ និងសេចក្ដីសរសើរដល់ព្រះជាម្ចាស់តែមួយប៉ុណ្ណោះ។ យើងគ្មានសិទ្ធិក្នុងការអួតខ្លួនថា យើងបានជឿដោយខ្លួនឯងនោះទេ។ យើងបាន “ជឿដោយព្រះគុណ” ហើយ “ដោយព្រះគុណ” ព្រះជាម្ចាស់ក៏បានជ្រើសតាំងលោកអ្នក (កិច្ចការ ១៨:២៧; រ៉ូម ១១:៥)។

ជំពូកទី៥

# ព្រះដ៏ឧត្តុង្គឧត្តម

មានសំបុត្រមួយក្នុងចំណោមសំបុត្រជាច្រើនដែលលោកគ្រូ លូធ័រ (Luther) បានសរសេរទៅកាន់លោកគ្រូ អ៊ែរ៉ាសមើស (Erasmus) ថា “លោក អ៊ែរ៉ាសមើស អើយ! លោកមានគំនិតអំពីព្រះជាម្ចាស់ ដូចមនុស្សពេកហើយ”។ មើលទៅលោកសាស្ត្រាចារ្យ លូធ័រ ដ៏ល្បីល្បាញម្នាក់នេះ ប្រហែលជាខឹងដែលបានស្ដីបន្ទោសលោកគ្រូ អ៊ែរ៉ាសមើស ដែលជាកូនអ្នកជីករ៉ែ។ តែទោះបីជាលោកគ្រូ លូធ័រ ខឹងយ៉ាងណាក៏ដោយ ក៏អ្វីដែលលោកបាននិយាយគឺត្រឹមត្រូវដែរ ព្រោះលោកគ្រូ អ៊ែរ៉ាសមើស ពិតជាស័ក្តិសមនឹងទទួលការស្ដីបន្ទោសបែបនោះមែន។ ក្នុងនាមយើងជាគ្រីស្ទបរិស័ទពិតប្រាកដ ទោះបើយើងមិនមែនជាអ្នកដឹកនាំដ៏ខ្លាំងពូកែ ឬសំខាន់ម្នាក់ក្នុងចំណោមអ្នកដឹកនាំជាគ្រីស្ទបរិស័ទ នាពេលបច្ចុប្បន្ននេះក៏ដោយ ក៏យើងត្រូវតែស្ដីបន្ទោសគ្រូអធិប្បាយភាគច្រើន និងអស់អ្នកដែលមានភាពខ្ជិលច្រអូស ជាអ្នកដែលបង្រៀនតែសេចក្ដីបង្រៀនរបស់

អ្នកដទៃ ជាជាងសិក្សាស្វែងយល់ពីសេចក្តីបង្រៀននៅក្នុងព្រះបន្ទូល ដោយខ្លួនឯងដែរ។ យើងត្រូវតែស្តីបន្ទោសពួកគេ ពីព្រោះពួកគេគិតអំពីព្រះជាម្ចាស់តាមបែបមនុស្សជាតិ។ សព្វថ្ងៃនេះ មានមនុស្សជាច្រើននៅស្ទើរគ្រប់ទីកន្លែងដែលមានគំនិតមិនគោរពដល់ព្រះជាម្ចាស់ ហើយថែមទាំងមើលងាយពីការសោយរាជ្យ និងអធិបតេយ្យភាពរបស់ទ្រង់ទៀតផង ហើយក៏មានមនុស្សជាច្រើនមិនបានដឹងថា ព្រះគម្ពីរបានរៀបរាប់ពីព្រះជាម្ចាស់យ៉ាងណានោះដែរ សូម្បីតែអ្នកដែលបានប្រកាសថាខ្លួនជាគ្រីស្ទបរិស័ទផង។

តាំងពីដើមមក ព្រះជាម្ចាស់បានស្តីបន្ទោសសាសន៍អ៊ីស្រាអែលដែលបានបែរចេញពីជំនឿ ដោយនាំគ្នាគិតថា “ឯងបានគិតស្មានថា អញដូចឯងតែប៉ុណ្ណោះ” (ទំនុកតម្កើង ៥០:២១)។ ជាមួយគ្នានេះដែរ នៅសព្វថ្ងៃនេះ ព្រះជាម្ចាស់ក៏ទាស់ប្រឆាំង និងស្តីបន្ទោសដល់គ្រីស្ទបរិស័ទដែលបានបែកចេញពីជំនឿដែរ ហើយទ្រង់រាប់ការបែកចេញនេះថាជាបទល្មើស។ មានមនុស្សជាច្រើនបានសន្មតថា ព្រះជាម្ចាស់ធ្វើអ្វីៗតាមអារម្មណ៍ជាជាងតាមគោលការណ៍របស់ទ្រង់។ ពួកគេគិតថា អំណាចព្រះចេស្តារបស់ព្រះជាម្ចាស់មិនមានប្រសិទ្ធភាពអ្វីទេ ដូច្នេះហើយបានជាអារក្សសាតាំងអាចរារាំងគ្រប់ទាំងចំណុចនៃគម្រោងការរបស់ទ្រង់បាន ហើយពួកគេគិតទៀតថា

ប្រសិនបើទ្រង់ពិតជាបានរៀបចំគម្រោងការណាមួយមែន នោះមានន័យថា គម្រោងការរបស់ទ្រង់ក៏ដូចគ្នានឹងគម្រោងការរបស់ពួកគេដែរ។ និយាយឲ្យចំទៅ គឺគម្រោងការដែលអាចប្រែប្រួលបានតាមកាលៈទេសៈ។ ពួកគេប្រកាសជាសាធារណៈថា អំណាចដែលទ្រង់មានគឺនៅមានព្រំដែននៅឡើយ។ បើទ្រង់ពិតជាមានអំណាចខ្លាំងពូកែមែន នោះមានន័យថា ទ្រង់កំពុងតែឈ្លានពានលើសិទ្ធិសេរីភាពក្នុងការជ្រើសរើសរបស់យើង ហើយក៏មានន័យថា ទ្រង់បានបង្កើតយើងមកឲ្យមានលក្ខណៈដូចជាមនុស្សយន្តដែរ។ ពួកគេបន្ទាបប្រសិទ្ធភាពនៃការប្រោសលោះរបស់ព្រះយេស៊ូវ ដែលទ្រង់បានធ្វើឡើងសម្រាប់អស់អ្នកដែលព្រះជាម្ចាស់បានជ្រើសតាំង ថាជាថ្នាំដែលមនុស្សមានបាបអាចជ្រើសរើសយកមកប្រើប្រាស់តាមដែលពួកគេត្រូវការ។ ពួកគេប្រកាសព័ន្ធកិច្ចដែលមិនចេះបរាជ័យរបស់ព្រះវិញ្ញាណបែបមិនគួរសមដោយថា ដំណឹងល្អនេះអាចទទួលយកឬបដិសេធចោលក៏បាន ពោលគឺអាចធ្វើតាមចិត្តរបស់ខ្លួនបាន។

ព្រះក្លែងក្លាយនៅសតវត្សរ៍ទី២០ មិនមានលក្ខណៈដូចជាព្រះដែលប្រកបដោយអធិបតេយ្យភាពដែលមានចែងនៅក្នុងព្រះគម្ពីរឡើយ។ បើយើងប្រៀបធៀប «ព្រះ» នៃសតវត្សរ៍នេះទៅនឹងព្រះដ៏ពិតនៃព្រះក្នុងព្រះគម្ពីរ នោះយើងនឹងឃើញថា វាហាក់បីដូចជាការ

ប្រៀបធៀបទៅនឹងភ្លើងទៀនដែលហៀបនឹងរលត់ជាមួយនឹងពន្លឺដ៏ចិញ្ចែងចិញ្ចាចនៃព្រះអាទិត្យអញ្ចឹង។ ភាគច្រើន គ្រូៗបង្រៀនដោយប្រើគំនិតរបស់ខ្លួនជាជាងពឹងលើគំនិតដែលមាននៅក្នុងព្រះគម្ពីរ នៅពេលដែលពួកគាត់អធិប្បាយអំពីព្រះ បង្រៀនអំពីទ្រង់នៅសាលាថ្ងៃអាទិត្យ ឬក៏និពន្ធសៀវភៅផ្សេងៗអំពីទ្រង់ ក៏ដូចជាបង្រៀនក្នុងសិក្ខាសាលាផងដែរ។ អ្នកមិនជឿនាំគ្នាបង្កើតព្រះចេញពីដើមឈើ និងពីថ្ម ហើយចំពោះគ្រីស្ទបរិស័ទដែលគ្រាន់តែរាប់ខ្លួនឯងថាជាអ្នកជឿវិញ ពួកគេក៏បានបង្កើតព្រះចេញពីគំនិតបែបលោកីយ៍ដែរ ព្រោះពួកគេពឹងលើគំនិតខ្លួនឯង។ ចំណុចដ៏ពិតដែលយើងអាចលើកឡើងនោះគឺថា ទាំងអ្នកមិនជឿ និងគ្រីស្ទបរិស័ទដែលគ្រាន់តែរាប់ខ្លួនឯងថាជាអ្នកជឿ គឺជាអ្នកដែលជឿថា មិនមានព្រះ ពីព្រោះគ្មានជម្រើសណាផ្សេងទៀតរវាងការជឿថា មានព្រះដ៏ឧត្ដុង្គឧត្ដមដែលសោយរាជ្យ និងគំនិតដែលថា គ្មានព្រះទាល់តែសោះនោះទេ។ ព្រះដែលមនុស្សអាចរារាំងព្រះហឫទ័យបាន ព្រះដែលមនុស្សអាចបង្អាក់គម្រោងការបាន និងព្រះដែលមនុស្សអាចយកឈ្នះលើគោលបំណងបាន គឺមិនមែនជាព្រះដ៏ពិតទេ ហើយព្រះនោះក៏មិនស័ក្តិសមនឹងទទួលការថ្វាយបង្គំពីមនុស្សដែរ ប៉ុន្តែគឺជាព្រះដែលស័ក្តិសមនឹងឲ្យមនុស្សមើលងាយទៅវិញទេតើ។

# ស្តេចលើអស់ទាំងស្តេច និងព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់

ចំពោះភាពឧត្តុង្គឧត្តមក្រៃលែងនៃព្រះដ៏ពិត និងមានព្រះជន្មគង់នៅវិញ គឺយើងអាចវែកញែកគន្លងដ៏គ្មានព្រំដែនរវាងសត្វដ៏ខ្លាំងបំផុត និងព្រះដ៏ខ្លាំងបំផុត។ ព្រះជាម្ចាស់ជាជាងស្មូន ហើយមនុស្សជាដីឥដ្ឋដែលកំពុងស្ថិតក្នុងព្រះហស្តទ្រង់។ ព្រះអង្គធ្វើការសម្រេចតាមព្រះទ័យរបស់ទ្រង់ ព្រះអង្គសព្វព្រះហឫទ័យសូនពួកគេឲ្យទៅជាភាជនៈដែលមានកិត្តិយស ឬក៏ជាភាជនៈដែលគេយកទៅបោកចោលក៏បាន (ទំនុកតម្កើង ២:៩)។ ទោះបីជាគ្រប់អ្វីៗទាំងអស់នៅស្ថានសួគ៌ និងនៅផែនដីប្រមូលផ្តុំគ្នា ដើម្បីប្រឆាំងនឹងព្រះជាម្ចាស់ក៏ដោយ ក៏មិនអាចធ្វើឲ្យទ្រង់មានភាពមិនស្រុះស្រួល ឬក៏បន្ទាបភាពអស់កល្បជានិច្ចរបស់ទ្រង់បានឡើយ ហើយការនោះក៏មិនអាចយកឈ្នះលើរាជ្យរបស់ទ្រង់បានដែរ។ វាប្រៀបដូចជារលកសមុទ្រមេឌីទែរ៉ាណេ (Mediterranean) ដែលមិនអាចយកឈ្នះលើផ្ទាំងសិលាហ្គីប្រាល់តាយ៉ាងដូច្នោះដែរ (Gibraltar)។ ការដែលរបស់សព្វសារពើទាស់ប្រឆាំងនឹងព្រះដ៏ជាព្រះ ប្រៀបដូចជាកូនក្មេងដ៏ទន់ខ្សោយម្នាក់ចង់មកវាយជាមួយនឹងមនុស្សដ៏ខ្លាំងពូកែម្នាក់។ ព្រះគម្ពីរបានចែងថា នៅពេលដែលពួកមហាក្សត្រនៅផែនដីរួមគ្នាជាមួយនឹង

សាសន៍អ៊ីស្រាអែលដែលបានធ្លាក់ក្នុងអំពើបាប មកទាស់ប្រឆាំងនឹងព្រះជាម្ចាស់ ក៏ដូចជាព្រះរាជ្យបុត្រារបស់ទ្រង់ ពេលនោះ «ព្រះដែលគង់នៅស្ថានសួគ៌ ទ្រង់នឹងសើច» ដាក់គេ (ទំនុកតម្កើង ២:៤)។

ព្រះគម្ពីរបានអះអាងពីភាពឧត្តុង្គឧត្តមក្រៃលែងរបស់ព្រះជាម្ចាស់យ៉ាងច្បាស់លាស់។ សូមអានកណ្ឌគម្ពីរ ១របាក្សត្រ ២៩:១១-១២ «ឱព្រះយេហូវ៉ាអើយ ភាពដ៏ធំនិងព្រះចេស្ដា សិរីល្អ ជ័យជម្នះ និងតេជានុភាព នោះសុទ្ធតែជារបស់ផងទ្រង់ ដ្បិតគ្រប់ទាំងអស់ដែលនៅលើមេឃ និងនៅផែនដី ជារបស់ផងទ្រង់ ឱព្រះយេហូវ៉ាអើយ រាជ្យនេះក៏ជារបស់ផងទ្រង់ដែរ ហើយទ្រង់បានតម្កើងឡើង ជាប្រធានលើទាំងអស់...ហើយគឺទ្រង់ដែលគ្រប់គ្រងលើទាំងអស់...»។ សូមកត់សម្គាល់ពីការដែលថា ឥឡូវនេះ ទ្រង់កំពុងគ្រប់គ្រង មិនមែននៅពេលអនាគតក្នុងគ្រាមួយពាន់ឆ្នាំនោះទេ។ កណ្ឌគម្ពីរ ២របាក្សត្រ ២០:៦ ក៏បានចែងដែរថា «ឱព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោយើងខ្ញុំរាល់គ្នាអើយ តើទ្រង់មិនមែនជាព្រះនៅស្ថានសួគ៌ទេឬអី តើទ្រង់មិនគ្រប់គ្រងលើអស់ទាំងនគររបស់សាសន៍ដទៃទេឬអី ហើយនៅព្រះហស្តទ្រង់ នោះក៏មានព្រះចេស្ដា និងឥទ្ធិឫទ្ធិដែរ ដល់ម៉្លេះបានជាគ្មានអ្នកណា អាចនឹងទប់ទល់នឹងទ្រង់បានឡើយ»។ បើប្រៀបធៀបប្រធានាធិបតី សម្ដេចប៉ាប ឬស្ដេច ឬក៏អធិរាជលើផែនដីនេះ

ទៅនឹងព្រះជាម្ចាស់ ពួកគេប្រៀបដូចជាសត្វកណ្ដូបប៉ុណ្ណោះ។

កណ្ឌគម្ពីរ យ៉ូប ២៣:១៣ ក៏បានចែងដែរថា «ទ្រង់មានគំនិតតែ១ តើអ្នកណានឹងបំផ្លាស់បំប្រែព្រះហឫទ័យទ្រង់បាន ការអ្វីដែលទ្រង់ចង់ធ្វើ នោះក៏ធ្វើទៅ»។ ឱមិត្តអ្នកអានរាល់គ្នាអើយ! ព្រះនៃព្រះគម្ពីរមិនមែនជាព្រះដែលមនុស្សបង្កើតមកទេ ហើយក៏មិនមែនជាព្រះដែលចេញពីគំនិតរបស់មនុស្សដែរ ប៉ុន្តែទ្រង់គឺជាស្តេចលើអស់ទាំងស្តេច និងជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់។ នេះជាអត្ថន័យនៃព្រះបន្ទូលនៅក្នុងកណ្ឌគម្ពីរ យ៉ូប ៤២:៣ ដែលថា «ទូលបង្គំបានយល់ហើយថា ទ្រង់អាចធ្វើគ្រប់អ្វីៗទាំងអស់បាន ហើយគ្មានអ្វីអាចរារាំងព្រះតម្រិះ ឬក៏គោលបំណងរបស់ទ្រង់បានឡើយ»។ គ្រប់អ្វីៗទាំងអស់ដែលទ្រង់ព្រះតម្រិះ ទ្រង់នឹងធ្វើសម្រេច។ កណ្ឌគម្ពីរ ទំនុកតម្កើង ១១៥:៣ បានលើកឡើងថា «ចំណែកព្រះនៃយើងខ្ញុំ ទ្រង់គង់នៅស្ថានសួគ៌ ទ្រង់បានធ្វើការដែលគាប់ដល់ព្រះហឫទ័យទ្រង់ហើយ»។ ហេតុអ្វីបានជាទ្រង់ធ្វើដូច្នេះ? ពីព្រោះ «គ្មានប្រាជ្ញាណា គ្មានយោបល់ណា ឬការប្រឹក្សាណា ដែលអាចទាស់នឹងព្រះយេហូវ៉ាបានឡើយ» (សុភាសិត ២១:៣០)។

## អ្វីដែលគាប់ដល់ព្រះហឫទ័យទ្រង់

ព្រះគម្ពីរបានបង្ហាញពីអស់ទាំងស្នាព្រះហស្តទ្រង់ ដែលទាក់ទងនឹងភាពឧត្តុង្គឧត្តមក្រៃលែងរបស់ទ្រង់យ៉ាងច្បាស់។ ទោះជារបស់ដែលគ្មានជីវិត និងសត្វដែលខ្វះវិចារណញ្ញាណទាំងអស់ក៏ធ្វើតាមព្រះហឫទ័យរបស់ទ្រង់ដែរ។ ទោះជាសមុទ្រក្រហមក៏ធ្វើតាមព្រះហឫទ័យទ្រង់ដែរ នៅពេលដែលទ្រង់បង្គាប់សមុទ្រនោះឲ្យញែកជាពីរ ហើយឲ្យឈរនឹងថ្កល់ជាជញ្ជាំង (និក្ខមនំ ១៤)។ នៅពេលដែលទ្រង់បង្គាប់ឲ្យផែនដីបើកមាត់លេបត្របាក់អស់ពួកអ្នកបះបោរ នោះផែនដីក៏ធ្វើតាមព្រះហឫទ័យរបស់ទ្រង់ (ជនគណនា ១៤) ហើយសូម្បីតែព្រះអាទិត្យក៏ឈរនៅនឹងមួយកន្លែង តាមបញ្ជារបស់ទ្រង់ដែរ (យ៉ូស្វេ ១០)។ ហើយក៏មានពេលមួយទៀតដែរ ព្រះជាម្ចាស់បានធ្វើឲ្យព្រះអាទិត្យថយក្រោយដប់ជំហានតាមការស្នើសុំរបស់ស្ដេច អ័ហាស (អេសាយ ៣៨:៨)។ ដើម្បីបើកសម្ដែងពីភាពឧត្តុង្គឧត្តមរបស់ព្រះជាម្ចាស់ ទ្រង់បានបង្គាប់ឲ្យសត្វក្អែកពាំនំប៉័ង និងសាច់មកជូនលោក អេលីយ៉ា (១ពង្សាវតារក្សត្រ ១៧) ទ្រង់បានធ្វើឲ្យផ្លែពូថៅដែលធ្លាក់ក្នុងទឹកអណ្ដែតឡើងមកវិញ (២ពង្សាវតារក្សត្រ ៦:៥) ទ្រង់បានធ្វើឲ្យសត្វសិង្ហនៅក្នុងរូងដែលស្ដេច ដារីយុស បានបោះលោក ដានីយ៉ែល ចូលទៅនោះ ប្រែក្លាយ

ជាស្លូត ហើយទ្រង់ក៏បានការពារលោក សាដ្រាក់ លោក មែសាក់ និងលោក អ័បេឌ-នេកោ មិនឲ្យរលាកភ្លើងផងដែរ។ ហេតុដូច្នេះ «ការអ្វីក៏ដោយ ដែលព្រះយេហូវ៉ាសព្វព្រះហឫទ័យចង់ធ្វើ នោះក៏បានធ្វើទៅ ទាំងនៅលើមេឃ នៅផែនដី នៅក្នុងសមុទ្រ ហើយនៅទីជម្រៅទាំងប៉ុន្មានផង» (ទំនុកតម្កើង ១៣៥:៦)។

ព្រះជាម្ចាស់ក៏បានបង្ហាញពីភាពឧត្តុង្គឧត្តមរបស់ទ្រង់ តាមរយៈការដែលទ្រង់សោយរាជ្យដ៏គ្រប់លក្ខណ៍លើការសម្រេចចិត្តរបស់មនុស្សដែរ។ ចូរសញ្ជឹងគិតពីកណ្ឌគម្ពីរ និក្ខមនំ ៣៤:២៤ ដោយយកចិត្តទុកដាក់ [«ដ្បិតអញនឹងបណ្តេញអស់ទាំងសាសន៍ដទៃពីមុខឯងចេញ ហើយនឹងវាតព្រំស្រុករបស់ឯងឲ្យធំទូលាយឡើង កាលណាឯងឡើងមកនៅចំពោះព្រះយេហូវ៉ាជាព្រះនៃឯង៣ដងក្នុង១ឆ្នាំ នោះនឹងគ្មានអ្នកណាលោភចង់បានស្រុករបស់ឯងឡើយ»។] ព្រះជាម្ចាស់តម្រូវឲ្យប្រុសៗនៃសាសន៍អ៊ីស្រាអែលចាកចេញពីផ្ទះរបស់ពួកគេបីដងក្នុងមួយឆ្នាំ ហើយធ្វើដំណើរទៅក្រុងយេរូសាឡឹម។ សាសន៍អ៊ីស្រាអែលរស់នៅកណ្តាលចំណោមខ្មាំងសត្រូវរបស់ខ្លួន ហើយអ្នកទាំងនោះក៏ស្អប់ពួកគេដែរ ពីព្រោះអ៊ីស្រាអែលបានយកទឹកដីរបស់ពួកគេ។ ដូច្នេះ ប្រសិនបើសាសន៍កាណានឆ្លៀតឱកាសដើម្បីសម្លាប់ស្ត្រីៗ និងក្មេងៗ ហើយយករបស់របរពីកសិដ្ឋានរបស់

ពួកអ៊ីស្រាអែលនៅពេលដែលពួកប្រុសៗមិននៅផ្ទះ គឺជាការងាយស្រួលណាស់។ ប្រសិនបើព្រះហស្តដ៏ឧត្តុង្គឧត្តមរបស់ព្រះជាម្ចាស់គ្មានអំណាចលើឆន្ទៈរបស់មនុស្សអាក្រក់ទេនោះ ទ្រង់ក៏មិនអាចសន្យាបានថា គ្មានអ្នកណាអាចដណ្តើមយកទឹកដីរបស់អ៊ីស្រាអែលបានដែរ។ កណ្ឌគម្ពីរ សុភាសិត ២១:១ បានចែងថា «ព្រះទ័យនៃស្តេច នោះនៅក្នុងព្រះហស្តព្រះយេហូវ៉ា ដូចជាផ្លូវនៃទឹកហូរទាំងឡាយ ទ្រង់ឲ្យបែរហូរទៅខាងណាក៏តាមតែព្រះហឫទ័យ»។

ប៉ុន្តែ ប្រហែលជានឹងមានមនុស្សមួយចំនួនជំទាស់ថា តើខគម្ពីរខាងលើនេះមិនបានឯកភាពនឹងអ្វីដែលយើងបានអានម្តងហើយម្តងទៀតនៅក្នុងព្រះគម្ពីរ អំពីការដែលមនុស្សបានមើលងាយព្រះជាម្ចាស់ បដិសេធព្រះហឫទ័យទ្រង់ ហើយមិនស្តាប់តាមបញ្ញត្តិទ្រង់ និងមិនព្រមស្តាប់ការព្រមានរបស់ទ្រង់ ព្រមទាំងការកែតម្រូវរបស់ទ្រង់ទេឬអី? ប្រាកដណាស់! យើងពិតជាបានអានការទាំងអស់នោះមែន។ ចុះតើការនេះមិនបានបដិសេធទៅនឹងអ្វីៗដែលយើងបានរៀបរាប់ទេឬអី? ប្រសិនបើការនេះពិតជាបដិសេធមែននោះមានន័យថា ព្រះគម្ពីរនិយាយទាស់នឹងខ្លួនឯងហើយ។ ប៉ុន្តែការនេះមិនអាចទៅរួចនោះទេ។ ចំណុចដែលអ្នកជំទាស់លើកឡើងនោះគឺថា អំពើអាក្រក់របស់មនុស្សអាក្រក់ទាស់នឹងព្រះបន្ទូលដែល

មិនមាននៅក្នុងព្រះគម្ពីរ ប៉ុន្តែអ្វីដែលយើងបានរៀបរាប់នៅខាងលើ គឺអំពីការដែលព្រះជាម្ចាស់បានគ្រោងទុកនៅក្នុងរូបអង្គទ្រង់ផ្ទាល់វិញទេតើ។ ក្នុងចំណោមយើងរាល់គ្នា គ្មានអ្នកណាម្នាក់អាចបំពេញតាមបទបញ្ញត្តិដែលព្រះជាម្ចាស់បានប្រទានឲ្យយើងរស់នៅតាមនោះឡើយ។ នៅពេលដែលព្រះជាម្ចាស់សម្រេចតាមព្រះតម្រិះដ៏អស់កល្បរបស់ទ្រង់ គឺទ្រង់បានធ្វើការនោះយ៉ាងល្អិតល្អន់។

ព្រះគម្ពីរសញ្ញាថ្មីក៏បានអះអាងអំពីភាពដ៏ឧត្តុង្គឧត្តមរបស់ព្រះជាម្ចាស់យ៉ាងច្បាស់ ដូចនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែរ។ កណ្ឌគម្ពីរ អេភេសូរ ១:១១ បានចែងថា ព្រះជាម្ចាស់ «ធ្វើឲ្យគ្រប់ការទាំងអស់បានសម្រេច ស្របតាមព្រះហឫទ័យរបស់ព្រះអង្គ» (គកស)។ នៅក្នុងភាសាក្រិក ពាក្យ «ធ្វើ» បង្កប់អត្ថន័យ «ធ្វើដោយអំណាច»។ ហេតុដូច្នេះហើយ បានជាយើងអាននៅក្នុងកណ្ឌគម្ពីរ រ៉ូម ១១:៣៦ ថា «ដ្បិតរបស់សព្វសារពើបានកើតមកពីទ្រង់ ដោយសារទ្រង់ ហើយសម្រាប់ទ្រង់ សូមឲ្យទ្រង់បានសិរីល្អនៅអស់កល្បជានិច្ច អាម៉ែន»។ មនុស្សមួយចំនួនប្រហែលជានឹងអួតខ្លួនឯងថា ពួកគេជាមនុស្សដែលមានសេរីភាព ជាមនុស្សដែលមានឆន្ទៈផ្ទាល់ខ្លួន ហើយពួកគេក៏មានសេរីភាពក្នុងការធ្វើអ្វីតាមតែចិត្តរបស់ខ្លួនដែរ នៅពេលដែលគេចង់ធ្វើ ប៉ុន្តែព្រះគម្ពីរបានមានបន្ទូលទៅអស់អ្នកដែលអួត

ខ្លួនឯងទាំងនោះថា “ថ្ងៃនេះ ឬថ្ងៃស្អែក យើងនឹងធ្វើដំណើរទៅក្រុងមួយ ហើយស្នាក់នៅក្រុងនោះមួយឆ្នាំ ដើម្បីនឹងរកស៊ីឲ្យបានចំណេញ...ផ្ទុយទៅវិញអ្នករាល់គ្នាគួរតែនិយាយថា បើព្រះអម្ចាស់សព្វព្រះហឫទ័យ” យើងនឹងទៅនេះទៅនោះ(យ៉ាកុប៤:១៣, ១៥ គកស)។

នេះជាទស្សនៈដែលជួយឲ្យចិត្តគំនិតរបស់យើងបានសម្រាកពិតប្រាកដ។ ជីវិតរបស់យើងមិនមែនកើតមកពីព្រេងវាសនា ឬព្រហ្មលិខិតដែលគ្មានអ្នកណាអាចមើលឃើញនោះទេ ហើយជីវិតរបស់យើងក៏មិនមែនកើតមកពីការផ្សងសំណាងដែលមានការផ្លាស់ប្រែឥតឈប់ឈរនោះដែរ ប៉ុន្តែផ្ទុយទៅវិញ គ្រប់អ្វីៗទាំងអស់ក្នុងជីវិតរបស់យើង កើតមកតាមការគ្រោងទុករបស់ព្រះជាម្ចាស់ ដែលមានតាំងពីអស់កល្បរៀងមក។ ឥឡូវនេះ គ្រប់អ្វីៗទាំងអស់ក៏កំពុងតែកើតឡើងក្រោមការសោយរាជ្យរបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ផងដែរ។ គ្មានអ្នកណាម្នាក់ ឬក៏អ្វីមួយអាចធ្វើឲ្យសក់លើក្បាលរបស់យើងជ្រុះបានឡើយ លុះត្រាតែព្រះជាម្ចាស់អនុញ្ញាត។ កណ្ឌគម្ពីរ សុភាសិត ១៦:៩ បានចែងថា “មនុស្សគិតគូរពីផ្លូវដែលខ្លួនត្រូវដើរ តែព្រះអម្ចាស់ជាអ្នកណែនាំផ្លូវ” (គខប)។ ខគម្ពីរនេះគួរតែផ្តល់ទំនុកចិត្ត កម្លាំង និងការកំសាន្តចិត្តដល់គ្រីស្ទបរិស័ទពិតប្រាកដ។

«ឯថ្ងៃអាយុរបស់ទូលបង្គំ សុទ្ធតែនៅក្នុងព្រះហស្តទ្រង់» (ទំនុកតម្កើង ៣១:១៥)។ ដូច្នេះព្រលឹង របស់ ខ្ញុំ អើយ «ចូរ ស្ងៀម នៅ ចំពោះ ព្រះយេហូវ៉ា ហើយរង់ចាំទ្រង់ចុះ» (ទំនុកតម្កើង ៣៧:៧)។

ជំពូកទី៦

# ព្រះដ៏មានអធិបតេយ្យភាព

យើងអាចពន្យល់ពីអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ថា ជាការដែលទ្រង់អនុវត្តភាពដ៏ឧត្តុង្គឧត្តមរបស់ទ្រង់។ [យោងតាមសម្តេចព្រះសង្ឃរាជ ជួន ណាត លោកបានពណ៌នាថា “អធិបតេយ្យភាព” មានន័យថា “សិទ្ធិអំណាចគ្រប់បែបយ៉ាង”]។ នេះមានន័យថា ព្រះជាម្ចាស់ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តមជាងគេទាំងអស់ ហើយគ្មានខ្នាតណាមួយដែលអាចវាស់វែងពីភាពដ៏ខ្ពង់ខ្ពស់របស់ទ្រង់បានឡើយ។ ទ្រង់ជាព្រះដែលខ្ពស់ជាងគេបង្អស់ ហើយទ្រង់ក៏ជាព្រះអម្ចាស់នៃស្ថានសួគ៌ និងផែនដីដែរ។ នៅលើពិភពលោកនេះ គ្មានបុគ្គលណាម្នាក់ដែលអាចឲ្យព្រះជាម្ចាស់ចុះចូលជាមួយបានឡើយ ហើយក៏គ្មានបុគ្គលណាម្នាក់អាចជះឥទ្ធិពលលើទ្រង់បានដែរ។ ទ្រង់មិនចាំបាច់ពឹងលើបុគ្គលណាម្នាក់ទេ ដ្បិតទ្រង់ជាព្រះដែលមានឯករាជ្យភាព។ ព្រះជាម្ចាស់ធ្វើគ្រប់ការទាំងអស់តាមដែលទ្រង់សព្វព្រះហឫទ័យ ហើយគ្មានអ្នកណាម្នាក់អាចបញ្ឈប់ ឬបង្អាក់ទ្រង់បានឡើយ។ យើង

អាចមើលឃើញការពិតនេះនៅក្នុងកណ្ឌគម្ពីរ អេសាយ ៤៦:១០ ដែលបានចែងថា «គំនិតសម្រេចរបស់អញនឹងស្ថិតស្ថេរនៅ អញនឹងធ្វើតាមបំណងចិត្តអញគ្រប់ប្រការ»។ កណ្ឌគម្ពីរ ដានីយ៉ែល ៤:៣៥ ក៏បានចែងផងដែរថា «ទ្រង់ធ្វើតាមតែព្រះហឫទ័យក្នុងពួកពលបរិវារនៃស្ថានសួគ៌ ហើយនៅកណ្ដាលពួកមនុស្សលោកផង ឥតមានអ្នកណាអាចនឹងឃាត់ទប់ព្រះហស្តទ្រង់ ឬនឹងទូលសួរទ្រង់ថា ទ្រង់ធ្វើអ្វីដូច្នេះបានឡើយ»។ ចំណុចដែលថា ទ្រង់ជាព្រះប្រកបដោយអធិបតេយ្យភាព មានន័យថាព្រះអង្គគឺជាព្រះដ៏ពិត មិនមែនគ្រាន់តែមានតែព្រះនាមនោះទេ។ ទ្រង់ជាព្រះដែលសោយរាជ្យលើចក្រវាលទាំងមូល ជាព្រះដែលត្រួតត្រា និងចាត់ចែងលើគ្រប់អ្វីៗទាំងអស់ «តាមដែលគាប់ព្រះហឫទ័យទ្រង់» (អេភេសូរ ១:១១)។

លោកគ្រូ ស៊ី. អេឆ. ស្ពើចិន (C. H. Spurgeon) បានលើកឡើងយ៉ាងត្រឹមត្រូវនៅក្នុងសេចក្ដីអធិប្បាយរបស់គាត់អំពីកណ្ឌគម្ពីរ ម៉ាថាយ ២០:១៥៖

«គ្មានលក្ខណសម្បត្តិណាមួយដែលអាចលួងលោមចិត្តបុត្រាបុត្រីរបស់ព្រះជាម្ចាស់ជាងលក្ខណសម្បត្តិដែលថា ទ្រង់ជាព្រះដែលប្រកបដោយអធិបតេយ្យភាពបាននោះឡើយ។ ទោះបីជាស្ថិតនៅក្នុងកាលៈទេសៈអវិជ្ជមាន ឬទុក្ខលំបាកបែបណាក៏ដោយ

ក៏គ្រីស្ទបរិស័ទពិតប្រាកដជឿថា ព្រះដែលប្រកបដោយអធិបតេយ្យភាព ជាព្រះដែលបានគ្រោងទុកនូវទុក្ខលំបាកនោះសម្រាប់ពួកគេ ទ្រង់ជាព្រះដែលគ្រប់គ្រងលើផែនការរបស់ពួកគេ ហើយទ្រង់ក៏ជាព្រះដែលនឹងញែកពួកគេចេញទុកជាបរិសុទ្ធដែរ។ គ្មានគោលលទ្ធិណាលើសជាងគោលលទ្ធិដែលថា ព្រះអម្ចាស់ជាព្រះលើគ្រប់អ្វីៗទាំងអស់ ដែលបុត្រាបុត្រីទ្រង់ត្រូវតែទទួលស្គាល់នោះឡើយ។ ពួកគេក៏ត្រូវតែទទួលស្គាល់ផងដែរថា ព្រះជាម្ចាស់គ្រងរាជ្យលើគ្រប់របស់ទាំងអស់ដែលជាស្នាព្រះហស្តទ្រង់ ហើយថាទ្រង់មានសិទ្ធិអំណាចគ្រប់បែបយ៉ាងក្នុងការដែលទ្រង់សោយរាជ្យលើបល្ល័ង្ករបស់ទ្រង់។ ម៉្យាងវិញទៀត គោលលទ្ធិដែលថា ព្រះដ៏មានអធិបតេយ្យភាព គឺជាគោលលទ្ធិដែលលោកីយ៍នេះស្អប់ខ្ពើមជាងគេបំផុត។ មនុស្សនឹងអនុញ្ញាតឲ្យព្រះជាម្ចាស់គង់នៅគ្រប់ទីកន្លែង លើកលែងតែធ្វើជាស្ដេចគ្រងលើបល្ល័ង្ករបស់ទ្រង់។ ពួកគេនឹងអនុញ្ញាតឲ្យទ្រង់គង់នៅក្នុងរោងជាងរបស់ទ្រង់ ដើម្បីបង្កើតពិភពលោក និងផ្កាយទាំងឡាយ។ ពួកគេនឹងអនុញ្ញាតឲ្យទ្រង់គង់នៅក្នុងរោងចក្រផលិតអាវុធរបស់ទ្រង់ ដើម្បីចែកចាយអាវុធ និងអំណោយរបស់ទ្រង់។ ប៉ុន្តែ នៅពេលដែលព្រះអង្គឡើងសោយរាជ្យជាស្ដេចលើបល្ល័ង្ករបស់ទ្រង់នោះពួកគេនឹងសង្កៀតធ្មេញ ហើយបះបោរទាស់ប្រឆាំងនឹងទ្រង់ជា

មិនខាន។ នៅពេលដែលយើងអភិសេកទ្រង់ឲ្យគង់លើបល្ល័ង្ករបស់ទ្រង់ ទាំងទទួលស្គាល់ថា ទ្រង់មានសិទ្ធិគ្រប់បែបយ៉ាងចំពោះអ្វីៗដែលទ្រង់បានបង្កើត ពោលគឺទ្រង់ចង់ធ្វើអ្វី និងព្រះតម្រិះអ្វីក៏បានដោយមិនចាំបាច់ប្រឹក្សាជាមួយយើង នោះលោកីយ៍នឹងស្រែកប្រឆាំងចំពោះទ្រង់។ លោកីយ៍នឹងមិនស្តាប់យើងឡើយ ដ្បិតទ្រង់មិនមែនជាព្រះដែលពួកគេស្រឡាញ់នោះទេ។ ទោះជាយ៉ាងណាក៏ដោយក៏ព្រះជាម្ចាស់ដែលគង់លើបល្ល័ង្ក នៅតែជាព្រះដែលយើងចូលចិត្តអធិប្បាយអំពីទ្រង់ ហើយក៏ជាព្រះដែលយើងទុកចិត្តលើផងដែរ»។

កណ្ឌគម្ពីរ ទំនុកតម្កើង ១៣៥:៦ បានចែងថា «ការអ្វីក៏ដោយដែលព្រះយេហូវ៉ាសព្វព្រះហឫទ័យចង់ធ្វើ នោះក៏បានធ្វើទៅ ទាំងនៅលើមេឃ នៅផែនដី នៅក្នុងសមុទ្រ ហើយនៅទីជម្រៅទាំងប៉ុន្មានផង»។ ឱមិត្តអ្នកអានរាល់គ្នាអើយ! ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ថា ព្រះជាម្ចាស់នៃយើង គឺជាព្រះមហាក្សត្រដែលកំពុងគ្រងរាជ្យ។ គ្មានអ្វីដែលអាចប្រៀបផ្ទឹមនឹងអានុភាពដ៏អស្ចារ្យរបស់ទ្រង់បានឡើយ។ ទ្រង់មានអំណាចឥតព្រំដែន ហើយក៏គ្មានអ្វីដែលអាចជះឥទ្ធិពលលើទ្រង់បានដែរ។ សព្វថ្ងៃនេះ យើងរស់នៅក្នុងសម័យកាលមួយ ដែលសូម្បីតែអ្នកជឿពិតប្រាកដខ្លះក៏មិនហ៊ានអះអាងថាព្រះជាម្ចាស់គឺជាព្រះដ៏ពិតដែរ។ ពួកគេប្រកាសថា បើយើងអះអាង

បែបនោះ មានន័យថាយើងមិនទទួលស្គាល់ថា មនុស្សយើងមានទំនួលខុសត្រូវទេ។ ប៉ុន្តែ ពួកគេភ្លេចថា ទំនួលខុសត្រូវរបស់មនុស្ស គឺពឹងផ្អែកលើអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ ហើយពួកគេក៏ភ្លេចថា ទំនួលខុសត្រូវរបស់មនុស្ស គឺជាលទ្ធផលនៃអធិបតេយ្យភាពរបស់ទ្រង់ផងដែរ។

## ទំនួលខុសត្រូវរបស់មនុស្ស និងអធិបតេយ្យភាព របស់ព្រះជាម្ចាស់

ទំនុកតម្កើង ១១៥:៣ បានចែងថា “ចំណែកព្រះនៃយើងខ្ញុំ ទ្រង់គង់នៅស្ថានសួគ៌ ទ្រង់បានធ្វើការដែលគាប់ដល់ព្រះហឫទ័យទ្រង់ហើយ”។ ព្រះនៃយើងដែលប្រកបដោយអធិបតេយ្យភាព ទ្រង់បានគ្រោងទុកនូវអ្វីៗទាំងអស់ដែលទ្រង់បានបង្កើតមកឲ្យស្ថិតនៅតាមកាលៈទេសៈ ហើយរបស់ទាំងអស់នោះកើតមានឡើងតាមព្រះតម្រិះរបស់ទ្រង់ដែលទ្រង់សព្វព្រះហឫទ័យ។ ទ្រង់បានបង្កើតទេវតាខ្លះឲ្យមានសេរីភាពនៅក្នុងឆន្ទៈរបស់ខ្លួន ហើយទ្រង់ក៏បានបង្កើតទេវតាខ្លះដែលមិនមានឆន្ទៈក្នុងការជ្រើសរើសដែរ ដែលនេះមានន័យថា ពួកគេយកព្រះគ្រីស្ទធ្វើជាសិរសារបស់ពួកគេ (១ធីម៉ូថេ ៥:២១; កូឡូស ២:១០)។ សូមកុំភ្លេចថា ទាំងពួកទេវតាដែលបានប្រព្រឹត្តអំពើបាប

និងពួកទេវតាដែលមិនបានប្រព្រឹត្តអំពើបាប គឺសុទ្ធតែជាទេវតារបស់ព្រះជាម្ចាស់ (២ពេត្រុស ២:៥)។ ទោះបីជាព្រះជាម្ចាស់ជ្រាបជាមុនថា ពួកគេនឹងធ្លាក់ក្នុងអំពើបាបក៏ដោយ ក៏ទ្រង់នៅតែបង្កើតពួកគេមកឲ្យមានឆន្ទៈដែលអាចធ្វើការជ្រើសរើស និងបានអនុញ្ញាតឲ្យពួកគេធ្លាក់ក្នុងអំពើបាបដែរ ប៉ុន្តែសូមកុំច្រឡំថា ទ្រង់ជាព្រះដែលបានតាក់តែងបាបរបស់ពួកគេនោះឡើយ។

ដូចគ្នានេះដែរ ព្រះជាម្ចាស់ដែលប្រកបដោយអធិបតេយ្យភាពក៏បានដាក់ឲ្យលោក អ័ដាម រស់នៅក្នុងសួនច្បារអេដែនដែរ ហើយទ្រង់បានប្រទានឲ្យគាត់មានឆន្ទៈក្នុងការជ្រើសរើសដោយខ្លួនឯង។ ម្យ៉ាងវិញទៀត ប្រសិនបើទ្រង់សព្វព្រះហឫទ័យ នោះទ្រង់ក៏អាចបង្កើតលោក អ័ដាម មកមិនមានឆន្ទៈក្នុងការជ្រើសរើសដោយខ្លួនឯងដែរ។ ប្រាកដណាស់ថា ទ្រង់ក៏អាចបង្កើតលោក អ័ដាម មកឲ្យមានលក្ខណៈដូចជាពួកទេវតាដែលមិនបានធ្លាក់ក្នុងអំពើបាបដែរ ហើយប្រសិនបើទ្រង់សព្វព្រះហឫទ័យ នោះទ្រង់ក៏អាចបង្កើតលោក អ័ដាម មកឲ្យមានទំនុកចិត្តដែលមិនចេះប្រែប្រួលដូចជាពួកបរិសុទ្ធរបស់ព្រះគ្រីស្ទ ដែលមានចិត្តស្មោះចំពោះទ្រង់ដែរ។ ប៉ុន្តែ ផ្ទុយទៅវិញ ទ្រង់បានសម្រេចព្រះហឫទ័យដាក់លោក អ័ដាម នៅក្នុងសួនច្បារអេដែន ឲ្យគាត់រស់នៅតាមលក្ខណៈដែលមានការទទួលខុស

ត្រូវបែបមនុស្សលោក ដើម្បីឲ្យដឹងថា តើគាត់នឹងនៅតែឈររឹងមាំចំពោះព្រះ ឬក៏ធ្លាក់ក្នុងអំពើបាប ទៅតាមការដែលគាត់ជ្រើសរើសស្ដាប់បង្គាប់ ឬក៏មិនស្ដាប់បង្គាប់ទ្រង់ដែលជាព្រះអាទិករ។ លោក អ័ដាម ត្រូវទទួលខុសត្រូវចំពោះបញ្ញត្តិដែលព្រះអាទិករបានប្រទានឲ្យគាត់។ លោក អ័ដាម មានទំនួលខុសត្រូវមួយដែលស្រាល ហើយព្រះជាម្ចាស់ក៏បានល្បងលគាត់ក្នុងកាលៈទេសៈមួយដែលគាត់មិនគួរងាយនឹងធ្លាក់ចុះបែបនេះដែរ។

ព្រះជាម្ចាស់មិនមែនបង្កើតលោក អ័ដាម មកឲ្យមានឆន្ទៈក្នុងការជ្រើសរើស និងឲ្យមានទំនួលខុសត្រូវ ដោយសារតែនោះជារឿងដ៏ត្រឹមត្រូវដែលទ្រង់គួរធ្វើនោះទេ ប៉ុន្តែវាជារឿងត្រឹមត្រូវ ដោយព្រោះតែព្រះជាម្ចាស់ជាអ្នកដែលធ្វើរឿងនោះ។ ព្រះជាម្ចាស់មិនបានប្រទានគ្រប់អ្វីៗទាំងអស់ដែលទ្រង់បានបង្កើតមក ដោយសារតែនោះជារឿងដ៏ត្រឹមត្រូវដែលទ្រង់ត្រូវធ្វើ ឬក៏ត្រូវបង្កើតនោះទេ ប៉ុន្តែនោះជារឿងត្រឹមត្រូវ ដោយព្រោះតែទ្រង់បានធ្វើវាហើយ។ ព្រះជាម្ចាស់គឺជាព្រះដែលប្រកបដោយអធិបតេយ្យភាព។ ព្រះហឫទ័យរបស់ទ្រង់ មានភាពឧត្តុង្គឧត្តមបំផុត។ ទ្រង់មិនស្ថិតក្រោមច្បាប់ដែលថា ការនេះ ឬការនោះត្រូវនោះទេ និយាយរួមគឺទ្រង់មិនស្ថិតក្រោមច្បាប់ណាមួយឡើយ។ ផ្ទុយទៅវិញ ទ្រង់គឺជាច្បាប់ដល់អង្គទ្រង់ផ្ទាល់ ហេតុដូច្នេះ

ហើយបានជាអ្វីដែលទ្រង់ធ្វើគឺត្រឹមត្រូវទាំងអស់។ វេទនាហើយអស់អ្នកដែលទាស់ប្រឆាំងនឹងព្រះដែលប្រកបដោយអធិបតេយ្យភាព៖ «វេទនាដល់អ្នកណាដែលតតាំងនឹងព្រះ ដែលបានបង្កើតខ្លួនមក គេជាអំបែងឆ្នាំង១នៅក្នុងអស់ទាំងអំបែងនៅផែនដី តើដីឥដ្ឋនឹងប្រកែកចំពោះជាងស្មូនថា តើធ្វើអ្វីដូច្នេះ ឬការដែលឯងធ្វើនឹងហ៊ានថា គេគ្មានថ្វីដៃទេឬអី?» (អេសាយ ៤៥:៩)។

ដូចគ្នានេះដែរ ព្រះអម្ចាស់ជាព្រះដែលប្រកបដោយអធិបតេយ្យភាព ក៏បានបណ្ដាលឲ្យសាសន៍អ៊ីស្រាអែលមានឆន្ទៈក្នុងការជ្រើសរើសដោយខ្លួនឯងផងដែរ។ កណ្ឌគម្ពីរ និក្ខមនំ ជំពូក១៩; ២០; ២៤ បានបង្ហាញយើងយ៉ាងច្បាស់អំពីភស្តុតាងនៃចំណុចនេះ។ ព្រះជាម្ចាស់បានដាក់ពួកគេនៅក្រោមសេចក្ដីសញ្ញានៃការប្រព្រឹត្តិ ហើយទ្រង់បានប្រទានបញ្ញត្តិមួយចំនួនដល់ពួកគេ ក៏បានសន្យាថានឹងប្រទានពរដល់ពួកគេទាំងអស់គ្នាទៅតាមការដែលពួកគេស្ដាប់បង្គាប់ ឬក៏មិនស្ដាប់បង្គាប់តាមបញ្ញត្តិរបស់ទ្រង់ដែរ។ ប៉ុន្តែអ៊ីស្រាអែលជាសាសន៍ដែលរឹងចចេស និងជាសាសន៍ដែលមានចិត្តមិនកាត់ស្បែក។ ពួកគេបានបះបោរទាស់នឹងព្រះយេហូវ៉ា និងបានបោះបង់បញ្ញត្តិទ្រង់ចោល ហើយងាកបែរទៅថ្វាយបង្គំព្រះដទៃវិញ ព្រមទាំងបដិសេធទ្រង់ទៀតផង។ ជាលទ្ធផល ព្រះជាម្ចាស់បាន

ដាក់ទោសពួកគេ ដោយប្រគល់ពួកគេទៅក្នុងកណ្ដាប់ដៃនៃខ្មាំងសត្រូវរបស់ខ្លួន ហើយទ្រង់បានធ្វើឲ្យពួកគេខ្ចាត់ខ្ចាយទៅគ្រប់ទិសទីនៅលើផែនដីនេះ។ សព្វថ្ងៃនេះ ទ្រង់ក៏នៅតែមិនសព្វព្រះហឫទ័យនឹងពួកគេដែរ។

ព្រះជាម្ចាស់ដែលប្រកបដោយអធិបតេយ្យភាពបានដាក់ឲ្យអារក្សសាតាំង និងបរិវាររបស់វា ក៏ដូចជាលោក អ័ដាម និងសាសន៍អ៊ីស្រាអែលមានទំនួលខុសត្រូវចំពោះទង្វើរបស់ពួកគេរៀងៗខ្លួន។ ព្រះដែលប្រកបដោយអធិបតេយ្យភាព មិនបានដកយកទំនួលខុសត្រូវចេញពីមនុស្សទេ ប៉ុន្តែទ្រង់បានដាក់ឲ្យពួកគេមានទំនួលខុសត្រូវ ព្រោះនោះគឺជារឿងត្រឹមត្រូវនៅចំពោះព្រះនេត្រទ្រង់។ ហើយដោយសារទ្រង់ជាព្រះដែលប្រកបដោយអធិបតេយ្យភាពលើអ្វីៗទាំងអស់នោះទ្រង់ពិតជាព្រះជាម្ចាស់លើអ្វីៗទាំងអស់មែន។ សរុបសេចក្ដីមក លក្ខណៈនៃព្រះដែលប្រកបដោយអធិបតេយ្យភាព និងទំនួលខុសត្រូវរបស់មនុស្ស មានភាពស៊ីគ្នាយ៉ាងល្អឥតខ្ចោះ។ មានមនុស្សជាច្រើនបាននិយាយដោយឥតពិចារណាថា យើងមិនអាចដាក់ដែនកំណត់ថាអធិបតេយ្យភាពរបស់ព្រះជាម្ចាស់បានចប់ត្រឹមណា ហើយទំនួលខុសត្រូវរបស់មនុស្សយើងចាប់ផ្ដើមនៅពេលណាបានទេ។ ទំនួលខុសត្រូវរបស់មនុស្សចាប់ផ្ដើមនៅក្នុង៖ ត្រង់ការ

គ្រោងទុករបស់ព្រះអាទិករ ដែលប្រកបដោយអធិបតេយ្យភាព។ អធិបតេយ្យភាពរបស់ព្រះជាម្ចាស់ គឺគ្មានទីបញ្ចប់ឡើយ។

ខាងក្រោមនេះ គឺជាភស្តុតាងខ្លះៗទៀតដែលបង្ហាញថា ទំនួលខុសត្រូវរបស់មនុស្សអាស្រ័យទៅលើអធិបតេយ្យភាពរបស់ព្រះជាម្ចាស់។ តើមានការអ្វីខ្លះនៅក្នុងព្រះគម្ពីរដែលជាការត្រឹមត្រូវ ដោយសារព្រះជាម្ចាស់បានមានបន្ទូលប្រាប់ថា វាជាការត្រឹមត្រូវ ហើយបើសិនជាព្រះជាម្ចាស់មិនបានមានបន្ទូលប្រាប់ថា វាជាការមិនត្រឹមត្រូវ នោះវាជាការខុសនៅឡើយ? តើលោក អ័ដាម បានទទួលសិទ្ធិ ក្នុងការបរិភោគផ្លែឈើនៅក្នុងសួនច្បារអេដែនមកពីណា? គឺព្រះអាទិករជាអ្នកផ្តល់សិទ្ធិឲ្យគាត់។ បើទ្រង់មិនបានផ្តល់សិទ្ធិឲ្យគាត់ទេ នោះគាត់មានឈ្មោះថាជាចោរហើយ (លោកុប្បត្តិ ២:១៦)។ តើសាសន៍អ៊ីស្រាអែលមានសិទ្ធិក្នុងការសុំគ្រឿងមាស គ្រឿងប្រាក់ និងខោអាវពីសាសន៍អេស៊ីព្ទ មកពីណា (និក្ខមនំ ៣:២២)? តើសាសន៍អ៊ីស្រាអែលមានសិទ្ធិក្នុងការសម្លាប់កូនចៀមជាច្រើន ដើម្បីធ្វើជាយញ្ញបូជា មកពីណា? ប្រាកដណាស់ថា ពួកគេគ្មានសិទ្ធិអ្វីទាំងអស់ លើកលែងតែព្រះជាម្ចាស់ផ្តល់សិទ្ធិដល់ពួកគេ។ តើសាសន៍អ៊ីស្រាអែលមានសិទ្ធិក្នុងការសម្លាប់ពួកសាសន៍កាណានមកពីអ្នកណា? ប្រាកដណាស់ គឺពួកគេគ្មានសិទ្ធិអ្វីនោះទេ នេះគឺ

ដោយសារព្រះជាម្ចាស់បានផ្ដល់សិទ្ធិឲ្យពួកគេប៉ុណ្ណោះ។ តើប្ដីមានសិទ្ធិក្នុងការទាមទារឲ្យប្រពន្ធចុះចូលចំពោះខ្លួន មកពីណា? ប្រាកដណាស់ គឺគាត់គ្មានសិទ្ធិអ្វីទេ លុះត្រាតែព្រះជាម្ចាស់បានតែងតាំងគាត់ ដូច្នេះយើងអាចបន្តទៅមុខទៀតបាន។ ទំនួលខុសត្រូវរបស់មនុស្ស គឺអាស្រ័យលើអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ទាំងស្រុង។

នេះជាឧទាហរណ៍មួយទៀតអំពីការដែលព្រះជាម្ចាស់អនុវត្តអធិបតេយ្យភាពលើអ្វីៗទាំងអស់របស់ទ្រង់៖ ព្រះជាម្ចាស់ដាក់អស់អ្នកដែលទ្រង់ជ្រើសតាំងឲ្យចូលក្រោមសេចក្ដីតាំងសញ្ញារបស់ទ្រង់ផ្សេងគ្នាពីលោក អ័ដាម និងសាសន៍អ៊ីស្រាអែល ពោលគឺទ្រង់ដាក់ពួកអ្នកដែលទ្រង់ជ្រើសតាំងដោយគ្មានល័ក្ខខ័ណ្ឌអ្វីទាំងអស់។ ព្រះជាម្ចាស់បានតែងតាំងព្រះយេស៊ូវជាសិរសារបស់ពួកគេនៅក្នុងសេចក្ដីសញ្ញាថ្មី ដែលនឹងតាំងនៅអស់កល្បជានិច្ច។ ព្រះយេស៊ូវបានយកទំនួលខុសត្រូវរបស់ពួកអ្នកដែលព្រះជាម្ចាស់បានជ្រើសតាំងមកដាក់លើអង្គទ្រង់ផ្ទាល់។ ព្រះអង្គបានសម្រេចសេចក្ដីសុចរិតសម្រាប់ពួកគេយ៉ាងល្អឥតខ្ចោះ ហើយគ្មានអ្នកណាអាចពាល់សេចក្ដីសុចរិតនោះបានឡើយ។ សេចក្ដីសុចរិតនោះនឹងស្ថិតនៅអស់កល្បជានិច្ច។ ព្រះជាម្ចាស់បានប្រទានឲ្យព្រះយេស៊ូវមានឆន្ទៈក្នុងការជ្រើសរើសក្នុងការស្ដាប់ ឬក៏មិនស្ដាប់បង្គាប់ ពីព្រោះ “ព្រះយេស៊ូវបានបន្ទាប

អង្គទ្រង់ក្រោមក្រឹត្យវិន័យ ដើម្បីប្រោសលោះពួកអ្នកក្រោមក្រឹត្យវិន័យ»។ លក្ខណៈដ៏អស្ចារ្យរបស់ទ្រង់ដែលប្លែកពីអ្នកផ្សេងនោះគឺ គ្មានអ្នកណាបានធ្វើការនោះសម្រេចដូចទ្រង់ឡើយ ពោលគឺទ្រង់មិនបានបរាជ័យ ហើយថែមទាំងគ្មានលទ្ធភាពក្នុងការបរាជ័យផង។ មានសំណួរមួយបានលើកឡើងថា តើអ្នកណាបានប្រទានឲ្យព្រះយេស៊ូវមានឆន្ទៈក្នុងការជ្រើសរើសដូច្នេះ? ចម្លើយគឺ ព្រះត្រៃឯក។ ព្រះដែលប្រកបដោយអធិបតេយ្យភាព ជាព្រះដែលបានគ្រោងឲ្យព្រះយេស៊ូវធ្វើកិច្ចការនោះ។ ព្រះដែលប្រកបដោយអធិបតេយ្យភាពដែលពោរពេញដោយសេចក្តីស្រឡាញ់ គឺជាព្រះដែលបានចាត់ទ្រង់ឲ្យមកផែនដីនេះ។ ព្រះដែលប្រកបដោយអធិបតេយ្យភាពដែលពោរពេញដោយអំណាចចេស្តា ក៏ជាព្រះដែលបានប្រទានកិច្ចការនោះឲ្យទ្រង់សម្រេចដែរ។

ព្រះជាម្ចាស់បានដាក់ល័ក្ខខ័ណ្ឌមួយចំនួនសម្រាប់អ្នកកណ្តាលដែលទ្រង់បានចាត់ឲ្យមក (២ធីម៉ូថេ ២:៥)។ ជាដំបូង ទ្រង់ត្រូវតែកើតមកក្នុងសាច់ឈាម ដែលមានលក្ខណៈដូចជាសាច់ឈាមដែលមានបាបអញ្ចឹង។ ទីពីរ ទ្រង់ត្រូវលើកតម្កើងក្រឹត្យវិន័យ និងត្រូវគោរពតាម។ ទីបី រូបកាយរបស់ទ្រង់ត្រូវជាប់នៅលើឈើឆ្កាង ដើម្បីទ្រាំទ្រអស់ទាំងអំពើបាបនៃរាស្ត្ររបស់ព្រះជាម្ចាស់។ ទីបួន ទ្រង់ត្រូវ

សម្រេចការលោះបាបរាស្ត្ររបស់ព្រះជាម្ចាស់ទាំងស្រុង។ ទីប្រាំ ទ្រង់ត្រូវទ្រាំទ្រចំពោះសេចក្ដីក្រោធរបស់ព្រះជាម្ចាស់។ ទីប្រាំមួយ ទ្រង់ត្រូវសុគត ហើយទទួលការបញ្ចុះក្នុងផ្នូរ។ កណ្ឌគម្ពីរ អេសាយ ៥៣:១០-១២ បានរៀបរាប់ពីការដែលព្រះជាម្ចាស់បានសន្យានឹងព្រះយេស៊ូវថា ទ្រង់នឹងទទួលបានរង្វាន់នៅពេលដែលទ្រង់បំពេញគ្រប់ល័ក្ខខ័ណ្ឌទាំងអស់នោះ។ ទ្រង់នឹងធ្វើជាបងច្បងក្នុងពួកបងប្អូនជាច្រើន (រ៉ូម ៨:២៩)។ ទ្រង់នឹងទទួលបានរាស្ត្រដែលនឹងមានចំណែកក្នុងសិរីល្អរបស់ទ្រង់។ សូមថ្វាយព្រះពរដល់ព្រះនាមទ្រង់នៅអស់កល្បជានិច្ច ដ្បិតទ្រង់បានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាំងអស់ហើយ។ ដោយសារទ្រង់បានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាំងអស់ ដូច្នេះព្រះវរបិតាក៏នឹងរក្សាសេចក្ដីសន្យារបស់ទ្រង់ ដោយរក្សាអស់អ្នកដែលព្រះយេស៊ូវបានធ្វើជាអ្នកកណ្ដាលឲ្យនៅអស់កល្បជានិច្ចដែរ។ ដោយសារព្រះយេស៊ូវបានរងទុក្ខជំនួសពួកគេ ដូច្នេះឥឡូវនេះ ពួកគេអាចមានចំណែកជាមួយទ្រង់ ពោលគឺសេចក្ដីសុចរិតរបស់ព្រះយេស៊ូវ ក៏ជាសេចក្ដីសុចរិតរបស់ពួកគេដែរ ហើយព្រះជាម្ចាស់ក៏ទតមើលមកពួកគេ ដូចដែលទ្រង់ទតមើលមកព្រះយេស៊ូវដែរ ហើយជីវិតរបស់ព្រះយេស៊ូវ ក៏ជាជីវិតរបស់ពួកគេដែរ។ ពួកគេមិនចាំបាច់បំពេញល័ក្ខខ័ណ្ឌអ្វីនោះទេ ហើយក៏មិនមានទំនួលខុសត្រូវអ្វីដែលពួកគេត្រូវដកខ្លួនចេញ ដើម្បី

ឲ្យទទួលបានជីវិតអស់កល្បជានិច្ចនោះដែរ។ «ដ្បិតទ្រង់ធ្វើឲ្យពួកអ្នកដែលបានញែកជាបរិសុទ្ធហើយ បានគ្រប់លក្ខណ៍អស់កល្បជានិច្ចដោយសារតង្វាយតែ១នោះ» (ហេព្រើរ ១០:១៤)។

សរុបមក ព្រះជាម្ចាស់បានបង្ហាញឲ្យមនុស្សគ្រប់គ្នាបានឃើញពីអធិបតេយ្យភាពរបស់ទ្រង់ ដោយទ្រង់បានបង្ហាញក្នុងរបៀបខុសៗគ្នាដូចដែលទ្រង់ធ្វើចំពោះអ្វីៗដែលទ្រង់បានបង្កើតមក។ ព្រះជាម្ចាស់បានដាក់ល័ក្ខខ័ណ្ឌដល់ពួកទេវតា លោក អ័ដាម និងសាសន៍អ៊ីស្រាអែលថា ទ្រង់នឹងបន្តប្រទានពរដល់ពួកគេ ទៅតាមការដែលពួកគេស្តាប់ ឬក៏មិនស្តាប់បង្គាប់ទ្រង់ ឬតើពួកគេនៅស្មោះត្រង់ចំពោះទ្រង់ ឬក៏អត់។ ប៉ុន្តែ ពេលនេះខុសគ្នាស្រឡះ ព្រះជាម្ចាស់មិនបានដាក់ល័ក្ខខ័ណ្ឌដូចនេះដល់ «ហ្វូងតូច» នេះឡើយ (លូកា ១២:៣២)។ តាមរយៈការតាំងសញ្ញារវាងព្រះតម្រិះ និងព្រះរាជបុត្រារបស់ទ្រង់ ព្រះជាម្ចាស់បានទតមើលមកពួកគេ ហើយឃើញថានឹងគ្មានការប្រែប្រួលអ្វីនៅចំពោះព្រះនេត្រទ្រង់ឡើយ។ វាមានលក្ខណៈបែបនេះ ពីព្រោះព្រះពររបស់ពួកគេអាស្រ័យលើអ្វីដែលព្រះគ្រីស្ទបានធ្វើទាំងស្រុង។ កណ្ឌគម្ពីរ ២ធីម៉ូថេ ២:១៩ បានចែងថា «ឯឫសមាំមួនរបស់ព្រះ នោះធន់នៅវិញ ដោយបានបោះត្រាថា ព្រះអម្ចាស់ទ្រង់ស្គាល់អស់អ្នកដែលជារបស់ផងទ្រង់»។ ភាព

ល្អឥតខ្ចោះ គឺជាមូលដ្ឋានគ្រឹះដែលរាស្ត្ររបស់ព្រះជាម្ចាស់ត្រូវតែប្រកាន់ខ្ជាប់៖ គ្មានអ្នកណាអាចបន្ថែមអ្វីចូល ឬដកអ្វីចេញបានឡើយ (សាស្តា ៣:១៤)។ តាមរយៈការនេះ យើងអាចមើលឃើញពីភាពដ៏ឧត្តុង្គឧត្តមនៃអធិបតេយ្យភាពរបស់ព្រះជាម្ចាស់បានយ៉ាងច្បាស់។ ប្រាកដណាស់ «ទ្រង់តែងផ្សាយមេត្តាករុណា ដល់អ្នកណាតាមព្រះហឫទ័យ ហើយទ្រង់ធ្វើឲ្យអ្នកណារឹងទទឹងក៏តាមតែព្រះហឫទ័យដែរ» (រ៉ូម ៩:១៨)។

## ជំពូកទី៧

# ព្រះដែលមិនចេះប្រែប្រួល

នេះគឺជាលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះមួយទៀតរបស់ព្រះជាម្ចាស់ ដែលមនុស្សជាច្រើនមិនសូវគិតគូរបានជិតដល់។ នេះជាលក្ខណៈដ៏ឧត្តុង្គឧត្តមមួយរបស់ព្រះអាទិករ ដែលញែកទ្រង់ចេញពីអ្វីៗទាំងអស់ដែលទ្រង់បានបង្កើត។ ព្រះជាម្ចាស់មិនចេះប្រែប្រួលឡើយ៖ ភាពជាព្រះរបស់ទ្រង់ លក្ខណសម្បត្តិ និងគម្រោងការរបស់ទ្រង់មិនចេះប្រែប្រួលទេ! ហេតុដូច្នេះហើយបានជាព្រះគម្ពីរបានប្រៀបធៀប ព្រះ ជាម្ចាស់ ទៅ នឹង ផ្ទាំង ថ្មដា ព្រោះ ថ្ម មាន លក្ខណៈ មាំមួន (ចោទិយកថា ៣២:៤។ល។) បើទោះជាសមុទ្រមានចលនាប្រែប្រួលឥតឈប់ឈរ ហើយអ្វីៗដែលទ្រង់បានបង្កើតមកតែងតែប្រែប្រួលក៏ដោយ ក៏ទ្រង់នៅតែមិនប្រែប្រួលដែរ។ ព្រះជាម្ចាស់មិនចេះប្រែប្រួលឡើយ ព្រោះទ្រង់ជាព្រះដែលគ្មានចំណុចចាប់ផ្តើម ឬចំណុចបញ្ចប់ទេ។ ទ្រង់ជាព្រះដែលគង់នៅតាំងពីអស់កល្បរៀងមក “ព្រះវរបិតានៃពន្លឺ ដែលទ្រង់មិនចេះប្រែប្រួល សូម្បីតែស្រមោលនៃ

សេចក្ដីផ្លាស់ប្រែក៏គ្មានដែរ» (យ៉ាកុប ១:១៧)។

## ទិដ្ឋភាពនៃការមិនផ្លាស់ប្រែរបស់ព្រះជាម្ចាស់

ទីមួយ ភាពជាព្រះរបស់ព្រះជាម្ចាស់មិនចេះប្រែប្រួលឡើយ។ ភាពជាព្រះ និងលក្ខណសម្បត្តិរបស់ទ្រង់នៅស្ថិតស្ថេរជាដរាប ហេតុដូច្នេះហើយបានជាទ្រង់មិនដែលប្រែប្រួល។ ប្រាកដណាស់! នៅក្នុងប្រវត្តិសាស្ត្រ មិនដែលមានពេលណាដែលទ្រង់មិនមែនជាព្រះនោះទេ ហើយនៅពេលអនាគតក៏នឹងមិនមានពេលដែលទ្រង់មិនមែនជាព្រះនោះដែរ។ ព្រះជាម្ចាស់ក៏មិនដែលវិវឌ្ឍ ចម្រើនវ័យ ឬក៏មានលក្ខណៈប្រសើរជាងមុននោះដែរ។ ភាពជាព្រះរបស់ទ្រង់នាពេលសព្វថ្ងៃនេះ គឺទ្រង់មានតាំងពីមុនអស់កល្បរៀងមកម៉្លេះ ហើយទ្រង់ក៏នឹងបន្តភាពជាព្រះនេះនៅពេលអនាគតទៀតដែរ។ ព្រះជាម្ចាស់បានអះអាងដោយអង្គទ្រង់ផ្ទាល់ «អញ គឺយេហូវ៉ា អញមិនប្រែប្រួលឡើយ» (ម៉ាឡាគី ៣:៦)។ ព្រះអង្គមិនអាចផ្លាស់ប្ដូរលក្ខណៈរបស់ទ្រង់ឲ្យកាន់តែល្អប្រសើរជាងមុនបានទេ ដ្បិតទ្រង់ល្អឥតខ្ចោះរួចទៅហើយ ហើយដោយសារតែទ្រង់ល្អឥតខ្ចោះ ដូច្នេះទ្រង់មិនអាចប្រែទៅជាអាក្រក់វិញបានឡើយ។ សរុបមក គ្មានអ្វីអាចជះឥទ្ធិពលលើទ្រង់ ក៏គ្មានអ្វីអាចធ្វើឲ្យទ្រង់ល្អប្រសើរជាងមុនបានទេ ហើយទ្រង់ក៏

មិនពុករលួយដែរ។ ទ្រង់មិនចេះប្រែប្រួលជានិរន្តរ៍។ មានតែទ្រង់មួយអង្គគត់ដែលអាចមានបន្ទូលថា “អញជាព្រះដ៏ជាព្រះ” (និក្ខមនំ ៣:១៤)។ ពេលវេលាក៏មិនអាចផ្លាស់ប្តូរទ្រង់បានដែរ។ នៅលើព្រះភក្ត្ររបស់ទ្រង់ នឹងមិនដែលមានភាពជ្រីវជ្រួញណាមួយកើតឡើងឡើយ។ ដូច្នេះ អំណាចព្រះចេស្តារបស់ទ្រង់នឹងមិនដែលអន់ថយនោះឡើយ ហើយពន្លឺនៃសិរីល្អរបស់ទ្រង់ក៏មិនដែលបាត់ដែរ។

ទីពីរ លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់មិនចេះប្រែប្រួល។ រាល់លក្ខណសម្បត្តិរបស់ទ្រង់ គឺមានតាំងពីមុនទ្រង់បង្កើតចក្រវាលនេះមកម្ល៉េះ ហើយឥឡូវនេះ ទ្រង់នៅតែមានលក្ខណសម្បត្តិនេះដដែល ពោលគឺលក្ខណសម្បត្តិរបស់ទ្រង់នឹងបន្តនៅជាដរាប។ ទ្រង់ត្រូវតែមានលក្ខណៈដដែល ព្រោះនោះជាលក្ខណៈដ៏ល្អឥតខ្ចោះ ហើយក៏ជាលក្ខណៈដ៏ចាំបាច់នៃភាពជាព្រះរបស់ទ្រង់ដែរ។ លក្ខណសម្បត្តិរបស់ទ្រង់គឺនៅស្ថិតស្ថេរជាដរាប។ គ្មានបុគ្គលណាម្នាក់អាចមកធ្វើឲ្យអំណាចព្រះចេស្តារបស់ទ្រង់ថមថយ ឬអាចមកបំផ្លាញព្រះប្រាជ្ញាញាណរបស់ទ្រង់ ឬក៏អាចមកធ្វើឲ្យភាពបរិសុទ្ធរបស់ទ្រង់រលាយសាបសូន្យបានឡើយ។ ដូចគ្នានេះដែរ ភាពជាព្រះរបស់ព្រះជាម្ចាស់នឹងមិនបាត់បង់ឡើយ ហើយលក្ខណសម្បត្តិរបស់ទ្រង់ក៏មិនអាចប្រែប្រួលបានដែរ។ ភាពស្មោះត្រង់របស់ទ្រង់មិនចេះប្រែ

ប្រែប្រួលឡើយ ដ្បិតព្រះបន្ទូលរបស់ទ្រង់បានចែងហើយថា «ទ្រង់បានតាំងនៅស្ថានសួគ៌ ជរាបដល់អស់កល្បជានិច្ច» (ទំនុកតម្កើង ១១៩:៨៩)។ សេចក្ដីស្រឡាញ់របស់ទ្រង់ស្ថិតស្ថេរនៅជាដរាប «អញបានស្រឡាញ់ឯងដោយសេចក្ដីស្រឡាញ់ដ៏ស្ថិតស្ថេរនៅអស់កល្ប» (យេរេមា ៣១:៣)។ សេចក្ដីសប្បុរសរបស់ទ្រង់គ្មានទីបញ្ចប់ឡើយ ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប (ទំនុកតម្កើង ១០០:៥)។

ទីបី ព្រះតម្រិះរបស់ព្រះជាម្ចាស់មិនចេះប្រែប្រួលឡើយ ហើយព្រះហឫទ័យរបស់ទ្រង់ក៏មិនចេះប្រែប្រួលដែរ។ ប្រាកដណាស់ថានឹងមានមនុស្សមួយចំនួនបដិសេធចំណុចនេះដោយលើកឡើងថា យើងគួរតែអានខគម្ពីរនេះ «នោះព្រះយេហូវ៉ាទ្រង់ស្តាយ ដោយបានបង្កើតមនុស្សមក» (លោកុប្បត្តិ ៦:៦)។ ចម្លើយដំបូងរបស់យើងគឺសួរទៅវិញថា តើព្រះបន្ទូលប្រឆាំងគ្នាមែនឬ? វាមិនអាចទៅរួចជាដាច់ខាត! កណ្ឌគម្ពីរ ជនគណនា ២៣:១៩ បានចែងយ៉ាងច្បាស់ណាស់ថា «ព្រះទ្រង់មិនមែនជាមនុស្ស ទ្រង់មិនចេះកុហកឡើយ ក៏មិនមែនជាកូនមនុស្សដែរ ទ្រង់មិនត្រូវការប្រែគំនិតទេ»។ កណ្ឌគម្ពីរ ១សាំយូអែល ១៥:២៩ ក៏ចែងដែរថា «មួយទៀត ព្រះដ៏ជាកម្លាំងនៃសាសន៍អ៊ីស្រាអែលទ្រង់មិនចេះកុហក ឬប្រែប្រួល

ឡើយ ដ្បិតទ្រង់មិនមែនជាមនុស្សដែលចេះប្រែប្រួលទេ»។ យើងអាចពន្យល់ខគម្ពីរនេះយ៉ាងងាយ នៅពេលដែលព្រះជាម្ចាស់មានព្រះបន្ទូលអំពីអង្គទ្រង់ផ្ទាល់ ហើយទ្រង់តែងតែប្រើព្រះបន្ទូលដែលយើងអាចយល់បាន។ ទ្រង់បានពណ៌នាថាទ្រង់មានរូបកាយ អវយវៈព្រះនេត្រ ព្រះស្រោត្រ[១] និងព្រះហស្ត។ល។ ព្រះអង្គបានមានបន្ទូលពីអង្គទ្រង់ផ្ទាល់ថា ទ្រង់ «តើនឡើង» «ពីព្រលឹមស្រាង» ប៉ុន្តែទ្រង់មិនងងុយ ឬក៏ផ្ទំលក់ឡើយ (ទំនុកតម្កើង ៧៨:៦៥; យេរេមា ៧:១៣)។ នៅពេលដែលទ្រង់ពណ៌នាអំពីការដែលទ្រង់ផ្លាស់ប្តូរព្រះហឫទ័យចំពោះមនុស្ស ទ្រង់បានប្រើពាក្យថា «ប្រែប្រួល»។

ប្រាកដណាស់! ព្រះតម្រិះទ្រង់មិនចេះប្រែប្រួលឡើយ។ កណ្ឌគម្ពីរ រ៉ូម ១១:២៩ បានចែងថា «ដ្បិតព្រះទ្រង់មិនដែលស្តាយអំណោយទានទ្រង់ ឬការដែលទ្រង់ហៅមនុស្សណានោះឡើយ»។ ព្រះតម្រិះទ្រង់មិនចេះប្រែប្រួលឡើយ ដ្បិត «ទ្រង់មានគំនិតតែមួយ តើអ្នកណានឹងបំផ្លាស់បំប្រែព្រះហឫទ័យទ្រង់បាន ការអ្វីដែលទ្រង់ចង់ធ្វើ នោះក៏ធ្វើទៅ» (យ៉ូប ២៣:១៣)។ ទោះបើយើងឃើញ ហើយរស់នៅជុំវិញការប្រែប្រួល និងភាពពុករលួយក៏ដោយ ក៏យើងនៅតែដឹងថា ព្រះជាម្ចាស់ដែលគង់នៅក្នុងយើង ទ្រង់មិនចេះប្រែប្រួលដែរ។ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មិនចេះប្រែប្រួលឡើយ។ មាន

ចំណុចពីរយ៉ាងដែលធ្វើឲ្យមនុស្សយើងកែប្រែចិត្តគំនិត ឬក៏ផ្លាស់ប្តូរផែនការៈ ១) ការគ្មានចក្ខុវិស័យដែលអាចប្រមើលមើលអ្វីៗគ្រប់យ៉ាងនៅថ្ងៃអនាគត ២) ការគ្មានអំណាចចេស្តាក្នុងការសម្រេចផែនការសោះ។ ប៉ុន្តែ ព្រះជាម្ចាស់ជ្រាបអំពីអ្វីៗទាំងអស់ ហើយទ្រង់មានពេញដោយអំណាចព្រះចេស្តា ហេតុដូច្នេះហើយបានជាព្រះអង្គមិនចាំបាច់កែប្រែព្រះតម្រិះរបស់ទ្រង់ឡើយ។ ពិតណាស់! ទ្រង់មិនចាំបាច់កែប្រែទេ! កណ្ឌគម្ពីរ ទំនុកតម្កើង ៣៣:១១ បានចែងថា «ឯដំបូន្មានផងព្រះយេហូវ៉ាវិញ នោះនៅជាប់ជានិច្ច ហើយតម្រិះក្នុងព្រះហឫទ័យទ្រង់ក៏នៅជាដរាបដល់អស់ទាំងដំណតទៅ»។ ហេតុដូច្នេះហើយបានជាយើងឃើញក្នុងព្រះគម្ពីរថា «ព្រះទ័យសម្រេចរបស់ទ្រង់ថា មិនចេះប្រែប្រួលឡើយ» (ហេព្រើរ ៦:១៧)។

## តើយើងអាចពឹងលើមនុស្សបានទេ?

តាមរយៈការនេះ យើងអាចយល់ពីគន្លងដ៏ធំមហិមារវាងអ្វីៗដែលព្រះជាម្ចាស់បានបង្កើត និងព្រះដែលជាអាទិករនៃអ្វីៗទាំងអស់នោះ។ អ្វីៗដែលព្រះជាម្ចាស់បានបង្កើត និងភាពប្រែប្រួលនៃរបស់ទាំងអស់នោះ គឺមិនខុសគ្នាទេ។ ប្រសិនបើអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមិនមានភាពប្រែប្រួល នោះមានន័យថា អ្វីៗទាំងអស់

នោះគឺជាព្រះហើយ។ តាមធម្មជាតិរបស់យើង យើងមានទំនោរឆ្ពោះទៅរកភាពសាបសូន្យ ពីព្រោះព្រះជាម្ចាស់បានបង្កើតយើងចេញពីភាពសាបសូន្យ។ ព្រះហឫទ័យ និងអំណាចទ្រទ្រង់របស់ព្រះជាម្ចាស់ គឺជាមូលហេតុដែលទ្រង់មិនបំផ្លាញយើងចោល។ គ្មានអ្នកណាអាចទ្រទ្រង់ខ្លួនឯងបានទេ សូម្បីតែមួយភ្លែតក៏មិនបានដែរ។ យើងត្រូវពឹងអាងលើព្រះអាទិករគ្រប់ខ្យល់ដង្ហើមរបស់យើង ហើយយើងក៏អាចបន្លឺសំឡេងដូចអ្នកនិពន្ធកណ្ឌគម្ពីរ ទំនុកតម្កើង ៦៦:៩ ដែលថា ទ្រង់ «រក្សាជីវិតយើងឲ្យរស់នៅ»។ ការដែលយើងទទួលស្គាល់គំនិតបែបនេះ គួរតែជំរុញយើងឲ្យក្រាបចុះក្រោម «ភាពគ្មានអ្វីសោះរបស់យើង» និងក្នុងព្រះវត្តមានរបស់ទ្រង់ «ដ្បិតគឺដោយសារទ្រង់ហើយ ដែលយើងរាល់គ្នាបានរស់ កំរើក ហើយមាននៅផង» (កិច្ចការ ១៧:២៨)។

ក្នុងនាមជាមនុស្ស យើងមិនត្រឹមតែប្រែប្រួលប៉ុណ្ណោះទេ ប៉ុន្តែគ្រប់អ្វីៗដែលនៅក្នុងយើង គឺតែងតែចង់ប្រឆាំងទាស់នឹងព្រះជាម្ចាស់ទៀតផង។ កណ្ឌគម្ពីរ យូដាស ១:១៣ បានចែងថា យើង «ជាផ្កាយមិនទៀង» ដែលបានធ្លាក់ចេញពីគន្លងធម្មតា។ «ពួកមនុស្សអាក្រក់ គេប្រៀបដូចជាសមុទ្រដែលចេះតែកំរើក ឥតមានស្ងប់ឡើយ» (អេសាយ ៥៧:២០)។ ដោយសារយើងធ្លាក់ក្នុងអំពើបាប នោះ

យើងមិនអាចនៅខ្ជាប់ខ្ជួនបានឡើយ។ យើងក៏អាចយកពាក្យសម្ដីដែលលោក យ៉ាកុប បានមានប្រសាសន៍ទៅកាន់ រូបេន ដែលជាកូនប្រុសរបស់គាត់ មកនិយាយដាក់កូនចៅគ្រប់រូបរបស់លោកអ័ដាម ដែរគឺ «រំពើកចុះឡើងដូចទឹក» (លោកុប្បត្តិ ៤៩:៤)។ ហេតុដូច្នេះ នេះមិនត្រឹមតែជាចំណែកនៃកោតខ្លាចព្រះជាម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាចំណែកនៃការមានប្រាជ្ញាតាមរយៈការស្ដាប់តាមបញ្ញត្តិនៃព្រះបន្ទូលរបស់ទ្រង់ដែរ «ចូរលែងទុកចិត្តដល់មនុស្សដែលមានតែដង្ហើមចេញចូលតាមរន្ធច្រមុះទៅ ដ្បិតតើនឹងពឹងដល់គេឯណាបាន» (អេសាយ ២:២២)។ ចូរកុំទុកចិត្តលើមនុស្សណាម្នាក់ឡើយ។ កណ្ឌគម្ពីរ ទំនុកតម្កើង ១៤៦:៣ បានចែងថា «កុំឲ្យទុកចិត្តនឹងអ្នកធំ ឬនឹងពូជពង្សនៃមនុស្សណាឡើយ គេនឹងជួយឯងមិនបានទេ»។ ដូច្នេះ ប្រសិនបើខ្ញុំមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ទេ នោះខ្ញុំសមនឹងទទួលការបោកបញ្ឆោត និងការមិនពេញចិត្តពីមនុស្សដទៃទៀតណាស់។ បុគ្គលដែលចូលចិត្តអ្នកនៅថ្ងៃនេះ អាចនឹងស្អប់អ្នកវិញនៅថ្ងៃស្អែក។ ហ្វូងមនុស្សដែលស្រែកថា «ហូសាណា! ដល់ព្រះវង្សហ្លួងដាវីឌ!» បានប្ដូរចិត្តយ៉ាងរហ័សថា «យកវាចេញ! យកវាចេញ! ឲ្យឆ្កាងវាទៅ!»។

## ទីកន្លែងជំហររបស់យើង

ចូរស្វែងរកចំណុចដ៏ស្រណុកសុខស្រួលដូចតទៅនេះ៖ យើងមិនអាចទុកចិត្តលើមនុស្សបានឡើយ ប៉ុន្តែយើងអាចទុកចិត្តលើព្រះជាម្ចាស់បាន! មិនថាខ្លួនខ្ញុំផ្ទាល់ ឬមិត្តភក្តិរបស់ខ្ញុំនោះទេ គឺយើងសុទ្ធតែមានចិត្តប្រែប្រួល ប៉ុន្តែព្រះជាម្ចាស់មិនដែលប្រែប្រួលសោះឡើយ។ ប្រសិនបើទ្រង់ចេះប្រែប្រួលដូចយើង ដោយមានបន្ទូលថ្ងៃនេះ ហើយប្តូរវិញនៅថ្ងៃស្អែក ឬចេះតែប្រែប្រួលតាមតែកាលៈទេសៈនោះតើអ្នកណាអាចទុកចិត្តទ្រង់បានទៀត? ប៉ុន្តែ ចូរយើងថ្វាយសិរីល្អដល់ទ្រង់ ដ្បិតទ្រង់នៅតែដដែលរហូតដល់អស់កល្បជានិច្ចតទៅ។ គោលបំណងរបស់ទ្រង់នៅនឹងនរជានិច្ច ព្រះហឫទ័យរបស់ទ្រង់រឹងប៉ឹង ហើយព្រះបន្ទូលរបស់ទ្រង់ក៏មិនចេះប្រែប្រួលដែរ។ ប្រាកដណាស់ យើងអាចឈរនៅលើថ្មដានេះបាន ខណៈពេលដែលរលកនៅជុំវិញយើងបក់បោកយ៉ាងខ្លាំង។ ភាពមិនចេះប្រែប្រួលនៃលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ បញ្ជាក់ថាទ្រង់នឹងបំពេញតាមក្តីសន្យារបស់ទ្រង់ «ពីព្រោះអស់ទាំងភ្នំធំនឹងបាត់ទៅបាន ហើយអស់ទាំងភ្នំតូចនឹងរើចេញទៅបានដែរ ប៉ុន្តែសេចក្តីសប្បុរសរបស់អញនឹងមិនដែលឃ្លាតបាត់ពីឯងឡើយ ហើយសេចក្តីសញ្ញាពីសេចក្តីមេត្រីរបស់

អញក៏មិនត្រូវរើចេញដែរ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ាដែលទ្រង់ប្រោសមេត្តាដល់ឯង» (អេសាយ ៥៤:១០)។

ដោយសារសេចក្តីពិតនេះ យើងគួរតែមានទឹកចិត្តក្នុងការអធិស្ឋានដូចជាលោកគ្រូ អេស៍. ឆ័រណោខ (S. Charnock, ១៦៧០) ថា៖ «យើងនឹងគ្មានទំនុកចិត្តទេ ប្រសិនបើយើងអធិស្ឋានទៅកាន់ព្រះដែលចេះតែប្រែប្រួលឥតឈប់ឈរ ដូចជាសត្វម៉្យាងដែលមានសណ្ឋានដូចបង្គួយ ដែលចេះតែប្តូរពណ៌ម្តងហើយម្តងទៀត នោះច្បាស់ជាគ្មានអ្នកណាដាក់ទុកចិត្តលើស្តេចនៃផែនដីនេះ ដែលនឹងអនុញ្ញាតញត្តិនោះនៅថ្ងៃនេះ ប៉ុន្តែប្តូរព្រះទ័យវិញនៅថ្ងៃស្អែកនោះទេ»។ តែបើមានអ្នកណាសួរថា «តើមានប្រយោជន៍អ្វី ដែលយើងអធិស្ឋានទៅកាន់ព្រះដែលមានព្រះហឫទ័យរឹងប៉ឹងហើយនោះ?»។ យើងគួរឆ្លើយថា «ពីព្រោះទ្រង់តម្រូវឲ្យយើងធ្វើបែបហ្នឹង»។ តើវានឹងមានប្រយោជន៍អ្វី បើយើងមិនទទួចសូមសេចក្តីសន្យាដែលព្រះជាម្ចាស់បានសន្យាចំពោះយើង? កណ្ឌគម្ពីរ ១យ៉ូហាន ៥:១៤ បានចែងថា «ប្រសិនបើយើងទូលសូមអ្វី ស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះទ្រង់នឹងព្រះសណ្តាប់យើងជាមិនខាន» (គខប)។ យើងក៏ដឹងដែរថា ព្រះជាម្ចាស់បានគ្រោងអ្វីៗដែលល្អទុកសម្រាប់បុត្រាបុត្រីរបស់ទ្រង់រួចហើយ។ បើយើងទូលសូមនូវអ្វីដែលមិនស្រប

តាមព្រះហឫទ័យរបស់ទ្រង់ នោះមានន័យថា យើងកំពុងតែបះបោរទាស់ប្រឆាំងនឹងទ្រង់ហើយ។

នេះជាអ្វីដែលពួកមនុស្សអាក្រក់ភ័យខ្លាច។ អស់អ្នកដែលមិនគោរពប្រតិបត្តិដល់ព្រះជាម្ចាស់នៅក្នុងជីវិតរស់នៅរបស់ខ្លួន ប៉ុន្តែបែរជារស់នៅដោយបង្ហាញថា គ្មានព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ នោះពួកគេគ្មានសិទ្ធិនឹងរំពឹងថា ព្រះជាម្ចាស់នឹងមានសេចក្តីមេត្តាដល់ខ្លួនឡើយ ប៉ុន្តែពួកគេអាចរំពឹងថា ព្រះជាម្ចាស់នឹងប្រទានរង្វាន់ដែលពួកគេសមនឹងទទួល។ ដ្បិតទ្រង់បានមានព្រះបន្ទូលហើយថា «ដូច្នេះ អញនឹងប្រព្រឹត្តដោយសេចក្តីក្រោធដែរ ភ្នែកអញនឹងមិនប្រណីឡើយ អញនឹងមិនអាណិតមេត្តាទេ ទោះបើគេអំពាវនាវដោយសំឡេងយ៉ាងខ្លាំងដាក់ត្រចៀកអញក៏ដោយ គង់តែអញមិនព្រមស្តាប់ឡើយ» (អេសេគាល ៨:១៨)។ ព្រះជាម្ចាស់នឹងមិនក្បត់ឧត្តមគតិរបស់ទ្រង់ ដើម្បីទៅបំពេញតណ្ហារបស់ពួកគេឡើយ ដ្បិតទ្រង់ជាព្រះដ៏បរិសុទ្ធ ហើយក៏មិនចេះប្រែប្រួលដែរ។ ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់ស្អប់អំពើបាប ហើយទ្រង់ស្អប់វារហូតដល់អស់កល្បជានិច្ច! ហេតុដូច្នេះហើយបានជាទ្រង់ដាក់ទណ្ឌកម្មរៀងដរាបលើអ្នកទាំងអស់នោះដែលស្លាប់នៅក្នុងអំពើបាបរបស់ខ្លួន។

«ព្រះដ៏មិនចេះប្រែប្រួល ទ្រង់ប្រៀបដូចជាពពកដែលបានបង្ខាំង

សាសន៍អ៊ីស្រាអែលពីកងទ័ពសាសន៍អេស៊ីព្ទ ទ្រង់មានទាំងធម៌ត្រជាក់ និងធម៌ក្ដៅ។ ចំណុចនេះបញ្ជាក់ថា៖ ១) ទ្រង់ប្រាកដជានឹងថ្កោលទោសពួកអ្នកមានបាបជាមិនខាន ២) ទ្រង់ប្រាកដជានឹងបំពេញតាមសេចក្ដីសន្យារបស់ទ្រង់ហើយ ៣) ទ្រង់នឹងគ្រាន់តែដាក់ទោសពួកគាត់បន្តិចបន្តួច ជាជាងយ៉ាងខ្លាំងដូចដែលព្រះបន្ទូលរបស់ទ្រង់បាននាំឲ្យយើងរំពឹង។ យើងជំទាស់នឹងការបោកបញ្ឆោត និងការពិចារណាដែលកោតក្រែងសេចក្ដីពិតនោះ ដែលថាព្រះអង្គចេះប្រែប្រួលក្នុងការប្រកាន់ខ្ជាប់ចំពោះការពិត និងគោលបំណង ក្នុងភាពស្មោះត្រង់ និងភាពយុត្តិធម៌»។[២] មានតែព្រះទេដែលបរិសុទ្ធ។

ជំពូកទី៨

# ភាពបរិសុទ្ធរបស់ព្រះ

កណ្ឌគម្ពីរ វិវរណៈ ១៥:៤ ចែងថា “ឱព្រះអម្ចាស់អើយ តើមានអ្នកណាមិនកោតខ្លាច ហើយលើកតម្កើងព្រះនាមព្រះអង្គ? ដ្បិតមានតែព្រះអង្គមួយប៉ុណ្ណោះដែលបរិសុទ្ធ” (គកស)។ មានទ្រង់តែមួយព្រះអង្គប៉ុណ្ណោះដែលបរិសុទ្ធនៅអស់កល្បជានិច្ច ហើយភាពបរិសុទ្ធរបស់ទ្រង់ក៏មិនចេះប្រែប្រួលដែរ។ ព្រះគម្ពីរតែងតែពណ៌នាពីទ្រង់ថាទ្រង់ជា “ព្រះដ៏បរិសុទ្ធ” ព្រោះក្នុងទ្រង់មានគ្រប់ទាំងសីលធម៌ដ៏ល្អឥតខ្ចោះ។ ទ្រង់ពេញដោយភាពបរិសុទ្ធ ហើយសូម្បីតែស្រមោលនៃអំពើបាបក៏មិនអាចប៉ះពាល់ភាពបរិសុទ្ធរបស់ទ្រង់បានដែរ៖ “ព្រះជាម្ចាស់ជាពន្លឺ ហើយគ្មានសេចក្ដីងងឹតនៅក្នុងព្រះអង្គឡើយ” (១យ៉ូហាន ១:៥ គគខ)។ ភាពបរិសុទ្ធ គឺជាភាពឧដុង្គឧត្ដមរបស់ព្រះជាម្ចាស់ដែលទាក់ទងនឹងលក្ខណសម្បត្តិរបស់ទ្រង់៖ ព្រះដ៏អស្ចារ្យ “មានសេចក្ដីបរិសុទ្ធដ៏វិសេស” (និក្ខមនំ ១៥:១១)។ ហេតុដូច្នេះហើយបានជាព្រះគម្ពីរចែងថា “ទ្រង់មានព្រះនេត្របរិសុទ្ធក្រៃលែង និង

ទតមើលការអាក្រក់មិនបាន ក៏នឹងពិនិត្យមើលការទុច្ចរិតមិនបានដែរ» (ហាបាគុក ១:១៣)។ ដូចដែលអំណាចព្រះចេស្ដារបស់ព្រះជាម្ចាស់ ផ្ទុយពីភាពទន់ខ្សោយនៃអ្វីៗទាំងអស់ដែលទ្រង់បានបង្កើតមកជាយ៉ាងណា ហើយដូចដែលព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ផ្ទុយពីភាពល្ងង់ខ្លៅជាយ៉ាងណា នោះភាពបរិសុទ្ធរបស់ទ្រង់ក៏ផ្ទុយពីសីលធម៌ដ៏កខ្វក់របស់មនុស្សដែរ។ តាំងពីដើមមកព្រះជាម្ចាស់បានរៀបចំឲ្យមានអ្នកចម្រៀង «ដែលត្រូវច្រៀងថ្វាយព្រះយេហូវ៉ា ហើយពោលសរសើរ ដោយស្លៀកពាក់ជាប្រដាប់បរិសុទ្ធ» (២របាក្សត្រ ២០:២១)។ លោកគ្រូ អេស៍. ឆ័រណោខ បានមានប្រសាសន៍ថា៖ «ក្នុងព្រះហស្តទ្រង់មានអំណាច។ ក្នុងព្រះនេត្រទ្រង់មានព្រះតម្រិះ។ ក្នុងឧទរទ្រង់មានសេចក្តីមេត្តាករុណា។ ក្នុងចិរវេលារបស់ទ្រង់មានភាពអស់កល្បជានិច្ច។ ប៉ុន្តែ ក្នុងភាពបរិសុទ្ធរបស់ទ្រង់ គឺមានភាពស្អាតស្អំ»។ ចំណុចដែលទ្រង់មានភាពបរិសុទ្ធស្អាតស្អំក្រៃលែងនេះហើយដែលធ្វើឲ្យអស់អ្នកដែលទ្រង់បានរំដោះពីបាបបានស្រឡាញ់ទ្រង់។

ព្រះគម្ពីរបានផ្តោតយ៉ាងខ្លាំងទៅលើភាពបរិសុទ្ធដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់។

«ព្រះគម្ពីរបានពណ៌នាអំពីភាពបរិសុទ្ធរបស់ទ្រង់ច្រើនជាង

អំណាចព្រះចេស្ដារបស់ទ្រង់ ហើយក៏បានញែកកិត្តិយសនេះខ្ពស់ជាងកិត្តិយសផ្សេងៗទៀតដែរ។ ព្រះគម្ពីរបានរៀបរាប់ពីលក្ខណសម្បត្តិមួយនេះ ដែលទាក់ទងនឹងព្រះនាមរបស់ទ្រង់ច្រើនជាងលក្ខណសម្បត្តិផ្សេងៗ។ លោកអ្នកនឹងមិនអាចរកឃើញពាក្យដែលចែងនៅក្នុងព្រះគម្ពីរថា "ព្រះនាមដ៏អង់អាច" ឬក៏ "ព្រះនាមដ៏ពេញដោយប្រាជ្ញា" ឡើយ ប៉ុន្តែនៅក្នុងព្រះគម្ពីរ លោកអ្នកនឹងឃើញពាក្យ ព្រះនាមដ៏ជាធំ ឬក៏ ព្រះនាមបរិសុទ្ធ។ នេះជាព្រះគោរមងារដ៏ខ្ពស់ក្រៃលែង។ នៅក្នុងព្រះនាមដ៏បរិសុទ្ធរបស់ព្រះអង្គ យើងឃើញពីឫទ្ធានុភាព និងកិត្តិយសដែលទ្រង់សមនឹងទទួល។» លោកគ្រូអេស៍. ឆ័រណេខ។

ពួកសេរភីមដែលនៅស្ថានសួគ៌បានសរសើរពីលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់នៅមុខបល្ល័ង្កទ្រង់ដោយបន្លឺសំឡេងឡើងថា «បរិសុទ្ធ បរិសុទ្ធ គឺព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់បរិសុទ្ធ» (អេសាយ ៦:៣)។ សូម្បីតែព្រះជាម្ចាស់ក៏បានលើកឡើងនូវលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះនេះដែរថា «អញបានស្បថម្តងហើយដោយនូវសេចក្តីបរិសុទ្ធរបស់អញ» (ទំនុកតម្កើង ៨៩:៣៥)។ ព្រះអង្គបានស្បថដោយនូវសេចក្តីបរិសុទ្ធរបស់ទ្រង់ ព្រោះនោះជាលក្ខណសម្បត្តិដែលបង្ហាញយ៉ាងច្បាស់អំពីអង្គទ្រង់ជាងលក្ខណសម្បត្តិផ្សេងៗ

ទៀត។ ហេតុដូច្នេះហើយបានជាកណ្ឌគម្ពីរ ទំនុកតម្កើង ៣០:៤ បានលើកទឹកចិត្តយើងឲ្យ “ច្រៀងសរសើរដល់ព្រះយេហូវ៉ាចុះ ចូរអរព្រះគុណ ដោយនឹកចាំពីសេចក្តីបរិសុទ្ធនៃទ្រង់”។ លោកគ្រូ ជេ. ហូវ (J. Howe, ១៦៧០) បានមានប្រសាសន៍ថា “នេះប្រហែលជាលក្ខណសម្បត្តិដ៏ខ្ពស់ជាងគេ។ លក្ខណសម្បត្តិនេះមានលាយក្នុងលក្ខណសម្បត្តិផ្សេងៗទៀត ហើយការនោះក៏ធ្វើឲ្យលក្ខណសម្បត្តិផ្សេងទៀតជះពន្លឺខ្លាំងជាងមុនដែរ។ នេះគឺជាលក្ខណសម្បត្តិលើសពីលក្ខណសម្បត្តិផ្សេងៗទៀតផង។” ហេតុដូច្នេះហើយបានជាព្រះគម្ពីរចែងអំពី “ភាពចុំថ្កើងរុងរឿងរបស់ព្រះអម្ចាស់” (ទំនុកតម្កើង ២៧:៤ គខប) ដែលនោះគ្មានអ្វីក្រៅពីភាព “បរិសុទ្ធ” របស់ទ្រង់ឡើយ (ទំនុកតម្កើង ១១០:៣)។

“ភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ ល្អលើសជាងភាពល្អឥតខ្ចោះរបស់ទ្រង់ទាំងអស់។ ភាពបរិសុទ្ធគឺជាភាពល្អឥតខ្ចោះរបស់ទ្រង់ ហើយភាពបរិសុទ្ធនោះមានទំនាក់ទំនងជាមួយភាពជាព្រះត្រៃឯករបស់ទ្រង់។ អំណាចចេស្តារបស់ទ្រង់ គឺជាកម្លាំងរបស់ព្រះត្រៃឯក។ ភាពបរិសុទ្ធ គឺជាព្រះសង្ហាររបស់ទ្រង់! ប្រសិនបើទ្រង់គ្មានអំណាចព្រះចេស្តាទេ នោះមានន័យថាទ្រង់ជាព្រះដែលទន់ខ្សោយ ហើយបើទ្រង់គ្មានភាពបរិសុទ្ធទេ នោះមានន័យថា លក្ខណសម្បត្តិរបស់ទ្រង់

ក៏មិនមានភាពល្អឥតខ្ចោះដែរ។ ប្រសិនបើលក្ខណសម្បត្តិនេះមានការខូចខាត នោះលក្ខណសម្បត្តិផ្សេងៗនឹងបាត់បង់កិត្តិយសដែរជាមិនខាន។ រឿងនេះប្រៀបដូចជាការដែលថា ប្រសិនបើព្រះអាទិត្យបាត់បង់ពន្លឺរបស់ខ្លួន នោះវាក៏នឹងបាត់បង់កំដៅ និងកម្លាំងរបស់វាដែរ ក៏ដូចជាឥទ្ធិពលដ៏ខ្លាំងរបស់វាដែរ។ ដូចដែលគ្រីស្ទបរិស័ទគ្រប់គ្នាចង់មានចិត្តស្មោះសរជាយ៉ាងណា នោះសេចក្តីបរិសុទ្ធក៏ជាលម្អនៃលក្ខណសម្បត្តិរបស់ព្រះត្រៃឯកយ៉ាងនោះដែរ។ សេចក្តីយុត្តិធម៌របស់ទ្រង់ គឺជាសេចក្តីយុត្តិធម៌ដ៏បរិសុទ្ធ ឯប្រាជ្ញារបស់ទ្រង់គឺជាប្រាជ្ញាដ៏បរិសុទ្ធ។ អំណាចព្រះចេស្តានៃព្រះហស្តទ្រង់ គឺជា "ព្រះពាហុដ៏បរិសុទ្ធ" (ទំនុកតម្កើង ៩៨:១)។ សេចក្តីពិត ឬក៏សេចក្តីសន្យា គឺជា "ព្រះបន្ទូលដ៏បរិសុទ្ធ" (ទំនុកតម្កើង ១០៥:៤២)។ ព្រះនាមរបស់ទ្រង់ដែលរាប់បញ្ចូលអស់ទាំងលក្ខណសម្បត្តិ គឺជា "ព្រះនាមដ៏បរិសុទ្ធ" (ទំនុកតម្កើង ១០៣:១)" លោកគ្រូ អេស៍. ឆ័រណេខ។

## ការបង្ហាញភាពបរិសុទ្ធរបស់ព្រះជាម្ចាស់

ស្នាព្រះហស្តរបស់ទ្រង់ពណ៌នាអំពីភាពបរិសុទ្ធរបស់ទ្រង់។ "ព្រះយេហូវ៉ាទ្រង់សុចរិតក្នុងគ្រប់ទាំងផ្លូវទ្រង់ ក៏សប្បុរសក្នុងគ្រប់

ទាំងកិច្ចការរបស់ទ្រង់ដែរ» (ទំនុកតម្កើង ១៤៥:១៧)។ មានតែភាពល្អឥតខ្ចោះតែប៉ុណ្ណោះ ដែលអាចកើតចេញមកពីព្រះជាម្ចាស់បាន។ គ្រប់អ្វីៗដែលព្រះអង្គធ្វើ គឺធ្វើចេញពីភាពបរិសុទ្ធរបស់ទ្រង់។ បន្ទាប់ពីទ្រង់បានបង្កើតគ្រប់របស់ទាំងអស់រួចរាល់ហើយ នោះព្រះអង្គបានមានបន្ទូលថា «ទាំងអស់ជាការល្អប្រពៃ» (លោកុប្បត្តិ ១:៣១)។ ប្រាកដណាស់! ព្រះអង្គមិនមានបន្ទូលបែបនេះទេ ប្រសិនបើអ្វីៗដែលទ្រង់បានបង្កើតមកមិនមានភាពល្អឥតខ្ចោះ និងមិនបរិសុទ្ធ។ ព្រះជាម្ចាស់បានបង្កើតមនុស្សមកឲ្យមានលក្ខណៈ «ទៀងត្រង់» ហើយទ្រង់ក៏បានបង្កើតពួកគេដូចរូបអង្គទ្រង់ផងដែរ (សាស្តា ៧:២៩)។ ព្រះគម្ពីរក៏បានប្រាប់យើងដែរថា កាលព្រះជាម្ចាស់បានបង្កើតពួកទេវតាទាំងនោះដែលបានធ្លាក់ក្នុងអំពើបាប ព្រះអង្គបានបង្កើតពួកគេមកក្នុងភាពបរិសុទ្ធ ប៉ុន្តែពួកគេ «មិនបានរក្សាសណ្ឋានដើមរបស់ខ្លួន» (យូដាស ១:៦)។ ព្រះគម្ពីរបានចែងពីអារក្សសាតាំងថា «ចាប់តាំងពីថ្ងៃដែលឯងកើតមក នោះឯងបានគ្រប់លក្ខណ៍ក្នុងគ្រប់ទាំងផ្លូវរបស់ឯង ដរាបដល់វេលាដែលឃើញមានសេចក្តីទុច្ចរិតនៅក្នុងឯង» (អេសេគាល ២៨:១៥)។

ក្រឹត្យវិន័យក៏បង្ហាញពីភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ដែរ។ ក្រឹត្យវិន័យបានហាមមិនឲ្យរាស្ត្ររបស់ព្រះជាម្ចាស់ធ្វើបាបទេ តែ

ឲ្យរាស្ត្ររបស់ព្រះជាម្ចាស់សម្លាប់បាបទាំងនោះចោលវិញ ទោះបើបាបនោះតូច ឬធំក្តី នៅក្នុងចិត្តក៏ដូចជាការប្រាថ្នា ឬការប្រព្រឹត្តិក្តី គឺរាស្ត្ររបស់ព្រះជាម្ចាស់ត្រូវតែសម្លាប់ចោលទាំងអស់! ហេតុដូច្នេះហើយបានជាយើងដឹងថា ក្រឹត្យវិន័យបរិសុទ្ធ «ក្រឹត្យវិន័យបរិសុទ្ធហើយបញ្ញត្តិក៏បរិសុទ្ធ សុចរិត ហើយល្អដែរ» (រ៉ូម ៧:១២ គកស)។ ប្រាកដណាស់ «សេចក្តីបញ្ញត្តរបស់ព្រះយេហូវ៉ាសុទ្ធតែទៀងត្រង់... ក៏បំភ្លឺភ្នែកសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាបរិសុទ្ធ ក៏នៅជាប់ជារៀងរាបដរាប អស់ទាំងខច្បាប់របស់ព្រះយេហូវ៉ាសុទ្ធតែពិតត្រង់ ហើយសុចរិតគ្រប់ជំពូក» (ទំនុកតម្កើង ១៩:៨; ៩)។

ឈើឆ្កាងក៏បានបង្ហាញពីភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ដែរ។ ការដែលព្រះយេស៊ូវធ្វើជាតង្វាយលោះបាប បានបង្ហាញពីភាពបរិសុទ្ធដ៏គ្មានដែនកំណត់របស់ព្រះជាម្ចាស់ និងការដែលទ្រង់ស្អប់អំពើបាបជាខ្លាំង ក្នុងលក្ខណៈយ៉ាងអស្ចារ្យ ហើយក៏គួរឲ្យម៉ត់ចត់ដែរ។ យើងឃើញថា ព្រះជាម្ចាស់ស្អប់អំពើបាបខ្លាំងណាស់ នៅពេលដែលទ្រង់ទម្លាក់ទោសនៃអំពើបាបនោះទៅលើព្រះរាជបុត្រារបស់ទ្រង់។

«ការដែលព្រះជាម្ចាស់ដាក់ទោសមនុស្សអាក្រក់ និងការដែលទ្រង់បំផ្លាញមនសិការរបស់មនុស្សមានបាប ព្រមទាំងការដែលទ្រង់ថ្កោលទោសអារក្សសាតាំង ឬក៏ការដែលទ្រង់ដាក់ទារុណកម្ម

នៅស្ថាននរក គឺមិនស្មើនឹងការដែលទ្រង់ស្អប់អំពើបាបរហូតដល់ទ្រង់បានចាក់សេចក្ដីក្រោធរបស់ទ្រង់លើព្រះរាជបុត្រានៅឯឈើឆ្កាងនោះឡើយ។ គ្មានពេលណាដែលភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ស្រស់ស្អាត និងគួរឲ្យស្រឡាញ់ លើសជាងពេលដែលព្រះជាម្ចាស់ឲ្យព្រះរាជបុត្រាទ្រង់សុគតនៅលើឈើឆ្កាងទេ ពោលគឺនៅពេលដែលទ្រង់បន្លឺសំឡេងមុនពេលដែលទ្រង់សុគត។ យោងតាមកណ្ឌគម្ពីរទំនុកតម្កើងជំពូក២២ យើងបានដឹងថា ព្រះជាម្ចាស់បានជ្រាបពីការនេះរួចទៅហើយ។ នៅពេលដែលព្រះជាម្ចាស់បែរព្រះភក្ត្ររបស់ទ្រង់ចេញពីព្រះយេស៊ូវ ដូចបានចាក់ព្រះហឫទ័យក្រោធរបស់ទ្រង់នឹងកាំបិត ការនោះបានធ្វើឲ្យព្រះយេស៊ូវព្រះកន្សែងទាំងស្រែកយ៉ាងខ្លាំងថា “ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់លះចោលទូលបង្គំ? ”។ ការនេះបង្ហាញថា ទ្រង់ស្រឡាញ់ភាពល្អឥតខ្ចោះនេះ ហើយថា “ទ្រង់បរិសុទ្ធ”» (ទំនុកតម្កើង ២២:៣; លោកគ្រូអេស៍. ឆ័រណោខ)។

ដោយសារព្រះជាម្ចាស់បរិសុទ្ធ ហេតុដូច្នេះហើយបានជាទ្រង់ស្អប់អំពើបាបទាំងអស់។ ព្រះអង្គស្រឡាញ់អ្វីៗទាំងអស់ដែលត្រាប់តាមក្រឹត្យវិន័យទ្រង់ ប៉ុន្តែទ្រង់ស្អប់អ្វីៗទាំងអស់ដែលទាស់ប្រឆាំងនឹងក្រឹត្យវិន័យរបស់ទ្រង់។ ព្រះបន្ទូលរបស់ទ្រង់បានចែងយ៉ាង

ច្បាស់ថា «មនុស្សវៀចជាទីខ្ពើមឆ្អើមដល់ព្រះយេហូវ៉ា» (សុភាសិត ៣:៣២)។ សុភាសិត ១៥:២៦ «គំនិតអាក្រក់ជាសេចក្ដីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា»។ ដោយព្រោះព្រះជាម្ចាស់ស្អប់អំពើបាប ហេតុដូច្នេះហើយបានជាទ្រង់ចាំបាច់ត្រូវតែថ្កោលទោសអំពើបាប និងដាក់ទោសមកលើអំពើបាប។ ប្រសិនបើអំពើបាបមិនបានកើតឡើងទេ នោះទ្រង់ក៏មិនស្អប់វាដែរ ហើយការដាក់ទោសមកលើអំពើបាបក៏មិនមានដែរ។ ព្រះជាម្ចាស់តែងតែអត់ទោសឲ្យមនុស្សមានបាប ប៉ុន្តែទ្រង់មិនដែលអត់ទោសឲ្យអំពើបាបទេ។ ព្រះជាម្ចាស់នឹងអត់ទោសឲ្យមនុស្សមានបាប ប្រសិនបើមានអ្នកដទៃទទួលអំពើបាបនោះជំនួសគាត់ ដោយទទួលយកការដាក់ទោសរបស់ព្រះជាម្ចាស់ជំនួសគាត់ ដ្បិត «បើគ្មានខ្ចាយឈាមទេ នោះគ្មានផ្លូវណាឲ្យបានរួចពីបាបឡើយ» (ហេព្រើរ ៩:២២)។ ហេតុដូច្នេះហើយបានជាព្រះគម្ពីរប្រាប់យើងថា «ព្រះយេហូវ៉ាទ្រង់សងសឹក ហើយក៏មានពេញដោយសេចក្ដីក្រោធ ព្រះយេហូវ៉ាទ្រង់សងសឹក ដល់ពួកអ្នកតតាំងនឹងទ្រង់ ហើយទ្រង់រក្សាទុកនូវសេចក្ដីក្រោធ សម្រាប់ពួកខ្មាំងសត្រូវ» (ណាហ៊ុម ១:២)។ ដ្បិតដោយសារអំពើបាបតែមួយសោះ ព្រះជាម្ចាស់បានដេញលោក អ័ដាម និងនាង អេវ៉ា ដែលជាឪពុកម្ដាយដំបូងរបស់យើងឲ្យចេញពីសួនច្បារអេដែន (លោកុប្បត្តិ ៣)។ ដ្បិតដោយសារ

អំពើបាបតែមួយសោះ កូនចៅទាំងអស់របស់លោក ហាំ បានទទួលបណ្តាសា ហើយបណ្តាសាទាំងនោះក៏នៅជាមួយពួកគេរហូតដល់សព្វថ្ងៃនេះ (លោកុប្បត្តិ ៩:២៤)។ ដ្បិតដោយសារអំពើបាបតែមួយសោះ ព្រះជាម្ចាស់មិនបានអនុញ្ញាតឲ្យលោក ម៉ូសេ ចូលទៅក្នុងទឹកដីកាណាន (ជនគណនា ២០)។ ដ្បិតដោយសារអំពើបាបតែមួយសោះ ព្រះជាម្ចាស់បានធ្វើឲ្យអ្នកបម្រើលោក អេលីយ៉ា កើតរោគឃ្លង់ (២ពង្សាវតាក្សត្រ ៥)។ ដ្បិតដោយសារអំពើបាបតែមួយសោះ ព្រះជាម្ចាស់បានផ្តាច់ជីវិតរបស់លោក អាន៉្នានាស និងនាង សាភីរ៉ា ពីការរស់នៅលើផែនដីនេះ (កិច្ចការ ៥)។

## ទស្សនៈលោកីយ៍អំពីភាពបរិសុទ្ធរបស់ព្រះជាម្ចាស់

តាមរយៈការនេះ យើងអាចឃើញភស្តុតាងអំពីការដែលថា ព្រះជាម្ចាស់ជាព្រះដែលបានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងបទគម្ពីរ (២ធីម៉ូថេ ៣:១៦)។ ពួកអ្នកដែលមិនទាន់បានកើតជាថ្មីច្បាស់ជាមិនជឿថា ព្រះជាម្ចាស់បរិសុទ្ធនោះទេ។ គំនិតរបស់ពួកគេអំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់មានភាពលម្អៀងទៅម្ខាង ដែលនោះមានន័យថាគេមិនយល់ពីទ្រង់ទាំងស្រុងឡើយ។ ពួកគេសង្ឃឹមថា សេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់នឹងនាំឲ្យទ្រង់បំភ្លេច

អ្វីៗផ្សេងទៀតចោល។ កណ្ឌគម្ពីរ ទំនុកតម្កើង ៥០:២១ បានចែងថា «ឯងបានគិតស្មានថា អញដូចឯងតែប៉ុណ្ណោះ»។ គំនិតស្មានបែបនេះ គឺជាគំនិតដែលនាំឲ្យព្រះជាម្ចាស់ទាស់នឹងពួកគេ។ ពួកគេគិតថាព្រះជាម្ចាស់ក៏មិនខុសពីព្រះដែលពួកគេបានឆ្លាក់ច្នៃតាមគំនិតអាក្រក់របស់ខ្លួនដែរ។ ហេតុដូច្នេះហើយបានជាពួកគេបន្តរស់នៅក្នុងគន្លងដ៏ល្ងីល្ងើរបស់ខ្លួនទៀត។ តាមការពណ៌នារបស់ព្រះគម្ពីរ ភាពបរិសុទ្ធរបស់ព្រះជាម្ចាស់មានការខុសគ្នាឆ្ងាយណាស់ពីគំនិតមនុស្ស ដែលការនេះបង្ហាញថាព្រះគម្ពីរមកពីព្រះជាម្ចាស់។ ការដែលមនុស្សជំនាន់មុន និងមនុស្សសម័យនេះវិភាគពីលក្ខណសម្បត្តិនៃព្រះរបស់ពួកគេ (ដែលជាព្រះក្លែងក្លាយ) គឺផ្ទុយពីលក្ខណសម្បត្តិដ៏បរិសុទ្ធ និងល្អឥតខ្ចោះរបស់ព្រះជាម្ចាស់ទាំងស្រុង។ ព្រះដ៏បរិសុទ្ធដែលយើងមិនអាចពណ៌នាបាន មិនមែនជាព្រះដែលកូនចៅរបស់លោក អ័ដាម បានឆ្លាក់ច្នៃនោះទេ។ ព្រះអង្គគឺជាព្រះដែលស្អប់អំពើបាបខ្លាំងណាស់។ គ្មានអ្វីដែលបង្ហាញយ៉ាងច្បាស់លាស់អំពីការដែលមនុស្សបានធ្លាក់ក្នុងអំពើបាប និងការដែលពួកគេប្រឆាំងនឹងព្រះជាម្ចាស់ ជាជាងការដែលពួកគេប្រឈមមុខចំពោះព្រះដ៏បរិសុទ្ធ និងមិនចេះប្រែប្រួលនោះទេ។ គំនិតរបស់ពួកគេអំពីអំពើបាប គឺមិនដូចជាការដែលលោកីយ៍នេះរាប់ថាជា «បទឧក្រិដ្ឋ» នោះ

ទេ។ អ្វីៗផ្សេងទៀតដែលខ្វះមិនដល់ចំណុចនោះ មនុស្សនឹងរាប់ថាជា «ការមិនមានរបៀបរៀបរយ» ឬ «កំហុសឆ្គង» ឬក៏ «ភាពទន់ខ្សោយ»។ល។ ទោះបីជាពួកគេទទួលស្គាល់ថា ខ្លួនបានធ្វើបាបក៏ដោយ ក៏ពួកគេនៅតែយកលេសនិយាយថា អ្វីៗដែលពួកគេបានធ្វើ គឺមិនខុសជ្រុលពេកនោះដែរ។

«ព្រះ» ដែលមនុស្សជាច្រើននាក់ដែលបានរាប់ខ្លួនថាជាគ្រីស្ទបរិស័ទ «ស្រឡាញ់» មើលទៅកាន់ព្រះជាម្ចាស់ថា ទ្រង់ដូចជាបុរសចំណាស់ម្នាក់ដែលមានចិត្តមេត្តា ប៉ុន្តែមិនចូលចិត្តអំពើបាប ហើយទ្រង់បែរជាមើលរំលងអំពើបាបតិចតួចរបស់ពួកគេ ដែលមើលទៅ «គ្មានគ្រោះថ្នាក់» វិញ។ ប៉ុន្តែព្រះបន្ទូលបានចែងហើយថា «ទ្រង់ក៏ស្អប់បណ្ដាអ្នកប្រព្រឹត្តអំពើទុច្ចរិត» (ទំនុកតម្កើង ៥:៥)។ ហើយជាថ្មីម្ដងទៀត «ទ្រង់ជាព្រះដែលមានសេចក្ដីខ្ញាល់ ចំពោះមនុស្សអាក្រក់រាល់តែថ្ងៃ» (ទំនុកតម្កើង ៧:១១)។ ប៉ុន្តែ មនុស្សមិនជឿថាព្រះមានលក្ខណៈបែបនេះទេ ពួកគេបែរជាកើតមានចិត្តក្ដៅក្រហាយ ទាំងសង្កៀតធ្មេញដាក់ទ្រង់ទៀតផង នៅពេលដែលទ្រង់ថ្កោលទោសចំពោះអំពើបាបរបស់ពួកគេដែលទ្រង់ស្អប់។ ទេ! មនុស្សដែលពេញដោយអំពើបាបនឹងមិនមានគំនិតដោយខ្លួនឯងផ្ទាល់ថាព្រះបរិសុទ្ធឡើយ ហើយពួកគេក៏នឹងថា មានបឹងភ្លើងដែលពួកគេនឹងត្រូវទទួល

រងទុក្ខជារៀងដរាបដែរ។

ដោយសារព្រះជាម្ចាស់បរិសុទ្ធ នោះទ្រង់មិនអាចទទួលយកមនុស្សដោយការខិតខំប្រឹងប្រែងរបស់ពួកគេបានឡើយ។ វាជាការងាយស្រួលជាងក្នុងការឲ្យមនុស្សមានបាបបង្កើតផែនដីនេះ ជាជាងធ្វើនូវអ្វីដែលនាំឲ្យព្រះជាម្ចាស់ដែលល្អឥតខ្ចោះទទួលយកពួកគេ។ តើភាពងងឹតអាចនៅជាមួយនឹងពន្លឺបានដែរឬទេ? តើព្រះដ៏ល្អឥតខ្ចោះអាចសព្វព្រះហឫទ័យនឹងយើងដែលប្រៀបដូចជា “អាវកខ្វក់” បានដែរឬទេ? (អេសាយ ៦៤:៦)។ ភាពកខ្វក់គឺជាចំណុចដ៏ល្អបំផុតដែលមនុស្សមានបាបអាចនាំមកចំពោះព្រះជាម្ចាស់។ ដើមឈើអាក្រក់មិនអាចបង្កើតផលផ្លែល្អបានទេ។ ប្រសិនបើព្រះជាម្ចាស់រាប់សេចក្តីទុច្ចរិតរបស់មនុស្សយើងជាសុចរិត នោះឈ្មោះថា ទ្រង់បានបដិសេធរូបអង្គទ្រង់ និងលក្ខណសម្បត្តិរបស់ទ្រង់ហើយ។ គ្រប់អ្វីៗដែលមនុស្សយើងធ្វើ គឺមិនល្អឥតខ្ចោះទេ ហើយក៏ពេញដោយអំពើបាបដែលទាស់ប្រឆាំងនឹងលក្ខណសម្បត្តិរបស់ទ្រង់ដែរ។

## ការសង្គ្រោះមនុស្ស

ប៉ុន្តែ ចូរថ្វាយព្រះពរដល់ព្រះកិត្តិនាមទ្រង់ចុះ ដ្បិតព្រះគុណរបស់ទ្រង់បានបំពេញនូវការទាមទារនៃសេចក្តីបរិសុទ្ធរបស់ព្រះអង្គ

រួចហើយ តាមរយៈព្រះយេស៊ូវគ្រីស្ទដ៏ជាព្រះអម្ចាស់នៃយើង។ ព្រះជាម្ចាស់នឹងទទួលយកអស់អ្នកមានបាបដែលមិនអាចសង្គ្រោះខ្លួនឯងបានមកនៅ «ក្នុងព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់» ប្រសិនបើពួកគេរត់ទៅរកទ្រង់ទុកជាទីពឹងជ្រក (អេភេសូរ ១:៦)។ ហាលេលូយ៉ា! ចូរសរសើរតម្កើងព្រះជាម្ចាស់!

## ការដែលមនុស្សចូលទៅកាន់ព្រះជាម្ចាស់

ដោយព្រោះព្រះជាម្ចាស់បរិសុទ្ធ ដូច្នេះហើយបានជាយើងត្រូវចូលទៅរកទ្រង់ដោយការកោតខ្លាចញាប់ញ័រ។ ទ្រង់ «ជាព្រះដែលគួរស្ញែងខ្លាចណាស់ នៅក្នុងទីប្រជុំនៃអស់អ្នកបរិសុទ្ធ ក៏គួរកោតខ្លាច លើសជាងអស់អ្នកនៅជុំវិញទ្រង់ផង» (ទំនុកតម្កើង ៨៩:៧)។ បន្ទាប់មក «ចូរលើកតម្កើងព្រះយេហូវ៉ាជាព្រះនៃយើងខ្ញុំ ហើយថ្វាយបង្គំនៅទៀបកំណល់កល់ព្រះបាទទ្រង់ ដ្បិតទ្រង់បរិសុទ្ធ» (ទំនុកតម្កើង ៩៩:៥)។ ត្រូវហើយ! យើងត្រូវតែ «ថ្វាយបង្គំនៅទៀបកំណល់កល់ព្រះបាទទ្រង់» នេះជាការបង្ហាញថា យើងបានបន្ទាបខ្លួនឲ្យទាបបំផុតនៅចំពោះព្រះភក្ត្រទ្រង់ ដើម្បីក្រាបថ្វាយបង្គំទ្រង់។ នៅពេលដែលលោក ម៉ូសេ ដើរតម្រង់ទៅកាន់ភ្លើងដែលកំពុងឆេះគុម្ពបន្លា ពេលនោះព្រះជាម្ចាស់បានមានបន្ទូលថា «ចូរដោះ

ស្បែកជើងចេញ» (និក្ខមនំ ៣:៥)។ យើងត្រូវតែបម្រើព្រះអង្គ «ដោយកោតខ្លាច» ដល់ទ្រង់ (ទំនុកតម្កើង ២:១១)។ ទ្រង់បានទាមទារពីសាសន៍អ៊ីស្រាអែលថា «ត្រូវឲ្យអស់អ្នកដែលចូលមកជិតអញ បានលើកអញជាបរិសុទ្ធ ហើយត្រូវឲ្យអញបានសិរីល្អនៅចំពោះមុខជនទាំងឡាយដែរ» (លេវីវិន័យ ១០:៣)។ នៅពេលដែលចិត្តរបស់យើងកាន់តែស្ញប់ស្ញែងចំពោះភាពបរិសុទ្ធដែលមិនអាចពណ៌នាបាន នោះព្រះអង្គនឹងកាន់តែទទួលយើងនៅពេលដែលយើងចូលចំពោះទ្រង់។

ដោយសារព្រះជាម្ចាស់បរិសុទ្ធ ដូច្នេះយើងគួរតែមានចិត្តប្រាថ្នាចង់ក្រាប់តាមទ្រង់។ ព្រះអង្គបានចេញបញ្ញត្តិថា «ចូរឲ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ» (១ពេត្រុស ១:១៦)។ ព្រះជាម្ចាស់មិនបានតម្រូវឲ្យយើងក្លាយទៅជាមនុស្សដែលមានគ្រប់អំណាចចេស្តា ឬក៏ជ្រាបគ្រប់អ្វីៗទាំងអស់នោះទេ ប៉ុន្តែទ្រង់តម្រូវឲ្យយើងមានភាពបរិសុទ្ធ ពោលគឺត្រូវ «បរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់» (១ពេត្រុស ១:១៥)។

«ចំណុចនេះគឺជាចំណុចចម្បងនៃការគោរពកោតខ្លាចដល់ព្រះជាម្ចាស់។ យើងថ្វាយសិរីល្អដល់ព្រះជាម្ចាស់នៅពេលដែលយើងមានមហិច្ឆតាចង់មានទំនាក់ទំនងជាមួយទ្រង់ ដោយមានវិញ្ញាណដែលឥតសៅហ្មង ហើយមានមហិច្ឆតាចង់រស់នៅសម្រាប់ទ្រង់ តាម

រយៈការរស់នៅដូចទ្រង់ដែរ» (លោកគ្រូ អេស៍. ឆ័រណេខ)។

ដោយសារមានតែព្រះជាម្ចាស់មួយប៉ុណ្ណោះដែលជាប្រភពនៃភាពបរិសុទ្ធ ចូរយើងសង្វាតរកសេចក្តីបរិសុទ្ធពីទ្រង់! ចូរអធិស្ឋានទូលសូមទ្រង់ឲ្យ «ញែកអ្នករាល់គ្នាចេញជាបរិសុទ្ធសព្វគ្រប់ ហើយឲ្យទាំងព្រលឹងនិងវិញ្ញាណ ហើយរូបកាយទាំងមូលបានបម្រុងទុកឥតសៅហ្មង ដរាបដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ទ្រង់យាងមក» (១ថែស្សាឡូនីច ៥:២៣)។

ជំពូកទី៩

# ព្រះដ៏មានសព្វានុភាព

## ការបង្កើតឲ្យមានគំនិតត្រឹមត្រូវលើសព្វានុភាពរបស់ព្រះជាម្ចាស់

យើងមិនអាចមានទស្សនៈត្រឹមត្រូវអំពីព្រះជាម្ចាស់បានឡើយ លុះត្រាតែយើងទទួលស្គាល់ថា ទ្រង់ជាព្រះដែលប្រកបដោយសព្វានុភាព និងព្រះប្រាជ្ញាញាណសិន។ ព្រះដែលមិនអាចធ្វើតាមអ្វីៗដែលខ្លួនបានគ្រោងទុក និងមិនអាចធ្វើអ្វីតាមព្រះហឫទ័យខ្លួន គឺមិនអាចជាព្រះដ៏ពិតបានឡើយ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យចង់សម្រេចនូវអ្វីៗដែលទ្រង់ព្រះតម្រិះថាល្អ ដូចទ្រង់មានអំណាចអាចធ្វើអ្វីៗតាមព្រះហឫទ័យរបស់ទ្រង់បានដែរ។

“សព្វានុភាពរបស់ព្រះជាម្ចាស់មានន័យថា ទ្រង់មានសមត្ថភាព និងមានកម្លាំងអាចធ្វើនូវអ្វីៗដែលទ្រង់សព្វព្រះហឫទ័យឲ្យកើតឡើងបាន និយាយរួមគឺអ្វីៗទាំងអស់ដែលស្ថិតក្រោមការត្រួត

ត្រានៃព្រះប្រាជ្ញាញាណដ៏គ្មានដែនកំណត់របស់ទ្រង់ និងអ្វីៗទាំងអស់ដែលភាពបរិសុទ្ធដ៏គ្មានដែនកំណត់របស់ទ្រង់បានសម្រេចធ្វើ...ជាមួយគ្នាដែរ ប្រសិនបើសេចក្ដីបរិសុទ្ធរបស់ព្រះជាម្ចាស់ គឺជាភាពថ្កុំថ្កើងនៃលក្ខណសម្បត្តិរបស់ទ្រង់ នោះសព្វានុភាពរបស់ទ្រង់ គឺជាឫទ្ធានុភាពដែលធ្វើឲ្យអ្វីៗគ្រប់យ៉ាងមានជីវិត ហើយមានចលនា ដើម្បីបង្ហាញពីលក្ខណៈគ្រប់លក្ខណ៍នៃភាពជាព្រះរបស់ទ្រង់។ ព្រះតម្រិះសម្រេចរបស់ទ្រង់នឹងមិនមានប្រយោជន៍អ្វីឡើយ ប្រសិនបើទ្រង់មិនអាចធ្វើឲ្យអ្វីៗឲ្យកើតឡើងបាន។ ប្រសិនបើទ្រង់គ្មានអំណាចព្រះចេស្ដា នោះសេចក្ដីមេត្តាករុណារបស់ទ្រង់ក៏មិនអាចជួយអ្វីដល់យើងបានដែរ។ រីឯសេចក្ដីសន្យារបស់ទ្រង់ក៏ប្រៀបដូចជាខ្យល់ ហើយការគម្រាមកំហែងរបស់ទ្រង់វិញ គឺគ្រាន់តែដូចជាទីងមោងមួយប៉ុណ្ណោះ។

សព្វានុភាពរបស់ទ្រង់ គឺមានលក្ខណៈដូចជាអង្គទ្រង់ផ្ទាល់តែម្ដង៖ ពោលគឺគ្មានដែនកំណត់ ស្ថិតស្ថេរនៅជាដរាប មិនអាចយល់បាន ហើយក៏គ្មានអ្នកណាម្នាក់អាចពិនិត្យឆែកឆេរ ហាមឃាត់ ឬក៏រារាំងទ្រង់បានឡើយ» (លោកគ្រូ អេស៍. ឆ័រណខ )។

កណ្ឌគម្ពីរ ទំនុកតម្កើង ៦២:១១ បានចែងថា «ព្រះទ្រង់បានមានបន្ទូលម្ដងហើយ ខ្ញុំបានឮសេចក្ដីនេះ២ដងផង គឺថា ឫទ្ធានុភាព

សម្រេចនៅលើព្រះ»។ ដោយសារតែ «ព្រះទ្រង់បានមានបន្ទូលម្តងហើយ»៖ ដូច្នេះទ្រង់មិនចាំបាច់មានបន្ទូលម្តងទៀតនោះទេ! ផ្ទៃមេឃនិងផែនដីនឹងកន្លងបាត់ទៅ តែព្រះបន្ទូលរបស់ទ្រង់នឹងមិនដែលបាត់ឡើយ (ម៉ាថាយ ២៤:៣៥) ពីព្រោះ «ព្រះទ្រង់បានមានបន្ទូលម្តងហើយ»។ ដូច្នេះ ទ្រង់ស័ក្តិសមនឹងទទួលអានុភាពដ៏អស្ចារ្យ! រីឯយើងទាំងអស់គ្នាដែលជាមនុស្សទៀងនឹងស្លាប់វិញ ប្រហែលជាត្រូវនិយាយម្តងហើយម្តងទៀត ហើយក៏គ្មានអ្នកណាស្តាប់យើងទេ។ ប៉ុន្តែ ចំពោះព្រះជាម្ចាស់វិញ ទ្រង់គ្រាន់តែមានព្រះបន្ទូលមួយព្រះឱស្ឋប៉ុណ្ណោះ ព្រះបន្ទូលនោះក៏សាយភាយពីជើងមេឃម្ខាងដល់ជើងមេឃម្ខាងទៀត។

«ព្រះយេហូវ៉ាទ្រង់បញ្ចេញជាផ្គរនៅលើមេឃ ព្រះដ៏ខ្ពស់បំផុតទ្រង់បញ្ចេញព្រះសូរសៀង ព្រមទាំងព្រឹល នឹងរងើកភ្លើងផង ក៏បាញ់ព្រួញនៃទ្រង់ទៅកំចាត់កំចាយគេ នឹងរន្ទះជាច្រើន ទៅបំបាក់ពួកគេនោះបាតផ្លូវទឹកក៏លេចឡើង ហើយឫសលោកីយ៍បានបើកឲ្យឃើញដោយទ្រង់បន្ទោស ឱព្រះយេហូវ៉ាអើយ គឺដោយព្ទសូរខ្យល់គំហុកចេញពីព្រះនាសាទ្រង់» (ទំនុកតម្កើង ១៨:១៣-១៥)។

«ព្រះទ្រង់បានមានបន្ទូលម្តងហើយ» ចូរឲ្យយើងស្ងប់ស្ងែងនឹងសញ្ញានុភាពដែលមិនចេះប្រែប្រួលរបស់ទ្រង់ចុះ។ «ដ្បិតតើមានអ្នក

ណានៅលើមេឃ ដែលផ្ទឹមនឹងព្រះយេហូវ៉ាបាន ក្នុងអស់ពួកខ្លាំងពូកែ តើមានអ្នកណាឲ្យដូចព្រះយេហូវ៉ា» (ទំនុកតម្កើង ៨៩:៦)។ «ឯអស់ទាំងមនុស្សលោកក៏រាប់ទុកជាឥតការទទេ ទ្រង់ធ្វើតាមតែព្រះហឫទ័យក្នុងពួកពលបរិវារនៃស្ថានសួគ៌ ហើយនៅកណ្តាលពួកមនុស្សលោកផង ឥតមានអ្នកណាអាចនឹងឃាត់ទប់ព្រះហស្តទ្រង់ ឬនឹងទូលសួរទ្រង់ថា "ទ្រង់ធ្វើអ្វីដូច្នេះបានឡើយ?"» (ដានីយ៉ែល ៤:៣៥)។ ព្រះជាម្ចាស់បានបង្ហាញពីការនេះយ៉ាងច្បាស់ នៅពេលដែលទ្រង់យាងមកយកកំណើតជាមនុស្ស ហើយរស់នៅជាមួយនឹងមនុស្សលោក (យ៉ូហាន ១:១៤)។ ព្រះយេស៊ូវបានមានព្រះបន្ទូលទៅកាន់អ្នកកើតរោគឃ្លង់ដែលចង់ឲ្យទ្រង់ព្យាបាលគាត់ថា «ខ្ញុំចង់ដែរ ចូរឲ្យជាស្អាតចុះ ស្រាប់តែរោគឃ្លង់ក៏ជាស្អាតភ្លាម» (ម៉ាថាយ ៨:៣)។ ព្រះអង្គបានមានព្រះបន្ទូលទៅបុគ្គលម្នាក់ដែលគេបានកប់នៅក្នុងផ្នូរអស់រយៈពេលបួនថ្ងៃថា «ឡាសារអើយ! ចូរចេញមក!» ហើយអ្នកស្លាប់នោះក៏ចេញមកមែន (យ៉ូហាន ១២:៤៣)។ មួយទៀត ទ្រង់បានកំហែងខ្យល់ និងបង្គាប់ឲ្យសមុទ្រនៅស្ងៀម ហើយឈប់ទ្រឹងដោយព្រះបន្ទូលរបស់ទ្រង់ដែរ (ម៉ាកុស ៤:៣៩; ម៉ាថាយ ៨:២៣-២៧)។ សូម្បីតែពួកអារក្សមួយចំនួនក៏មិនអាចបដិសេធដោយមិនស្តាប់បញ្ញត្តិដ៏មានអំណាចព្រះចេស្តារបស់ទ្រង់បានដែរ

(ម៉ាថាយ ៨:២៨-៣៤)។

## ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ និងអំនួតរបស់មនុស្ស

"ឫទ្ធានុភាពសម្រេចនៅលើព្រះ" គឺនៅលើអង្គទ្រង់តែមួយគត់។ គ្មានអ្វីនៅលើចក្រវាលនេះមានឫទ្ធានុភាពនោះទេ សូម្បីតែបន្តិចក៏គ្មានដែរ លើកលែងតែទ្រង់ប្រទានឫទ្ធានុភាពនោះឲ្យគេ។ ប៉ុន្តែឫទ្ធានុភាពរបស់ទ្រង់ ទ្រង់មិនចាំបាច់យាងទៅស្វែងរក ឬក៏ទិញពីកន្លែងណាមួយនោះទេ ហើយក៏មិនចាំបាច់មានអ្នកណាម្នាក់ទទួលស្គាល់ថា ទ្រង់មានឫទ្ធានុភាពដែរ ដ្បិតឫទ្ធានុភាពនោះមាននៅលើទ្រង់ផ្ទាល់រួចស្រេចទៅហើយ។

"ឫទ្ធានុភាពរបស់ព្រះជាម្ចាស់គឺមានលក្ខណៈដូចទ្រង់ផ្ទាល់តែម្តង៖ ទ្រង់មានព្រះជន្មដោយអង្គទ្រង់ផ្ទាល់ ហើយក៏ទ្រទ្រង់ដោយអង្គទ្រង់ផ្ទាល់ដែរ។ ទោះបីជាមនុស្សដែលខ្លាំងជាងគេនៅលើពិភពលោកនេះ ក៏មិនអាចបន្ថែមឫទ្ធានុភាពដ៏ខ្លាំងក្លាណាមួយដល់ព្រះដ៏មានសព្វានុភាពបានដែរ សូម្បីតែប៉ុនសរសៃសក់ក៏មិនបានផង។ ទ្រង់មិនគង់នៅលើបល្ល័ង្កដែលមានប្រដាប់ទប់ទ្រ ហើយទ្រង់ក៏មិនផ្អែកលើដៃបល្ល័ង្កជាជំនួយដែរ។ រាជវាំងរបស់ទ្រង់មិនត្រូវការអ្នកថែរក្សា ឬក៏ខ្វីភាពរុងរឿងពីអ្វីៗដែលទ្រង់បានបង្កើតនោះដែរ។

ដ្បិតទ្រង់ផ្ទាល់គឺជាចំណុចស្នូលដ៏អស្ចារ្យ និងជាមេផ្តើមនៃអំណាចព្រះចេស្តា ដោយអង្គទ្រង់ផ្ទាល់រួចស្រាប់ទៅហើយ» (លោកគ្រូ ស៊ី. អេឆ. ស្ពើចិន)។

គ្រប់របស់សព្វសារពើមិនត្រឹមតែស្ញប់ស្ញែងនឹងឫទ្ធានុភាពដ៏អស្ចារ្យរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែពួកវាក៏ស្ញប់ស្ញែងចំពោះការដែលព្រះជាម្ចាស់មិនត្រូវការពួកវាផងដែរ។ ចូរអានការសួរដេញដោលរបស់ទ្រង់៖ «តើឯងនៅឯណាក្នុងកាលដែលអញចាប់តាំងបង្កផែនដីឡើង ចូរប្រាប់មក បើឯងមានយោបល់ បើឯងដឹង តើអ្នកណាបានកំណត់ទំហំផែនដី តើអ្នកណាបានសន្ធឹងខ្សែទៅវាស់ តើឫសផែនដីបានទៅជាប់នៅលើអ្វី តើអ្នកណាបានបញ្ចុះថ្មជ្រុងនោះ» (យ៉ូប ៣៨:៤-៦)។ តាមរយៈសំណួរនេះ យើងឃើញថា ព្រះជាម្ចាស់បានកប់អំនួតរបស់មនុស្សយើងទៅក្នុងដីបាត់ហើយ!

«ព្រះគម្ពីរក៏បានប្រើពាក្យ “ព្រះចេស្តា” ថាជាព្រះនាមរបស់ព្រះជាម្ចាស់ដែរ៖ “កូនមនុស្សអង្គុយនៅខាងស្តាំនៃព្រះចេស្តា” (ម៉ាកុស ១៤:៦២)។ ឃ្លាថា “នៅខាងស្តាំនៃព្រះចេស្តា” មានន័យថា “នៅខាងស្តាំព្រះជាម្ចាស់”។ យើងមិនអាចបំបែកព្រះជាម្ចាស់និងអំណាចព្រះចេស្តារបស់ទ្រង់ចេញពីគ្នាបានទេ តែផ្ទុយទៅវិញអំណាចព្រះចេស្តាគឺជាការឆ្លើយតបរបស់ព្រះជាម្ចាស់ចំពោះភាព

ជាព្រះរបស់ទ្រង់។ ដោយសារភាពជាព្រះរបស់ទ្រង់ធំក្រៃលែង នោះព្រះវត្តមានរបស់ទ្រង់ក៏មិនមានព្រំដែន ត្រង់ថាទ្រង់ត្រូវគង់នៅតែកន្លែងណាមួយប៉ុណ្ណោះនោះទេ។ ដូចដែលទ្រង់មានព្រះជន្មអស់កល្បជានិច្ច ហើយទ្រង់ក៏មិនស្ថិតក្រោមពេលវេលា ដូចគ្នានោះដែរ ព្រះអង្គក៏មានពេញទៅដោយព្រះចេស្តា ហើយធ្វើនូវអ្វីដែលទ្រង់សព្វព្រះហឫទ័យក៏បានដែរ» (លោកគ្រូ អេស៍. ឆ័រណខ)។

កណ្ឌគម្ពីរ យ៉ូប ២៦:១៤ បានចែងថា «មើល៍ ការទាំងនេះគ្រាន់តែជាកិច្ចខាងក្រៅរបស់ទ្រង់ទេ ហើយយើងឮនិយាយពីទ្រង់ ជាសំឡេងខ្សាវយ៉ាងណាទៅ ឯសំឡេងលាន់ឮពីឥទ្ធិឫទ្ធិរបស់ទ្រង់នោះតើអ្នកណានឹងយល់បាន?»។ តើអ្នកណាអាចរាប់ចំនួនស្នាព្រះហស្តរបស់ទ្រង់បាន? តើអ្នកណាមានសមត្ថភាពក្នុងការរាប់គ្រប់ការរម្លឹកទាំងអស់នៃអំណាចព្រះចេស្តារបស់ព្រះជាម្ចាស់បាន? សូម្បីតែតាមរយៈការដែលអ្វីៗដែលទ្រង់បានបង្កើតមកបង្ហាញអំពីព្រះចេស្តារបស់ទ្រង់ក៏លើសពីការយល់ទាំងស្រុងរបស់យើងផងដែរ។ ហើយយើងក៏កាន់តែមិនសូវយល់ដែរ នៅពេលដែលយើងព្យាយាមយល់នូវអត្ថន័យនៃពាក្យ «សព្វានុភាព»។ ពិតណាស់! មានអំណាចដែលមិនមានព្រំដែនក្នុងលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ច្រើនជាងការដែលរបស់សព្វសារពើដែលទ្រង់បានបង្កើតមកបង្ហាញឲ្យឃើញ។

# ការលាក់ឫទ្ធានុភាពរបស់ព្រះជាម្ចាស់

ចំពោះ «កិច្ចខាងក្រៅរបស់ទ្រង់»៖ យើងបានមើលឃើញតាមរយៈអ្វីៗដែលទ្រង់បានបង្កើតមក តាមរយៈការគ្រោងទុក និងតាមរយៈការប្រោសលោះរបស់ទ្រង់ ប៉ុន្តែនោះគ្រាន់តែជាឫទ្ធានុភាពបន្តិចបន្តួចដែលយើងបានមើលឃើញតែប៉ុណ្ណោះ។ កណ្ឌគម្ពីរ ហាបាគុក ៣:៤ បានប្រាប់យើងយ៉ាងច្បាស់ថា «នោះឯងជាទីលាក់ទុកនូវព្រះចេស្ដានៃទ្រង់»។ យើងមិនអាចគិតឃើញពីអ្វីដែលហួសពីរូបភាពដ៏អស្ចារ្យ នៃការបំភ្លៃរៅហារនៅក្នុងខគម្ពីរនេះទេ ហើយក៏គ្មានអ្វីហួសពីភាពថ្លៃថ្នូរនៃការដែលឃ្លានេះបានពណ៌នាដែរ។ ហោរាហាបាគុក បានឃើញការជាក់ស្ដែងអំពីព្រះដ៏មានព្រះចេស្ដា ដែលទ្រង់កំចាត់កំចាយកូនភ្នំ និងបានក្រឡាប់ភ្នំនានា។ តាមរយៈការជាក់ស្ដែងនេះ យើងប្រហែលជាគិតថា ព្រះទ្រង់កំពុងសម្ដែងព្រះចេស្ដាដ៏អស្ចារ្យរបស់ទ្រង់ហើយ ប៉ុន្តែសូមកុំច្រឡំឲ្យសោះ ពីព្រោះខគម្ពីរនេះបានប្រាប់យើងហើយថា ការនោះគឺ «ជាទីលាក់ទុក» របស់ទ្រង់ ជាជាងការបង្ហាញពីអំណាចព្រះចេស្ដារបស់ទ្រង់វិញ។ តើនេះមានន័យយ៉ាងដូចម្ដេច? នេះមានន័យថា៖ យើងមិនអាចយល់ពីអំណាចព្រះចេស្ដារបស់ព្រះជាម្ចាស់បានឡើយ ព្រោះអំណាចព្រះចេស្ដារបស់ទ្រង់ធំធេងណាស់ ហើយក៏គ្មានអ្នកណាអាចគ្រប់

គ្រងបានដែរក្រៅពីទ្រង់។ សូម្បីតែការដែលទ្រង់ប្រើអំណាចនោះនៅក្នុងធម្មជាតិ ក៏ធម្មជាតិលាក់ពីយើង ជាជាងបង្ហាញពីអំណាចព្រះចេស្ដាដ៏គ្មានដែនកំណត់របស់ទ្រង់ដល់យើងដែរ!

## ភាពធំសម្បើមនៃឫទ្ធានុភាពរបស់ព្រះជាម្ចាស់

ប្រសិនបើយើងតភ្ជាប់បទគម្ពីរទាំងនេះភ្ជាប់គ្នា នោះជាការប្រពៃណាស់៖ ទ្រង់ «យាងទៅលើរលកសមុទ្រ» ពណ៌នាពីអំណាចព្រះចេស្ដាដ៏គ្មានគូប្រៀបបាន (យ៉ូប ៩:៨)។ ចំណុចដែលថា «ទ្រង់ក៏យាងនៅតែលើផ្ទៃមេឃ» ក៏បង្ហាញពីព្រះវត្តមានដ៏មហិមារបស់ទ្រង់ផងដែរ (យ៉ូប ២២:១៤)។ ការដែល «ទ្រង់យាងលើស្លាបខ្យល់» បញ្ជាក់ពីការសម្រេចព័ន្ធកិច្ចដ៏រហ័សរបស់ទ្រង់ (ទំនុកតម្កើង ១០៤:៣)។ យើងត្រូវចាប់អារម្មណ៍លើខគម្ពីរចុងក្រោយនេះឲ្យមែនទែន។ ទ្រង់មិនបាន «ហោះ» ឬក៏ «រត់» នោះទេ ប៉ុន្តែទ្រង់បាន «យាងលើស្លាបខ្យល់» ហើយការនេះបញ្ជាក់ថាទ្រង់បានយាងលើធម្មជាតិដែលពោរពេញដោយកម្លាំងរុញច្រាន ដែលម្ដងបក់ទៅខាងលិច ម្ដងបក់ទៅខាងកើតដោយសារកម្លាំងយ៉ាងខ្លាំង ហើយបក់ទៅបក់មកដោយកម្លាំងខ្យល់ដែលយើងគិតមិនដល់។ ប៉ុន្តែ ទោះជាយ៉ាងនេះក្ដី ក៏ខ្យល់នោះនៅក្រោមព្រះបាទរបស់ទ្រង់ដែរ ពោលគឺនៅក្រោម

ការគ្រប់គ្រងដ៏ល្អឥតខ្ចោះរបស់ទ្រង់!

ចូរយើងសញ្ជឹងគិតអំពីអំណាចព្រះចេស្តារបស់ទ្រង់ ក្នុងការដែលទ្រង់បង្កើតរបស់សព្វសារពើទាំងអស់មក។ «ផ្ទៃមេឃជារបស់ផងទ្រង់ ព្រមទាំងផែនដីផង ឯលោកីយ៍ និងសព្វសារពើ ដែលនៅក្នុងលោកីយ៍ នោះគឺទ្រង់បានសង់ឡើងដែរ ទ្រង់បានបង្កើតទិសខាងជើង និងទិសខាងត្បូង ឯភ្នំតាបោរ និងភ្នំហ៊ើម៉ូន នោះក៏បានរីករាយចំពោះព្រះនាមទ្រង់» (ទំនុកតម្កើង ៨៩:១១-១២)។ មុនដែលមនុស្សយើងអាចធ្វើកិច្ចការអ្វីមួយបាន គឺយើងត្រូវការឧបករណ៍ និងសម្ភារៈផ្សេងៗ ប៉ុន្តែព្រះជាម្ចាស់មិនត្រូវការអ្វីឡើយ ក្នុងការដែលទ្រង់បានចាប់ផ្តើមសូនផែនដី និងផ្ទៃមេឃ។ ព្រះអង្គគ្រាន់តែមានព្រះបន្ទូល នោះភាពទទេសូន្យក៏កើតមានរបស់សព្វសារពើទាំងអស់។ ហើយប្រាជ្ញារបស់យើងមិនអាចយល់អំពីការនេះបានទេ «ដ្បិតទ្រង់គ្រាន់តែមានបន្ទូល នោះក៏កើតមានដូច្នោះ ទ្រង់បានបង្គាប់ នោះក៏មាននៅ» (ទំនុកតម្កើង ៣៣:៩)។ រូបធាតុតាំងពីបុរាណបានឮព្រះបន្ទូលរបស់ទ្រង់ «ព្រះទ្រង់មានបន្ទូលថាចូរឲ្យមាន...ដូច្នេះក៏មានឡើង» (លោកុប្បត្តិ ១)។ ចូរយើងបន្លឺសម្រែកឡើងថា «ទ្រង់មានព្រះពាហុខ្លាំងពូកែ ព្រះហស្តទ្រង់មានឫទ្ធិខ្លាំង ព្រះហស្តស្តាំទ្រង់ក៏ខ្ពស់ណាស់» (ទំនុកតម្កើង ៨៩:១៣[១])។

“នៅពេលដែលបុរសម្នាក់ងើយមើលទៅផ្ទៃមេឃនៅពេលយប់ ហើយឮសំឡេងផ្គរលាន់នៃព្យុះមួយ តើគាត់នឹងមានគំនិតបែបណាចំពោះព្រះអាទិករ? គាត់នឹងគិតថា នេះជាការអស្ចារ្យណាស់ ព្រោះព្រះបានបង្កើតផ្គរលាន់ទាំងនោះដោយមិនប្រើសម្ភារៈអ្វីទាល់តែសោះ។ ព្រះជាម្ចាស់បានបង្កើតផ្គរលាន់នោះពីភាពទទេសូន្យតែម្តង ហើយរចនាសម្ព័ន្ធនៃសកលលោកនេះក៏ទ្រង់បានបង្កើតចេញពីភាពទទេសូន្យផងដែរ។ ព្រះជាម្ចាស់មិនបានប្រើឧបករណ៍អ្វីមួយមកតុបតែងរៀបចំចក្រវាលនេះទេ។ ព្រះជាម្ចាស់បានធ្វើឲ្យគ្រប់ ចំណុចទាំងអស់មានលក្ខណៈល្អស្មើៗគ្នា។ គ្រប់កិច្ចការទាំងអស់ដែលទ្រង់បានបង្កើតមក គឺសុទ្ធតែកើតចេញពីការបង្គាប់របស់ទ្រង់។ នៅពេលដែលព្រះជាម្ចាស់មានបន្ទូលថា “ចូរឲ្យមាន” នោះក៏មានឡើងមែន។ ព្រះអង្គមិនបានបន្ថែមអ្វីទៀតទេ គឺទ្រង់គ្រាន់តែមានព្រះបន្ទូលតែប៉ុណ្ណោះ នោះរចនាសម្ព័ន្ធដ៏ស្អាត ហើយគ្រប់លក្ខណ៍ ក៏បានលេចចេញជារូបរាងឡើងក្នុងចំណោមពួកទេវតាដែលកំពុងច្រៀងសរសើរតម្កើងព្រះអាទិករ។ កណ្ឌគម្ពីរ ទំនុកតម្កើង ៣៣:៦ បានចែងថា “ផ្ទៃមេឃបានកើតមក ដោយសារព្រះបន្ទូលព្រះយេហូវ៉ា ហើយពួកបរិវារនៅលើនោះ បានកើតដោយសារខ្យល់ពីព្រះឱស្ឋទ្រង់”»។[១] (លោកគ្រូ ចេមស៍ ហើវី James Hervey, ១៧៨៩)។

ចូរយើងសញ្ជឹងគិតអំពីសព្វានុភាពរបស់ទ្រង់ក្នុងការដែលទ្រង់ផ្គត់ផ្គង់ ទំនុកបម្រុង និងថែរក្សាយើង។ អ្វីៗដែលព្រះជាម្ចាស់បានបង្កើតមិនអាចផ្គត់ផ្គង់ ទំនុកបម្រុង និងថែរក្សាខ្លួនឯងបានទេ។ កណ្ឌគម្ពីរ យ៉ូប ៨:១១ បានចែងថា «តើដើមកក់ដុះដោយឥតភក់បាន ឬ ឯដើមផ្នក់ទឹក តើនឹងដុះដោយឥតទឹកបានឬទេ»? ទាំងមនុស្ស និងសត្វប្រាកដជាស្លាប់ ប្រសិនបើគ្មានរុក្ខជាតិ និងសត្វធ្វើជាម្ហូបអាហារ ហើយរុក្ខជាតិក៏នឹងប្រាកដជាងាប់ដែរ ប្រសិនបើព្រះជាម្ចាស់មិនប្រទានទឹក ដើម្បីឲ្យវាលូតលាស់ ហើយបង្កើតផលផ្លែទេនោះ។ ហេតុដូច្នេះហើយបានជាយើងហៅព្រះនាមព្រះជាម្ចាស់ថា ជាអង្គដែល «ទំនុកបម្រុងទាំងមនុស្ស និងសត្វ» (ទំនុកតម្កើង ៣៦:៦) «ទ្រទ្រង់គ្រប់របស់ទាំងអស់ ដោយសារព្រះបន្ទូលដ៏មានព្រះចេស្ដានៃទ្រង់» (ហេព្រើរ ១:៣)។ នេះជាអំណាចព្រះចេស្ដាដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ដែលទ្រង់បានប្រើ ដើម្បីថែរក្សាមនុស្សយើងគ្រប់ៗរូប! ការដែលទារកអាចមានជីវិតរស់នៅក្នុងផ្ទៃដ៏តូច និងគគ្រិចរបស់ម្ដាយខ្លួនអស់ជាច្រើនឆ្នាំ ដោយមិនចាំបាច់ដកដង្ហើម គឺមិនអាចទៅរួចបានទេ ប្រសិនបើគ្មានអំណាចព្រះជាម្ចាស់។ ប្រាកដណាស់ គឺព្រះជាម្ចាស់ហើយដែលបាន «រក្សាជីវិតយើងឲ្យរស់នៅ» (ទំនុកតម្កើង ៦៦:៩)។

ការដែលព្រះជាម្ចាស់ការពារ និងថែរក្សាផែនដីពីអំណាចនៃសមុទ្រកុំឲ្យលិចលង់ គឺជាការបង្ហាញពីអំណាចនៃព្រះចេស្តាដ៏ខ្លាំងរបស់ទ្រង់។ តើធ្វើយ៉ាងដូចម្ដេចបានជាទឹកនៅកន្លែងដើមរបស់ខ្លួន ពោលគឺវានឹងនៅកន្លែងដែលព្រះបានឲ្យវានៅ ដោយមិនបណ្ដាលឲ្យមានទឹកជំនន់លិចផែនដី ហើយមិនកម្ទេចតំបន់ទាបៗនៃផែនដីនេះបាន? ជាទូទៅ ស្ថានភាពធម្មជាតិរបស់ទឹកគឺត្រូវនៅពីលើផែនដី ដោយសារតែវាមានទម្ងន់ស្រាលជាងដី ហើយវាត្រូវនៅក្រោមខ្យល់ ដោយសារវាធ្ងន់ជាងខ្យល់។ តើមានអ្នកណាអាចឃាត់ទប់ធម្មជាតិមិនឲ្យមានលក្ខណៈបែបនេះបាន? ប្រាកដជាមិនមែនមនុស្សលោកទេ ហើយមនុស្សលោកក៏គ្មានអំណាចអ្វីបែបនេះដែរ គឺមានតែការបង្គាប់ដែលមកពីព្រះអាទិករមួយប៉ុណ្ណោះដែលអាចឃាត់ទប់វាបាន "ដោយពាក្យថា ឯងនឹងមកបានតែត្រឹមនេះ នឹងហួសទៅទៀតមិនបាន រលកដ៏អង់អាចរបស់ឯងត្រូវឈប់នៅទីនេះ" (យ៉ូប ៣៨:១១)។ ការដែលព្រះជាម្ចាស់ទ្រទ្រង់ ថែរក្សា ហើយទំនុកបម្រុងផែនដី គឺជាការបង្ហាញពីស្នាព្រះហស្តដែលប្រកបដោយអំណាចព្រះចេស្តារបស់ទ្រង់!

ចូរយើងសញ្ជឹងគិតអំពីអំណាចព្រះចេស្តារបស់ទ្រង់ ក្នុងការដែលទ្រង់គ្រប់គ្រងរាជរដ្ឋាភិបាល។ ឧទាហរណ៍៖ ព្រះជាម្ចាស់បានរារាំង

ទប់ស្កាត់អារក្សសាតាំងមិនឲ្យវាប្រព្រឹត្តអំពើព្យាបាទ។ កណ្ឌគម្ពីរ ១ពេត្រុស ៥:៨ បានចែងថា “អារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន”។ អារក្សសាតាំងវាស្អប់ព្រះជាម្ចាស់ខ្លាំងណាស់ ហើយវាធ្វើអំពើសាហាវយង់ឃ្នងលើមនុស្សយើង ជាពិសេសលើអ្នកជឿដែលជាពួកបរិសុទ្ធរបស់ព្រះជាម្ចាស់។ វាច្រណែននឹងលោក អ័ដាម នៅក្នុងសួនច្បារអេដែន ហើយវាក៏ច្រណែននឹងយើងដែរ ពោលគឺវាមិនចង់ឲ្យយើងទទួលបានការអរសប្បាយចេញពីព្រះពររបស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើអារក្សសាតាំងអាចធ្វើអ្វីតាមតែចិត្តរបស់វាបាន នោះវាប្រាកដជាធ្វើចំពោះយើងគ្រប់គ្នាដូចដែលវាបានធ្វើចំពោះលោក យ៉ូប ជាមិនខានះ វានឹងពិតជាទម្លាក់ភ្លើងពីលើមេឃ ដើម្បីបំផ្លាញភោគផលរបស់ផែនដី សម្លាប់គោក្របី បង្កឲ្យមានព្យុះភ្លៀងដើម្បីរំលំផ្ទះយើងចោល ឬក៏ធ្វើឲ្យខ្លួនរបស់យើងមានពេញទៅដោយដំបៅជាមិនខាន។ ប៉ុន្តែ ទោះបីជាមនុស្សយើងមិនសូវដឹងអំពីចំណុចនេះក៏ដោយ ក៏ព្រះជាម្ចាស់នៅតែបង្ខាំងវាយ៉ាងពេញទីដែរ ដោយរារាំងវាមិនឲ្យធ្វើសម្រេចតាមគម្រោងការរបស់វាឡើយ ហើយទ្រង់ក៏ឃុំវាក្នុងព្រំដែនដែលទ្រង់បានបង្គាប់ឲ្យវានៅក្រោមដែរ។

ព្រះជាម្ចាស់ក៏រារាំងមិនឲ្យមនុស្សយើងចេះតែធ្វើតាមនិស្ស័យដ៏ពុករលួយរបស់យើងផងដែរ។ ទ្រង់អនុញ្ញាតឲ្យយើងរងទុក្ខក្នុងអំពើបាបរបស់ខ្លួន ដើម្បីបង្ហាញថា យើងមិនអាចសង្គ្រោះខ្លួនឯងបាន ហើយយើងក៏នៅដាច់ឆ្ងាយពីទ្រង់ដែរ។ «តែគ្រប់គ្នាបានវង្វេងចេញ បានត្រឡប់ទៅជាស្មោកគ្រោកទាំងអស់ គ្មានអ្នកណាមួយដែលប្រព្រឹត្តល្អឡើយ សូម្បីតែ១ក៏គ្មានផង» (ទំនុកតម្កើង ១៤:៣)។ «ហើយមាត់គេមានពេញដោយសេចក្ដីបណ្ដាសា នឹងសេចក្ដីជូរចត់ ជើងគេរហ័សនឹងកំចាយឈាម» (រ៉ូម ៣:១៤-១៥)។ នេះហើយគឺជានិស្ស័យដើមរបស់កូនចៅលោក អ័ដាម។ ប្រសិនបើព្រះជាម្ចាស់មិនបានចុះអន្តរាគមន៍ ហើយរាំងមនុស្សយើងពីការបែរទៅរកអំពើបាបទាំងស្រុង អំពើអសីលធម៌ដែលមិនមានការគ្រប់គ្រងលើ នោះអំនួតដ៏ល្វីល្វើនឹងសោយរាជ្យលើផែនដីនេះជាមិនខាន។ ប៉ុន្តែ វាពិតជាហួសហេតុណាស់ ដែលយើងនៅព្យាយាមដោះខ្លួនចេញពីព្រះហស្តដ៏ល្អរបស់ព្រះជាម្ចាស់។ (សូមអានបន្ថែមទៀតនៅក្នុងកណ្ឌគម្ពីរ ទំនុកតម្កើង ៩៣:៣-៤)។

ចូរយើងសញ្ជឹងគិតអំពីអំណាចព្រះចេស្ដារបស់ព្រះជាម្ចាស់ក្នុងការដែលទ្រង់ថ្កោលទោស។ នៅពេលដែលទ្រង់ទះ គ្មានអ្នកណាអាចឃាត់ទ្រង់បានឡើយ (អេសេគាល ២២:១៣-១៤)។ យើង

បានឃើញចំណុចនេះយ៉ាងច្បាស់នៅពេលដែលទ្រង់បានបណ្ដាលឲ្យមានទឹកជំនន់! ព្រះជាម្ចាស់បានបើក «គ្រប់អស់ទាំងរន្ធទឹកនៅទីជម្រៅធំក៏ធ្លាយ ហើយទ្វារទំនប់នៅលើមេឃក៏ត្រូវបើកចេញ» ហើយទ្រង់បានសម្លាប់មនុស្សទាំងអស់ (លើកលែងតែអ្នកនៅក្នុងទូកធំ) ដ្បិតពួកគេមិនអាចគេចរួចពីព្យុះនៃសេចក្ដីក្រោធរបស់ទ្រង់បានឡើយ (លោកុប្បត្តិ ៦)។ ព្រះជាម្ចាស់បាន «បង្អុរភ្លៀងជាស្ពាន់ធ័រនឹងភ្លើងពីលើមេឃមកលើក្រុងសូដុំមនឹងក្រុងកូម៉ូរ៉ា» (លោកុប្បត្តិ ១៨-១៩)។ ស្ដេច ផារ៉ោន និងទ័ពរបស់ទ្រង់បានស្លាប់ស្ងួកស្ងឹង នៅពេលដែលព្រះជាម្ចាស់ច្បាំងនឹងពួកគេនៅសមុទ្រក្រហម (និក្ខមនំ ១៤)។ ពាក្យពេចន៍ដែលមានចែងនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៩:២២ ពិតជាគួរឲ្យខ្លាចមែន «ចុះបើសិនជាព្រះទ្រង់ចង់សម្ដែងសេចក្ដីក្រោធ ព្រមទាំងបើកឲ្យស្គាល់ព្រះចេស្ដា ដល់គ្រឿងប្រដាប់គួរនឹងក្រោធ ដែលរៀបចំឡើងសម្រាប់តែត្រូវបំផ្លាញដូច្នេះ ដែលទ្រង់ទ្រាំទ្រដោយអំណត់ជាយូរមកហើយ?»។ ព្រះជាម្ចាស់នឹងបង្ហាញអំណាចព្រះចេស្ដារបស់ទ្រង់ដល់មនុស្សចោលម្សៀត ទ្រង់នឹងមិនធ្វើការនោះដោយគ្រាន់តែបោះពួកគេចូលទៅក្នុងបឹងភ្លើងប៉ុណ្ណោះទេ ប៉ុន្តែទ្រង់នឹងទុករូបសាច់ និងព្រលឹងរបស់ពួកគេ បែបអធិធម្មជាតិ ឲ្យទទួលរងការឈឺចាប់អស់កល្បជានិច្ចនៅក្នុងបឹងភ្លើងទៀតផង។

ជាការល្អណាស់ បើយើងទាំងអស់គ្នាមានការភ័យញាប់ញ័រនៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់! ការប្រមាថព្រះជាម្ចាស់ដែលអាចកិនយើងយ៉ាងងាយស្រួលជាងការដែលយើងអាចកិនសត្វខ្មូត គឺដូចជាការដែលយើងចង់សម្លាប់ខ្លួនឯងហើយ។ ប្រសិនបើយើងបំបាក់មុខព្រះជាម្ចាស់ជាសាធារណៈ នោះគឺជារឿងដ៏ឆ្កួតលីលាបំផុត។ ព្រះជាម្ចាស់មានពេញដោយសព្វានុភាព ហើយទ្រង់អាចហែកយើងជាចំរៀកតូចៗ ឬក៏បោះយើងចូលទៅក្នុងភ្លើងនរកនៅពេលណាក៏បាន។ ការពន្យល់ជាមូលដ្ឋាន វាគ្រាន់តែជាផ្នែកមួយនៃប្រាជ្ញាក្នុងការស្តាប់តាមបញ្ញត្តិរបស់ព្រះអង្គទេ «ចូរថើបព្រះរាជបុត្រា ក្រែងទ្រង់ខ្ញាល់ឡើង ហើយឯងរាល់គ្នាត្រូវវិនាសតាមផ្លូវ ដ្បិតបន្តិចទៀត សេចក្តីខ្ញាល់របស់ទ្រង់នឹងឆួលឡើង មានពរហើយ អស់អ្នកណាដែលយកទ្រង់ជាទីពឹងជ្រក» (ទំនុកតម្កើង ២:១២)។

ជាការល្អណាស់ ប្រសិនបើយើងដែលជាអ្នកជឿស្រឡាញ់ព្រះជាម្ចាស់ យើងនឹងថ្វាយបង្គំទ្រង់ ដ្បិតទ្រង់ជាព្រះដ៏ឧត្តុង្គឧត្តម និងជាព្រះដ៏ល្អឥតខ្ចោះដែលគ្មានដែនកំណត់។ ប្រសិនបើមនុស្សខ្លាំងពូកែ ហើយល្បីល្បាញ អាចទាមទារឲ្យមនុស្សនៅលើពិភពលោកនេះគោរពគាត់បាន នោះព្រះដែលប្រកបដោយអំណាចព្រះចេស្តា ទ្រង់ក៏អាចទាមទារឲ្យយើងគោរព ហើយកោតខ្លាចទ្រង់

បានដែរ។ «ឱព្រះយេហូវ៉ាអើយ តើមានព្រះឯណាឲ្យដូចទ្រង់ តើមានអ្នកឯណាដែលមានសេចក្តីបរិសុទ្ធដ៏វិសេសដូចទ្រង់ ដែលគួរសរសើរតម្កើង ហើយក៏ធ្វើការអស្ចារ្យផង?» (និក្ខមនំ ១៥:១១)។

ជាការល្អណាស់ ប្រសិនបើយើងដែលជាពួកបរិសុទ្ធទុកចិត្តលើទ្រង់ ដ្បិតទ្រង់ពិតជាស័ក្តិសមនឹងឲ្យយើងទុកចិត្តលើបាន! គ្មានអ្វីមួយដែលពិបាកសម្រាប់ទ្រង់នោះទេ។ ប្រសិនបើអំណាចព្រះចេស្តា និងកម្លាំងរបស់ព្រះជាម្ចាស់មានដែនកំណត់ នោះយើងច្បាស់ជាគ្មានសង្ឃឹមហើយ។ ប៉ុន្តែ ដោយសារទ្រង់ពេញដោយអំណាចព្រះចេស្តា ហេតុដូច្នេះហើយ គ្មានសេចក្តីអធិស្ឋានណាមួយរបស់យើងដែលទ្រង់ពិបាកនឹងឆ្លើយតបនោះឡើយ ក៏គ្មានតម្រូវការណាមួយដែលធំហួសពីការដែលទ្រង់អាចបំពេញបាននោះដែរ។ គ្មានអ្នកខ្លាំងណាម្នាក់ដែលទ្រង់មិនអាចគ្រប់គ្រងបាននោះទេ ក៏គ្មានសេចក្តីល្បួងលណាមួយដែលទ្រង់មិនអាចរំដោះចេញបាននោះដែរ ហើយក៏គ្មានការឈឺចាប់ណាមួយដែលទ្រង់មិនអាចធ្វើឲ្យធូរស្បើយបានដែរ។ «ព្រះយេហូវ៉ាទ្រង់ជាទីពឹងពំនាក់នៃជីវិតខ្ញុំ តើត្រូវឲ្យខ្ញុំភ័យចំពោះអ្នកណា?» (ទំនុកតម្កើង ២៧:១)។

«ឯព្រះដែលអាចនឹងធ្វើហួសសន្ធឹក លើសជាងអ្វីៗដែលយើងសូម ឬគិត ដោយព្រះចេស្តាដែលធ្វើការនៅក្នុងយើង សូមលើក

តម្កើងសិរីល្អដល់ព្រះអង្គ ក្នុងក្រុមជំនុំ និងក្នុងព្រះគ្រីស្ទយេស៊ូវ ដល់គ្រប់ជំនាន់ អស់កល្បជានិច្ចរៀងរាបតទៅ។ អាម៉ែន។» (អេភេសូរ ៣:២០-២១)។

ជំពូកទី១០

# ព្រះដែលស្មោះត្រង់

ភាពមិនស្មោះត្រង់ គឺជាអំពើបាបគួរឲ្យខ្លាចមួយនៅសម័យកាលដ៏អាក្រក់នេះ។ នៅក្នុងពិភពជំនួញ អ្នករកស៊ីភាគច្រើនជាមនុស្សដែលនិយាយបាតដៃខ្នងដៃ ហើយមានមនុស្សភាគតិចណាស់ដែលនៅគោរពពាក្យសម្ដីរបស់ខ្លួន។ នៅក្នុងសង្គមសព្វថ្ងៃនេះ មានពេញទៅដោយការផិតក្បត់ ដូចជាប្ដីក្បត់ប្រពន្ធ ប្រពន្ធក្បត់ប្ដី ហើយពួកគេរាប់ការក្បត់ស្នេហ៍បរិសុទ្ធរបស់ខ្លួនទុកដូចជាការផ្លាស់ប្ដូរខោអាវចាស់ចោល។ មានបុរសរាប់ពាន់នាក់បានសន្យានៅក្នុងក្រុមជំនុំថា ពួកគេនឹងអធិប្បាយអំពីសេចក្ដីពិត ប៉ុន្តែពួកគេបែរជាវាយប្រហារទាំងប្រឆាំង ហើយបដិសេធព្រះគម្ពីរទៅវិញ។ សូម្បីតែមិត្តអ្នកអាន និងយើងខ្ញុំដែលជាអ្នកនិពន្ធ ក៏មិនអាចគេចផុតពីទុក្ខភ័យនៃអំពើបាបដ៏គួរឲ្យខ្លាចនេះបានដែរ។ យើងបានប្រព្រឹត្តអំពើដែលមិនស្មោះត្រង់ចំពោះព្រះគ្រីស្ទ ពន្លឺ និងអភ័យឯកសិទ្ធិដែលទ្រង់បានប្រទានដល់យើងជាច្រើនលើកច្រើនសារ។ វាពិតជាផ្ដល់កម្លាំងចិត្តដល់យើង

ហើយក៏ជាព្រះពរដែលមិនអាចពណ៌នាបានដែរ នៅពេលដែលយើងមើលរំលងកន្លែងដែលពេញដោយការខូចខាត ពោលគឺយើងសម្លឹងទៅឯព្រះដ៏ស្មោះត្រង់ ដែលទ្រង់ស្មោះត្រង់ចំពោះអ្វីៗទាំងអស់ ហើយក៏ស្មោះត្រង់គ្រប់ពេលគ្រប់វេលាផងដែរ។

កណ្ឌគម្ពីរ ចោទិយកថា ៧:៩ បានចែងថា «ដូច្នេះចូរដឹងថា ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ពិតជាព្រះហើយ គឺជាព្រះស្មោះត្រង់»។ ភាពស្មោះត្រង់នេះ គឺចាំបាច់ណាស់ចំពោះភាពជាព្រះដ៏មានព្រះជន្មរស់ ហើយបើគ្មានលក្ខណសម្បត្តិនេះទេ ព្រះជាម្ចាស់មិនអាចជាព្រះបានឡើយ។ ប្រសិនបើព្រះជាម្ចាស់មិនស្មោះត្រង់ នោះមានន័យថា ទ្រង់ប្រឆាំងនឹងនិស្ស័យពិតរបស់ទ្រង់ហើយ ប៉ុន្តែការនោះមិនអាចទៅរួចទេ៖ «ប្រសិនបើយើងមិនស្មោះត្រង់ ព្រះអង្គនៅតែស្មោះត្រង់ដដែល ដ្បិតព្រះអង្គពុំអាចបដិសេធព្រះអង្គទ្រង់បានឡើយ» (២ធីម៉ូថេ ២:១៣ គកស)។ ភាពស្មោះត្រង់ គឺជាលក្ខណសម្បត្តិដ៏ឧត្តុង្គឧត្តមមួយនៃភាពជាព្រះរបស់ទ្រង់។ ព្រះអង្គប្រកបដោយភាពស្មោះត្រង់ «ឱព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារអើយ តើមានអ្នកណាខ្លាំងពូកែដូចជាទ្រង់ ឱព្រះយេហូវ៉ាអើយ សេចក្តីស្មោះត្រង់របស់ទ្រង់ ក៏នៅព័ទ្ធជុំវិញទ្រង់» (ទំនុកតម្កើង ៨៩:៨)។ នៅពេលដែលព្រះបានយាងមកយកកំណើតជាមនុស្ស ព្រះគម្ពីរ

បានចែងថា “សេចក្ដីសុចរិតនឹងបានជាខ្សែក្រវាត់ចង្កេះរបស់អ្នកនោះ ហើយសេចក្ដីស្មោះត្រង់ជាខ្សែក្រវាត់កម្លាំងផង” (អេសាយ ១១:៥)។

កណ្ឌ គម្ពីរ ទំនុកតម្កើង៣៦:៥បាន ចែង ពី សេចក្ដី ពិត ថា “ឱព្រះយេហូវ៉ាអើយ សេចក្ដីសប្បុរសនៃទ្រង់ខ្ពស់ដល់ផ្ទៃមេឃ សេចក្ដីស្មោះត្រង់នៃទ្រង់ក៏ដល់ពពកផង”។ ភាពស្មោះត្រង់របស់ព្រះជាម្ចាស់មិនចេះប្រែប្រួលឡើយ ហើយក៏លើសពីគំនិតដ៏តូចតាចរបស់យើងអាចគិតដល់ផង។ គ្រប់ចំណុចរបស់ព្រះជាម្ចាស់ គឺសុទ្ធតែអស្ចារ្យ មហិមា ហើយក៏គ្មានអ្វីប្រៀបផ្ទឹមបាននោះដែរ។ ទ្រង់មិនមានការភ្លេចភ្លាំងទេ! ព្រះអង្គមិនដែលបរាជ័យឡើយ! ទ្រង់មិនមានការរអាក់រអួល! ទ្រង់មិនដែលលេបពាក្យសម្ដី! ព្រះជាម្ចាស់បានបំពេញគ្រប់ទាំងសេចក្ដីសន្យា និងទំនាយដែលទ្រង់បានប្រកាសយ៉ាងពេញលេញ ហើយទ្រង់ក៏នឹងបំពេញនូវគ្រប់ទាំងសេចក្ដីសញ្ញាក៏ដូចជាការគម្រាមកំហែងរបស់ព្រះអង្គផងដែរ ដ្បិត “ព្រះទ្រង់មិនមែនជាមនុស្ស ទ្រង់មិនចេះកុហកឡើយ ក៏មិនមែនជាកូនមនុស្សដែរ ទ្រង់មិនត្រូវការនឹងប្រែគំនិតទេ សេចក្ដីដែលទ្រង់មានវាចាហើយ តើទ្រង់មិនធ្វើតាមឬអី ឬសេចក្ដីដែលទ្រង់មានបន្ទូល តើមិនសម្រេចតាមទេឬអី?» (ជនគណនា ២៣:១៩)។ ហេតុដូច្នេះហើយបានជាអ្នកជឿបន្លឺសំឡេងឡើងថា “ឯសេចក្ដីមេត្តាករុណារបស់ទ្រង់ នោះ

មិនចេះផុតឡើយ សេចក្តីទាំងនោះ ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច សេចក្តីស្មោះត្រង់របស់ទ្រង់ធំណាស់» (បរិទេវ ៣:២២-២៣)។

បទគម្ពីរបានចែងទុកជាញឹកញាប់អំពីការសម្តែងនូវភាពស្មោះត្រង់របស់ព្រះជាម្ចាស់។ ប្រមាណបួនពាន់ឆ្នាំមុន ព្រះអង្គបានមានបន្ទូលថា «កាលនៅមានផែនដីនៅឡើយ នោះមិនដែលខាននឹងមានរដូវសាបព្រោះ រដូវច្រូតកាត់ ត្រជាក់ហើយក្តៅ ប្រាំងវស្សា ថ្ងៃហើយយប់ទៀតឡើយ» (លោកុប្បត្តិ ៨:២២)។ គ្រប់ឆ្នាំថ្មីដែលចូលមកដល់ គឺសុទ្ធតែនាំមកនូវការបំពេញសម្រេចនៃសេចក្តីសន្យារបស់ព្រះជាម្ចាស់។ នៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ១៥ យើងឃើញថា ព្រះជាម្ចាស់បានមានព្រះបន្ទូលទៅកាន់លោក អ័ប្រាហាំ ថា «ពូជឯងនឹងត្រូវទៅជាអ្នកដទៃនៅស្រុក១ដែលមិនមែនជាស្រុករបស់ផងខ្លួន ហើយត្រូវបម្រើពួកស្រុកនោះ…ដល់ដំណទី៤ នោះគេនឹងវិលមកឯណេះវិញ» (ខ១៣-១៦)។ ពេលវេលាជាច្រើនសតវត្សរ៍ក៏បានកន្លងផុតបាត់ទៅ ហើយយើងឃើញថា កូនចៅលោក អ័ប្រាហាំ បានត្អូញត្អែរខណៈពេលដែលពួកគេកំពុងធ្វើដុំឥដ្ឋនៅប្រទេស អេស៊ីព្ទ។ តើព្រះជាម្ចាស់បានភ្លេចពួកគេឬ? មិនដូច្នោះទេ! សូមអានកណ្ឌគម្ពីរ និក្ខមនំ ១២:៤១ «រួចដល់ផុតពី៤៣០ឆ្នាំនោះទៅ នៅថ្ងៃដដែលនោះឯង ពួកកកកុញរបស់ព្រះយេហូវ៉ាគេក៏នាំគ្នាចេញពីស្រុកអេស៊ីព្ទ

ទៅ»។ ព្រះជាម្ចាស់បានមានព្រះបន្ទូលតាមរយៈហោរា អេសាយ ថា «មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយនិងឲ្យព្រះនាមថា អេម៉ាញូអែល» (៧:១៤)។ ហើយទោះបីជាពេលវេលាបានកន្លងទៅជាច្រើនសតវត្សរ៍ក៏ដោយ «តែលុះវេលាកំណត់បានមកដល់ នោះព្រះទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកចាប់កំណើតនឹងស្ត្រី គឺកើតក្រោមអំណាចនៃក្រឹត្យវិន័យ» (កាឡាទី ៤:៤)។

ព្រះជាម្ចាស់ទ្រង់ទៀងត្រង់ ហើយយើងអាចទុកចិត្តលើព្រះបន្ទូលសន្យារបស់ទ្រង់បាន។ រាល់ទំនាក់ទំនងរបស់ព្រះអង្គជាមួយរាស្ត្ររបស់ទ្រង់ គឺទ្រង់សុទ្ធតែបង្ហាញចេញនូវភាពស្មោះត្រង់។ ដូច្នេះយើងអាចពឹងផ្អែកលើទ្រង់បានទាំងស្រុង។ គ្មានអ្នកណាដែលទុកចិត្តលើព្រះអង្គហើយ បានទទួលផលជាការឥតប្រយោជន៍នោះទេ។ យើងរកឃើញសេចក្តីពិតដ៏មានតម្លៃនេះ ស្ទើរតែគ្រប់ទីកន្លែងក្នុងព្រះបន្ទូល ដ្បិតរាស្ត្ររបស់ទ្រង់ត្រូវតែដឹងថា ភាពស្មោះត្រង់គឺជាចំណុចដ៏សំខាន់មួយនៃលក្ខណសម្បត្តិរបស់ទ្រង់។ នេះហើយជាមូលដ្ឋាននៃទំនុកចិត្តរបស់យើងលើទ្រង់។ នេះគ្រាន់តែជារឿងមួយផ្នែកប៉ុណ្ណោះក្នុងការដែលយើងទទួលស្គាល់ភាពស្មោះត្រង់របស់ព្រះជាម្ចាស់ ថាជាធាតុពិតនៃភាពជាព្រះរបស់ទ្រង់ ប៉ុន្តែផ្នែកមួយទៀតនោះគឺថា តើយើងនឹងរស់នៅដូចដែលយើងនឹងទទួលស្គាល់

ដែរឬទេ? ព្រះជាម្ចាស់បានប្រទានសេចក្តីសន្យាដ៏អស្ចារ្យ និងមានតម្លៃជាច្រើនដល់យើង ប៉ុន្តែតើយើងពិតជារំពឹងថា ទ្រង់នឹងបំពេញសេចក្តីសន្យាទាំងនោះដែរឬទេ? តើយើងពិតជាជឿថា ព្រះអង្គនឹងធ្វើនូវគ្រប់អ្វីៗដែលទ្រង់បានសន្យាថា ទ្រង់នឹងធ្វើសម្រាប់យើងដែរឬទេ? តើយើងពិតជាមានទំនុកចិត្តទាំងស្រុងលើការធានានៃព្រះបន្ទូលរបស់ទ្រង់ដែលថា «ព្រះដែលបានសន្យានោះទ្រង់ស្មោះត្រង់» ដែរឬទេ (ហេព្រើរ ១០:២៣)?

## ពេលរឿងពិបាកៗកើតឡើង

យើងទាំងអស់គ្នាសុទ្ធតែធ្លាប់ឆ្លងកាត់ពេលវេលាដែលយើងពិបាកទទួលជឿថា ព្រះទ្រង់ស្មោះត្រង់ សូម្បីតែគ្រីស្ទបរិស័ទក៏មានពេលដូចនេះដែរ។ ទ្រង់បានល្បងលជំនឿរបស់យើងយ៉ាងខ្លាំង ហើយយើងដេកយំជាច្រើនយប់ ហើយតាមរយៈការនេះ យើងក៏លែងឃើញសេចក្តីស្រឡាញ់របស់ទ្រង់ធ្វើការក្នុងយើងដែរ។ លោកីយ៍តែងតែបង្វែរត្រចៀកយើងដោយសំឡេងរបស់វា ហើយអារក្សសាតាំងតែងតែបៀតបៀនយើងដោយខ្សឹបខ្សៀវថា គ្មានព្រះទេ ហេតុដូច្នេះហើយបានជាយើងពិបាកនឹងឮព្រះសូរសៀងដ៏តូចតែផ្អែមល្ហែមរបស់ព្រះជាម្ចាស់ ផែនការដ៏គួរឲ្យស្រឡាញ់របស់យើងត្រូវបានផ្អាក។

មិត្តភក្តិដែលយើងទុកចិត្តបានធ្វើឲ្យយើងបរាជ័យ ហើយអ្នកដែលរាប់ខ្លួនថាជាអ្នកជឿបានក្បត់នឹងយើង។ ឯយើងក៏ដើរទ្រេតទ្រោត។ ទោះបីជាយើងបានប្តេជ្ញាថា យើងនឹងរស់នៅដោយស្មោះត្រង់ចំពោះទ្រង់ក៏ដោយ ក៏ឥឡូវនេះមានពពកខ្មៅមកបាំងយើងមិនឲ្យឃើញទ្រង់ដែរ។ យើងមានការពិបាក ហើយក៏មិនអាចទៅរួចបាន ក្នុងការយល់អំពីចំណុចពិតដែលថា ព្រះជាម្ចាស់អនុញ្ញាតឲ្យមានរឿងពិបាកៗក្នុងជីវិតយើងជាមួយនឹងសេចក្តីសន្យាដ៏ពេញដោយព្រះគុណរបស់ទ្រង់។ ឱ! មិត្តអ្នករួមដំណើរធម្មយាត្រាដែលទទួលបានការសាកល្បងយ៉ាងខ្លាំង ហើយចាប់ផ្តើមចុះខ្សោយអើយ! ចូរព្យាយាមរកព្រះគុណក្នុងការស្តាប់តាមកណ្ឌគម្ពីរ អេសាយ ៥០:១០៖ «ក្នុងពួកឯងរាល់គ្នា តើមានអ្នកណាដែលកោតខ្លាចដល់ព្រះយេហូវ៉ា ដែលស្តាប់តាមសំឡេងរបស់អ្នកបម្រើទ្រង់ ឯអ្នកដែលដើរក្នុងសេចក្តីងងឹត ឥតមានពន្លឺសោះ ត្រូវឲ្យអ្នកនោះទុកចិត្តដល់ព្រះនាមនៃព្រះយេហូវ៉ា ហើយផ្អែកទៅលើព្រះនៃខ្លួនចុះ»។

នៅពេលដែលអារក្សសាតាំងល្បួងលោកអ្នកឲ្យមានមន្ទិលសង្ស័យលើភាពស្មោះត្រង់របស់ព្រះជាម្ចាស់ នោះចូរស្រែកឡើងថា «នែ សាតាំង ចូរឯងថយចេញពីអញទៅ» (ម៉ាថាយ ៤:១០)។ ទោះបើលោកអ្នកមិនអាចរកឃើញភាពស៊ីគ្នារវាងការប្រព្រឹត្តិដ៏ពេញ

ដោយអាថ៌កំបាំង និងការប្រកាសជាសាធារណៈនៃសេចក្ដីស្រឡាញ់របស់ទ្រង់ឥឡូវនេះក៏ដោយ ក៏លោកអ្នកគួរតែបន្តរង់ចាំឲ្យទ្រង់បង្ហាញពន្លឺថែមទៀតដែរ។ នៅពេលដល់កំណត់ នោះទ្រង់នឹងបើកសម្ដែងឲ្យយើងឃើញយ៉ាងច្បាស់ «ការដែលខ្ញុំធ្វើ នោះអ្នកមិនយល់ក្នុងពេលឥឡូវនេះទេ តែទៅមុខទើបនឹងបានយល់វិញ» (យ៉ូហាន ១៣:៧)។ យើងនឹងឃើញម្ដងហើយម្ដងទៀតថា ព្រះជាម្ចាស់មិនបានបោះបង់ ឬក៏បោកបញ្ឆោតបុត្រាបុត្រីរបស់ទ្រង់ឡើយ។ «ទោះបើយ៉ាងនោះ គង់តែព្រះយេហូវ៉ាទ្រង់រង់ចាំឱកាស នឹងផ្តល់ព្រះគុណដល់ឯងរាល់គ្នាដែរ ហើយទោះបើយ៉ាងនោះក៏ដោយ គង់តែទ្រង់នឹងចាំឯងលើកតម្កើងទ្រង់ឡើង ដើម្បីឲ្យទ្រង់មានសេចក្តីអាណិតមេត្តាដល់ឯងពីព្រោះព្រះយេហូវ៉ាទ្រង់ជាព្រះដ៏ប្រកបដោយយុត្តិធម៌។ មានពរហើយអស់អ្នកណាដែលរង់ចាំទ្រង់» (អេសាយ ៣០:១៨)។

«កុំឲ្យថ្កោលទោសព្រះអម្ចាស់តាមរយៈការយល់ដឹងដ៏ទន់ខ្សោយរបស់ខ្លួនឡើយ។ តែចូរទុកចិត្តលើព្រះអង្គដោយដឹងថា ទ្រង់នឹងប្រទានព្រះគុណមក។ ទ្រង់បានលាក់ព្រះភក្ត្រដ៏ញញឹមនៅក្រោមការចងចិញ្ចើមរបស់ព្រះអង្គ។ ឱ! ពួកអ្នកបរិសុទ្ធដែលមានការភ័យខ្លាចអើយ! ចូរមានទំនុកចិត្តជាថ្មីឡើង។ ពពកដែលអ្នកទាំងអស់គ្នាភ័យខ្លាចមានពេញដោយសេចក្តីមេត្តាករុណា ហើយនៅពេលដែល

វាបើកឡើងនោះវានឹងចាក់ព្រះពរមកលើក្បាលអ្នក»។[១]

កណ្ឌគម្ពីរ ទំនុកតម្កើង ១១៩:១៣៨ បានចែងថា «ទ្រង់បានតាំងសេចក្តីបន្ទាល់របស់ទ្រង់នៅលើសេចក្តីយុត្តិធម៌ ហើយលើសេចក្តីស្មោះត្រង់ដ៏ពិតផង»។ ព្រះជាម្ចាស់មិនត្រឹមតែបានប្រាប់យើងអំពីដំណឹងដ៏ល្អបំផុតប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏បានប្រាប់យើងឲ្យដឹងពីដំណឹងដ៏អាក្រក់ផងដែរ។ ព្រះអង្គបានពណ៌នាយ៉ាងស្មោះត្រង់អំពីចំណុចអវិជ្ជមានដែលកើតចេញពីការដែលយើងបានធ្លាក់ក្នុងអំពើបាប។ ទ្រង់បានវិនិច្ឆ័យយ៉ាងស្មោះត្រង់អំពីលទ្ធផលដ៏អាក្រក់ដែលបាបបានបង្កើតឡើង។ ព្រះអង្គបានសម្តែងយ៉ាងស្មោះត្រង់ថា ទ្រង់ស្អប់អំពើអាក្រក់ ហើយទ្រង់ក៏នឹងមិនប្រែព្រះតម្រិះពីសេចក្តីសម្អប់នោះដែរ។ លើសពីនោះទៅទៀត ទ្រង់ក៏នឹងដាក់ទោសអំពើអាក្រក់នោះដែរ។ ទ្រង់ក៏បានព្រមានយើងយ៉ាងស្មោះត្រង់ដែរថា ទ្រង់ជា «ភ្លើងដែលឆេះបន្សុស» (ហេព្រើរ ១២:២៩)។ ព្រះបន្ទូលរបស់ទ្រង់មិនត្រឹមតែបើកសម្តែងឲ្យយើងឃើញភាពទៀងត្រង់នៃការដែលព្រះអង្គបំពេញសេចក្តីសន្យារបស់ទ្រង់ម្តងហើយម្តងទៀតនោះទេ ប៉ុន្តែព្រះបន្ទូលក៏បានចែងម្តងហើយម្តងទៀតអំពីគំរូនៃភាពស្មោះត្រង់របស់ទ្រង់ក្នុងការដែលទ្រង់អនុម័តសេចក្តីគម្រាមកំហែងរបស់ទ្រង់ផងដែរ។ នៅក្នុងប្រវត្តិសាស្ត្រសាសន៍អ៊ីស្រាអែលគ្រប់ជំនាន់

មានការបើកសម្ដែងពីគំរូនៃព្រឹត្តិការណ៍នេះយ៉ាងឱឡារិក។ សូម្បីតែបុគ្គលម្នាក់ៗដូចជា៖ ស្ដេចផារ៉ោន កូរេ អេកាន និងមនុស្សជាច្រើនទៀត ក៏ជាភស្ដុតាងនៃរឿងរ៉ាវនេះដែរ។ ឱមិត្តអ្នកអានរាល់គ្នាអើយ! រឿងនេះក៏អាចនឹងកើតឡើងចំពោះលោកអ្នកដែរ លុះត្រាតែលោកអ្នកបានរត់ ឬកំពុងតែរត់ទៅរកព្រះគ្រីស្ទ ដើម្បីយកទ្រង់ជាទីពឹងជ្រក បើមិនដូច្នោះទេលោកអ្នកប្រាកដជាទទួលទណ្ឌកម្មនៅក្នុងបឹងភ្លើងដែលឆេះអស់កល្បជានិច្ច។ ព្រះជាម្ចាស់ទ្រង់ស្មោះត្រង់!

## ភាពស្មោះត្រង់បានបង្ហាញ

ព្រះជាម្ចាស់ស្មោះត្រង់ក្នុងការថែរក្សារាស្ដ្ររបស់ទ្រង់។ កណ្ឌគម្ពីរ ១កូរិនថូស ១:៩ បានចែងថា “ឯព្រះដែលបានហៅអ្នករាល់គ្នាមក ឲ្យមានសេចក្ដីប្រកបនឹងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង នោះទ្រង់ស្មោះត្រង់”។ ខ៨នៃជំពូកនេះបានអះអាងថា ព្រះជាម្ចាស់ “នឹងតាំងអ្នករាល់គ្នាឲ្យខ្ជាប់ខ្ជួន ដរាបដល់ចុងបំផុត”។ ទំនុកចិត្តដ៏មិនចេះប្រែប្រួលរបស់សាវ័ក ប៉ុល ចំពោះអស់អ្នកជឿ គឺមិនមែនពឹងផ្អែកលើលទ្ធភាពនៃដំណោះស្រាយ ឬក៏សមត្ថភាពនៃការថែរក្សារបស់ពួកគេនោះទេ ប៉ុន្តែគឺពឹងផ្អែកលើភាពត្រឹមត្រូវរបស់ព្រះជាម្ចាស់វិញ ដ្បិតទ្រង់មិនចេះកុហកឡើយ។

ដោយសារព្រះជាម្ចាស់បានសន្យាចំពោះព្រះរាជបុត្រាទ្រង់ថា ព្រះអង្គនឹងប្រទានរាស្ត្រមួយជាមរតកដល់ទ្រង់ នោះទ្រង់ប្រាកដជារំដោះពួកគេឲ្យរួចផុតពីអំពើបាប និងការថ្កោលទោសជាមិនខាន ហើយទ្រង់ក៏នឹងឲ្យពួកគេមានចំណែកក្នុងសិរីរុងរឿងដ៏អស់កល្បជានិច្ចរបស់ទ្រង់ផងដែរ។ ប្រាកដណាស់! ព្រះអង្គនឹងមិនអនុញ្ញាតឲ្យពួកគេវិនាសឡើយ។

ព្រះជាម្ចាស់ស្មោះត្រង់ក្នុងការដែលទ្រង់ផ្ចាញ់ផ្ចាលរាស្ត្ររបស់ទ្រង់។ ទ្រង់មិនគ្រាន់តែស្មោះត្រង់ក្នុងការដែលទ្រង់មិនប្រទានឲ្យនោះទេ តែទ្រង់ក៏ស្មោះត្រង់ក្នុងការដែលទ្រង់ប្រទានឲ្យផងដែរ។ ព្រះអង្គស្មោះត្រង់ក្នុងការប្រទានសេចក្ដីទុក្ខព្រួយ ក៏ដូចជាស្មោះត្រង់ក្នុងការប្រទានសេចក្ដីអំណរផងដែរ។ ចូរកុំឲ្យយើងទទួលស្គាល់ភាពស្មោះត្រង់របស់ព្រះជាម្ចាស់តែនៅពេលណាដែលយើងមានសេចក្ដីសុខនោះឡើយ ប៉ុន្តែចូរឲ្យយើងទទួលស្គាល់នៅពេលដែលយើងស្ថិតនៅក្រោមការស្ដីបន្ទោសដ៏ពិបាកផងដែរ ហើយក៏មិនគួរឲ្យយើងសារភាពការនេះចេញតែពីបបូរមាត់របស់យើងនោះឡើយ ប៉ុន្តែត្រូវឲ្យចេញពីចិត្តរបស់យើងផងដែរ។ នៅពេលដែលព្រះជាម្ចាស់វាយយើងដោយព្រនង់នៃការវាយផ្ចាល គឺទ្រង់បានធ្វើការនោះឡើងដោយសេចក្ដីស្មោះត្រង់របស់ទ្រង់។ ហើយដើម្បីឲ្យយើងអាចទទួលស្គាល់ការ

នេះបាន គឺយើងត្រូវតែបន្ទាបខ្លួននៅចំពោះទ្រង់ ទាំងទទួលស្គាល់ថា យើងពិតជាស័ក្តិសមនឹងឲ្យទ្រង់កែតម្រង់មែន ហើយយើងត្រូវតែអរព្រះគុណទ្រង់ជាជាងរអ៊ូរទាំដាក់ទ្រង់។ ព្រះជាម្ចាស់មិនដែលនាំទុក្ខលំបាកដល់យើងដោយគ្មានហេតុផលនោះឡើយ។ សាវ័ក ប៉ុល បានផ្តល់ឧទាហរណ៍ទាក់ទងនឹងគោលការណ៍នេះដោយលើកឡើងថា «គឺដោយហេតុនោះបានជាមានអ្នករាល់គ្នាជាច្រើន ទៅជាខ្សោយ ហើយឈឺ» (១កូរិនថូស ១១:៣០)។ នៅពេលដែលព្រនង់របស់ទ្រង់បានធ្លាក់លើយើង ចូរយើងបន្លឺឡើងដូចជាលោក ដានីយ៉ែល ថា «ឱព្រះអម្ចាស់អើយ សេចក្តីសុចរិតជារបស់ផងទ្រង់ហើយ តែខាងយើងខ្ញុំ មានតែសេចក្តីជ្រប់មុខវិញ» (ដានីយ៉ែល ៩:៧)។

កណ្ឌគម្ពីរ ទំនុកតម្កើង ១១៩:១៥ បានចែងថា «ទូលបង្គំនឹងរំពឹងគិតពីបញ្ញត្តិរបស់ទ្រង់ ហើយនឹងស្រឡាញ់រាប់អានអស់ទាំងផ្លូវរបស់ទ្រង់»។ ព្រះជាម្ចាស់បានសន្យាថា អស់អ្នកណាដែលនៅក្នុងព្រះគ្រីស្ទនឹងជួបបញ្ហា ហើយនិងទុក្ខលំបាក ប៉ុន្តែទ្រង់នឹងប្រើការទាំងនោះ ដើម្បីសម្រេចព្រះហឫទ័យរបស់ទ្រង់។ ព្រះជាម្ចាស់មិនត្រឹមតែស្មោះត្រង់ក្នុងការដែលទ្រង់មិនបញ្ជូនទុក្ខលំបាកដល់យើងប៉ុណ្ណោះទេ តែទ្រង់ក៏ស្មោះត្រង់ក្នុងការបញ្ជូនទុក្ខលំបាកទាំងនោះមកដែរ។ «នោះអញនឹងធ្វើទោសចំពោះការរំលងរបស់គេដោយ

ដំបង ហើយចំពោះការទុច្ចរិតរបស់គេដោយស្នាមរំពាត់។ ប៉ុន្តែអញនឹងមិនដកសេចក្តីសប្បុរសរបស់អញចេញពីដាវីឌឡើយ ក៏មិនឲ្យសេចក្តីស្មោះត្រង់របស់អញខាតខានដែរ» (ទំនុកតម្កើង ៨៩:៣២-៣៣)។ សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់មិនមែនត្រឹមតែជាគន្លឹះនៃការដែលយើងយល់ពីការវាយផ្ចាលរបស់ទ្រង់នោះទេ ប៉ុន្តែការវាយផ្ចាលគឺជាលទ្ធផល និងជាការបង្ហាញពីសេចក្តីសប្បុរសរបស់ទ្រង់ចំពោះយើង។ ការនេះនឹងកំសាន្តចិត្តរាស្ត្ររបស់ព្រះជាម្ចាស់ប្រសិនបើពួកគេចងចាំថា សម្ពន្ធមេត្រីនៃសេចក្តីស្រឡាញ់របស់ទ្រង់បានចងភ្ជាប់ទៅដោយការកែតម្រង់ម្តងម្កាល។ ទុក្ខវេទនាគឺជាការចាំបាច់សម្រាប់យើង «កាលណាគេមានសេចក្តីវេទនា នោះគេនឹងស្វែងរកអញយ៉ាងស្រវាស្រទេញ» (ហូសេ ៥:១៥)។

ព្រះជាម្ចាស់ស្មោះត្រង់ក្នុងការដែលទ្រង់លើកតម្កើងរាស្ត្ររបស់ទ្រង់។ «ព្រះដែលបានត្រាស់ហៅអ្នករាល់គ្នា ទ្រង់ស្មោះត្រង់ ហើយព្រះអង្គនឹងធ្វើសម្រេចការនេះ» (១ថែស្សាឡូនិច ៥:២៤ គកស)។ បរិបទភ្លាមៗនៃខគម្ពីរនេះគឺ៖ ការដែលព្រះជាម្ចាស់ថែរក្សាពួកបរិសុទ្ធដែលទ្រង់ «បានបម្រុងទុកឥតសៅហ្មង ដរាបដល់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង ទ្រង់យាងមក»។ ព្រះជាម្ចាស់នឹងមិនប្រព្រឹត្តចំពោះយើងតាមរយៈអំពើល្អដែលយើងប្រព្រឹត្តនោះឡើយ ប៉ុន្តែទ្រង់

ប្រព្រឹត្តចំពោះយើងដោយពឹងលើកិត្តិនាមដ៏អស្ចារ្យរបស់ទ្រង់វិញ។ ព្រះជាម្ចាស់ខ្ជាប់ខ្ជួនចំពោះព្រះអង្គទ្រង់ផ្ទាល់ និងចំពោះគម្រោងការនៃព្រះគុណរបស់ទ្រង់៖ «ពួកអ្នកដែលទ្រង់បានហៅ...នោះទ្រង់ក៏បានតម្កើងឡើងដែរ» (រ៉ូម ៨:៣០)។ ព្រះជាម្ចាស់បើកសម្តែងអំពីភាពគួរឲ្យជឿទាក់ទងនឹងសេចក្តីល្អដ៏នៅអស់កល្បជានិច្ច តាមរយៈការត្រាស់ហៅពួករើសតាំងឲ្យចេញពីភាពងងឹតចូលទៅក្នុងពន្លឺរបស់ទ្រង់។ ការនេះគួរតែផ្តល់នូវទំនុកចិត្តឲ្យយើងកាន់តែជឿជាក់ថា ព្រះទ្រង់នឹងបន្តធ្វើជាព្រះដ៏ល្អ។ «គ្រឹះដ៏រឹងមាំរបស់ព្រះនៅស្ថិតស្ថេរដរាប» (២ធីម៉ូថេ ២:១៩ គកស)។ សាវ័ក  ប៉ុល កំពុងសម្រាកលើភាពស្មោះត្រង់របស់ព្រះជាម្ចាស់ នៅពេលដែលគាត់មានប្រសាសន៍ថា «ដ្បិតខ្ញុំស្គាល់ព្រះដែលខ្ញុំបានជឿតាម ហើយខ្ញុំជឿពិតថា ទ្រង់អាចនឹងថែរក្សាបញ្ញើ ដែលខ្ញុំបានផ្ញើទុកនឹងទ្រង់ដរាបដល់ថ្ងៃនោះឯង» (២ធីម៉ូថេ ១:១២)។

## ជំនឿក្នុងភាពស្មោះត្រង់របស់ព្រះជាម្ចាស់

នៅពេលដែលយើងស្គាល់សេចក្តីពិតនៃព្រះពររបស់ទ្រង់នេះ នោះនឹងជួយការពារយើងមិនឲ្យព្រួយបារម្ភ។ បើយើងស្គាល់ភាពស្មោះត្រង់របស់ព្រះជាម្ចាស់ នោះចូរកុំឲ្យយើងភ័យខ្លាចជាមួយនឹង

កាលៈទេសៈដ៏ពិបាកនៅពេលបច្ចុប្បន្ននេះ ឬព្រួយបារម្ភពីអ្វីដែលអាចនឹងកើតឡើងចំពោះយើងនៅថ្ងៃស្អែកឡើយ។ ទ្រង់នឹងមិនបោះបង់បុត្រាបុត្រីរបស់ទ្រង់ចោលឡើយ ទោះបើពួកគេកាន់តែមានវ័យចាស់ទៅៗក៏ដោយ ពីព្រោះទ្រង់ជាអ្នកមើលថែពួកគេតាំងពីក្មេងមកម្ល៉េះ។ ព្រះអង្គដែលបានព្រះសណ្ដាប់សេចក្ដីអធិស្ឋានរបស់យើងកន្លងមក ទ្រង់នឹងមិនបដិសេធការបំពេញតម្រូវការភ្លាមៗនៅពេលបច្ចុប្បន្នរបស់យើងនោះឡើយ។ ចូរពឹងអាងលើកណ្ឌគម្ពីរ យ៉ូប ៥:១៩ «ទ្រង់នឹងប្រោសឲ្យអ្នករួចពីសេចក្ដីវេទនា៦មុខ អើ ដល់គំរប់៧ផង នោះសេចក្ដីអាក្រក់នឹងមិនមកពាល់ប៉ះអ្នកឡើយ»។

ការយល់ដឹងអំពីសេចក្ដីពិតនៃព្រះពរនេះ នឹងជួយយើងមិនឲ្យរអ៊ូរទាំទៀត។ ព្រះអម្ចាស់បានជ្រាបអំពីអ្វីៗដែលល្អបំផុតសម្រាប់យើង ហើយបើយើងពិតជាជឿលើសេចក្ដីពិតនេះមែន នោះយើងនឹងមិនបន្តរអ៊ូរទាំទៀតឡើយ។ ព្រះជាម្ចាស់នឹងទទួលបានកិត្តិយសយ៉ាងក្រៃលែង នៅពេលដែលយើងមានគំនិតវិជ្ជមានអំពីទ្រង់ ហើយទទួលស្គាល់ថា ទ្រង់នៅតែស្រឡាញ់យើងទោះបីជាទ្រង់បានវាយផ្ចាលយើងក៏ដោយ។

ការយល់ដឹងអំពីព្រះពរនៃសេចក្ដីពិតនេះនឹងជួយយើងឲ្យកាន់តែមានទំនុកចិត្តលើព្រះជាម្ចាស់។ «ដូច្នេះ ពួកអ្នកដែលរងទុក្ខ តាម

ព្រះហឫទ័យនៃព្រះ នោះត្រូវផ្ញើព្រលឹងខ្លួន ទុកនឹងព្រះដ៏បង្កបង្កើត ដែលទ្រង់ស្មោះត្រង់ ដោយខ្លួនប្រព្រឹត្តការល្អចុះ» (១ពេត្រុស ៤:១៩)។ នៅពេលដែលយើងដកការទុកចិត្តលើខ្លួនយើងចេញ ហើយផ្ទេរគ្រប់ទាំងកិច្ចការរបស់យើងទៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ ដោយទុកចិត្តលើសេចក្ដីស្រឡាញ់ និងភាពស្មោះត្រង់របស់ទ្រង់ ការនោះនឹងនាំយើងនឹងស្កប់ចិត្តចំពោះអ្វីដែលទ្រង់បានប្រទានមកដល់យើង ហើយក៏នឹងទទួលស្គាល់ថា «គ្រប់កិច្ចការដែលលោកធ្វើ សុទ្ធតែល្អទាំងអស់» (ម៉ាកុស ៧:៣៧)។

ជំពូកទី១១

# សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់

កណ្ឌាគម្ពីរ (ទំនុកតម្កើង ៥២:១) បានចែងថា “សេចក្ដីសប្បុរសនៃព្រះស្ថិតស្ថេរនៅជាដរាប”។ “សេចក្តីសប្បុរស” របស់ព្រះជាម្ចាស់សំដៅទៅលើភាពល្អឥតខ្ចោះនៃលក្ខណសម្បត្តិរបស់ទ្រង់៖ “ព្រះជាម្ចាស់ជាពន្លឺ គ្មានសេចក្ដីងងឹតនៅក្នុងព្រះអង្គទាល់តែសោះ” (១យ៉ូហាន ១:៥ គខប)។ នៅក្នុងលក្ខណសម្បត្តិ និងនិស្ស័យជាព្រះរបស់ទ្រង់មានភាពដ៏ល្អឥតខ្ចោះ ហើយភាពដ៏ល្អឥតខ្ចោះនោះមិនចាំបាច់ត្រូវការអ្វីផ្សេងទៀត ឬក៏មានអ្វីអាចមកបង្ខូចភាពដ៏ល្អឥតខ្ចោះនោះបានដែរ ហើយក៏គ្មានអ្វីមួយដែលអាចយកមកបន្ថែមពីលើភាពដ៏ល្អឥតខ្ចោះរបស់ព្រះ ដើម្បីឲ្យកាន់តែប្រសើរជាងនេះទៀតបានឡើយ។

“ព្រះជាម្ចាស់គឺសប្បុរសតាំងពីដើមមកម្ល៉េះ ទ្រង់សប្បុរសនៅ

ក្នុងរូបអង្គទ្រង់ផ្ទាល់ ហើយក៏គ្មានអ្វីដែលមានសេចក្ដីសប្បុរស ប្រសើរជាងទ្រង់ដែរ។ អ្វីៗដែលទ្រង់បានបង្កើតមក មានលក្ខណៈ សប្បុរសតាមរយៈការរួមចំណែក និងទំនាក់ទំនងជាមួយទ្រង់តែ ប៉ុណ្ណោះ។ សេចក្ដីសប្បុរសជាមូលដ្ឋានរបស់ទ្រង់ ហើយទ្រង់មិន ត្រឹមតែមានមូលដ្ឋានជាសេចក្ដីសប្បុរសប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ផ្ទាល់ គឺជាសេចក្ដីសប្បុរសតែម្ដង៖ អ្វីៗដែលទ្រង់បានបង្កើតមក មាន លក្ខណៈសប្បុរស ព្រោះទ្រង់បានប្រទានដល់ពួកគេ ប៉ុន្តែចំពោះ ទ្រង់វិញ សេចក្ដីសប្បុរសគឺជាលក្ខណៈដែលទ្រង់មានដោយអង្គ ទ្រង់ផ្ទាល់។ សេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ស្ថិតស្ថេរនៅអស់ កល្បជានិច្ច។ អ្វីៗដែលទ្រង់បានបង្កើតមកសុទ្ធតែមានលក្ខណៈ សប្បុរស ប៉ុន្តែចំពោះសេចក្ដីសប្បុរសមនុស្សលោកវិញ យើងមាន តែមួយដំណាក់ប៉ុណ្ណោះ។ រីឯនៅក្នុងព្រះជាម្ចាស់វិញទ្រង់មានសេចក្ដី សប្បុរសប្រៀបដូចជាទឹកសមុទ្រដែលគ្មានព្រំដែន។ ព្រះអង្គសប្បុរស រហូតអស់កល្បជានិច្ច ហើយសេចក្ដីសប្បុរសរបស់ទ្រង់ក៏មិនចេះ ប្រែប្រួលដែរ ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់នឹងមិនដែលស្រុត ចុះទាបជាងលក្ខណៈដើមរបស់ទ្រង់ឡើយ។ យើងដឹងហើយថា គ្មានអ្វីមួយអាចយកមកបន្ថែម ឬដកចំណុចណាមួយចេញពីទ្រង់ ដើម្បីឲ្យទ្រង់មើលទៅកាន់តែមានសេចក្ដីសប្បុរសទៀតនោះឡើយ»

(លោកគ្រូ ថូម៉ាស មែនថិន Thomas Manton)។

## ព្រះជាម្ចាស់គឺជាកំពូលនៃសេចក្ដីសប្បុរស

ព្រះជាម្ចាស់មិនត្រឹមតែជាព្រះដ៏ល្អលើសអ្វីៗទាំងអស់ប៉ុណ្ណោះទេ តែទ្រង់ក៏ល្អអស្ចារ្យដាច់គេផងដែរ។ នៅពេលដែលព្រះអាទិករបង្កើតអ្វីៗទាំងអស់មក ព្រះអង្គបានដាក់គ្រប់ទាំងសេចក្ដីសប្បុរសនៅក្នុងរបស់ទាំងនោះ ប៉ុន្តែសេចក្ដីសប្បុរសរបស់ព្រះអង្គមិនមានប្រភពមកពីខាងក្រៅទេ ដ្បិតនោះគឺជាលក្ខណសម្បត្តិដែលទ្រង់មានតាំងពីអស់កល្បរៀងមកម្ល៉េះ។ ព្រះជាម្ចាស់មានឫទ្ធានុភាពលើសលុបតាំងពីអស់កល្បរៀងមក ពោលគឺតាំងពីមុនដែលទ្រង់បានបើកសម្ដែងពីសព្វានុភាពរបស់ទ្រង់ឲ្យយើងឃើញទៅទៀត។ ព្រះអង្គក៏មានពេញដោយសេចក្ដីសប្បុរសតាំងពីមុនពេលដែលមានអ្នកណាអាចពណ៌នាពីលក្ខណសម្បត្តិនោះ ឬក៏មុនពេលដែលមានអ្នកដែលទ្រង់ចែកឲ្យរួមចំណែកក្នុងសេចក្ដីសប្បុរសនោះទៅទៀតដែរ។ ទ្រង់បានបើកសម្ដែងឲ្យយើងឃើញលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះរបស់ទ្រង់ តាមរយៈអ្វីៗដែលទ្រង់បានបង្កើតមក៖ “ទ្រង់ល្អប្រសើរ ហើយក៏ធ្វើការល្អដែរ” (ទំនុកតម្កើង ១១៩:៦៨)។ នៅក្នុងព្រះអង្គមានព្រះពរដ៏មហាសាល និងមិនចេះរីងស្ងួត ដែលអាច

ផ្គត់ផ្គង់គ្រប់អ្វីៗទាំងអស់បាន។

គ្រប់ទាំងអំណាចព្រះចេស្ដាដែលចេញពីព្រះជាម្ចាស់ដូចជាៈ ព្រះតម្រិះ ការបង្កើត ក្រឹត្យវិន័យ និងការគ្រោងទុករបស់ទ្រង់ទាំងអស់នេះ សុទ្ធតែល្អទាំងអស់ ដូចដែលកណ្ឌគម្ពីរ លោកុប្បត្តិ ១:៣១ បានចែងថា «រួចព្រះទ្រង់ទតគ្រប់ទាំងរបស់ដែលទ្រង់បានធ្វើនោះ ក៏ឃើញថា ទាំងអស់ជាការល្អប្រពៃ»។ តាមរយៈអ្វីៗដែលទ្រង់បានបង្កើតមក យើងអាចមើលឃើញពីលក្ខណសម្បត្តិនៃសេចក្ដីសប្បុរសរបស់ទ្រង់មុនពេលដែលយើងមើលឃើញលក្ខណសម្បត្តិផ្សេងៗទៀត។ នៅពេលដែលយើងកាន់តែសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅអំពីអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមក នោះយើងនឹងកាន់តែឃើញយ៉ាងច្បាស់អំពីសេចក្ដីសប្បុរសនៃព្រះអាទិកររបស់យើង។ ឧទាហរណ៍ៈ ប្រសិនបើយើងសិក្សាស្វែងយល់អំពីមនុស្ស នោះយើងនឹងឃើញសេចក្ដីសប្បុរសជាច្រើនរបស់ទ្រង់ ដូចដែលអ្នកនិពន្ធកណ្ឌគម្ពីរ ទំនុកតម្កើង ១៣៩:១៤ បានលើកឡើងថា «ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោតគួរអស្ចារ្យ ឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់ ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ»។

គ្រប់អវយវៈទាំងអស់របស់យើងសុទ្ធតែបង្ហាញពីសេចក្ដីសប្បុរស

របស់ព្រះអាទិករ។ វាគឺជាការដ៏អស្ចារ្យណាស់ ដែលរាងកាយរបស់យើងទាំងមូលអាចធ្វើចលនាទៅតាមលក្ខណៈរបស់វាបានយ៉ាងរស់រវើក! ព្រះអម្ចាស់នៃយើងពិតជាអស្ចារ្យណាស់ ព្រោះទ្រង់បានប្រទានឲ្យយើងមានទាំងដំណេក ដើម្បីឲ្យរាងកាយដែលនឿយហត់របស់យើងបានសម្រាក! សេចក្តីសប្បុរសដែលទ្រង់បានប្រទានដល់យើងមានត្របកភ្នែក និងចិញ្ចើម ដើម្បីការពារភ្នែករបស់យើង ហើយនោះក៏ជាអ្វីដែលគួរឲ្យស្ងប់ស្ងែងដែរ។ ក្នុងរបៀបនេះ យើងអាចបន្តលើកឡើងឧទាហរណ៍ជាច្រើនទៀតបាន។

សេចក្តីសប្បុរសរបស់ព្រះមិនមែនសម្រាប់មនុស្សលោកនោះទេ ប៉ុន្តែយើងក៏ឃើញអំពីសេចក្តីសប្បុរសរបស់ទ្រង់ក្នុងអ្វីៗដែលទ្រង់បានបង្កើតមកដែរ។ "ភ្នែករបស់មនុស្សទាំងអស់រង់ចាំតែទ្រង់ ហើយទ្រង់ក៏ប្រទានអាហារដល់គេតាមត្រូវពេល ទ្រង់លាព្រះហស្តក៏បំពេញចិត្តប្រាថ្នានៃជីវិតទាំងឡាយ" (ទំនុកតម្កើង ១៤៥:១៥-១៦)។ យើងអាចនិពន្ធសៀវភៅជាច្រើនក្បាល ហើយក៏មានអ្នកនិពន្ធជាច្រើននាក់មែន ដើម្បីពន្យល់ពីសេចក្តីពិតនេះ។ ព្រះជាម្ចាស់បានផ្គត់ផ្គង់តម្រូវការជាច្រើនទៅដល់បក្សាបក្សីនៅលើអាកាស សត្វព្រៃ ក៏ដូចជាត្រីនៅក្នុងទន្លេ និងសមុទ្រផងដែរ។ ព្រះជាម្ចាស់បាន "ប្រទានអាហារដល់សត្វលោកទាំងឡាយដ្បិតព្រះហឫទ័យមេត្តាករុណា

របស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ» (ទំនុកតម្កើង ១៣៦:២៥ គខប)។ ប្រាកដណាស់! «ផែនដីមានពេញដោយសេចក្ដីសប្បុរស នៃព្រះយេហូវ៉ា» (ទំនុកតម្កើង ៣៣:៥)។

យើងអាចមើលឃើញសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ តាមរយៈការអរសប្បាយដែលទ្រង់បានដាក់នៅក្នុងកំណើតធម្មជាតិជាច្រើនប្រភេទរបស់យើង។ ព្រះជាម្ចាស់មិនចាំបាច់ចម្អែតយើងតាមរយៈអាហារ ដោយឲ្យស្គាល់រសជាតិឆ្ងាញ់នោះទេ ប៉ុន្ដែដោយសារទ្រង់ជាព្រះដ៏សប្បុរស ដូច្នេះហើយបានជាទ្រង់ថែមទាំងប្រទានឲ្យមាត់របស់យើងទទួលបានរសជាតិឆ្ងាញ់ពីសាច់ បន្លែ និងផ្លែឈើជាដើម។ល។ ព្រះជាម្ចាស់មិនត្រឹមតែប្រទានប្រសាទវិញ្ញាណទាំង៥ ឲ្យយើងប៉ុណ្ណោះទេ តែទ្រង់ក៏បានប្រទាននូវអ្វីៗដែលធ្វើឲ្យប្រសាទវិញ្ញាណទាំងនោះបានពេញចិត្តផងដែរ ដើម្បីឲ្យប្រសាទវិញ្ញាណទាំងនោះបានពេញចិត្តផងដែរ ហើយការនេះបញ្ជាក់ឲ្យយើងឃើញអំពីសេចក្ដីសប្បុរសរបស់ទ្រង់។ ព្រះជាម្ចាស់អាចបង្កើតផែនដីឲ្យមានជីវជាតិល្អ ដោយមិនចាំបាច់ឲ្យវាមានពណ៌ស្រស់ៗក៏បាន។ ព្រះជាម្ចាស់អាចនឹងទ្រទ្រង់យើងបានដោយមិនចាំបាច់ប្រទានការស្ដាប់ស្ដាល់ដល់យើង ឬបំពេញសេចក្ដីប៉ងប្រាថ្នានៃញាណរបស់យើង ដោយឲ្យយើងឃើញរបស់ស្អាត និងទទួលក្លិនឈ្ងុយនោះទេ។ យើង

ក៏អាចដើរក្នុងព្រៃដោយមិនចាំបាច់ឮសំឡេងសត្វបក្សីច្រៀងដែរ តែទ្រង់អនុញ្ញាតឲ្យយើងឮ។ ហេតុអ្វីបានជាព្រះប្រទានឲ្យយើងអាចដកពិសោធលើភាពស្រស់ស្អាតនៅជុំវិញយើង ដែលយើងមើលឃើញនៅក្នុងធម្មជាតិនេះបាន? ព្រោះទ្រង់មានព្រះហឫទ័យទន់សន្ដោសចំពោះយើង! ប្រាកដណាស់! «ព្រះហឫទ័យទន់សន្ដោសរបស់ទ្រង់ក៏គ្របលើកិច្ចការរបស់ទ្រង់ទាំងប៉ុន្មាន» (ទំនុកតម្កើង ១៤៥:៩)។

ការដែលព្រះជាម្ចាស់យឺតនឹងបង្ហាញសេចក្ដីក្រោធរបស់ទ្រង់ចំពោះយើង នៅពេលដែលយើងបានធ្វើបាបទាស់នឹងទ្រង់នោះ បង្ហាញឲ្យយើងឃើញពីសេចក្ដីសប្បុរសរបស់ទ្រង់។ ប្រសិនបើព្រះជាម្ចាស់ដកគ្រប់ទាំងព្រះពរ សេចក្ដីសុខ និងភាពអរសប្បាយចេញពីយើងនៅពេលដែលយើងបានធ្លាក់ក្នុងអំពើបាប នោះវាក៏នៅត្រឹមត្រូវដែរ។ ប៉ុន្តែ ផ្ទុយទៅវិញ ទ្រង់បែរជាប្រទានឲ្យយើងនូវការដាក់បញ្ចូលគ្នារវាងសេចក្ដីមេត្តាករុណា និងការជំនុំជម្រះ។ ប្រសិនបើយើងពិចារណាលើចំណុចនេះឲ្យបានត្រឹមត្រូវ នោះយើងនឹងឃើញថា នេះជារឿងដ៏អស្ចារ្យណាស់ ហើយប្រសិនបើយើងកាន់តែវិភាគលើរបៀបមួយនេះ នោះយើងនឹងកាន់តែឃើញថា «សេចក្ដីមេត្តានោះរមែងឈ្នះការជំនុំជម្រះ» (យ៉ាកុប ២:១៣)។

មានរឿងល្អៗជាច្រើនកើតឡើងចំពោះមនុស្សលោកយើងនៅ

លើផែនដីនេះ ហើយវាមានលើសច្រើនជាងអំពើអាក្រក់ដែលកើតឡើងមកកាន់យើងដែរ។ ជាទូទៅ ប្រសិនបើយើងប្រៀបធៀបអំពីថ្ងៃដែលយើងឈឺ ទៅនឹងថ្ងៃដែលយើងជា នោះយើងនឹងឃើញថាយើងមានថ្ងៃជាច្រើនជាងថ្ងៃឈឺ។ មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលមានថ្ងៃឈឺច្រើនជាងថ្ងៃជា។ មនុស្សដែលមានភាពអរសប្បាយ ក៏មានច្រើនជាងអ្នកដែលកើតតែទុក្ខព្រួយដែរ។ ទោះបើយើងស្ថិតក្នុងការព្រួយបារម្ភ ក៏យើងនៅតែទទួលបានការសម្រាលទុក្ខជាច្រើនដែរ។ ព្រះជាម្ចាស់បានប្រទានដល់យើងនូវខួរក្បាលមួយដែលអាចបត់បែនបាន ដូច្នេះយើងអាចសម្របសម្រួលទៅតាមកាលៈទេសៈ ហើយក៏អាចនាំមកនូវគុណប្រយោជន៍ជាច្រើនចេញពីកាលៈទេសៈនោះផង។

ទោះបើមានទុក្ខលំបាក និងការឈឺចាប់នៅក្នុងលោកីយ៍នេះក៏ដោយ ក៏យើងមិនអាចមានមន្ទិលសង្ស័យយ៉ាងយុត្តិធម៌អំពីសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់បានដែរ។ ប្រសិនបើមនុស្សយើងប្រព្រឹត្តអំពើបាបទាស់នឹងសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ ប្រសិនបើពួកគាត់ស្អប់ “សេចក្ដីសប្បុរសដ៏ឥតគណនា ព្រមទាំងសេចក្ដីទ្រាំទ្រនឹងសេចក្ដីអត់ធន់របស់ទ្រង់” ហើយយោងតាមការរឹងទទឹង និងការមិនទទួលស្គាល់កំហុសខ្លួន ដែលគាត់បានផ្ទុកនៅលើខ្លួនឯងនូវ

សេចក្ដីក្រោធទាស់នឹងថ្ងៃជំនុំជម្រះ (រ៉ូម ២:៤-៥) តើគាត់គួរបន្ទោសអ្នកណា ក្រៅពីខ្លួនឯង? តើព្រះជាម្ចាស់នៅតែជាព្រះដ៏សប្បុរសដែរឬទេ បើទ្រង់មិនថ្កោលទោសអស់អ្នកដែលមិនប្រើប្រាស់ព្រះពររបស់ទ្រង់ឲ្យបានល្អ អ្នកដែលប្រមាថសេចក្ដីសប្បុរសរបស់ទ្រង់ និងអ្នកដែលជាន់ឈ្លីសេចក្ដីមេត្តាករុណារបស់ទ្រង់ក្រោមបាតជើងរបស់ពួកគេនោះ? យើងនឹងកាន់តែមើលឃើញសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់យ៉ាងច្បាស់ នៅពេលដែលទ្រង់កំចាត់អស់អ្នកដែលប្រព្រឹត្តល្មើសទាស់នឹងក្រឹត្យវិន័យរបស់ទ្រង់លើផែនដីនេះ អ្នកដែលប្រឆាំងនឹងសញ្ញានុភាពរបស់ទ្រង់ អ្នកដែលចំអកមើលងាយទូតរបស់ទ្រង់ ក៏ដូចជាអ្នកដែលស្អប់ព្រះរាជបុត្រារបស់ទ្រង់ និងអស់អ្នកដែលបៀតបៀនដល់អ្នកដែលព្រះយេស៊ូវបានសុគតជំនួស។

យើងអាចមើលឃើញសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់បានកាន់តែច្បាស់ តាមរយៈការដែលទ្រង់បញ្ជូនព្រះរាជបុត្រារបស់ទ្រង់ «ឲ្យមកចាប់កំណើតនឹងស្ត្រី គឺកើតក្រោមអំណាចនៃក្រឹត្យវិន័យ ដើម្បីនឹងលោះពួកអ្នកដែលនៅក្រោមក្រឹត្យវិន័យ ប្រយោជន៍ឲ្យយើងបានទទួលសគុណ ទុកជាកូនចិញ្ចឹម» (កាឡាទី ៤:៤-៥)។ ហើយយើងក៏បានមើលឃើញសេចក្ដីសប្បុរសរបស់ទ្រង់ តាមរយៈការដែលពួកទេវតាច្រៀងសរសើរដល់ព្រះអាទិកររបស់គេដោយថា «សូមថ្វាយ

សិរីល្អដល់ព្រះដែលគង់នៅស្ថានដ៏ខ្ពស់បំផុត ហើយនៅផែនដី សូមឲ្យបានប្រកបដោយសេចក្តីសុខសាន្ត ដល់អស់អ្នកដែលព្រះអង្គគាប់ព្រះហឫទ័យ!» (លូកា ២:១៤ គកស)។ ដំណឹងល្អបានបង្ហាញអំពី «ព្រះគុណនៃព្រះ ដែលនាំសេចក្តីសង្គ្រោះមកដល់មនុស្សទាំងឡាយបានលេចមកហើយ» (ទីតុស ២:១១)។ ពាក្យថា «ព្រះគុណ» ក្នុងភាសាក្រិកក៏អាចមានន័យថា «សេចក្តីសប្បុរស ឬក៏សេចក្តីល្អ» ដែរ។ យើងគ្មានសិទ្ធិសង្ស័យថា តើព្រះសប្បុរសឬ ក៏មិនសប្បុរសនោះឡើយ ទោះបីជាទ្រង់មិនបានសង្គ្រោះមនុស្សមានបាបទាំងអស់តាមរយៈព្រះគុណរបស់ទ្រង់ក៏ដោយ។ ព្រះជាម្ចាស់មិនបានសង្គ្រោះពួកទេវតាដែលបានធ្លាក់ទៅក្នុងអំពើបាបទេ។ ទោះបីជាមនុស្សទាំងអស់វិនាសទៅដោយមិនបានទទួលសេចក្តីសង្គ្រោះក៏ដោយ ក៏ការនោះមិនអាចដកសេចក្តីសប្បុរសចេញពីព្រះជាម្ចាស់បានដែរ។ ចំពោះអស់អ្នកដែលសួរដេញដោលលើប្រយោគនេះ យើងនឹងរម្លឹកពួកគេអំពីអធិបតេយ្យភាពដ៏ពេញសិទ្ធិរបស់ព្រះអម្ចាស់នៃយើងថា៖ «តើខ្ញុំគ្មានសិទ្ធិនឹងយកប្រាក់របស់ខ្ញុំ ទៅធ្វើអ្វីតាមបំណងចិត្តខ្ញុំទេឬ? ឬមួយអ្នកច្រណែន មកពីឃើញខ្ញុំមានចិត្តសប្បុរស?» (ម៉ាថាយ ២០:១៥ គខប)។

# ចូរសរសើរព្រះជាម្ចាស់សម្រាប់សេចក្តីសប្បុរសទ្រង់

«ឱសូមឲ្យមនុស្សទាំងឡាយសរសើរដល់ព្រះយេហូវ៉ា ដោយព្រោះសេចក្តីសប្បុរសរបស់ទ្រង់ ហើយដោយព្រោះអស់ទាំងការអស្ចារ្យ ដែលទ្រង់បានប្រោសដល់មនុស្សជាតិ» (ទំនុកតម្កើង ១០៧:៨)។ ការដឹងគុណគឺជាការឆ្លើយតបដ៏ត្រឹមត្រូវចំពោះសេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ ប៉ុន្តែជាទូទៅយើងមិនបានអរព្រះគុណដល់ព្រះដ៏សប្បុរសរបស់យើង ដែលសេចក្តីសប្បុរសរបស់ទ្រង់ទៀងទាត់ ហើយបរិបូណ៌នោះទេ។ មើលទៅ យើងហាក់ដូចជាមិនសូវអរព្រះគុណទ្រង់នោះទេ ពីព្រោះសេចក្តីសប្បុរសដែលទ្រង់សម្តែងរាល់ថ្ងៃនោះ ស្ថិតនៅក្នុងកាលៈទេសៈសាមញ្ញពេក។ យើងមិនសូវចាប់អារម្មណ៍ចំពោះការអរព្រះគុណទ្រង់ទេ ព្រោះយើងទទួលសេចក្តីសប្បុរសរបស់ទ្រង់ជារៀងរាល់ថ្ងៃ។ កណ្ឌគម្ពីរ រ៉ូម ២:៤ បានសួរថា តើយើង «មើលងាយសេចក្តីសប្បុរស» របស់ទ្រង់ឬ? មនុស្សយើងបាន «មើលងាយ» សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ នៅពេលដែលយើងមិនបានប្រើសេចក្តីសប្បុរសនោះ ដើម្បីនាំឲ្យប្រែចិត្តជឿលើទ្រង់ ហើយបែរជាប្រើវា ដើម្បីធ្វើឲ្យមានចិត្តរឹងរូស មិនជឿថាទ្រង់បានអត់ទោសបាបរបស់មនុស្សលោក។

សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ គឺជាទំនុកចិត្តនៃជីវិតអ្នក

ជឿ។ លក្ខណសម្បត្តិដ៏ឧត្ដុង្គឧត្ដមរបស់ព្រះជាម្ចាស់មួយនេះ ទាក់ទាញអារម្មណ៍របស់យើងជាងគេក្នុងចំណោមលក្ខណសម្បត្តិផ្សេងៗទៀត។ យើងមិនត្រូវបាក់ទឹកចិត្តឡើយ ព្រោះសេចក្ដីសប្បុរសរបស់ទ្រង់នៅស្ថិតស្ថេរជាដរាប៖ «ព្រះយេហូវ៉ាទ្រង់ល្អ ទ្រង់ជាទីពឹងមាំមួននៅគ្រាលំបាក ក៏ស្គាល់អស់អ្នកដែលយកទ្រង់ជាទីពឹងផ្អែក» ផងដែរ (ណាហ៊ុម ១:៧)។

«នៅពេលដែលអ្នកដទៃធ្វើអាក្រក់មកលើយើង ការនោះគួរតែជំរុញយើងឲ្យអរព្រះគុណដល់ព្រះជាម្ចាស់ឲ្យអស់ពីចិត្តរបស់យើង ដ្បិតទ្រង់ជាព្រះដ៏សប្បុរស។ នៅពេលដែលយើងដឹងខ្លួនថា យើងនៅឆ្ងាយពីសេចក្ដីសប្បុរសណាស់ ការនោះគួរតែជំរុញឲ្យយើងកាន់តែចេះថ្វាយព្រះពរដល់ទ្រង់ដោយការគោរព ដ្បិតទ្រង់ជាព្រះដ៏សប្បុរស។ ទោះបើយើងមានមន្ទិលសង្ស័យលើអ្វីផ្សេងៗទៀតអំពីព្រះជាម្ចាស់ក៏ដោយ ក៏យើងមិនគួរមានមន្ទិលសង្ស័យលើសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ដែរ ពីព្រោះសេចក្ដីសប្បុរសរបស់ព្រះអង្គគឺពិតប្រាកដណាស់។ របៀបដែលព្រះជាម្ចាស់ផ្ដត់ផ្គង់អាចផ្លាស់ប្ដូរបាន ប៉ុន្តែលក្ខណសម្បត្តិរបស់ទ្រង់គឺនៅដដែលជារៀងរហូត (លោកគ្រូ ស៊ី. អេឆ. ស្ពើចិន)។

ជំពូកទី១២

# ការអត់ធ្មត់របស់ព្រះជាម្ចាស់

លក្ខណសម្បត្តិនៃការអត់ធ្មត់របស់ព្រះជាម្ចាស់ មិនសូវជាមានអ្នកនិពន្ធយកមកបកស្រាយច្រើនប៉ុន្មានទេ បើប្រៀបធៀបជាមួយនឹងលក្ខណសម្បត្តិនានា។ មនុស្សភាគច្រើនដែលបាននិពន្ធសៀវភៅអំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់បានរំលងការអត់ធ្មត់របស់ព្រះជាម្ចាស់ ហើយក៏មិនបានសរសេរអ្វីអំពីលក្ខណៈនោះដែរ។ វាក៏មិនងាយទេក្នុងការលើកឡើងជាសំណើអំពីមូលហេតុ ដែលអ្នកនិពន្ធបានរំលងការអត់ធ្មត់របស់ព្រះជាម្ចាស់ក្នុងការសរសេររបស់ពួកគាត់។ ដ្បិតការអត់ធ្មត់របស់ព្រះជាម្ចាស់ក៏ជាលក្ខណសម្បត្តិដ៏សំខាន់ដូចលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះផ្សេងទៀតរបស់ទ្រង់ ដែលមានដូចជាព្រះប្រាជ្ញា និងអំណាចព្រះចេស្ដា ព្រមទាំងសេចក្ដីបរិសុទ្ធ ហើយយើងក៏គួរស្ញប់ស្ញែង និងកោតខ្លាចចំពោះលក្ខណសម្បត្តិនេះ

ដូចដែលយើងស្អប់ស្អែង និងកោតខ្លាចចំពោះលក្ខណសម្បត្តិផ្សេង នោះផងដែរ។ ជាការពិតណាស់ យើងអាចរកឃើញពាក្យនេះ ទោះបើមិនមានជាញឹកញាប់ដូចពាក្យផ្សេងៗទៀតដែលមាននៅក្នុងសៀវភៅវិជ្ជាសមោធាននោះទេ បើប្រៀបទៅនឹងលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះផ្សេងទៀត។ ប៉ុន្តែ ទោះជាយ៉ាងណាក្ដី ក៏យើងនៅតែមើលឃើញសិរីរុងរឿងនៃព្រះគុណនៃការអត់ធ្មត់របស់ទ្រង់នៅស្ទើរគ្រប់ទំព័រទាំងអស់នៃព្រះគម្ពីរដែរ។ ប្រសិនបើយើងមិនសញ្ជឹងគិតអំពីភាពអត់ធ្មត់របស់ព្រះជាម្ចាស់ឲ្យបានញឹកញាប់ ហើយអធិស្ឋានឲ្យអស់ពីចិត្ត ដើម្បីឲ្យដួងចិត្ត និងជីវិតរស់នៅរបស់យើងកាន់តែត្រាប់តាមទ្រង់ទេនោះ យើងនឹងខាតបង់យ៉ាងច្រើនជាមិនខាន។

មូលហេតុចម្បងដែលអ្នកនិពន្ធជាច្រើនមិនបានសរសេរសៀវភៅដែលគ្រាន់តែផ្ដោតលើលក្ខណសម្បត្តិនេះ គឺដោយសារតែពួកគាត់មានការពិបាកក្នុងការបែងចែករវាងលក្ខណសម្បត្តិមួយនេះ និងលក្ខណសម្បត្តិដែលបង្ហាញថា ទ្រង់ជាព្រះដែលប្រកបដោយក្ដីសប្បុរស និងសេចក្ដីមេត្តាករុណា ជាពិសេសលក្ខណសម្បត្តិនៃសេចក្ដីមេត្តាករុណា។ ព្រះគម្ពីរបានពណ៌នាអំពីការអត់ធ្មត់របស់ព្រះជាម្ចាស់ដែលស្របទៅនឹងព្រះគុណ និងសេចក្ដីមេត្តាករុណារបស់ទ្រង់ម្ដងហើយម្ដងទៀត ហើយយើងក៏អាចមើលឃើញចំណុច

នេះនៅក្នុងកណ្ឌគម្ពីរដូចជា និក្ខមនំ ៣៤:៦; ជនគណនា ១៤:១៨; ទំនុកតម្កើង ៨៦:១៥។ល។ ព្រះគម្ពីរបានលើកឡើងម្ដងហើយម្ដងទៀតអំពីភាពអត់ធ្មត់របស់ព្រះជាម្ចាស់ ដែលទ្រង់បានសម្ដែងតាមរយៈសេចក្ដីមេត្តាករុណារបស់ទ្រង់ ហើយយើងក៏មិនអាចបដិសេធសេចក្ដីពិតនេះបានដែរ ប៉ុន្តែយើងមិនអាចរាប់ថា លក្ខណសម្បត្តិទាំងពីរនេះដូចគ្នាទាំងស្រុងបានទេ។ ប្រាកដណាស់! យើងនឹងមានការពិបាកក្នុងការញែកញែកអំពីចំណុចនីមួយៗនៃលក្ខណសម្បត្តិទាំងពីរនេះ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ព្រះគម្ពីរបានបញ្ជាក់ប្រាប់យើងយ៉ាងច្បាស់ហើយថា ការអត់ធ្មត់របស់ព្រះជាម្ចាស់មានលក្ខណសម្បត្តិខ្លះដែលសេចក្ដីមេត្តាករុណារបស់ទ្រង់មិនមាន ហើយសេចក្ដីមេត្តាករុណារបស់ទ្រង់ក៏មានលក្ខណសម្បត្តិខ្លះដែលការអត់ធ្មត់របស់ព្រះជាម្ចាស់មិនមានដែរ។

## ការអត់ធ្មត់របស់ព្រះជាម្ចាស់ឈ្នះ

លោកគ្រូ ស្ទេហ្វិន ឆ័រណោក ដែលជាអ្នកព្យួរីតិន (Puritan) ម្នាក់បានរៀបរាប់អំពីការអត់ធ្មត់របស់ព្រះជាម្ចាស់ក្នុងអត្ថន័យមួយដូចតទៅ៖

“ការអត់ធ្មត់គឺជាផ្នែកមួយនៃសេចក្ដីសប្បុរស និងសេចក្ដីមេត្តា

ករុណារបស់ព្រះជាម្ចាស់ ប៉ុន្តែការអត់ធ្មត់ខុសប្លែកពីលក្ខណសម្បត្តិទាំងពីរនោះ។ ដោយព្រោះទ្រង់ជាព្រះដ៏សប្បុរសបំផុត ដូច្នេះទ្រង់ក៏ជាព្រះដ៏ស្លូតបំផុតផងដែរ។ ភាពស្លូតបូតតែងតែដេញតាមភាពសប្បុរសដ៏ពិត៖ កាន់តែសប្បុរស កាន់តែស្លូតបូត។ តើមានអ្នកណាបរិសុទ្ធ ហើយស្លូតបូតដូចជាព្រះគ្រីស្ទដែរឬទេ? ការយឺតនឹងខ្ញាល់របស់ព្រះជាម្ចាស់ គឺជាផ្នែកមួយនៃសេចក្ដីមេត្តាករុណារបស់ទ្រង់៖ "ព្រះយេហូវ៉ាទ្រង់ប្រកបដោយក្ដីមេត្តាករុណា និងអាណិតអាសូរទ្រង់យឺតនឹងខ្ញាល់" (ទំនុកតម្កើង ១៤៥:៨)។ ការអត់ធ្មត់ខុសពីសេចក្ដីមេត្តាករុណាត្រង់ការពិចារណាទៅលើប្រធានបទ៖ សេចក្ដីមេត្តាករុណាកើតមានចំពោះមនុស្សដែលរងទុក្ខវេទនា ឯការអត់ធ្មត់កើតមានចំពោះមនុស្សឧក្រិដ្ឋ។ សេចក្ដីមេត្តាករុណាដុះចេញនូវការអាណិតអាសូរដល់មនុស្សដែលរងទុក្ខវេទនា ឯការអត់ធ្មត់វិញដុះចេញនូវការទ្រាំទ្រចំពោះអំពើបាប ដែលនាំមកនូវសេចក្ដីវេទនា ហើយក៏បង្កើតឲ្យមានសេចក្ដីវេទនាថែមទៀតដែរ»។

យើងអាចនឹងពណ៌នាអំពីភាពអត់ធ្មត់របស់ព្រះជាម្ចាស់ដោយខ្លួនយើងផ្ទាល់ថា ជាការដែលទ្រង់គ្រប់គ្រងលើអំណាចព្រះចេស្ដារបស់ទ្រង់ផ្ទាល់ ដែលការនោះបណ្ដាលឲ្យព្រះអង្គទ្រាំទ្រចំពោះមនុស្សអាក្រក់ ហើយការនោះក៏បណ្ដាលឲ្យទ្រង់ពន្យារពេលយ៉ាង

យូរ មុនដែលទ្រង់ដាក់ទោសពួកគេដែរ។ យើងអាចមើលឃើញចំណុចនេះនៅក្នុងកណ្ឌគម្ពីរ ណាហ៊ុម ១:៣ ដែលបានចែងថា “ព្រះយេហូវ៉ាទ្រង់យឺតនឹងខ្ញាល់ ហើយមានព្រះចេស្តាយ៉ាងធំ”។ លោកគ្រូ (ស្ទេហ្វិន ឆ័រណេក) បានលើកឡើងទាក់ទងនឹងខគម្ពីរត្រង់ចំណុចនេះថា៖

“មនុស្សដែលមានមុខមាត់ខ្ពង់ខ្ពស់នៅក្នុងលោកីយ៍នេះតែងតែឆាប់ខឹង ហើយមិនងាយនឹងអត់ទោសដល់អ្នកដែលធ្វើខុសចំពោះខ្លួនទេ ក៏មិនចេះទ្រាំទ្រនឹងអ្នកដែលធ្វើខុសចំពោះខ្លួនឡើយ ដែលអ្នកទាំងនោះមានឋានៈទាបជាងពួកគេ។ ការចង់បានអំណាចនេះហើយ ដែលនាំឲ្យមនុស្សជាច្រើនធ្វើនូវអ្វីដែលខ្លួនមិនគួរធ្វើ នៅពេលដែលមានការញុះញង់បន្តិចបន្តួច។ ព្រះអម្ចាស់ [នៅលើផែនដីនេះ] ដែលចេះគ្រប់គ្រងរូបអង្គទ្រង់ គឺជាស្តេចលើខ្លួនឯង ហើយក៏ដូចជាស្តេចលើរាស្ត្ររបស់ទ្រង់ផងដែរ។ ព្រះជាម្ចាស់យឺតនឹងខ្ញាល់ ព្រោះទ្រង់មានពេញដោយអំណាចព្រះចេស្តា។ ដែលព្រះជាម្ចាស់មានអំណាចលើអង្គទ្រង់ផ្ទាល់យ៉ាងណា នោះទ្រង់ក៏មានអំណាចលើអ្វីៗដែលទ្រង់បានបង្កើតមកយ៉ាងនោះដែរ។”

ប្រសិនបើយើងវិភាគមើលទៅ នោះយើងនឹងមើលឃើញយ៉ាងច្បាស់ថា គឺចំណុចខាងលើនេះហើយ ដែលញែកការអត់ធ្មត់របស់

ព្រះជាម្ចាស់ចេញពីសេចក្ដីមេត្តាករុណារបស់ទ្រង់។ ការអត់ធ្មត់របស់ព្រះជាម្ចាស់មានទំនាក់ទំនងជាចម្បងចំពោះទ្រង់។ ការអត់ធ្មត់របស់ទ្រង់គឺជាអ្វីដែលទ្រង់បានដាក់លើទង្វើល្អរបស់ទ្រង់ តាមរយៈព្រះហឫទ័យរបស់ទ្រង់។ ចំណែកឯសេចក្ដីមេត្តាករុណារបស់ទ្រង់វិញ គឺទ្រង់ផ្ដោតយ៉ាងខ្លាំងដល់អ្វីៗដែលទ្រង់បានបង្កើតចោលមកទាំងស្រុង។ ភាពអត់ធ្មត់របស់ព្រះជាម្ចាស់គឺជាលក្ខណសម្បត្តិដ៏ឧដុង្គឧត្តមរបស់ទ្រង់ ដែលនាំឲ្យទ្រង់ទ្រាំទ្រការរងរបួសដោយមិនចាំបាច់សងសឹកភ្លាមៗ។ ព្រះជាម្ចាស់មានអំណាចព្រះចេស្ដាក្នុងការអត់ធ្មត់ ក៏ដូចជាសេចក្ដីយុត្តិធម៌របស់ទ្រង់ផងដែរ។ ហេតុដូច្នេះហើយបានជាអ្នកបកប្រែព្រះគម្ពីរប្រើពាក្យ «អត់ធ្មត់» នៅក្នុងភាសាហេព្រើរថា «យឺតនឹងខ្ញាល់» នៅក្នុងកណ្ឌគម្ពីរ នេហេមា ៩:១៧ និងទំនុកតម្កើង ១០៣:៨។ល។ ចូរកុំច្រឡំថា ព្រះជាម្ចាស់មានលក្ខណៈឆាប់នឹងខ្ញាល់ទ្បើយ ប៉ុន្តែគឺទ្រង់ប្រព្រឹត្តដោយប្រាជ្ញាវិញទេតើ ហើយព្រះហឫទ័យរបស់ទ្រង់ក៏វិសេសវិសាលដែរ ឯការដែលទ្រង់ជ្រាបពីអ្វីៗដោយផ្ទាល់ក៏បានបញ្ជាក់ដែរថាទ្រង់ជាព្រះដ៏ឧដុង្គឧត្តម។

ដើម្បីពង្រឹងលើអត្ថន័យនៃការអត់ធ្មត់ដ៏ឧត្តមរបស់ព្រះជាម្ចាស់ដែលយើងបានលើកទ្បើងខាងលើនេះ គឺយើងអាចលើកឧទាហរណ៍អំពីការដែលលោក ម៉ូសេ អំពាវនាវដល់ព្រះជាម្ចាស់ដោយពឹងផ្អែក

លើលក្ខណសម្បត្តិមួយនេះ ពោលគឺសុំឲ្យទ្រង់អត់ទោសឲ្យសាសន៍អ៊ីស្រាអែល ព្រោះពួកគេបានប្រព្រឹត្តអំពើបាបយ៉ាងធំធេងនៅឯស្រុកកាដេស-បារនា។ ព្រះជាម្ចាស់បានមានព្រះបន្ទូលទៅកាន់បាវបម្រើរបស់ទ្រង់ថា ទ្រង់នឹងប្រហារពួកគេដោយរោគប៉ូស ហើយដកមរតករបស់ពួកគេចេញ។ បន្ទាប់មកយើងឃើញលោក ម៉ូសេ ដែលជាអ្នកកណ្ដាល (ជាប្រភេទមួយនៃព្រះគ្រីស្ទដែលនឹងយាងមក) បានបន្លឺឡើងថា “ឥឡូវនេះ ទូលបង្គំសូមអង្វរដល់ទ្រង់ ឲ្យព្រះចេស្ដានៃព្រះអម្ចាស់បានធំ ដូចជាទ្រង់មានបន្ទូលរួចហើយថា ព្រះយេហូវ៉ាទ្រង់យឺតនឹងខ្ញាល់” (ជនគណនា ១៤:១៧-១៨)។ សរុបមក ភាព “យឺតនឹងខ្ញាល់” នេះគឺជា “អំណាចព្រះចេស្ដា” ដែលបណ្ដាលឲ្យទ្រង់គ្រប់គ្រងលើព្រះអង្គទ្រង់ផ្ទាល់ ដោយមិនសម្ដែងសេចក្ដីក្រោធភ្លាមៗឡើយ។

យើងក៏អាចអាននៅក្នុងកណ្ឌគម្ពីរ រ៉ូម ៩:២២ ដែលថា “ចុះបើសិនជាព្រះទ្រង់ចង់សម្ដែងសេចក្ដីក្រោធ ព្រមទាំងបើកឲ្យស្គាល់ព្រះចេស្ដា ដល់គ្រឿងប្រដាប់គួរនឹងក្រោធ ដែលរៀបចំឡើងសម្រាប់តែត្រូវបំផ្លាញដូច្នេះ...”? ប្រសិនបើព្រះជាម្ចាស់បំផ្លាញ “គ្រឿងប្រដាប់គួរនឹងក្រោធ” នោះភ្លាម ការនោះនឹងមិនបង្ហាញឲ្យឃើញច្បាស់លាស់អំពីអំណាចព្រះចេស្ដា ដែលទ្រង់ចេះគ្រប់គ្រងលើព្រះអង្គទ្រង់

នោះទេ។ តាមរយៈការដែលព្រះអង្គទ្រាំទ្រចំពោះមនុស្សអាក្រក់ទាំងនោះ និងការដែលទ្រង់ពន្យារពេលក្នុងការដាក់ទោសពួកគេ បង្ហាញយ៉ាងច្បាស់អំពីការអត់ធ្មត់ដ៏អស្ចារ្យរបស់ទ្រង់។ ប្រាកដណាស់! មនុស្សអាក្រក់កាត់ស្រាយការយឺតនឹងខ្វាល់របស់ព្រះអង្គខុសពីការដែលពួកគេគួរកាត់ស្រាយ «ចិត្តរបស់ពួកមនុស្សជាតិបានផ្ដាច់ទៅឲ្យប្រព្រឹត្តតាមអំពើអាក្រក់ជានិច្ច ដោយព្រោះតែការធ្វើទោស ចំពោះអំពើអាក្រក់ មិនបានសម្រេចជាយ៉ាងឆាប់» (សាស្តា ៨:១១)—ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏អ្នកជឿនៅស្រឡាញ់នូវអ្វីដែលពួកគេកំពុងរំលោភបំពានដែរ។

«ព្រះនៃសេចក្តីអត់ធ្មត់» គឺជាព្រះនាមមួយនៃព្រះនាមជាច្រើនរបស់ព្រះជាម្ចាស់ (រ៉ូម ១៥:៥)។ ទ្រង់មានព្រះនាមដូច្នេះព្រោះ *ទី១* ទ្រង់ជាអង្គនិពន្ធផង និងជាអង្គដែលទទួលព្រះគុណនៃការអត់ធ្មត់ក្នុងពួកបរិសុទ្ធផង។ *ទី២* ក្នុងរូបអង្គនៃទ្រង់ផ្ទាល់ គឺទ្រង់ជាព្រះដែលពេញដោយការអត់ធ្មត់ ដូច្នេះហើយបានជាការអត់ធ្មត់គឺជាលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះរបស់ទ្រង់។ *ទី៣* នេះជាលំនាំសម្រាប់យើង «ដូច្នេះ...ចូរប្រដាប់កាយ ដោយចិត្តក្ដួលអាណិត សប្បុរស សុភាពស្លូតបូត និងចិត្តអត់ធ្មត់ចុះ» (កូឡូស ៣:១២ គកស)។ ហើយជាថ្មីម្តងទៀត «...ដើរក្នុងសេចក្ដីស្រឡាញ់ ដូចជាព្រះគ្រីស្ទបានស្រឡាញ់

យើង» (អេភេសូរ ៥:២)។ នៅពេលដែលយើងជួបសេចក្ដីល្បួងដែលនាំឲ្យយើងស្អប់អ្នកណាម្នាក់ ដោយការស្ដីករបស់អ្នកផ្សេង ឬសងសឹកចំពោះអ្នកណាម្នាក់ដែលបានប្រព្រឹត្តខុសមកលើយើង នោះចូរយើងចងចាំអំពីការអត់ធ្មត់ និងភាពយឺតនឹងខ្ញាល់ដ៏ឥតព្រំដែនរបស់ព្រះជាម្ចាស់ ដែលទ្រង់មានចំពោះយើងជាមុនសិន។

## ភាពអត់ធ្មត់របស់ព្រះជាម្ចាស់នៅពេលមុន និងឥឡូវនេះ

យើងឃើញការអត់ធ្មត់របស់ព្រះជាម្ចាស់តាមរយៈទំនាក់ទំនងរបស់ទ្រង់ជាមួយនឹងមនុស្សមានបាប។ ហើយយើងក៏ឃើញយ៉ាងច្បាស់អំពីការអត់ធ្មត់របស់ទ្រង់ទៅកាន់មនុស្សនៅជំនាន់មុនសម័យទឹកជំនន់ដែរ។ ទោះបើមនុស្សនៅសម័យនោះបានប្រែពីល្អទៅអាក្រក់ ហើយមនុស្សទាំងអស់បែរទៅជាដើរក្នុងផ្លូវដ៏ពុករលួយក៏ដោយ ក៏ព្រះជាម្ចាស់មិនបានបំផ្លាញពួកគេចោលដែរ រហូតដល់ពេលដែលទ្រង់បានប្រាប់ពួកគេឲ្យដឹងជាមុនសិន។ កណ្ឌគម្ពីរ ១ពេត្រុស ៣:២០ បានបង្ហាញឲ្យយើងឃើញថាទ្រង់ «បានរង់ចាំ» ហើយបើយើងមើលនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៦:៣ គឺប្រហែលជាមិនតិចជាង១២០ ឆ្នាំទេ ហើយខណៈពេលនោះលោក ណូអេ «ជាអ្នកប្រកាសប្រាប់ពី

សេចក្តីសុចរិត» (២ពេត្រុស ២:៥)។ ដូចគ្នាផងដែរ នៅពេលដែលសាសន៍ដទៃចាប់ផ្តើមថ្វាយបង្គំ និងបម្រើរបស់ដែលព្រះអាទិករបានបង្កើតមកជាជាងថ្វាយបង្គំ និងបម្រើទ្រង់ ហើយពួកគេក៏ថែមទាំងបាននាំគ្នាប្រព្រឹត្តអំពើដ៏គួរឲ្យស្អប់ខ្ពើមដែលជាទង្វើប្រាសចាកពីធម្មជាតិរបស់ខ្លួន (រ៉ូម ១:១៩-២៦) ដែលការនោះកាន់តែនាំឲ្យអំពើបាបរបស់ពួកគេកើនឡើងៗ ក៏ជាជាងដកដាវរបស់ទ្រង់ ដើម្បីបំផ្លាញពួកបះបោរនោះចោល ក៏ព្រះជាម្ចាស់ «បានអនុញ្ញាតឲ្យគ្រប់ទាំងសាសន៍ ដើរតាមផ្លូវរបស់គេរៀងខ្លួន...ទ្រង់ប្រោសប្រទានឲ្យភ្លៀងធ្លាក់ចុះពីលើមេឃ ឲ្យមានរដូវដ៏សំបូរ» (កិច្ចការ ១៤:១៦-១៧)។

ការដែលព្រះជាម្ចាស់បានអត់ធ្មត់ចំពោះសាសន៍អ៊ីស្រាអែល ហើយបានសម្តែងការនោះដល់ពួកគេ គឺជារឿងគួរឲ្យស្ញប់ស្ញែងខ្លាំងណាស់។ ជាដំបូងទ្រង់បាន «ទ្រាំទ្រនឹងកិរិយារបស់គេ» អស់រយៈពេល៤០ឆ្នាំនៅក្នុងទីរហោស្ថាន (កិច្ចការ ១៣:១៨)។ ហើយក្រោយមកទៀត នៅពេលដែលពួកគេបានចូលទៅកាន់ទឹកដីកាណាន ពួកគេក៏បានត្រាប់តាមទំនៀមទំលាប់ដ៏អាក្រក់ៗរបស់ជាតិសាសន៍ដែលនៅជុំវិញពួកគេ ហើយបាននាំគ្នាទៅថ្វាយបង្គំព្រះដទៃវិញ ដែលការនោះបានបណ្តាលឲ្យព្រះជាម្ចាស់ដាក់ទោសពួកគេយ៉ាងខ្លាំង ប៉ុន្តែទ្រង់មិនបានបំផ្លាញពួកគេចោលទាំងស្រុង

នោះទេ ហើយនៅពេលដែលពួកគេរងទុក្ខ ទ្រង់ក៏បានតាំងឲ្យមានអ្នកជួយសង្គ្រោះពួកគេដែរ។ នៅពេលដែលពួកគេធ្វើបាបកាន់តែច្រើនឡើងៗ ព្រះដ៏ពេញដោយភាពអត់ធ្មត់នៅតែទ្រាំទ្រពួកគេដដែល ហើយទ្រង់បានទុកជីវិតឲ្យពួកគេជាច្រើនឆ្នាំមុនពេលទ្រង់អនុញ្ញាតឲ្យសាសន៍បាប៊ីឡូនមកចាប់ពួកគេយកទៅស្រុកបាប៊ីឡូន។

នៅទីបញ្ចប់ នៅពេលដែលការប្រឆាំងបះបោររបស់ពួកគេបានឈានដល់កម្រិតខ្ពស់បំផុត គឺរហូតដល់ពួកគេបានយកព្រះរាជបុត្រារបស់ទ្រង់ទៅឆ្កាង។ ព្រះអង្គបានរង់ចាំអស់រយៈពេល៤០ឆ្នាំ មុនដែលទ្រង់ចាត់សាសន៍រ៉ូមឲ្យមកទាស់នឹងពួកគេ ហើយការនោះបានកើតឡើងមុនពេលដែលពួកគេវិនិច្ឆ័យខ្លួនឯងថា ខ្លួន «មិនគួរនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចនោះទេ» (កិច្ចការ ១៣:៤៦)។

ភាពអត់ធ្មត់របស់ព្រះជាម្ចាស់ចំពោះលោកីយ៍សព្វថ្ងៃនេះ គឺអស្ចារ្យណាស់។ មនុស្សយើងភាគច្រើនកំពុងធ្វើបាបទាស់នឹងព្រះជាម្ចាស់យ៉ាងអនាធិបតេយ្យ។ មនុស្សយើងបានជាន់ឈ្លីក្រឹត្យវិន័យរបស់ព្រះជាម្ចាស់នឹងបាតជើង ហើយក៏បានបង្ហាញជាសាធារណៈថា ពួកគេស្អប់ទ្រង់ពេញក្រអៅបេះដូងរបស់ខ្លួនដែរ។ វាគួរឲ្យភ្ញាក់ផ្អើលខ្លាំងណាស់ដែលទ្រង់មិនបានសម្លាប់អស់អ្នកដែលបំបាក់មុខទ្រង់ដោយឥតញញើត! តើហេតុអ្វីបានជាទ្រង់

មិនកំចាត់ពួកឆ្មើងឆ្មៃ ពួកអ្នកមិនជឿ និងពួកអ្នកដែលប្រមាថទ្រង់ ដោយឥតអៀនខ្មាសចោលភ្លាមៗ ដូចដែលទ្រង់បានធ្វើចំពោះលោក អាន៉ានាស និងនាង សាភីរ៉ា ដូច្នេះ (កិច្ចការ ៥)? តើហេតុអ្វីបាន ជាទ្រង់មិនអនុញ្ញាតឲ្យផែនដី បើកមាត់លេបត្របាក់អស់អ្នកដែល បៀតបៀនរាស្ត្ររបស់ទ្រង់ទាំងរស់ក្នុងរណ្តៅ ដូចដែលទ្រង់បានធ្វើ ចំពោះលោក ដាថាន និងលោក អ័ប៊ីរ៉ាម (ជនគណនា ១៦)? ចុះ ចំពោះក្រុមគ្រីស្ទបរិស័ទដែលបានចូលក្រុមខុសឆ្គង មិនរើសអើង បាប ហើយថែមទាំងប្រព្រឹត្តបាបជាច្រើន ដោយលាក់បាបនោះ នៅក្រោមព្រះនាមដ៏បរិសុទ្ធរបស់ព្រះយេស៊ូវវិញ? តើហេតុអ្វីបានជា សេចក្ដីក្រោធដ៏យុត្តិធម៌របស់ព្រះនៃស្ថានសួគ៌ មិនបំផ្លាញពួកគេដ៏ គួរឲ្យស្អប់ខ្ពើមចោលភ្លាមៗដូច្នេះ? មានចម្លើយតែមួយគត់ដែលសម ហេតុសមផលគឺ៖ ពីព្រោះព្រះជាម្ចាស់ទ្រាំទ្រនឹង «គ្រឿងប្រដាប់គួរ នឹងក្រោធ ដែលរៀបចំឡើងសម្រាប់តែត្រូវបំផ្លាញដូច្នេះ ដែលទ្រង់ ទ្រាំទ្រដោយអំណត់ជាយូរមកហើយ» (រ៉ូម ៩:២២)។

ចុះចំណែកយើងខ្ញុំដែលជាអ្នកនិពន្ធ និងមិត្តអ្នកអានវិញ? ចូរ យើងពិនិត្យមើលជីវិតខ្លួនឯង ដ្បិតទើបតែថ្មីៗនេះទេ ដែលយើងបាន ធ្វើតាមគំរូអាក្រក់ជាច្រើន ដោយមិនខ្វល់ពីសិរីល្អរបស់ព្រះជាម្ចាស់ ព្រមទាំងរស់នៅ ដើម្បីបំពេញតែបំណងចិត្តខ្លួនឯង។ យើងបាន

ឃើញហើយថា ព្រះជាម្ចាស់មានសេចក្ដីអត់ធ្មត់ខ្លាំងប៉ុណ្ណាចំពោះ អំពើអាក្រក់របស់យើង! ឥឡូវនេះ ព្រះគុណបានដកយើងចេញពី ភ្លើងដូចជាត្រាដែកដែលគេប្រើសម្រាប់បោះសម្គាល់។ ព្រះគុណបាន ផ្ដល់ឲ្យយើងក្លាយទៅជាសមាជិកនៅក្នុងគ្រួសាររបស់ទ្រង់ ហើយក៏ បាននាំយើងឲ្យទទួលមរតកដ៏អស់កល្បជានិច្ចនៅក្នុងសិរីល្អរបស់ ទ្រង់ផងដែរ។ ប៉ុន្តែ យើងមិនបានថ្វាយសិរីល្អដល់ព្រះអង្គទេ ផ្ទុយទៅ វិញ យើងបែរជាប្រព្រឹត្តបែបមិនគួរគប្បីចំពោះទ្រង់ថែមទៀត។ ហេតុអ្វី បានជាយើងធ្វើជាមនុស្សដែលមិនសូវចេះដឹងគុណ ជាមនុស្សដែល យឺតនឹងស្ដាប់បង្គាប់ទ្រង់ និងចេះតែប្រព្រឹត្តបាបម្ដងហើយម្ដងទៀត ដូច្នេះ! ហេតុផលដែលទ្រង់ទុកឲ្យអ្នកជឿនៅបន្តរស់ក្នុងសាច់ឈាម ព្រោះទ្រង់ "មានព្រះហឫទ័យអត់ធ្មត់នឹងយើងរាល់គ្នា" (២ពេត្រុស ៣:៩)។ ព្រះជាម្ចាស់សព្វព្រះហឫទ័យសម្ដែងសេចក្ដីអត់ធ្មត់ចំពោះ យើង ព្រោះទ្រង់អាចសម្ដែងលក្ខណសម្បត្តិនេះដល់យើងតែនៅលើ ផែនដីនេះប៉ុណ្ណោះ។

## សាលានៃបទពិសោធន៍បរិសុទ្ធ

តាមរយៈការសញ្ជឹងគិតអំពីលក្ខណសម្បត្តិនេះ ចូរឲ្យយើងទាំង អស់គ្នាមានចិត្តសុភាព មានបញ្ញាចិត្តទន់ភ្លន់ និងចេះអត់ធ្មត់ ហើយ

ចូរឲ្យយើងរៀនពីសាលានៃបទពិសោធន៍បរិសុទ្ធអំពី “សេចក្ដីអត់ធ្មត់របស់ពួកបរិសុទ្ធ” ពោលគឺចេះចុះចូលចំពោះព្រះហឫទ័យរបស់ទ្រង់ ហើយបន្តរស់នៅឲ្យបានល្អ។ ចូរយើងត្រាប់តាមលក្ខណសម្បត្តិនេះ ដោយពឹងអាងលើព្រះគុណរបស់ព្រះជាម្ចាស់ទាំងស្រុង។ “ដូច្នេះ ចូរឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ដូចជាព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌ ទ្រង់គ្រប់លក្ខណ៍ដែរ” (ម៉ាថាយ ៥:៤៨)។ នៅក្នុងបរិបទភ្លាមៗនៃខគម្ពីរនេះ គឺព្រះគ្រីស្ទកំពុងដាស់តឿនយើងឲ្យស្រឡាញ់ខ្មាំងសត្រូវរបស់ខ្លួន ហើយឲ្យពរដល់អស់អ្នកដែលប្រទេចផ្ដាសាយើង ព្រមទាំងប្រព្រឹត្តល្អចំពោះអស់អ្នកដែលស្អប់យើងផងដែរ។ ព្រះជាម្ចាស់ទ្រាំទ្រនឹងមនុស្សអាក្រក់អស់រយៈពេលយ៉ាងយូរ ទោះបីជាព្រះអង្គទតឃើញថា ពួកគេមានពេញទៅដោយអំពើបាបក៏ដោយ។ ហេតុដូច្នេះហើយបានជាយើងមិនគួរចងគំនុំសងសឹកចំពោះអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងបន្តិចបន្តួចឡើយ!

ជំពូកទី១៣

# ព្រះគុណរបស់ព្រះជាម្ចាស់

ព្រះគុណគឺជាលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះមួយរបស់ព្រះជាម្ចាស់ ដែលទ្រង់បង្ហាញដល់អ្នកជ្រើសតាំងតែប៉ុណ្ណោះ។ ទាំងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មីមិនដែលលើកឡើងអំពីព្រះគុណដែលទាក់ទងនឹងមនុស្សជាទូទៅនោះទេ ក៏មិនដែលលើកឡើងទាក់ទងនឹងអ្វីៗដែលទ្រង់បានបង្កើតមកដែលទាបជាងមនុស្សដែរ។ ព្រះគុណ និងសេចក្តីមេត្តាករុណាមានលក្ខណៈខុសគ្នាត្រង់ថា សេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់គឺទ្រង់មាន “លើកិច្ចការរបស់ទ្រង់ទាំងប៉ុន្មាន” (ទំនុកតម្កើង ១៤៥:៩)។ មានតែព្រះគុណមួយប៉ុណ្ណោះដែលជាប្រភពបង្ហូរនូវសេចក្តីសប្បុរស សេចក្តីស្រឡាញ់ និងសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់មកលើអស់អ្នកដែលទ្រង់បានជ្រើសតាំង។ នៅក្នុងសៀវភៅ *The Reign of Grace* (ដែលមានន័យថា “រាជ្យនៃព្រះគុណ”) ដែលនិពន្ធដោយលោកគ្រូ អ័ប្រាហាំ ប៊ូធ (Abraham Booth) បានពណ៌នាយ៉ាងមានប្រយោជន៍អំពីលក្ខណ

សម្បត្តិរបស់ព្រះជាម្ចាស់ដូចតទៅ៖

“ព្រះគុណគឺជាការដែលព្រះសព្វព្រះហឫទ័យប្រទាននូវអ្វីដែលយើងមិនស័ក្តិសមនឹងទទួលដោយឥតគិតថ្លៃ ដែលទ្រង់មានតាំងពីអស់កល្បរៀងមកម្ល៉េះ ដែលជាព្រះពរដ៏អស់កល្បជានិច្ចខាងឯវិញ្ញាណដែលទ្រង់បង្ហាញដល់ឧក្រិដ្ឋជន និងអ្នកដែលមិនសមនឹងទទួល”។

ព្រះគុណរបស់ព្រះជាម្ចាស់គឺជាអធិបតេយ្យភាព និងជាសេចក្តីសង្គ្រោះដែលជាសេចក្តីល្អរបស់ព្រះដែលទ្រង់ប្រទានជាព្រះពរដល់អស់អ្នកដែលមិនសមនឹងទទួល ហើយទ្រង់ក៏មិនទាមទារឲ្យពួកគេសងទ្រង់វិញដែរ។ ទេ! លើសពីនេះទៅទៀត ព្រះគុណគឺជាសេចក្តីល្អរបស់ព្រះជាម្ចាស់ដែលទ្រង់បង្ហាញដល់អស់អ្នកដែលគ្មានអ្វីល្អនៅក្នុងខ្លួនសោះ ជាមនុស្សដែលសមតែនឹងទទួលសេចក្តីអាក្រក់ហើយធ្លាក់ក្នុងនរក។ យើងមិនសមនឹងទទួលបានព្រះគុណទាល់តែសោះ ទោះបីជាយើងព្យាយាមស្វែងរកយ៉ាងណាក៏មិនឃើញដែរ ព្រោះមានតែព្រះជាម្ចាស់មួយប៉ុណ្ណោះដែលជាអ្នកប្រទានឲ្យ។ ទោះបីជានៅក្នុង ចេញពី ឬក៏តាមរយៈអ្នកដែលទទួលបានព្រះគុណក៏ដោយ ក៏ពួកគេគ្មានអ្វីដែលអាចទាក់ទាញព្រះជាម្ចាស់ឲ្យផ្តល់ព្រះគុណដល់ពួកគេបានដែរ។ យើងមិនអាចយកលុយទិញព្រះគុណ

ឬខំសន្សំអំពើល្អដើម្បីដូរឲ្យបានព្រះគុណ ឬក៏ទទួលបានជារង្វាន់ពីព្រះជាម្ចាស់ដើម្បីយកបានព្រះគុណព្រះអង្គមកនោះទេ។ ប្រសិនបើយើងពិតជាអាចរកបានដូច្នេះមែន នោះនឹងលែងហៅថា ព្រះគុណទៀតហើយ។ នៅពេលដែលយើងនិយាយថា អ្នកណាម្នាក់បានទទួលព្រះគុណ នោះមានន័យថា បុគ្គលដែលបានទទួលនោះមិនបានធ្វើអ្វី ដើម្បីឲ្យទទួលបានព្រះគុណនោះទេ។ ព្រះជាម្ចាស់បានប្រទានព្រះគុណមក ទុកជាអំណោយទានទាំងស្រុងដល់អស់អ្នកដែលបានទទួល ទោះបីជាដំបូងពួកគេមិនទាំងបានសូម ឬក៏ចង់ទទួលបានព្រះគុណក៏ដោយ ក៏ទ្រង់នៅតែប្រទានឲ្យដែរ។

យើងអាចរកឃើញការពន្យល់យ៉ាងក្បោះក្បាយអំពីព្រះគុណដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នៅក្នុងសំបុត្រផ្សេងៗរបស់សាវ័ក ប៉ុល។ នៅក្នុងសំបុត្រនោះ គាត់បានពណ៌នាថា «ព្រះគុណ» គឺផ្ទុយពីការប្រព្រឹត្តិនិងភាពស័ក្តិសមរបស់មនុស្សយើង ទោះបើបុគ្គលនោះមានលក្ខណសម្បត្តិល្អ ឬខ្ពង់ខ្ពស់បែបណាក៏ដោយ។ កណ្ឌគម្ពីររ៉ូម ១១:៦ បានពណ៌នាការនោះយ៉ាងច្បាស់ថា «ប៉ុន្តែ ប្រសិនបើព្រះអង្គជ្រើសរើសដោយសារព្រះគុណ នោះមិនមែនដោយអាងការប្រព្រឹត្តិទៀតឡើយ ពុំនោះទេ ព្រះគុណលែងជាព្រះគុណទៀតហើយ»។ យើងមិនអាចលាយព្រះគុណ និងការប្រព្រឹត្តិបញ្ចូល

គ្នាបានទេ ដូចយើងមិនអាចលាយទឹកអាស៊ីតនឹងអាល់កាឡាំង យ៉ាងនោះដែរ។ «ដ្បិតដោយសារព្រះគុណ អ្នករាល់គ្នាបានសង្គ្រោះ តាមរយៈជំនឿ ហើយសេចក្ដីនេះមិនមែនមកពីអ្នករាល់គ្នាទេ គឺជាអំណោយទានរបស់ព្រះវិញ» (អេភេសូរ ២:៨-៩)។ សេចក្ដីល្អដ៏ឥតល័ក្ខខ័ណ្ឌរបស់ព្រះជាម្ចាស់មិនអាចមានការលាយឡំគ្នាជាមួយនឹងការប្រព្រឹត្តិរបស់មនុស្សបានឡើយ គឺប្រៀបដូចជាទឹកនិងប្រេង ដែលមិនអាចលាយបញ្ចូលគ្នាជាដាច់ខាត (សូមអានកណ្ឌគម្ពីរ រ៉ូម ៤:៤-៥)។

មាន លក្ខណ សម្បត្តិ សំខាន់ៗ បី យ៉ាង អំពី ព្រះ គុណ របស់ ព្រះ ជាម្ចាស់។ *ទី១* ព្រះ គុណ មាន តាំង ពី អស់ កល្ប រៀង មក។ ព្រះជាម្ចាស់មានគម្រោងបង្ហាញព្រះគុណតាំងពីយូរណាស់មកហើយ ពោលគឺទ្រង់សព្វព្រះហឫទ័យចង់ប្រទានមកតាំងពីមុនពេលដែលទ្រង់បានប្រទានមកម្ល៉េះ៖ «ទ្រង់បានសង្គ្រោះយើង ហើយបានត្រាស់ហៅយើងមកក្នុងការងារបរិសុទ្ធ មិនមែនដោយសារការប្រព្រឹត្តិរបស់យើងនោះទេ គឺដោយសារបំណង និងព្រះគុណរបស់ព្រះអង្គ ដែលបានប្រទានមកយើងក្នុងព្រះគ្រីស្ទយេស៊ូវ មុនសម័យកាលទាំងអស់មកម្ល៉េះ» (២ធីម៉ូថេ ១:៩ គកស)។ *ទី២* ព្រះគុណរបស់ព្រះជាម្ចាស់ គឺឥតគិតថ្លៃ ដ្បិតមិនមានអ្នកណាបានទិញឡើយ៖ «តែដោយសារ

ព្រះគុណរបស់ព្រះអង្គ ពួកគេបានរាប់ជាសុចរិតដោយឥតគិតថ្លៃ» (រ៉ូម ៣:២៤ គខប)។ *ទី៣* ព្រះគុណមានពេញដោយអធិបតេយ្យភាព ព្រោះទ្រង់បង្ហាញ និងប្រទានព្រះគុណដល់អស់អ្នកដែលទ្រង់សព្វព្រះហឫទ័យប្រទានឲ្យ៖ «ដើម្បីឲ្យព្រះគុណបានសោយរាជ្យ» (រ៉ូម ៥:២១)។ ប្រសិនបើព្រះគុណ «សោយរាជ្យ» នោះមានន័យថា ព្រះគុណគង់លើបល្ល័ង្ក ហើយព្រះអង្គដែលគង់លើបល្ល័ង្កមានពេញដោយការគ្រប់គ្រង។ ហេតុដូច្នេះហើយបានជាកណ្ឌគម្ពីរ ហេព្រើរ ៤:១៦ បានចែងថាបល្ល័ង្ករបស់ព្រះអង្គជា «បល្ល័ង្កនៃព្រះគុណ»។

## អធិបតេយ្យភាពនៃការជ្រើសរើសរបស់ព្រះជាម្ចាស់

ដោយសារព្រះគុណគឺជាអំណោយទានឥតគិតថ្លៃ ដែលមនុស្សយើងមិនសមនឹងទទួលបាន ដូច្នេះហើយបានជាព្រះអង្គដែលប្រទានព្រះគុណមក គឺជាព្រះអង្គដែលមានអធិបតេយ្យភាពលើអ្វីៗទាំងអស់។ ដូច្នេះហើយបានជាព្រះជាម្ចាស់មានព្រះបន្ទូលថា «អញនឹងប្រោសដល់អ្នកណាដែលអញចង់ប្រោស» (និក្ខមនំ ៣៣:១៩)។ ប្រសិនបើព្រះជាម្ចាស់បង្ហាញព្រះគុណចំពោះកូនចៅទាំងអស់របស់លោក អ័ដាម នោះមនុស្សយើងនឹងសន្មតថា សេចក្ដីសុចរិតរបស់ទ្រង់បានជំរុញឲ្យព្រះអង្គនាំយើងទាំងអស់គ្នាទៅស្ថានសួគ៌ ដើម្បីរាប់

ការនោះថាជាការសងដល់យើង ព្រោះទ្រង់បានអនុញ្ញាតឲ្យយើងធ្លាក់ចុះក្នុងអំពើបាប។ ប៉ុន្តែ បើនិយាយឲ្យចំទៅ ព្រះដ៏អស្ចារ្យទ្រង់មិនជាប់បំណុលនឹងអ្វីៗដែលទ្រង់បានបង្កើតមកនោះទេ ជាពិសេសគឺអស់អ្នកដែលបះបោរទាស់ប្រឆាំងនឹងទ្រង់។

ការទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច គឺជាអំណោយទានពីព្រះជាម្ចាស់ ហេតុដូច្នេះហើយបានជាគ្មានបុគ្គលណាម្នាក់អាចទទួលបានដោយសារទង្វើល្អរបស់ខ្លួន ឬក៏អះអាងថាខ្លួនមានសិទ្ធិអំណាចទទួលជីវិតអស់កល្បនោះបានឡើយ។ យើងឃើញថា សេចក្តីសង្គ្រោះគឺជា «អំណោយទាន» ដូច្នេះ តើមានបុគ្គលណាដែលមានសិទ្ធិទូលប្រាប់ព្រះជាម្ចាស់ថា ទ្រង់គួរសង្គ្រោះអ្នកនេះឬអ្នកនោះដែរឬទេ? យោងតាមច្បាប់ដែលទ្រង់មាន៖ គឺទ្រង់មិនដែលបដិសេធមិនព្រមប្រទានអំណោយទាននេះ ដល់អស់អ្នកណាដែលស្វែងរកដោយអស់ពីចិត្តនោះឡើយ។ ប្រាកដណាស់ គឺមិនដូច្នោះទេ! ព្រះអង្គមិនបដិសេធអស់អ្នកដែលមកកាន់ទ្រង់ដោយដៃទទេ ហើយមកក្នុងរបៀបដែលព្រះអង្គមានព្រះបន្ទូលថាពួកគេគួរមកកាន់ទ្រង់។ ប៉ុន្តែ ប្រសិនបើចេញពីលោកីយ៍នៃអ្នកបះបោរដែលមិនចេះខ្មាសអៀន និងមិនមានចិត្តជឿ ព្រះជាម្ចាស់បានសម្រេចថានឹងប្រើប្រាស់សិទ្ធិនៃអធិបតេយ្យភាពរបស់ទ្រង់ដោយជ្រើសរើស

ចំនួនមនុស្សតែមួយចំនួន ដើម្បីឲ្យទទួលបានការសង្គ្រោះ តើអ្នកណាជាអ្នកខុសទៅ? តើព្រះជាម្ចាស់បង្ខំអស់អ្នកដែលឲ្យតម្លៃលើអំណោយទានរបស់ទ្រង់ ទទួលយកអំណោយទាននោះមែនឬ? តើទ្រង់ចាំបាច់ត្រូវសង្គ្រោះអស់អ្នកដែលបានសម្រេចចិត្តថា គេនឹងធ្វើតាមតែចិត្តរបស់គេមែនឬ?

មនុស្សយើងងាយខឹងនឹងព្រះជាម្ចាស់ ហើយបញ្ចេញឫសគល់នៃចិត្តដែលទាស់ប្រឆាំងនឹងទ្រង់ ពេលដែលយើងឮអំពីព្រះគុណដ៏អស់កល្បជានិច្ចដែលជាព្រះគុណឥតគិតថ្លៃ និងឮអំពីព្រះគុណទាំងអស់នៃអធិបតេយ្យភាពរបស់ទ្រង់។ នេះពិតជាធ្វើឲ្យពួកគាត់មានអារម្មណ៍ថា ខ្លួនមិនសំខាន់ទាល់តែសោះក្នុងការគិតទៅលើការដែលព្រះជាម្ចាស់បានសម្រេចផែនការរបស់ទ្រង់តាំងពីអស់កល្បរៀងមក ដោយទ្រង់មិនបានស្ទង់មតិពីអ្វីៗដែលទ្រង់បានបង្កើតមកទាល់តែសោះ។ ដោយសារយើងមិនបានធ្វើអ្វីសោះ ដើម្បីឲ្យយើងស័ក្តិសមទទួលបានព្រះគុណ ដូច្នេះហើយយើងក៏មិនអាចអួតអាងថា ខ្លួនអស្ចារ្យ ហើយសុចរិតដោយខ្លួនឯងបានឡើយ ទោះបើយើងចង់ទិញព្រះគុណក៏យើងមិនអាចទិញបានដែរ។ ការដែលថា ព្រះ ជាម្ចាស់ ប្រទាន ព្រះ គុណ មក ដល់ តែ អ្នក ណា ដែល ទ្រង់ សព្វព្រះហឫទ័យធ្វើឲ្យអ្នកដែលប្រឆាំងនឹងទ្រង់ក្តៅក្រហាយខ្លាំង

ណាស់។ ដីឥដ្ឋបានក្រោកឡើងទាស់នឹងជាងស្មូន ហើយសួរថា "តើឯងសូនអញជាស្អី?" (អេសាយ ៤៥)។ យើងដែលជាឧក្រិដ្ឋជន ដែលជាអ្នកកំពូលបះបោរ ពិតជាហ៊ានខ្លាំងណាស់ គឺហ៊ានសូម្បីតែមានមន្ទិលសង្ស័យដេញដោលអំពីភាពយុត្តិធម៌របស់ព្រះដែលប្រកបដោយអធិបតេយ្យភាពទៀតផង។

យើងអាចឃើញព្រះគុណនៃការជ្រើសរើសរបស់ព្រះជាម្ចាស់ក្នុងការដែលព្រះអង្គបានសង្គ្រោះមនុស្សមួយចំនួនក្រោមអធិបតេយ្យភាពរបស់ទ្រង់ ដើម្បីឲ្យពួកគេធ្វើជារាស្ត្រជាទីស្រឡាញ់របស់ទ្រង់។ យើងប្រើពាក្យ "ជ្រើសរើស" ពីព្រោះព្រះគុណមាន "ការរើសអើង ហើយមានភាពទីទៃពីគ្នា" និងជ្រើសរើសមនុស្សតែមួយចំនួនប៉ុណ្ណោះ ដែលនេះមានន័យថា ព្រះអង្គបានមើលរំលងមនុស្សមួយចំនួនផ្សេងទៀត។ ព្រះគុណនៃការជ្រើសរើសរបស់ព្រះជាម្ចាស់បានជ្រើសរើសលោក អ័ប្រាហាំ ចេញពីចំណោមអស់អ្នកជិតខាងគាត់ ដែលកំពុងថ្វាយបង្គំព្រះក្លែងក្លាយ ហើយយកគាត់មកធ្វើជា "មិត្តសម្លាញ់របស់ព្រះអង្គ" (យ៉ាកុប ២:២៣)។ ព្រះគុណនៃការជ្រើសរើសរបស់ព្រះជាម្ចាស់បានសង្គ្រោះពួកអ្នកយកពន្ធ និងមនុស្សមានបាប ប៉ុន្តែទ្រង់បានមានបន្ទូលអំពីពួកផារិស៊ីថា កុំអំពល់នឹងគេធ្វើអ្វី (ម៉ាថាយ ១៥:១៤)។ ការដែលព្រះជាម្ចាស់បានប្រទាន

ព្រះគុណដល់អស់អ្នកដែលមិនស័ក្តិសមនឹងទទួល នោះបានបង្ហាញពីសិរីល្អ និងអធិបតេយ្យភាពរបស់ទ្រង់យ៉ាងច្បាស់លាស់។ លោកគ្រូ ចេមស៍ ហើវេ (James Hervey នៅឆ្នាំ ១៧៨១) បានពណ៌នាអំពីចំណុចនេះយ៉ាងច្បាស់៖

“ព្រះជាម្ចាស់បានប្រកាសពីនគរស្ថានសួគ៌ថា "កន្លែងណាដែលមានបាបចម្រើនជាបរិបូរឡើង នោះព្រះគុណក៏ចម្រើនជាបរិបូរលើសទៅទៀត” (រ៉ូម ៥:២០)។ ស្តេច ម៉ាន៉ាសេ ជាស្តេចមួយដ៏អាក្រក់ក្រៃលែង ដ្បិតទ្រង់បានបង្ខំកូនឲ្យដើរកាត់ក្នុងឡភ្លើង ហើយក៏បានសម្លាប់មនុស្សសុចរិតជាច្រើននៅក្នុងក្រុងយេរូសាឡឹមដែរ (២ពង្សាវតារក្សត្រ ២១)។ ស្តេច ម៉ាន៉ាសេ ជាស្តេចដែលប្រសប់មួយអង្គក្នុងការប្រព្រឹត្តិអំពើបាប ដ្បិតទ្រង់មិនត្រឹមតែបង្កើនរបៀបធ្វើបាបរហូតទាល់តែអស់របៀបប៉ុណ្ណោះទេ គឺទ្រង់ថែមទាំងបង្ខូចគោលការណ៍ និងនាំរាស្ត្រឲ្យធ្វើអាក្រក់តាមទ្រង់ជាច្រើនផង។ ការដែលពួកគេធ្វើគឺគួរឲ្យស្អប់ខ្ពើមជាងការដែលពួកអ្នកថ្វាយបង្គំព្រះក្លែងក្លាយបានធ្វើទៅទៀត (២របាក្សត្រ ៣៣)។ ប៉ុន្តែ តាមរយៈព្រះគុណដ៏បរិបូរ ព្រះជាម្ចាស់បានបន្ទាបស្តេច ម៉ាន៉ាសេ ចុះ ហើយបានបំផ្លាស់បំប្រែគាត់ និងបានអត់ទោសឲ្យគាត់ ព្រមទាំងបានប្រទានមរតកនៃសិរីល្អដ៏អស់កល្បជានិច្ចដល់គាត់ផងដែរ»។

ចូរមើលពីជីវប្រវត្តិរបស់លោក សុល ដែលជាអ្នកបៀតបៀនពួកជំនុំដំបូងដ៏សាហាវព្រៃផ្សៃម្នាក់។ គាត់បានគម្រាមកំហែង និងធ្វើឲ្យសិស្សរបស់ព្រះយេស៊ូវព្រួយបារម្ភយ៉ាងខ្លាំង ព្រមទាំងសម្លាប់ពួកគេជាច្រើននាក់ទៀតផង។ ការបង្ហិនបំផ្លាញដែលគាត់បានប្រព្រឹត្តិការដែលគាត់បានបំផ្លាញគ្រួសារជាច្រើនដែលមិនគួរជួបមហន្តរាយមិនបានធ្វើឲ្យចិត្តរបស់គាត់ដែលពេញដោយការសងសឹកបានស្ងប់ស្ងល់ទេ ប៉ុន្តែគឺគ្រាន់តែជាការភ្លក់រសជាតិបន្តិចបន្តួចប៉ុណ្ណោះ។ ការនោះមិនបានចម្អែតការបៀតបៀនរបស់គាត់ទេ ប៉ុន្តែវាបានធ្វើឲ្យគាត់កាន់តែចង់បៀតបៀនចង់បំផ្លាញ និងសម្លាប់មនុស្សកាន់តែច្រើនថែមទៀត។ គាត់ញៀនក្នុងការប្រព្រឹត្តអំពើឃោរឃៅ និងការសម្លាប់អ្នកដទៃ។ គាត់មិនគ្រាន់តែចង់បៀតបៀនហើយញៀននឹងការបៀតបៀនដោយមិនចេះឆ្អែតឆ្អន់ប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងគម្រាមកំហែង ហើយសម្លាប់សិស្សរបស់ព្រះយេស៊ូវជាច្រើនទៀតផង (កិច្ចការ ៩:១)។ ពាក្យសម្តីរបស់គាត់ប្រៀបដូចជាលំពែង និងព្រួញ ហើយអណ្តាតដូចជាដាវយ៉ាងមុត។ ការដែលគាត់គម្រាមកំហែងគ្រីស្ទបរិស័ទ គឺជារឿងធម្មតាដូចជាការដែលគាត់ដកដង្ហើមដូច្នោះដែរ។ គាត់បានធ្វើឲ្យគ្រីស្ទបរិស័ទហូរឈាមគ្រប់ពេលវេលាដោយសារគាត់មានចិត្តគុំគួន និងចង់បានអំណាច ហេតុដូច្នេះ

ហើយបានជាគ្រប់ព្យាង្គដែលគាត់វាចា និងគ្រប់ដង្ហើមដែលគាត់ដក គឺបានបង្គាប់ឲ្យគេសម្លាប់គ្រប់ពេលវេលា ទោះបីជាគាត់បានសម្លាប់សិស្សដ៏សុចរិតរបស់ព្រះយេស៊ូវមួយចំនួនហើយក៏ដោយ។ បើយោងតាមច្បាប់នៃការថ្កោលទោសរបស់មនុស្សយើង គឺយើងនឹងរាប់គាត់ថាជាមនុស្សដ៏អាក្រក់លើសលប់ម្នាក់ ហើយនឹងត្រូវធ្លាក់នរកច្រើនជាន់ជាមិនខាន។ លើសពីនោះទៅទៀត យើងមិនត្រឹមតែរាប់គាត់ថាជាមនុស្សអាក្រក់បែបនេះទេ ប៉ុន្តែប្រសិនបើមានច្រវាក់ធ្ងន់ជាងនោះ ឬក៏គុកដ៏ជ្រៅជាងនោះយើងប្រាកដជាចង់ដាក់គាត់នៅក្នុងនោះជាមិនខាន ព្រោះគាត់ជាសត្រូវដែលទាស់នឹងព្រះដ៏ពិត។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏ព្រះគុណដែលគ្មានទីបញ្ចប់របស់ព្រះជាម្ចាស់បាននាំលោក សុល ឲ្យចូលក្នុងចំណោមពួកហោរា ហើយបានរាប់គាត់ថាជាអ្នករងទុក្ខក្នុងចំណោមអ្នករងទុក្ខដ៏ល្អដទៃទៀត ព្រមទាំងញែកគាត់ទុកជាបុគ្គលដ៏អស្ចារ្យម្នាក់ក្នុងចំណោមពួកសាវ័កដទៃទៀតផងដែរ។

មនុស្សមួយចំនួនដែលនៅក្នុងក្រុមជំនុំកូរិនថូសគឺជាជនល្មើសសូម្បីតែឈ្មោះទីក្រុងរបស់ពួកគេក៏មានន័យថា «ជនល្មើសដែរ»។ អ្នកខ្លះបានប្រព្រឹត្តិអំពើដែលមិនគួរគប្បី ហើយក៏បានប្រព្រឹត្តិអំពើអយុត្តិធម៌ម្តងហើយម្តងទៀតដែរ។ សរុបសេចក្តីមកអំពើដែលពួក

គេបានប្រព្រឹត្តិគឺខុសពីធម្មជាតិទាំងស្រុង។ ទោះជាយ៉ាងណាក្តី ក៏ព្រះជាម្ចាស់នៅតែលាងសម្អាតពួកគេ ញែកពួកគេជាបរិសុទ្ធ និងរាប់ពួកគេជាសុចរិតដែរ ទោះបើពួកគេជាមនុស្សដែលពេញដោយអំពើហិង្សា និងជាបាវបម្រើនៃភាពត្រេកត្រអាលក៏ដោយ (១កូរិនថូស ៦:៩-១១ គកស)។ ព្រះជាម្ចាស់ “បានលាងសម្អាត” ពួកគេដោយព្រះលោហិតដ៏មានតម្លៃនៃព្រះដ៏ប្រោសលោះដែលបានសុគតជំនួសបាបរបស់ពួកគេ។ ព្រះជាម្ចាស់បាន “ញែកពួកគេជាបរិសុទ្ធ” ដោយអំណាចព្រះចេស្តានៃព័ន្ធកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធដែលពេញដោយព្រះពរ ហើយទ្រង់បាន “រាប់ពួកគេជាសុចរិត” ដោយសេចក្តីមេត្តាករុណាដ៏គ្មានដែនកំណត់នៃព្រះគុណរបស់ទ្រង់។ ផែនដីធ្លាប់រាប់ពួកកូរិនថូសថាជាបន្ទុក ឥឡូវនេះត្រូវបានរាប់ថាជាសេចក្តីអំណរនៃស្ថានសួគ៌ និងជាក្តីរីករាយនៃពួកទេវតាហើយតាមរយៈព្រះគុណ។»

បច្ចុប្បន្ននេះ យើងអាចមើលឃើញព្រះគុណរបស់ព្រះជាម្ចាស់នៅ*ក្នុង*ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយអាចមើលឃើញ*ដោយ*ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ក៏ដូចជា*តាមរយៈ*ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទដែរ។ «ដ្បិតក្រឹត្យវិន័យបានប្រទានមកតាមរយៈលោកម៉ូសេ តែព្រះគុណ និងសេចក្តីពិត បានមកតាមរយៈព្រះយេស៊ូវគ្រីស្ទ»

(យ៉ូហាន ១:១៧ គកស)។ ចូរកុំច្រឡំថា ព្រះជាម្ចាស់មិនដែលសម្តែងព្រះគុណរបស់ទ្រង់មកលើមនុស្សយើង មុនពេលដែលព្រះរាជបុត្រារបស់ទ្រង់បានយាងមកយកកំណើតជាមនុស្សនៅលើផែនដីនេះឡើយ។ កណ្ឌគម្ពីរ លោកុប្បត្តិ ៦:៨, និក្ខមនំ ៣៣:១៩ និងកណ្ឌគម្ពីរផ្សេងៗទៀតបានបង្ហាញយ៉ាងច្បាស់លាស់។ ប៉ុន្តែនៅពេលដែលព្រះដ៏ប្រោសលោះបានយាងមកផែនដីនេះ យើងក៏បានមើលឃើញព្រះគុណ និងសេចក្តីពិតយ៉ាងពេញលេញដែរ ហើយនោះជាគំរូដ៏ល្អឥតខ្ចោះមួយសម្រាប់យើង ព្រោះទ្រង់បានសុគតនៅលើឈើឆ្កាងជំនួសប្រជារាស្ត្ររបស់ទ្រង់។ មានតែតាមរយៈព្រះគ្រីស្ទដែលជាអ្នកកណ្តាលរបស់យើងតែមួយប៉ុណ្ណោះ ដែលនាំឲ្យព្រះគុណរបស់ព្រះជាម្ចាស់ហូរទៅដល់ពួកអ្នកជ្រើសតាំងរបស់ទ្រង់បាន។ «ប្រាកដជាព្រះគុណនៃព្រះ និងអំណោយទាននៃព្រះគុណនោះ ដែលមកដោយសារមនុស្សតែម្នាក់ គឺព្រះយេស៊ូវគ្រីស្ទ...ប្រាកដជាពួកអ្នកដែលទទួលព្រះគុណដ៏បរិបូរ និងអំណោយទានជាសេចក្តីសុចរិត នោះនឹងបានសោយរាជ្យក្នុងជីវិតលើសទៅទៀត ដោយសារតែម្នាក់ដែរ គឺជាព្រះយេស៊ូវគ្រីស្ទ...ដើម្បីឲ្យព្រះគុណបានសោយរាជ្យដោយសារសេចក្តីសុចរិត សម្រាប់ជាជីវិតអស់កល្បជានិច្ច ដោយនូវព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង» (រ៉ូម ៥:១៥, ១៧, ២១)។

តាមរយៈដំណឹងល្អ យើងក៏អាចមើលឃើញព្រះគុណរបស់ព្រះជាម្ចាស់ដែរ (កិច្ចការ ២០:២៤)។ ចំពោះសាសន៍ យូដា ដែលបានរាប់ខ្លួនពួកគេថាជាមនុស្សសុចរិត ពួកគេគិតថា ព្រះគុណធ្វើឲ្យគេ «ជំពប់ដួល» ហើយចំពោះសាសន៍ ក្រិក ដែលជាទស្សនៈវិទូវិញ ព្រះគុណគឺជា «សេចក្ដីល្ងីល្ងើ»។ ហេតុអ្វីបានជាដូច្នេះ? ព្រោះព្រះគុណមិនអាចចម្អែតអំនួតរបស់មនុស្សបានឡើយ។ ព្រះគុណប្រកាសថា បើយើងមិនទទួលបានសេចក្ដីសង្គ្រោះតាមរយៈព្រះគុណទេ នោះមានន័យថា យើងមិនអាចទទួលសេចក្ដីសង្គ្រោះបានឡើយ។ ព្រះគុណក៏ប្រកាសទៀតដែរថា បើយើងដាច់ចេញពីព្រះគ្រីស្ទ ដែលទ្រង់ជាអំណោយទានរបស់ព្រះជាម្ចាស់ដ៏រកថ្លៃងពុំបាន នោះមានន័យថា មនុស្សគ្រប់រូបគ្មានសង្ឃឹមទេ ក៏មិនអាចកែប្រែបានដែរ។ ដំណឹងល្អរាប់មនុស្សយើងថា មានទោស ស័ក្តិសមនឹងទៅស្ថាននរក ហើយក៏រាប់យើងថាជាឧក្រិដ្ឋជនដែលគួរតែវិនាសផងដែរ។ ដំណឹងល្អប្រកាសថា ទោះបីជាមនុស្សដែលមានសីលធម៌ល្អបំផុត ក៏មិនអាចជួយសង្គ្រោះខ្លួនឯងបានដែរ។ ពួកគេក៏ដូចជាមនុស្សដ៏អាក្រក់លើសលប់ដែរ ហើយថាអ្នកដែលបានប្រកាសខ្លួនថាជាអ្នកជឿ ហើយមានចិត្តខ្នះខ្នែង ព្រមទាំងបានបំពេញគ្រប់តាមបែបបទរបស់សាសនា ក៏មិនមានអ្វីខុសពីមនុស្សដែលមិនជឿ

ថាមានសាសនាដែរ។

ដំណឹងល្អរាប់កូនចៅលោក អ័ដាម ថាពួកគេបានធ្លាក់ក្នុងអំពើបាប មានពេញដោយភាពកខ្វក់ ហើយស័ក្តិសមនឹងធ្លាក់ស្ថាននរក ហើយក៏រាប់ថាពួកគាត់ជាមនុស្សមានបាបដែលមិនអាចជួយខ្លួនឯងបានដែរ។ ព្រះគុណដែលដំណឹងល្អបានប្រកាសនោះ គឺជាសេចក្តីសង្ឃឹមតែមួយគត់របស់ពួកគេ។ ចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់ បុគ្គលគ្រប់រូបសុទ្ធតែជាអ្នកដែលមិនបានត្រាប់តាមក្រឹត្យវិន័យដ៏បរិសុទ្ធរបស់ទ្រង់ ពោលគឺពួកគេមានទោស និងជាឧក្រិដ្ឋជនដែលសមនឹងវិនាស ហើយពួកគេមិនមែនកំពុងរង់ចាំទទួលការកាត់ក្តីទេ ប៉ុន្តែគឺកំពុងរង់ចាំទទួលការប្រតិបត្តិនៃការកាត់ទោសដែលទ្រង់បានរៀបចំសម្រាប់ពួកគេតាំងពីយូរណាស់មកហើយវិញ (យ៉ូហាន ៣:១៨; រ៉ូម ៣:១៩)។ បុគ្គលណាដែលរអ៊ូរទាំចំពោះការរើកញ្ញែកអំពីព្រះគុណ បុគ្គលនោះប្រៀបដូចជាកំពុងសម្លាប់ខ្លួនឯងដូច្នោះដែរ។ ប្រសិនបើមនុស្សដែលមានបាបទាមទារព្រះជាម្ចាស់ឲ្យកាត់ទោសគាត់ដោយយុត្តិធម៌ នោះមានន័យថា គាត់មិនអាចគេចផុតពីស្ថាននរកបានឡើយ។ ព្រះគុណរបស់ព្រះជាម្ចាស់ដែលទ្រង់បានបើកសម្តែងនៅក្នុងដំណឹងល្អ គឺជាសេចក្តីសង្ឃឹមតែមួយគត់របស់មនុស្សមានបាប។ ដោយទទួលស្គាល់ថាខ្លួនមានទោស ពួកគេសង្ឃឹមថា

ព្រះជាម្ចាស់នឹងកាត់ទោសដោយមានសេចក្ដីមេត្តាករុណា ទោះបើយុត្តិធម៌តាមការសម្រេចរបស់ព្រះជាម្ចាស់ចំពោះពួកគេក៏ដោយ។ ជាជាងនាំនូវអ្វីមកថ្វាយព្រះអង្គ គឺពួកគេទេដែលជាអ្នកទទួលព្រះគុណរបស់ព្រះជាម្ចាស់ ដែលទ្រង់បានបើកសម្ដែងតាមរយៈដំណឹងល្អ។

ព្រះវិញ្ញាណបរិសុទ្ធដែលជាបុគ្គលទីបីនៃព្រះត្រៃឯក មានមុខងារជាអង្គទំនាក់ទំនងអំពីព្រះគុណ ហេតុដូច្នេះហើយបានជាកណ្ឌគម្ពីរសាការី ១២:១០ បានលើកឡើងថា ព្រះនាមរបស់ទ្រង់គឺ «វិញ្ញាណនៃព្រះគុណ»។ ព្រះដ៏ជាព្រះវរបិតា គឺជាប្រភពនៃព្រះគុណ ដ្បិតទ្រង់បានគ្រោងក្នុងព្រះអង្គទ្រង់ផ្ទាល់អំពីការតាំងសញ្ញាដ៏អស់កល្ប ដើម្បីនឹងប្រោសលោះមនុស្សមានបាប។ មនុស្សយើងអាចទទួលបានព្រះគុណតាមរយៈព្រះរាជបុត្រាតែមួយអង្គគត់។ ដំណឹងល្អគឺជាការប្រកាសអំពីព្រះគុណ។ ព្រះវិញ្ញាណគឺជាអង្គដែលប្រទានឲ្យយើងទទួលបានព្រះគុណ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាអង្គដែលប្រើដំណឹងល្អដ៏មានអំណាចក្នុងការសង្គ្រោះអ្នកដែលមិនទាន់ជឿ។ ទ្រង់ជាអង្គដែលដាស់តឿនអស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើស ទោះបីជាពួកគេកំពុងស្លាប់ខាងឯវិញ្ញាណក៏ដោយ ក៏ទ្រង់នៅតែឲ្យគេជឿលើដំណឹងល្អដែរ។ ទ្រង់ជាអង្គដែលវាយយកជ័យជម្នះលើឆន្ទៈដែលពោរពេញដោយការប្រឆាំងរបស់ពួកគេ។ ទ្រង់ជាអង្គ

ដែលរំលាយចិត្តដ៏រឹងរូសរបស់ពួកគេចោល។ ទ្រង់ជាអង្គដែលបើកភ្នែកខ្វាក់របស់ពួកគេឲ្យបានមើលឃើញឡើងវិញ។ ទ្រង់ជាអង្គដែលសម្អាតរោគឃ្លង់នៃអំពើបាបរបស់គេឲ្យស្អាតឡើងវិញ។ ដូច្នេះហើយបានជាយើងអាចបន្លឺសំឡេងឡើងដូចលោកគ្រូ ជី. អេស៍. ប៊ីហ្សប (G. S. Bishop) ថា៖

"ព្រះជាម្ចាស់បានប្រទានព្រះគុណដល់មនុស្សលោក ដែលបានធ្លាក់ក្នុងអំពើបាបយ៉ាងជ្រៅដែលអំពើបាបនោះធ្វើឲ្យពួកគេមិនទាំងអាចលើកពូថៅនៃសេចក្ដីយុត្តិធម៌បានផង។ ពួកគេមានពេញដោយអំពើពុករលួយ នោះធ្វើឲ្យពួកគេមិនទាំងអាចកែខ្លួនឯងបានឡើយ។ ព្រះអង្គក៏បានប្រទានព្រះគុណដល់មនុស្សដែលបានបែកចេញឆ្ងាយពីព្រះជាម្ចាស់ និងមិនអាចងាកបែរទៅរកទ្រង់វិញដោយខ្លួនឯងបានដែរ។ ពួកគេខ្វាក់ ហើយមិនអាចមើលព្រះជាម្ចាស់ឃើញបានឡើយ។ ពួកគេថ្លង់ និងមិនអាចស្ដាប់ឮព្រះសូរសៀងព្រះជាម្ចាស់បានឡើយ។ ពួកគេស្លាប់ ហើយមិនអាចធ្វើឲ្យខ្លួនឯងរស់ឡើងវិញបានឡើយ។ ដូច្នេះហើយបានព្រះជាម្ចាស់ត្រូវតែបើកផ្នូររបស់ពួកគេ ហើយប្រោសពួកគេឲ្យរស់ឡើងវិញ"។

ជំពូកទី១៤

# សេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់

## សេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់មានប្រភពពីសេចក្ដីសប្បុរសរបស់ទ្រង់

“ចូរលើកតម្កើងព្រះអម្ចាស់ ដ្បិតព្រះអង្គមានព្រះហឫទ័យសប្បុរស ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ!” (ទំនុកតម្កើង ១៣៦:១ គខប)។ ដោយសារលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះនេះ ព្រះជាម្ចាស់ស័ក្តិសមនឹងទទួលបានការលើកតម្កើងយ៉ាងធំក្រៃលែងពីយើង។ អ្នកនិពន្ធទំនុកតម្កើង ជំពូក ១៣៦ នេះបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យលើកតម្កើងព្រះអម្ចាស់ចំពោះលក្ខណសម្បត្តិដ៏គួរឲ្យស្រឡាញ់មួយនេះបីដង។ នេះជាសំណើមួយដ៏តូចដែលអ្នកនិពន្ធទំនុកតម្កើងជំពូកនេះបានស្នើពីអស់អ្នកដែលបាន

ទទួលសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់ម្ដងហើយម្ដងទៀត។ នៅពេលដែលយើងពិចារណា ហើយសញ្ជឹងគិតអំពីលក្ខណសម្បត្តិដ៏ឧដុង្គឧត្ដមនេះរបស់ព្រះជាម្ចាស់ នោះយើងនឹងឃើញថាគ្មានអ្វីមួយផ្សេងទៀតដែលយើងអាចធ្វើបាន ក្រៅពីថ្វាយព្រះពរដល់ទ្រង់នោះឡើយ។ សេចក្ដីមេត្តាករុណារបស់ទ្រង់ «ធំ» (១ពង្សាវតាក្សត្រ ៣:៦; ១ពេត្រុស ១:៣) «បរិបូរ» (ទំនុកតម្កើង ៨៦:៥) «លើសលប់» (លូកា ១:៧៨) ហើយសេចក្ដីសប្បុរសរបស់ទ្រង់ «ស្ថិតស្ថេរនៅតាំងពីអស់កល្បជរាបដល់អស់កល្បជានិច្ចចំពោះអស់អ្នកដែលកោតខ្លាចដល់ទ្រង់» (ទំនុកតម្កើង ១០៣:១៧)។ នេះជាការល្អណាស់ប្រសិនបើយើងបន្លឺសំឡេងឡើងដូចអ្នកនិពន្ធកណ្ឌគម្ពីរ ទំនុកតម្កើង ៥៩:១៦ ថា «ទូលបង្គំនឹងច្រៀងសរសើរដល់ទ្រង់ ដ្បិតព្រះទ្រង់...ប្រកបដោយមេត្តាករុណាចំពោះទូលបង្គំ»។

«អញនឹងឲ្យអស់ទាំងសេចក្ដីសប្បុរសរបស់អញដើរកាត់នៅមុខឯង ព្រមទាំងប្រកាសពីព្រះនាម «យេហូវ៉ា» នៅមុខឯងផង អញនឹងប្រោសដល់អ្នកណាដែលអញចង់ប្រោស ហើយនឹងផ្សាយសេចក្ដីមេត្តាករុណាដល់អ្នកណាដែលអញចង់ផ្សាយឲ្យ» (និក្ខមនំ ៣៣:១៩)។ ដូច្នេះ តើយើងមើលឃើញពីចំណុចខុសៗគ្នារវាង «សេចក្ដីមេត្តាករុណា» របស់ព្រះជាម្ចាស់ និង «ព្រះគុណ»

របស់ទ្រង់ ហើយឬនៅ? សេចក្តីសប្បុរសគឺជាប្រភពនៃសេចក្តីមេត្តាករុណារបស់ទ្រង់។ *ទី១* ការសម្តែងនៃសេចក្តីសប្បុរសដំបូងរបស់ព្រះជាម្ចាស់គឺព្រះហឫទ័យសទ្ធារបស់ទ្រង់ ដែលទ្រង់បានប្រទានជាបរិបូណ៌ទៅកាន់អ្វីៗដែលទ្រង់បានបង្កើតមក។ ឧទាហរណ៍៖ ទ្រង់បានប្រទានជីវិតដល់របស់ទាំងអស់នោះ។ *ទី២* ព្រះជាម្ចាស់បានសម្តែងសេចក្តីសប្បុរសរបស់ទ្រង់តាមរយៈសេចក្តីមេត្តាករុណារបស់ទ្រង់ ដោយទ្រង់បានបម្រុងព្រះអង្គទ្រង់ផ្ទាល់ទុកសម្រាប់ជួយរំដោះអ្នករងទុក្ខដែលធ្លាក់ក្នុងអំពើបាប។ សរុបសេចក្តីមក ដើម្បីឲ្យមានការសម្តែងសេចក្តីមេត្តាករុណា ត្រូវមានអំពើបាបជាមុនសិន។

ទោះបើក្នុងការពិចារណាលើកដំបូងមិនងាយនឹងឲ្យយើងអាចយល់អំពីលក្ខណៈខុសគ្នាពិតប្រាកដរវាងព្រះគុណ និងសេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ក៏ដោយ ក៏វាអាចជួយយើងបានខ្លះដែរ ប្រសិនបើយើងសញ្ជឹងគិតដោយយកចិត្តទុកដាក់ អំពីការដែលទ្រង់បានធ្វើចំពោះពួកទេវតាដែលមិនបានធ្លាក់ចុះក្នុងអំពើបាប។ ព្រះជាម្ចាស់មិនដែលមានសេចក្តីមេត្តាករុណាដល់ទេវតាទេ ដ្បិតពួកគេមិនដែលត្រូវការសេចក្តីមេត្តាករុណារបស់ទ្រង់ឡើយ ព្រោះពួកគេមិនបានប្រព្រឹត្តអំពើបាប ឬស្ថិតក្រោមឥទ្ធិពលនៃបណ្តាសាឡើយ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ពួកគេជាអ្នកទទួលព្រះ

គុណដែលពេញដោយអធិបតេយ្យ និងឥតគិតថ្លៃរបស់ព្រះជាម្ចាស់ដែរ។ *ទី១* ព្រោះទ្រង់បានជ្រើសតាំងពួកគេចេញពីចំណោមទេវតាទាំងអស់រួចទៅហើយ (១ធីម៉ូថេ ៥:២១)។ *ទី២* ជាលទ្ធផលនៃការជ្រើសតាំង ទ្រង់ក៏បានថែរក្សាពួកគេមិនឲ្យធ្លាក់ចុះក្នុងអំពើបាបដែរ នៅពេលដែលអារក្សសាតាំងបះបោរប្រឆាំងនឹងទ្រង់ហើយបានអូសទាញទេវតានៅស្ថានសួគ៌ចំនួនមួយភាគបី ឲ្យធ្លាក់ចុះជាមួយវា (វិវរណៈ ១២:៤)។ *ទី៣* ក្នុងការដែលព្រះជាម្ចាស់បានតាំងព្រះគ្រីស្ទជាព្រះសិរសារបស់ពួកគេ (កូឡុស ២:១០; ១ពេត្រុស ៣:២២) នោះពួកគេក៏ទទួលបានសុវត្ថិភាពដ៏អស់កល្បជានិច្ចនៅក្នុងភាពបរិសុទ្ធដែលព្រះជាម្ចាស់បានបង្កើតពួកគេមកដែរ។ *ទី៤* ដោយសារព្រះជាម្ចាស់បានប្រទានឋានៈដ៏ខ្ពង់ខ្ពស់ដល់ពួកគេ៖ ឲ្យពួកគេរស់នៅក្នុងព្រះវត្តមានរបស់ទ្រង់ដោយផ្ទាល់ (ដានីយ៉ែល ៧:១០) ឲ្យពួកគេបម្រើទ្រង់នៅក្នុងព្រះវិហាររបស់ព្រះអង្គដែលនៅស្ថានសួគ៌ម្ដងហើយម្ដងទៀត និងឲ្យពួកគេទទួលមុខងារដែលមានមុខមាត់ពីទ្រង់ (ហេព្រើរ ១:១៤)។ ការទាំងអស់នេះ រាប់ថាជាព្រះគុណដ៏ធំធេងរបស់ព្រះជាម្ចាស់ចំពោះពួកគេ មិនមែនជា «សេចក្ដីមេត្តាករុណា» ទេ។

នៅក្នុងការដែលយើងព្យាយាមសិក្សាអំពីសេចក្ដីមេត្តាករុណា

របស់ព្រះជាម្ចាស់ដែលមានចែងនៅក្នុងព្រះបន្ទូល គឺយើងត្រូវវែកញែកចំណុចបីយ៉ាងឲ្យដាច់ពីគ្នា ប្រសិនបើយើងពិតជាចង់ «កាត់ស្រាយព្រះបន្ទូលនៃសេចក្តីពិតយ៉ាងត្រឹមត្រូវ» (២ធីម៉ូថេ ២:១៥)។ *ទី១ ព្រះជាម្ចាស់មិនត្រឹមតែប្រទានសេចក្តីមេត្តាករុណាទូទៅ*របស់ទ្រង់ដល់មនុស្សលោកទាំងអ្នកជឿ និងអ្នកមិនជឿប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏សម្តែងសេចក្តីមេត្តាករុណានោះចំពោះរបស់សព្វសារពើទាំងអស់ដែលទ្រង់បានបង្កើតមកផងដែរ៖ «ព្រះហឫទ័យទន់សន្តោសរបស់ទ្រង់ ក៏គ្របលើកិច្ចការរបស់ទ្រង់ទាំងប៉ុន្មាន» (ទំនុកតម្កើង ១៤៥:៩) ហើយ «ទ្រង់ឲ្យគ្រប់ទាំងអស់មានជីវិត មានដង្ហើមគ្រប់ជំពូក» (កិច្ចការ ១៧:២៥)។ ព្រះជាម្ចាស់ទតឃើញថា អ្វីៗទាំងអស់ដែលទ្រង់បានបង្កើតមកសុទ្ធតែមានតម្រូវការ ដូច្នេះហើយបានជាទ្រង់បំពេញតម្រូវការរបស់ពួកគេ។ *ទី២ មានសេចក្តីមេត្តាករុណាដ៏ពិសេស*របស់ព្រះជាម្ចាស់ដែលជាជំនួយដល់មនុស្សយើង ទោះបីជាយើងមានពេញដោយអំពើបាបក៏ដោយ។ ទ្រង់ក៏បានប្រទានអ្វីៗដែលមានសារៈសំខាន់ដែលជាតម្រូវការនៃជីវិតរស់នៅរបស់មនុស្សលោកដែរ៖ «ព្រោះទ្រង់ធ្វើឲ្យថ្ងៃរបស់ទ្រង់រះឡើង បំភ្លឺទាំងមនុស្សអាក្រក់ និងមនុស្សល្អ ហើយទ្រង់បង្អុរឲ្យភ្លៀងធ្លាក់មក លើទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិតផង» (ម៉ាថាយ ៥:៤៥)។ *ទី៣*

*មានសេចក្ដីមេត្តាករុណាដ៏លើសលប់ដែលទ្រង់គ្រោងទុកសម្រាប់អស់អ្នកដែលទ្រង់ប្រទានសេចក្ដីសង្គ្រោះឲ្យ* ហើយសេចក្ដីមេត្តាករុណានោះបានធ្វើការប្រាស្រ័យទាក់ទងនឹងពួកគេតាមរយៈការតាំងសញ្ញា ដោយព្រះយេស៊ូវជាអ្នកសម្របសម្រួល។

## ការប្រទានសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់

អ្វីដែលខុសគ្នារវាងចំណុចទី២ និងទី៣ គឺថាព្រះគុណដែលព្រះជាម្ចាស់បានសម្ដែងមកមនុស្សអាក្រក់គឺគ្រាន់តែសម្រាប់ជីវិតរស់នៅលើផែនដីសព្វថ្ងៃនេះប៉ុណ្ណោះ ប៉ុន្តែព្រះគុណនោះមិនស្ថិតនៅជាដរាបទេ។ ព្រះជាម្ចាស់នឹងលែងប្រទានព្រះគុណដល់ពួកគេទៀតក្រោយពេលដែលពួកគេស្លាប់បាត់ទៅ៖ «ជនជាតិនេះឥតមានយោបល់ ហេតុដូច្នេះ ព្រះដែលបានបង្កើតគេ ទ្រង់នឹងមិនប្រណីដល់គេឡើយ ព្រះដែលបានសូនគេឡើង ទ្រង់នឹងមិនផ្តល់ព្រះគុណដល់គេសោះ» (អេសាយ ២៧:១១)។ ប៉ុន្តែ នៅពេលដែលមកដល់ចំណុចនេះ ប្រហែលជាមានអ្នកអានខ្លះនឹងជំទាស់ថា តើព្រះបន្ទូលមិនបានអះអាងថា «ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅទេឬ?» (ទំនុកតម្កើង ១៣៦:១)។ មានចំណុចពីរយ៉ាងដែលយើងគួរលើកឡើងទាក់ទងនឹងគំនិតបែបនេះ៖ *ទី១*

ព្រះជាម្ចាស់នឹងមិនឈប់ប្រទានសេចក្ដីមេត្តាករុណារបស់ទ្រង់ឡើយ ដ្បិតសេចក្ដីមេត្តាករុណាគឺជាលក្ខណសម្បត្តិមួយនៃភាពជាព្រះរបស់ទ្រង់ (ទំនុកតម្កើង ១១៦:៥)។ *ទី២* ការប្រទានសេចក្ដីមេត្តាករុណានេះគឺចេញពីព្រះហឫទ័យដែលទ្រង់បានគ្រោងទុកជាមុន។ រឿងនេះត្រូវតែកើតឡើងបែបនេះជាដាច់ខាត ដ្បិតគ្មានអ្វីដែលអាចបង្ខំឲ្យព្រះជាម្ចាស់ធ្វើរឿងអ្វីមួយបានឡើយ ក្រៅពីព្រះអង្គទ្រង់ផ្ទាល់ ពីព្រោះបើមានអ្វីមួយ ឬក៏អ្នកណាម្នាក់អាចបង្ខំព្រះជាម្ចាស់បាន នោះមានន័យថា គេធំជាងព្រះ ហើយព្រះជាម្ចាស់នឹងលែងជាព្រះទៀតហើយ។

ព្រះ ជាម្ចាស់ ប្រទាន សេចក្ដី មេត្តា ករុណា មក តែ តាម រយៈ ព្រះគុណដែលទ្រង់បានគ្រោងទុកប៉ុណ្ណោះ។ ព្រះជាម្ចាស់បានប្រកាសអះអាងអំពីធាតុពិតនេះនៅក្នុងកណ្ឌគម្ពីររ៉ូម ៩:១៥ «ដ្បិតព្រះអង្គមានព្រះបន្ទូលទៅកាន់លោក ម៉ូសេ ថា៖ “យើងនឹងមានចិត្តមេត្តាករុណាដល់នរណា ដែលយើងមេត្តាករុណា”» (គបខ)។ មិនមែនដោយសារទុក្ខវេទនានៃអ្វីៗដែលព្រះអង្គបានបង្កើតមកនោះទេ ដែលបណ្ដាលឲ្យទ្រង់សម្ដែងសេចក្ដីមេត្តាករុណារបស់ទ្រង់ដល់ពួកគេដូចជាបានប្រទានដល់យើង ដ្បិតគ្មានអ្វីអាចជះឥទ្ធិពលលើទ្រង់ក្រៅតែពីទ្រង់ផ្ទាល់នោះឡើយ។ ប្រសិនបើការរងទុក្ខវេទនាដ៏ធ្ងន់ធ្ងរ

របស់មនុស្សអាចជះឥទ្ធិពលដល់ព្រះហឫទ័យរបស់ទ្រង់នោះទ្រង់ប្រាកដជាសម្អាត ហើយសង្គ្រោះពួកគេទាំងអស់ជាមិនខាន។ ប៉ុន្តែធាតុពិតមិនដូច្នោះទេ! ហេតុអ្វី? បើនិយាយឲ្យខ្លីទៅ នោះមិនមែនជាព្រះហឫទ័យ និងជាគម្រោងការដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើឡើយ។ លើសពីនេះទៅទៀត ប្រសិនបើយើងគិតថា ព្រះជាម្ចាស់បានប្រទានសេចក្តីមេត្តាករុណារបស់ទ្រង់ដោយសារទង្វើល្អរបស់យើង នោះក៏មិនអាចទៅរួចដែរ ដ្បិតគំនិតបែបនោះ គឺផ្ទុយពីអត្ថន័យនៃពាក្យថា «សេចក្តីមេត្តាករុណា»។ «ទ្រង់បានជួយសង្គ្រោះយើងមិនមែនដោយការដែលយើងបានប្រព្រឹត្តដោយសុចរិតនោះទេ គឺដោយសេចក្តីមេត្តាករុណារបស់ទ្រង់វិញ» (ទីតុស ៣:៥)។ នេះមានន័យថា ទង្វើល្អរបស់យើង គឺផ្ទុយពីសេចក្តីមេត្តាករុណាទាំងស្រុង។ សូម្បីតែការប្រព្រឹត្តរបស់ព្រះគ្រីស្ទក៏មិនបានបណ្តាលឲ្យព្រះជាម្ចាស់សម្តែងសេចក្តីមេត្តាករុណាចំពោះអស់អ្នកដែលទ្រង់បានជ្រើសតាំងដែរ៖ ប្រសិនបើបែបនោះមែន នោះមានន័យថា ផលកើតមុនហេតុហើយ។ នោះគឺ «ដោយព្រោះ» ព្រះហឫទ័យមេត្តាករុណារបស់ព្រះនៃយើង ទើបទ្រង់បានបញ្ជូនព្រះគ្រីស្ទមកឯរាស្ត្ររបស់ទ្រង់ (លូកា ១:៧៨)។ អ្វីៗដែលព្រះគ្រីស្ទបានធ្វើ បានបើកផ្លូវឲ្យព្រះជាម្ចាស់អាចសម្តែងសេចក្តីមេត្តាករុណាខាងឯវិញ្ញាណដ៏សុចរិត ដល់ពួក

អ្នកជ្រើសតាំងរបស់ទ្រង់ ហើយទង្វើទាំងអស់របស់ទ្រង់ ក៏បានធ្វើឲ្យព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងសម្ដែងសេចក្ដីយុត្តិធម៌ទាំងស្រុងផងដែរ។ យើងទទួលបានសេចក្ដីមេត្តាករុណាតាមតែបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់តែមួយគត់។

## តើអ្នកណានឹងទទួលសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់?

ទោះបើនេះជាការពិតមែន នោះយើងត្រូវតែថ្វាយព្រះពរ និងសិរីល្អ ចំពោះការដែលលើកឡើងថា ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ "នៅស្ថិតស្ថេររហូតតទៅ" នោះយើងត្រូវពិនិត្យមើលដោយយកចិត្តទុកដាក់ថា តើព្រះជាម្ចាស់ប្រទាន "សេចក្ដីមេត្តាករុណា" ដល់អស់អ្នកណា? ការដែលទ្រង់បញ្ជូនមនុស្សចោលម្សៀតទៅបឹងភ្លើងក៏ជាទង្វើនៃសេចក្ដីមេត្តាករុណា។ យើងត្រូវមានទស្សនៈបីយ៉ាងទាក់ទងនឹងការពិចារណារបស់យើងលើការដែលព្រះជាម្ចាស់ដាក់ទោសមនុស្សអាក្រក់។ *ទី១ ទស្សនៈរបស់ព្រះជាម្ចាស់៖* នេះជាការកាត់ទោសដ៏យុត្តិធម៌ ហើយក៏ជាការដែលទ្រង់សងសឹក ដើម្បីកិត្តិយសរបស់ទ្រង់ផងដែរ។ ព្រះជាម្ចាស់មិនដែលសម្ដែងក្ដីមេត្តាករុណារបស់ទ្រង់ដោយមើលរំលងសេចក្ដីបរិសុទ្ធ និងសេចក្ដីសុចរិត

របស់ទ្រង់ឡើយ។ *ទី២ ទស្សនៈរបស់អស់អ្នកដែលត្រូវបានបោះចូលបឹងភ្លើង៖* នៅពេលដែលពួកគេទទួលលទ្ធផលនៃអំពើបាបរបស់ខ្លួន នោះគឺជារឿងសមហេតុសមផលណាស់។ *ទី៣ ទស្សនៈរបស់អ្នកដែលព្រះជាម្ចាស់បានប្រោសលោះ៖* ការដែលព្រះជាម្ចាស់ដាក់ទោសពួកមនុស្សអាក្រក់ គឺជាការផ្ដល់សេចក្ដីមេត្តាករុណាដែលមិនអាចពណ៌នាបាន។ ប្រសិនបើបុត្រាបុត្រីរបស់ព្រះជាម្ចាស់ត្រូវបន្តរស់នៅជាមួយនឹងកូនចៅរបស់អារក្សសាតាំងនៅអស់កល្បជានិច្ច ដូចដែលពួកគេកំពុងរស់នៅសព្វថ្ងៃនេះ នោះពិតជាអាក្រក់ណាស់! នគរស្ថានសួគ៌នឹងលែងជានគរស្ថានសួគ៌ទៀតហើយ ប្រសិនបើត្រចៀកនៃពួកបរិសុទ្ធនៅតែស្ដាប់ឮពាក្យជេរប្រមាថ និងពាក្យសម្ដីអាក្រក់ដែលចេញពីមាត់ពួកចោលម្សៀតទៀតនោះ។ ព្រះហឫទ័យមេត្តាករុណាពិតជាអស្ចារ្យណាស់ដែលនៅក្រុងយេរូសាឡឹមថ្មី «គ្មានអ្វីស្មោកគ្រោក ឬអ្នកណាដែលប្រព្រឹត្តបែបគួរខ្ពើម ឬសេចក្ដីកំភូតណាចូលទៅក្នុងទីក្រុងនោះបានឡើយ!» (វិវរណៈ ២១:២៧)។

ប្រសិនបើមិត្តអ្នកអានគិតថា យើងបានដកស្រង់កថាខណ្ឌខាងលើនេះចេញពីគំនិតប្រឌិតរបស់យើងមែន នោះចូរមើលនៅក្នុងព្រះគម្ពីរតទ្បូវនេះ ដែលជាភស្ដុតាងអំពីចំណុចដែលយើងបានលើកឡើង។ តាមរយៈកណ្ឌគម្ពីរ ទំនុកតម្កើង ១៤៣:១២ យើងឃើញ

ស្ដេច ដាវីឌ បានអធិស្ឋានបែបនេះថា “ហើយសូមកាត់ពួកខ្មាំងសត្រូវទូលបង្គំចេញ ដោយសេចក្ដីសប្បុរសរបស់ទ្រង់ ព្រមទាំងបំផ្លាញអស់អ្នកដែលសង្កត់សង្កិនព្រលឹងទូលបង្គំផង ដ្បិតទូលបង្គំជាអ្នកបម្រើទ្រង់ហើយ”។ សូមមើលម្ដងទៀតនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង ១៣៦:១៥ ដែលចែងថា ព្រះជាម្ចាស់ “បានរលាស់ទម្លាក់ផារ៉ោន ព្រមទាំងពលទ័ពទៅក្នុងសមុទ្រក្រហម ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប”។ ការដែលព្រះជាម្ចាស់ប្រព្រឹត្តចំពោះស្ដេច ផារ៉ោន និងរាស្ត្ររបស់ទ្រង់ គឺជាការសងសឹក ប៉ុន្តែចំពោះសាសន៍អ៊ីស្រាអែលការនោះជាសេចក្ដីមេត្តាករុណាវិញ។ ជាថ្មីម្ដងទៀត នៅក្នុងកណ្ឌគម្ពីរ វិវរណៈ ១៩:១-៣ ក៏បានចែងផងដែរថា៖

“ក្រោយមក ខ្ញុំបានឮហាក់ដូចជាសំឡេងយ៉ាងខ្លាំងរបស់មនុស្សច្រើនកុះករ នៅស្ថានសួគ៌ថា៖ “ហាលេលូយ៉ា! ការសង្គ្រោះ សិរីល្អ និងព្រះចេស្ដាជារបស់ព្រះនៃយើង ដ្បិតការជំនុំជម្រះរបស់ព្រះអង្គ សុទ្ធតែពិតត្រង់ ហើយសុចរិត ព្រោះព្រះអង្គបានជំនុំជម្រះស្រ្តីពេស្យាដ៏ធំ ដែលបង្ខូចផែនដីដោយអំពើសហាយស្មន់របស់នាង ហើយព្រះអង្គក៏បានសងសឹក ដោយព្រោះឈាមពួកអ្នកបម្រើរបស់ព្រះអង្គដែលនាងកំចាយនោះដែរ”។ ពួកគេក៏ពោលពាក្យម្ដងទៀត

ថា៖ “ហាលេលូយ៉ា! ផ្សែងនៃក្រុងនេះហុយឡើងអស់កល្បជានិច្ចរៀងរាបតទៅ”»។

យោងតាមខគម្ពីរខាងលើនេះ ចូរយើងកត់សម្គាល់អំពីរបៀបដែលឥតប្រយោជន៍ និងការឥតកោតក្រែងរបស់មនុស្សអាក្រក់ ដែលពួកគេសង្ឃឹមថា ទោះបីជាពួកគេនៅបន្តទាស់ប្រឆាំងនឹងព្រះជាម្ចាស់ទៀតក៏ដោយ ក៏ទ្រង់នៅតែបន្តសម្ដែងសេចក្ដីមេត្តាករុណារបស់ទ្រង់ចំពោះពួកគេដែរ។ មានមនុស្សជាច្រើនបានលើកឡើងថា ខ្ញុំជឿថាព្រះជាម្ចាស់នឹងមិនទម្លាក់ខ្ញុំចូលទៅក្នុងបឹងភ្លើងឡើយ ពីព្រោះទ្រង់មានព្រះហឫទ័យមេត្តាករុណាដ៏ធំធេង។ ខ្ញុំហៅសេចក្ដីសង្ឃឹមបែបនេះថាជាសេចក្ដីសង្ឃឹមពស់វែក ព្រោះទោះបីជាពួកគេឱបក្រសោបវាយ៉ាងណា ក៏គង់តែត្រូវវាចឹកស្លាប់ដែរ។ ព្រះជាម្ចាស់គឺជាព្រះដ៏យុត្តិធម៌ ទោះបីជាទ្រង់មានពេញដោយសេចក្ដីមេត្តាករុណាក៏ដោយ ហើយទ្រង់បានប្រកាសជាសាធារណៈថា ទ្រង់នឹង «មិនរាប់មនុស្សមានទោសទុកជាឥតទោសឡើយ» (និក្ខមនំ ៣៤:៧០)។ ប្រាកដណាស់! ព្រះអង្គបានមានព្រះបន្ទូលថា «សូមឲ្យមនុស្សអាក្រក់គឺប្រជាជាតិទាំងប៉ុន្មានដែលបំភ្លេចព្រះជាម្ចាស់ វិលទៅរកស្ថានមនុស្សស្លាប់វិញទៅ» (ទំនុកតម្កើង ៩:១៧ គខប)។ មនុស្សមួយចំនួនប្រហែលជាគិតថា ប្រសិនបើជាអ្នកខ្លះរស់នៅកន្លែងកខ្វក់

ដូចជារស់នៅក្បែរលូទឹកស្អុយ ឬរស់នៅកន្លែងដែលមិនមានខ្យល់អាកាសបរិសុទ្ធ ខ្ញុំមិនជឿថា ព្រះជាម្ចាស់នឹងបណ្តោយឲ្យពួកគេឈឺនោះឡើយ។ ធាតុពិតគឺថា អ្នកណាដែលមិនគោរពតាមច្បាប់សុខភាព នោះច្បាស់ជាកើតមានជំងឺជាមិនខាន ទោះបើមានសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ក៏ដោយ។ ឯអ្នកណាដែលមិនគោរពតាមច្បាប់សុខភាពខាងឯវិញ្ញាណ អ្នកនោះក៏នឹងត្រូវស្លាប់ជាលើកទីពីរយ៉ាងអស់កល្បជានិច្ចដែរ ពោលគឺពួកគេនឹងត្រូវធ្លាក់នរក។

នៅពេលដែលយើងមើលឃើញមនុស្សជាច្រើនមើលងាយចំពោះលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះរបស់ទ្រង់ នោះវាជារឿងមួយគួរឲ្យសោកស្តាយដែលមិនអាចពណ៌នាបាន។ ពួកគេបន្តមើលងាយចំពោះអំណាចព្រះចេស្តារបស់ព្រះជាម្ចាស់ ហើយជាន់ឈ្លីក្រឹត្យវិន័យរបស់ទ្រង់ដោយបន្តរស់នៅក្នុងអំពើបាបរបស់ពួកគេ ប៉ុន្តែស្របពេលជាមួយគ្នានោះពួកគេនៅតែគិតថា ទ្រង់នៅតែប្រទានសេចក្តីមេត្តាករុណារបស់ទ្រង់ដល់ពួកគេដដែល។ ប៉ុន្តែ ទ្រង់នឹងមិនធ្វើជាព្រះអយុត្តិធម៌ចំពោះព្រះអង្គទ្រង់ផ្ទាល់នោះទេ។ ព្រះជាម្ចាស់សម្តែងសេចក្តីមេត្តាករុណារបស់ទ្រង់ដល់អស់អ្នកដែលពិតជាទទួលស្គាល់កំហុសរបស់ខ្លួន ប៉ុន្តែទ្រង់នឹងមិនធ្វើដូច្នោះចំពោះអ្នកដែលមិនទទួលស្គាល់កំហុសរបស់ខ្លួននោះឡើយ (លូកា ១៣:៣)។ ប្រសិន

បើបុគ្គលម្នាក់បន្តរស់នៅក្នុងអំពើបាប ហើយរំពឹងថាព្រះជាម្ចាស់នឹងសម្តែងសេចក្តីមេត្តាករុណារបស់ទ្រង់ចំពោះគាត់ដោយគិតថាទ្រង់នឹងលុបទោសរបស់គាត់ចោល បុគ្គលនោះមានលក្ខណៈដូចជាអារក្សហើយ! គំនិតបែបនោះគឺប្រៀបដូចជាការនិយាយថា "ចូរប្រព្រឹត្តការអាក្រក់ ដើម្បីឲ្យការល្អបានកើតឡើង" ដ្បិតចំពោះអ្នកដែលគិតដូច្នោះ "ទោសនៃពួកអ្នកដែលប្រកាន់ដូច្នោះ នោះត្រឹមត្រូវហើយ" (រ៉ូម ៣:៨)។ ការសន្មតបែបនេះ នឹងប្រាកដជាជួបការខកចិត្តជាមិនខាន (សូមអានបន្ថែមក្នុងកណ្ឌគម្ពីរ ចោទិយកថា ២៩:១៨-២០)។ ព្រះគ្រីស្ទគឺជាបល្ល័ង្កនៃសេចក្តីមេត្តាករុណាខាងឯវិញ្ញាណ ហើយអស់អ្នកណាដែលមើលងាយ និងបដិសេធភាពជាព្រះអម្ចាស់របស់ទ្រង់គឺសមនឹង "ត្រូវវិនាសតាមផ្លូវ ដ្បិតបន្តិចទៀត សេចក្តីខ្ញាល់របស់ទ្រង់នឹងឆួលឡើង" (ទំនុកតម្កើង ២:២១)។

ប៉ុន្តែ ជាចុងក្រោយនេះ ចូរយើងគិតអំពីសេចក្តីមេត្តាករុណាខាងឯវិញ្ញាណរបស់ព្រះជាម្ចាស់ចំពោះរាស្ត្ររបស់ទ្រង់វិញ "ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គខ្ពស់រហូតដល់ផ្ទៃមេឃ" (ទំនុកតម្កើង ៥៧:១០ គខប)។ សេចក្តីមេត្តាករុណាដ៏លើសលប់របស់ព្រះជាម្ចាស់ ខ្ពស់ជាងគំនិតដ៏ឆ្លៀវឆ្លាតរបស់យើងឆ្ងាយណាស់។ "ផ្ទៃមេឃខ្ពស់ពីផែនដីយ៉ាងណា ព្រះហឫទ័យមេត្តាករុណា

របស់ព្រះអង្គចំពោះអស់អ្នកដែលគោរពកោតខ្លាចព្រះអង្គក៏ខ្ពស់យ៉ាងនោះដែរ» (ទំនុកតម្កើង ១០៣:១១ គខប)។ គ្មានអ្នកណាអាចវាស់ស្ទង់សេចក្តីមេត្តាករុណារបស់ទ្រង់បានឡើយ។ កណ្ឌគម្ពីរ រ៉ូម ៩:២៣ បានហៅពួកអ្នកជ្រើសតាំងថាជាអ្នក «ពួកគ្រឿងប្រដាប់ ដែលគួរនឹងសេចក្តីមេត្តាករុណា»។ ដោយសារសេចក្តីមេត្តាករុណាដ៏លើសលប់របស់ព្រះជាម្ចាស់បានប្រោសឲ្យពួកគេមានជីវិតក្នុងកាលដែលពួកគេស្លាប់ក្នុងការរំលងនៅឡើយ (អេភេសូរ ២:៤-៥)។ ដោយសារក្តីមេត្តាករុណា ពួកគេបានទទួលសេចក្តីសង្គ្រោះ (ទីតុស ៣:៥)។ សេចក្តីមេត្តាករុណាដ៏បរិបូររបស់ទ្រង់ក៏បានផ្តល់មរតកដ៏អស់កល្បជានិច្ចដល់ពួកគេដែរ (១ពេត្រុស ១:៣)។ យើងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបរាប់អំពីការដែលទ្រង់ថែរក្សាទ្រទ្រង់ អត់ទោស និងសម្តែងសេចក្តីមេត្តាករុណាដល់យើងឡើយ។ ចំពោះព្រះអង្គផ្ទាល់ ទ្រង់គឺជា «ព្រះវរបិតាដ៏មានសេចក្តីមេត្តាករុណា» (២កូរិនថូស ១:៣)។

«ឱព្រះជាម្ចាស់អើយ! ពេលដែលព្រលឹងរបស់ទូលបង្គំព្យាយាមស្វែងយល់អំពីក្តីមេត្តាករុណារបស់ទ្រង់ ទូលបង្គំទទួលបានទស្សនៈដ៏អស្ចារ្យអំពីទ្រង់ ក្តីស្រឡាញ់របស់ទ្រង់ ហើយទូលបង្គំនឹងលើកតម្កើងព្រះអង្គ»។[១]

ជំពូកទី១៥

# សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់

ព្រះបន្ទូលបានប្រាប់យើងនូវចំណុចបីយ៉ាងទាក់ទងនឹងលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់។ *ទី១* «ព្រះទ្រង់ជាវិញ្ញាណ» (យ៉ូហាន ៤:២៤)។ នៅក្នុងភាសាក្រិកមិនមានពាក្យ «សាកល្បត្ថ» ដូចភាសាខ្មែរនោះទេ ហើយប្រសិនបើយើងនិយាយថា «ព្រះទ្រង់ជាវិញ្ញាណមួយ» នោះគឺជាការខុសឆ្គងហើយ ព្រោះនោះមានន័យថា យើងកំពុងតែចាត់ថ្នាក់ទ្រង់នៅក្នុងចំណោមវិញ្ញាណផ្សេងៗទៀតដែរ។ ព្រះអង្គជា «វិញ្ញាណ» លើអស់ទាំងវិញ្ញាណ។ ដោយសារទ្រង់ជា «វិញ្ញាណ» នោះទ្រង់មិនមានរូបរាងកាយ ឬជាសារធាតុម្យ៉ាងដែលយើងអាចមើលឃើញបាននោះទេ។ ប្រសិនបើព្រះជាម្ចាស់មានរូបកាយ នោះទ្រង់មិនអាចគង់នៅគ្រប់ទីកន្លែងបានទេ គឺអាចគង់នៅបានតែមួយកន្លែងក្នុងពេលតែមួយប៉ុណ្ណោះ ប៉ុន្តែដោយសារទ្រង់ជាវិញ្ញាណ ដូច្នេះ

ទ្រង់អាចគង់នៅគ្រប់ទីកន្លែង ទាំងនៅស្ថានសួគ៌ និងនៅផែនដីក្នុងពេលតែមួយបាន។ *ទី២* «ព្រះទ្រង់ជាពន្លឺ» ហើយនេះមានន័យថាទ្រង់មានលក្ខណៈផ្ទុយពីសេចក្ដីងងឹត (១យ៉ូហាន ១:៥)។ យោងតាមព្រះគម្ពីរ «សេចក្ដីងងឹត» តំណាងឲ្យអំពើបាប សេចក្ដីអាក្រក់ និងសេចក្ដីស្លាប់ ប៉ុន្តែ «ពន្លឺ» តំណាងឲ្យសេចក្ដីបរិសុទ្ធ សេចក្ដីសប្បុរស និងជីវិត។ ការដែលព្រះគម្ពីរលើកឡើងថា «ព្រះទ្រង់ជាពន្លឺ» នោះមានន័យថា ទ្រង់ល្អឥតខ្ចោះ ហើយឧត្ដុង្គឧត្ដមបំផុត។ *ទី៣* «ព្រះទ្រង់ជាសេចក្ដីស្រឡាញ់» (១យ៉ូហាន ៤:៨)។ នេះមិនមានន័យយ៉ាងសាមញ្ញថា ព្រះទ្រង់គ្រាន់តែស្រឡាញ់ប៉ុណ្ណោះទេ តែទ្រង់ជាតួអង្គនៃសេចក្ដីស្រឡាញ់តែម្ដង ហើយសេចក្ដីស្រឡាញ់មិនគ្រាន់តែជាលក្ខណសម្បត្តិមួយរបស់ទ្រង់ប៉ុណ្ណោះទេ តែជាសារជាតិដើមរបស់ទ្រង់។

សព្វថ្ងៃនេះ មានមនុស្សជាច្រើនបាននាំគ្នានិយាយពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ប៉ុន្តែតាមពិតពួកគេមិនទាន់ទាំងស្គាល់ព្រះនៃសេចក្ដីស្រឡាញ់នោះផង។ ជាទូទៅ ពួកគេគិតថា ព្រះនៃសេចក្ដីស្រឡាញ់នោះ គឺជាព្រះដ៏ទន់ខ្សោយ ហើយគ្រាន់តែជាព្រះដែលបណ្ដែតបណ្ដោយទៅតាមសេចក្ដីស្រឡាញ់របស់ខ្លួន។ ពួកគេរាប់សេចក្ដីស្រឡាញ់របស់ទ្រង់ថា ជាអនុស្សាវរីយ៍ដ៏ល្ងីងល្ងើរចត់។ បើ

និយាយឲ្យខ្លីទៅ គឺពួកគេរាប់សេចក្តីស្រឡាញ់របស់ទ្រង់ទៅតាមបែបលក្ខណៈអារម្មណ៍របស់មនុស្ស។ នៅត្រង់ចំណុចនេះ សេចក្តីពិតក៏ដូចជាចំណុចផ្សេងៗទៀតដែរគឺថា យើងត្រូវទុកឲ្យព្រះបន្ទូលធ្វើជាអ្នកផ្តួចផ្តើម ហើយដាក់កម្រិតលើគំនិតរបស់យើង។ មូលហេតុដែលយើងត្រូវធ្វើបែបនេះ គឺមិនគ្រាន់តែដោយសារមានមនុស្សជាច្រើនធ្វើមិនដឹងមិនឮនោះទេ ប៉ុន្តែដោយសារមានមនុស្សជាច្រើននៅស្ទើរគ្រប់ទីកន្លែងក្នុងចំណោមអ្នកដែលបានរាប់ខ្លួនថាជាគ្រីស្ទបរិស័ទតាមពិតមិនសូវមានចំណេះដឹងខាងឯព្រលឹងវិញ្ញាណដែលអាចមើលឃើញត្រង់ចំណុចនេះឡើយ។ ពួកគេហាក់បីដូចជាមិនសូវស្រឡាញ់ព្រះជាម្ចាស់ខ្លាំងណាស់ណានោះទេ។ ហេតុផលចម្បងមួយទាក់ទងនឹងការដែលយើងមិនសូវស្រឡាញ់ទ្រង់ នោះគឺមកពីយើងមិនសូវយកចិត្តទុកដាក់លើសេចក្តីស្រឡាញ់ដ៏អស្ចារ្យដែលទ្រង់មានចំពោះរាស្ត្ររបស់ទ្រង់។ នៅពេលណាដែលយើងកាន់តែយល់ពីសេចក្តីស្រឡាញ់របស់ទ្រង់ដែលមានដូចជា លក្ខណសម្បត្តិភាពបរិបូរណ៍ និងព្រះពរ នោះចិត្តរបស់យើងនឹងកាន់តែស្រឡាញ់ទ្រង់ថែមទៀតជាមិនខាន។

# លក្ខណសម្បត្តិ និងព្រះពរនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់

ចំណុចទី១៖ គ្មានអ្វីអាចមានឥទ្ធិពលលើសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានឡើយ។ ក្នុងឃ្លានេះយើងចង់មានន័យថា អស់អ្នកដែលព្រះជាម្ចាស់ស្រឡាញ់ គឺពួកគេមិនបានធ្វើអ្វី (សូម្បីតែបន្តិច) ដែលនាំឲ្យទ្រង់ស្រឡាញ់ពួកគេឡើយ ពោលគឺគ្មានអ្វីក្នុងពួកគេទាល់តែសោះដែលទាក់ទាញព្រះជាម្ចាស់ឲ្យស្រឡាញ់ពួកគេនោះទេ។ យើងស្រឡាញ់អ្នកដទៃ ព្រោះយើងឃើញពួកគេមានអ្វីមួយដែលគួរឲ្យយើងស្រឡាញ់ ប៉ុន្តែព្រះជាម្ចាស់ជ្រើសរើសស្រឡាញ់ដោយមិនមានអ្នកណាបង្ខំទ្រង់ឡើយ គឺកើតឡើងដោយឯកអង្គទ្រង់ផ្ទាល់ប៉ុណ្ណោះ ហើយក៏គ្មានអ្នកណាធ្វើឲ្យទ្រង់ស្រឡាញ់ពួកគេដែរ។ អធិបតេយ្យភាពនៃការជ្រើសរើសរបស់ទ្រង់គឺជាមូលហេតុដែលទ្រង់ស្រឡាញ់បុគ្គលណាម្នាក់៖ «ព្រះយេហូវ៉ាទ្រង់មិនបានស្រឡាញ់ឯងរាល់គ្នា ឬរើសឯង ដោយព្រោះឯងមានគ្នាច្រើនជាងសាសន៍ឯទៀតនោះទេ ដ្បិតឯងរាល់គ្នាជាសាសន៍តិចជាងសាសន៍ទាំងអស់ គឺដោយព្រោះព្រះយេហូវ៉ាទ្រង់ស្រឡាញ់ឯងរាល់គ្នាវិញ» (ចោទិយកថា ៧:៧-៨)។ ព្រះជាម្ចាស់បានស្រឡាញ់រាស្ត្ររបស់ទ្រង់តាំងពីអស់កល្បរៀងមកម្ល៉េះ ហេតុដូច្នេះហើយបានជា*ហេតុផល*

ដែលទ្រង់ស្រឡាញ់ គឺមិនមែននៅក្នុងអស់អ្នកដែលទ្រង់ស្រឡាញ់ទេ ដ្បិតទ្រង់ស្រឡាញ់ពួកគេតាំងពីអស់កល្បជានិច្ចមកហើយ។ សេចក្តីស្រឡាញ់របស់ព្រះគឺចេញមកពីអង្គទ្រង់ផ្ទាល់ «គឺដោយសារបំណង...របស់ព្រះអង្គ» (២ធីម៉ូថេ ១:៩ គកស)។

«យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន» (១យ៉ូហាន ៤:១៩)។ ព្រះជាម្ចាស់មិនបានស្រឡាញ់យើង ដោយសារយើងបានស្រឡាញ់ទ្រង់ជាមុននោះទេ ប៉ុន្តែទ្រង់បានស្រឡាញ់យើងតាំងពីមុនដែលយើងបានមានសេចក្តីស្រឡាញ់បន្តិចបន្តួចចំពោះទ្រង់ទៅទៀត។ ប្រសិនបើព្រះជាម្ចាស់ស្រឡាញ់យើងដោយសារយើងស្រឡាញ់ទ្រង់មុន នោះមានន័យថា សេចក្តីស្រឡាញ់របស់ទ្រង់មិនបានកើតឡើងដោយឯកអង្គទ្រង់ផ្ទាល់នោះទេ ប៉ុន្តែដោយសារទ្រង់ស្រឡាញ់យើងខណៈពេលដែលយើងមិនបានស្រឡាញ់ទ្រង់ នោះសបញ្ជាក់ឲ្យយើងឃើញយ៉ាងច្បាស់ថា គ្មានអ្វីអាចមានឥទ្ធិពលលើសេចក្តីស្រឡាញ់របស់ទ្រង់បានឡើយ។ ប្រសិនបើយើងពិតជាចង់គោរពព្រះជាម្ចាស់ និងចង់ឃើញដួងចិត្តខ្លួនឯងរឹងមាំឡើង នោះយើងត្រូវតែយល់ពីសេចក្តីពិតដ៏អស្ចារ្យនេះ។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើងខ្ញុំ និង «រាស្ត្ររបស់ទ្រង់» យើងម្នាក់ៗមិនមែនដោយសារយើងបានធ្វើអ្វីមួយដែលធ្វើឲ្យទ្រង់

ស្រឡាញ់យើងនោះទេ។ តើមានអ្វីនៅក្នុងខ្លួនយើងខ្ញុំដែលទាក់ទាញព្រះចិន្តារបស់ទ្រង់ឲ្យស្រឡាញ់យើងខ្ញុំបាន? ពិតណាស់! គឺយើងខ្ញុំគ្មានអ្វីទាល់តែសោះ! ប៉ុន្តែ ផ្ទុយទៅវិញ យើងខ្ញុំមានគ្រប់អ្វីៗទាំងអស់ក្នុងការរុញច្រានក្ដីស្រឡាញ់ទ្រង់ចេញ ហើយនិងមាននូវគ្រប់អ្វីៗទាំងអស់ក្នុងការធ្វើឲ្យទ្រង់ស្អប់យើងខ្ញុំដែរ។ សរុបសេចក្ដីមក យើងខ្ញុំមានពេញទៅដោយអំពើបាប ហើយក៏បានធ្លាក់ចុះក្នុងអំពើបាប ហើយក៏មានពេញដោយភាពពុករលួយ—ពោលគឺគ្មានអ្វីល្អនៅក្នុងយើងខ្ញុំទាល់តែសោះដែលគួរបណ្ដាលឲ្យទ្រង់ស្រឡាញ់ខ្ញុំឡើយ។«តើទូលបង្គំមានអ្វីដែលធ្វើឲ្យទ្រង់រាប់អានទូលបង្គំឬធ្វើឲ្យព្រះអាទិករសប្បាយព្រះទ័យ? ឱព្រះវរបិតាអើយ! ទោះបីជាដូច្នេះក៏ដោយ ក៏ទូលបង្គំត្រូវតែច្រៀងសរសើរទ្រង់ដដែលព្រោះនោះជាការល្អនៅក្នុងព្រះនេត្រព្រះអង្គ»។

ចំណុចទី២៖ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់មានតាំងពីអស់កល្បជានិច្ចមកម្ល៉េះ។ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ត្រូវតែមានតាំងពីអស់កល្បជានិច្ច ពីព្រោះព្រះជាម្ចាស់ផ្ទាល់គង់នៅតាំងពីអស់កល្បជានិច្ច។ ដូចដែលទ្រង់គ្មានដើមចម នោះសេចក្ដីស្រឡាញ់របស់ទ្រង់ក៏គ្មានដើមកំណើតដែរ។ យើងក៏ត្រូវទទួលស្គាល់ថា គំនិតបែបនេះហួសពីការយល់ដឹងនៃខួរក្បាលដ៏តូចរបស់យើងផងដែរ

ប៉ុន្តែទោះបើយើងមិនអាចយល់បានក៏ដោយ ក៏យើងនៅតែអាចថ្វាយបង្គំព្រះជាម្ចាស់ដោយសេចក្តីស្រឡាញ់បានដែរ។ កណ្ឌគម្ពីរយេរេមា ៣១:៣ បានចែងយ៉ាងច្បាស់អំពីចំណុចនេះថា “អើ អញបានស្រឡាញ់ឯង ដោយសេចក្តីស្រឡាញ់ដ៏ស្ថិតស្ថេរនៅអស់កល្បហេតុនេះបានជាអញទាញនាំឯងមក ដោយសេចក្តីសប្បុរស”។ នេះជាព្រះពរដ៏ធំធេងណាស់សម្រាប់យើង ដោយសារយើងដឹងថា ព្រះដ៏បរិសុទ្ធបំផុតស្រឡាញ់រាស្ត្ររបស់ទ្រង់តាំងពីមុនពេលដែលទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដី ហើយទ្រង់បានដាក់ព្រះទ័យស្រឡាញ់ពួកគេតាំងពីអស់កល្បរៀងមកម្ល៉េះ។ ភស្តុតាងដ៏ច្បាស់លាស់ត្រង់ចំណុចនេះគឺថា សេចក្តីស្រឡាញ់របស់ទ្រង់បានកើតឡើងដោយឯកអង្គទ្រង់ផ្ទាល់ ដ្បិតទ្រង់ស្រឡាញ់ពួកគេតាំងពីយូរលង់ណាស់មកហើយ គឺតាំងពីមុនពេលដែលពួកគេមានកំណើតទៅទៀត។

សេចក្តីពិតដ៏អស្ចារ្យដដែលនេះក៏មានចែងនៅក្នុងកណ្ឌគម្ពីរអេភេសូរ ១:៤-៥ ដែរ “តាមដែលព្រះអង្គបានជ្រើសរើសយើងក្នុងព្រះគ្រីស្ទ តាំងពីមុនកំណើតពិភពលោកមកម្ល៉េះ ដើម្បីឲ្យយើងបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាននៅចំពោះព្រះអង្គ ដោយសេចក្តីស្រឡាញ់ ព្រះអង្គបានតម្រូវយើងទុកជាមុន”។ ការដែលព្រះបន្ទូលបានចែងបែបនេះគួរតែជំរុញចិត្តបុត្រាបុត្រីរបស់ទ្រង់ឲ្យកាន់តែលើក

តម្កើងទ្រង់ខ្លាំងឡើងៗ! ដោយព្រោះសេចក្ដីស្រឡាញ់របស់ព្រះអង្គចំពោះយើងគ្មានដើមចម ហើយក៏គ្មានទីបញ្ចប់ផងនោះ វាគួរតែសម្រាលទុក្ខយើង។ ដោយសារព្រះដ៏ជាព្រះដែលគង់នៅ «តាំងពីអស់កល្បរៀងមករហូតដល់អស់កល្បរៀងទៅ» ដូច្នេះយើងក៏អាចនិយាយថា ទ្រង់ស្រឡាញ់រាស្ត្ររបស់ទ្រង់ «តាំងពីអស់កល្បរៀងមករហូតដល់អស់កល្បរៀងទៅ» បានដែរ។

ចំណុច ទី៣៖ សេចក្ដី ស្រឡាញ់ របស់ ព្រះ ជាម្ចាស់ ប្រកបដោយអធិបតេយ្យភាព។ នេះច្បាស់លាស់ណាស់ ហើយក៏មិនត្រូវមានការពន្យល់ដែរ។ ព្រះជាម្ចាស់គឺជាព្រះដែលប្រកបដោយអធិបតេយ្យភាព ទ្រង់មិនចាំបាច់ឆ្លើយតបចំពោះអ្នកណាទេ ព្រោះទ្រង់គឺជាច្បាប់សម្រាប់អង្គទ្រង់ផ្ទាល់—ពោលគឺទ្រង់អាចប្រព្រឹត្តអ្វីទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ព្រោះទ្រង់ជាអង្គគ្រប់គ្រងដ៏ខ្ពង់ខ្ពស់។ ដោយសារទ្រង់ជាព្រះដែលប្រកបដោយអធិបតេយ្យភាព ហើយទ្រង់ក៏ជាសេចក្ដីស្រឡាញ់ ដូច្នេះនេះជាការចាំបាច់ណាស់ដែលថាសេចក្ដីស្រឡាញ់របស់ទ្រង់ប្រកបដោយអធិបតេយ្យភាព។ ដោយសារព្រះជាម្ចាស់ជាព្រះ នោះមានន័យថា ព្រះអង្គអាចធ្វើនូវអ្វីដែលទ្រង់សព្វព្រះហឫទ័យនឹងធ្វើក៏បាន។ ដូចគ្នានេះដែរ ដោយសារទ្រង់ជាសេចក្ដីស្រឡាញ់ នោះទ្រង់ក៏អាចជ្រើសរើសអស់អ្នកណា

ដែលទ្រង់សព្វព្រះហឫទ័យនឹងស្រឡាញ់តាមតែបំណងព្រះហឫទ័យរបស់ទ្រង់បានដែរ។ ទ្រង់បានអះអាងយ៉ាងច្បាស់អំពីចំណុចនេះថា “អញបានស្រឡាញ់យ៉ាកុប តែស្អប់អេសាវវិញ” (រ៉ូម ៩:១៣)។ ទាំងលោក យ៉ាកុប និងលោក អេសាវ ពួកគេសុទ្ធតែគ្មានអ្វីដែលគួរឲ្យព្រះជាម្ចាស់ស្រឡាញ់មួយលើសជាងគ្នានោះទេ។ អ្នកទាំងពីរមានឪពុកម្ដាយតែមួយ ហើយក៏កើតមកក្នុងពេលតែមួយដែរ។ ពួកគេជាកូនភ្លោះ ប៉ុន្តែព្រះជាម្ចាស់ស្រឡាញ់ម្នាក់ ហើយស្អប់ម្នាក់ទៀត។ តើហេតុអ្វី? ពីព្រោះទ្រង់សព្វព្រះហឫទ័យនឹងធ្វើបែបនោះ។

អធិបតេយ្យភាពនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ត្រូវតែហូរចេញពីសេចក្ដីពិតដែលថា អស់អ្នកដែលទទួលសេចក្ដីស្រឡាញ់របស់ទ្រង់ ពួកគេមិនមានឥទ្ធិពលអ្វីដែលធ្វើឲ្យទ្រង់ស្រឡាញ់ពួកគេនោះទេ។ ហេតុដូច្នេះហើយ អំណះអំណាងដែលថា ទ្រង់ផ្ទាល់ជាប្រភពនៃសេចក្ដីស្រឡាញ់មានន័យថា ទ្រង់មានសិទ្ធិស្រឡាញ់អ្នកដែលទ្រង់សព្វព្រះទ័យនឹងស្រឡាញ់ក៏បានដែរ។ សូមចំណាយពេលបន្តិច ដើម្បីគិតបញ្ច្រាសអំពីប្រយោគមុននេះ។ ឧបមាថា មានអ្វីផ្សេងទៀតក្រៅពីព្រះហឫទ័យរបស់ទ្រង់ដែលធ្វើឲ្យទ្រង់ស្រឡាញ់ក្នុងកាលៈទេសៈនោះ មានន័យថា ទ្រង់ស្រឡាញ់មកពីមានច្បាប់ដែលត្រូវឲ្យទ្រង់ស្រឡាញ់ ហើយប្រសិនបើទ្រង់ស្រឡាញ់មកពី

ទ្រង់ត្រូវគោរពតាមច្បាប់នោះ មានន័យថា ទ្រង់ស្ថិតនៅក្រោមច្បាប់នៃសេចក្តីស្រឡាញ់ ហើយប្រសិនបើដូច្នោះមែន នោះមានន័យថា ទ្រង់គ្មានសិទ្ធិសេរីភាពក្នុងការជ្រើសរើសស្រឡាញ់អ្នកណាទេ ព្រោះទ្រង់ស្ថិតនៅក្រោមច្បាប់ដែលចែងថា ទ្រង់ត្រូវតែស្រឡាញ់។ បើដូច្នេះ «ដោយសេចក្តីស្រឡាញ់...ទ្រង់បានតម្រូវយើងរាល់គ្នាទុកជាមុន សម្រាប់ឲ្យទ្រង់បានទទួលយើងជាកូនចិញ្ចឹម ដោយសារព្រះយេស៊ូវគ្រីស្ទ តាម...»—អ្វី? តើទ្រង់បានតម្រូវពួកគេទុកជាមុន មកពីទ្រង់ទតឃើញថានៅក្នុងពួកគេមានចំណុចល្អឬ? ទេ មិនដូច្នោះឡើយ! បើមិនដូច្នោះទេ តើអ្វីទៅជាមូលហេតុ? ចម្លើយគឺថា ទ្រង់ជ្រើសរើសស្រឡាញ់ពួកគេ «តាមបំណងព្រះហឫទ័យទ្រង់» (អេភេសូរ ១:៤-៥)។

ចំណុចទី៤៖ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់គ្មានដែនកំណត់ឡើយ។ គ្រប់ចំណុចទាំងអស់ដែលទាក់ទងនឹងព្រះជាម្ចាស់ គឺគ្មានដែនកំណត់ទេ។ ភាពជាព្រះរបស់ទ្រង់មាននៅពេញលើផ្ទៃមេឃ និងផែនដីទាំងមូល ហើយព្រះប្រាជ្ញាញាណរបស់ទ្រង់ក៏គ្មានដែនកំណត់ផងដែរ ដ្បិតទ្រង់ជ្រាបគ្រប់អ្វីៗទាំងអស់ ទោះទាំងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលក្តី។ អំណាចព្រះចេស្តារបស់ទ្រង់គ្មានដែនកំណត់ឡើយ ដ្បិតគ្មានអ្វីដែលពិបាកសម្រាប់ទ្រង់នោះ

ទេ។ ដូច្នេះ សេចក្តីស្រឡាញ់របស់ទ្រង់គ្មានដែនកំណត់ឡើយ។ សេចក្តីស្រឡាញ់របស់ទ្រង់ជ្រាលជ្រៅគ្មាននរណាម្នាក់អាចវាស់បានទេ ហើយក៏មានកំពស់ខ្ពស់ដែលគ្មានបុគ្គលណាម្នាក់អាចឡើងទៅដល់បានដែរ។ គ្មានរង្វាស់ណាមួយដែលអាចវាស់ពីបណ្តោយ និងទទឹងនៃសេចក្តីស្រឡាញ់របស់ទ្រង់បានទេ ហើយចំពោះបុគ្គលណាដែលចង់វាស់វែងសេចក្តីស្រឡាញ់របស់ទ្រង់ នោះគាត់ពិតជាបាក់មុខដល់ខ្លួនឯងជាមិនខាន។ សរុបសេចក្តីមក គ្មានខ្នាត ឬរង្វាស់ណាដែលអាចយកមកវាស់ពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានទេ។ កណ្ឌគម្ពីរ អេភេសូរ ២:៤ បានរៀបរាប់អំពីចំណុចនេះយ៉ាងក្បោះក្បាយថា៖ «ប៉ុន្តែ ព្រះដែលមានសេចក្តីមេត្តាករុណាដ៏លើសលប់ ដោយព្រោះសេចក្តីស្រឡាញ់ជាខ្លាំងដែលព្រះអង្គបានស្រឡាញ់យើង»។ ពាក្យថា «ជាខ្លាំង» ស្រដៀងគ្នានឹងប្រយោគដែលកណ្ឌគម្ពីរ យ៉ូហាន ៣:១៦ បានចែងថា «ព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ»។ ចំណុចនេះបង្ហាញពីសេចក្តីស្រឡាញ់ដ៏ធំធេងរបស់ព្រះជាម្ចាស់ដែលយើងមិនអាចវាស់វែងបាន។

«គ្មានអណ្តាតណាអាចពណ៌នាអំពីសេចក្តីស្រឡាញ់ដ៏គ្មានដែនកំណត់របស់ព្រះជាម្ចាស់បានពេញលេញទេ ហើយក៏មិនមានខួរក្បាលណាដែលអាចយល់ពីសេចក្តីស្រឡាញ់របស់ទ្រង់បានគ្រប់

ជ្រុងជ្រោយបានដែរ ដ្បិតសេចក្តីស្រឡាញ់របស់ទ្រង់ “ប្រសើរហួសពីការយល់ឃើញរបស់មនុស្ស” ទៅទៀត (អេភេសូរ ៣:១៩ គខប)។ ចំណុចធំបំផុតដែលខួរក្បាលដ៏តូចរបស់មនុស្សយើងអាចយល់ពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បាននោះ គឺនៅតែជាចំណុចដ៏តូចបំផុតដែលយើងអាចយល់បាននៅឡើយ។ ផ្ទៃមេឃមិនខ្ពស់ឆ្ងាយពីផែនដីដូចជាសេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ខ្ពស់លើសការគិតដែលយើងមានអំពីសេចក្តីសប្បុរសរបស់ព្រះជាម្ចាស់នោះឡើយ។ យើងអាចប្រៀបប្រដូចសេចក្តីស្រឡាញ់របស់ទ្រង់ទៅនឹងសមុទ្រមួយដែលទឹកជោរជន់ឡើងខ្ពស់ហួសជាងភ្នំដែលមានកម្ពស់ផ្ទុយពីវា។ សេចក្តីស្រឡាញ់របស់ទ្រង់ គឺជាប្រភពនៃការប្រទាននូវរាល់អ្វីៗដ៏ល្អដល់អស់អ្នកដែលមានចំណាប់អារម្មណ៍ត្រូវការ” (លោកគ្រូ ចន ប្រាយអិន, ១៧៤៣)។

ចំណុចទី៥៖ សេចក្តីស្រឡាញ់របស់ទ្រង់មិនចេះប្រែប្រួលឡើយ។ ដូចគ្នាជាមួយនឹងព្រះជាម្ចាស់ផ្ទាល់ “ទ្រង់មិនចេះប្រែប្រួលសូម្បីតែស្រមោលនៃសេចក្តីផ្លាស់ប្រែក៏គ្មានដែរ” (យ៉ាកុប ១:១៧) នោះសេចក្តីស្រឡាញ់របស់ទ្រង់ក៏មិនចេះប្រែប្រួល ឬក៏ចុះថយផងដែរ។ លោក យ៉ាកុប ដែលជាអ្នកតូចតាចម្នាក់គឺជាឧទាហរណ៍ដ៏ច្បាស់លាស់៖ ព្រះជាម្ចាស់បានមានព្រះបន្ទូលយ៉ាងច្បាស់ថា

“អញបានស្រឡាញ់យ៉ាកុប” ហើយទោះបីជាលោក យ៉ាកុប មិនជឿ ហើយបានវង្វេងពីទ្រង់ក៏ដោយ ក៏ទ្រង់មិនដែលឈប់ស្រឡាញ់គាត់ដែរ។ កណ្ឌគម្ពីរ យ៉ូហាន ១៣:១ ក៏បានផ្តល់ឧទាហរណ៍ដ៏ល្អមួយទៀតផងដែរ។ នៅយប់នោះ មានសាវ័កម្នាក់បាននិយាយថា “សូមបង្ហាញព្រះវរបិតាឲ្យយើងខ្ញុំឃើញផង” ហើយក៏មានសាវ័កមួយទៀតដែលបដិសេធទ្រង់ដោយជេរប្រមាថគេផងដែរ។ សរុបមក សាវ័កទាំងអស់បានបោះបង់ព្រះអង្គចោល (យ៉ូហាន ១៤:៨)។ ទោះជាយ៉ាងណាក្តី “ដូច្នេះ ដែលទ្រង់បានស្រឡាញ់ដល់ពួកទ្រង់នៅក្នុងលោកីយ៍នេះ នោះទ្រង់ក៏ចេះតែស្រឡាញ់គេ ដរាបដល់ចុងបំផុត” (យ៉ូហាន ១៣:១)។ សេចក្តីស្រឡាញ់របស់ទ្រង់មិនស្ថិតនៅក្រោមការផ្លាស់ប្តូរទេ។ សេចក្តីស្រឡាញ់របស់ទ្រង់ “មានកម្លាំងដូចជាសេចក្តីស្លាប់...ទឹកជាច្រើនយ៉ាងណាក៏មិនអាចនឹងពន្លត់សេចក្តីស្រឡាញ់បានឡើយ” (បទចំរៀងសាឡូម៉ូន ៨:៦-៧)។ គ្មានអ្វីអាចពង្រាត់សេចក្តីស្រឡាញ់របស់ទ្រង់បានឡើយ រ៉ូម ៨:៣៥-៣៩។

“សេចក្តីស្រឡាញ់របស់ទ្រង់គ្មានទីបញ្ចប់ គ្មានខ្នាតណាអាចវាស់ស្ទង់សព្វគ្រប់បានឡើយ គ្មានការផ្លាស់ប្តូរទិសដៅខ្លួនឡើយ គឺហូរចេញពីប្រភពតែមួយជារៀងរហូត”។[១]

ចំណុចទី៦៖ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់គឺបរិសុទ្ធ។

សេចក្តីស្រឡាញ់របស់ទ្រង់មិនស្ថិតក្រោមចិត្តឆេះឆួលភ្លើតភ្លើន ឬនៅក្រោមមនោសញ្ចេតនានោះទេ ប៉ុន្តែទ្រង់ស្រឡាញ់ព្រោះទ្រង់មានគោលការណ៍ថាទ្រង់នឹងស្រឡាញ់។ ព្រះគុណរបស់ទ្រង់មិនសោយរាជ្យដោយមើលរំលងអំពើបាបរបស់បុគ្គលណាម្នាក់នោះទេ ប៉ុន្តែសោយរាជ្យ «ដោយសារសេចក្តីសុចរិត» វិញ (រ៉ូម ៥:២១)។ ដូចគ្នានេះដែរ សេចក្តីស្រឡាញ់របស់ទ្រង់ក៏មិនដែលជំទាស់នឹងភាពបរិសុទ្ធរបស់ទ្រង់ដែរ។ អ្នកនិពន្ធកណ្ឌគម្ពីរ យ៉ូហាន បានលើកឡើងថា «ព្រះទ្រង់ជាពន្លឺ» (១យ៉ូហាន ១:៥ គកស) មុនពេលដែលគាត់លើកឡើងថា «ព្រះទ្រង់ជាសេចក្តីស្រឡាញ់» (១យ៉ូហាន ៤:៨ គកស)។ ចូរកុំយល់ច្រឡំថា សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ដ៏ទន់ខ្សោយ ឬម៉ិកម៉ូក់ដូចស្រីនោះឡើយ។ ព្រះបន្ទូលបានប្រាប់រួចហើយថា «ព្រះអម្ចាស់ប្រៀនប្រដៅអ្នកណាដែលទ្រង់ស្រឡាញ់ ហើយក៏វាយផ្ចាលអស់ទាំងកូនដែលព្រះអង្គទទួល» ដែរ (ហេព្រើរ ១២:៦)។ ព្រះជាម្ចាស់នឹងមិនបិទព្រះនេត្រធ្វើជាមើលមិនឃើញអំពើបាបរបស់មនុស្សលោកទេ សូម្បីតែរាស្ត្ររបស់ទ្រង់ក៏ទ្រង់នឹងមិនបិទព្រះនេត្រដែរ។ សេចក្តីស្រឡាញ់របស់ទ្រង់បរិសុទ្ធត្រឹមត្រូវ ហើយក៏មិនមានលាយឡំជាមួយការបញ្ចុះបញ្ចូលពីអស់អ្នកដែលទទួលសេចក្តីស្រឡាញ់របស់ទ្រង់ដែរ។

ចំណុចទី៧៖ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់មានពេញដោយព្រះគុណ។ យើងមិនអាចញែកសេចក្ដីស្រឡាញ់ និងការដែលទ្រង់សព្វព្រះហឫទ័យចំពោះបុគ្គលណាម្នាក់ឲ្យដាច់ចេញពីគ្នាបានឡើយ។ កណ្ឌគម្ពីរ រ៉ូម ៨:៣២-៣៩ បានពណ៌នាអំពីចំណុចនេះយ៉ាងក្បោះក្បាយ។ យើងអាចយល់អំពីសេចក្ដីស្រឡាញ់ដែលគ្មានអ្នកណាអាច «ពង្រាត់» បានយ៉ាងងាយ ដោយគ្រាន់តែមើលទៅលើបរិបទនៃខគម្ពីរទាំងនេះ៖ ដោយសារសេចក្ដីសប្បុរស និង ព្រះ គុណ នោះ ឯង ដែល បណ្ដាល ឲ្យ ព្រះ ជាម្ចាស់ ប្រទានព្រះរាជបុត្រារបស់ទ្រង់សម្រាប់ពួកមនុស្សមានបាប។ ដោយសារអំណាចនៃសេចក្ដីស្រឡាញ់ដ៏ខ្លាំងក្លារបស់ព្រះជាម្ចាស់ ទើបព្រះយេស៊ូវបានយាងមកយកកំណើតជាមនុស្សនៅលើផែនដី៖ «ព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១» (យ៉ូហាន ៣:១៦)។ ព្រះគ្រីស្ទមិនបានសុគត ដើម្បីឲ្យព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកនោះទេ ប៉ុន្តែទ្រង់បានស្រឡាញ់មនុស្សលោកជាមុនរួចទៅហើយ។ នៅលើភ្នំលលាដ៍ក្បាល យើងអាចមើលឃើញពីសេចក្ដីស្រឡាញ់ដ៏ឧត្ដុង្គឧត្ដមរបស់ទ្រង់បាន។ ឱមិត្តអ្នកអានដែលជាគ្រីស្ទបរិស័ទអើយ! នៅពេលដែលលោកអ្នកជួបការល្បួងដោយមានមន្ទិលសង្ស័យចំពោះសេចក្ដីស្រឡាញ់របស់

ព្រះជាម្ចាស់ នោះចូរត្រឡប់ទៅមើលទិដ្ឋភាពដែលបានកើតឡើងនៅលើភ្នំលលាដ៍ក្បាលដែលមានចែងទុកនៅក្នុងព្រះគម្ពីរសញ្ញាថ្មីចុះ។

គឺនៅត្រង់ចំណុចនេះហើយដែលយើងអាចមើលឃើញពីហេតុផលយ៉ាងច្រើនដែលយើងគួរបន្តទុកចិត្តលើទ្រង់ និងមានការអត់ធ្មត់នៅពេលដែលទ្រង់វាយផ្ចាលយើង (ហេព្រើរ ១២:៤-១១)។ ទោះបីជាព្រះគ្រីស្ទជាបុត្រស្ងួនភ្ងារបស់ព្រះវរបិតាក៏ដោយ ក៏ព្រះវរបិតានៅតែអនុញ្ញាតឲ្យព្រះរាជបុត្រាទ្រង់ជួបប្រទះនឹងភាពក្រីក្រ ការជេរប្រមាថ និងការបៀតបៀនដែរ។ ព្រះយេស៊ូវបានជួបនឹងការស្រេកឃ្លាន។ ហេតុដូច្នេះហើយបានជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់មិនផ្ទុយគ្នាពីការដែលទ្រង់អនុញ្ញាតឲ្យព្រះយេស៊ូវរងទុក្ខវេទនា ដោយមានគេស្ដោះដាក់ទ្រង់ ហើយថែមទាំងវាយទ្រង់នោះទេ។ ដូច្នេះគ្រីស្ទបរិស័ទរាល់គ្នាអើយ! ចូរកុំសួរដេញដោលព្រះជាម្ចាស់អំពីសេចក្ដីស្រឡាញ់របស់ទ្រង់ នៅពេលដែលទ្រង់អនុញ្ញាតឲ្យអ្នករាល់គ្នាជួបនឹងទុក្ខលំបាក ឬការល្បួងលនោះឡើយ។ ព្រះជាម្ចាស់មិនបានអនុញ្ញាតឲ្យព្រះយេស៊ូវក្លាយទៅជាអ្នកមានម្នាក់នៅលើផែនដីនេះទេ សូម្បីតែមួយវិនាទីក៏មិនមានផង។ ដូចមានសេចក្ដីចែងទុកនៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ៨:២០ ហើយថា “តែកូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ”។ ប៉ុន្តែ ព្រះជាម្ចាស់ពិតជាបានប្រទាន

ព្រះវិញ្ញាណបរិសុទ្ធមកព្រះយេស៊ូវដោយគ្មានកម្រិតមែន។ ចូរដឹងថា ព្រះពរខាងឯវិញ្ញាណ គឺជាអំណោយទាននៃសេចក្តីស្រឡាញ់ដ៏ពិសេសជាងគេរបស់ព្រះជាម្ចាស់។ នេះគឺជាព្រះពរដ៏អស្ចារ្យសម្រាប់យើងដែលយើងដឹងថា ទោះបីជាលោកីយ៍នេះស្អប់យើងក៏ព្រះជាម្ចាស់នៅតែស្រឡាញ់យើងដែរ!

ជំពូកទី១៦

# សេចក្តីក្រោធរបស់ព្រះជាម្ចាស់

វាជារឿងដ៏គួរឲ្យសោកស្តាយណាស់ នៅពេលដែលមនុស្សជាអ្នកដែលរាប់ខ្លួនឯងថាជាគ្រីស្ទបរិស័ទមានអារម្មណ៍ថា ពួកគេត្រូវសុំទោសលោកីយ៍ ពីព្រោះព្រះជាម្ចាស់ជាព្រះដែលមានសេចក្តីក្រោធ។ ហើយវាជារឿងដ៏គួរឲ្យសោកស្តាយដែលនៅពេលអ្នកទាំងនោះប៉ងប្រាថ្នាថា ព្រះជាម្ចាស់មិនគួរមានសេចក្តីក្រោធឡើយ។ ទោះបីជាមានបុគ្គលមួយចំនួនមិនហ៊ានអះអាងជាសាធារណៈថា សេចក្តីក្រោធរបស់ព្រះជាម្ចាស់ គឺជាចំណុចដែលយើងគួរបន្ទោសទ្រង់បានក៏ដោយ ក៏ពួកគេមិនបានរាប់សេចក្តីក្រោធរបស់ទ្រង់ថាជាការដែលពួកគេពេញចិត្តទាំងស្រុងនោះដែរ។ ពួកគេមិនចូលចិត្តសញ្ជឹងគិតអំពីលក្ខណសម្បត្តិនេះទេ ហើយនៅពេលដែលពួកគេឮអ្នកផ្សេងនិយាយអំពីលក្ខណសម្បត្តិនេះ ពួកគេតែងតែមានការអាក់អន់ចិត្ត

ទៀតផង។ សូម្បីតែក្នុងចំណោមអស់អ្នកដែលមានការយកចិត្តទុកដាក់ក្នុងការគិតគូររបស់គាត់ក៏ដោយក៏នៅតែហាក់បីដូចជានៅគិតថា សេចក្តីក្រោធរបស់ព្រះជាម្ចាស់ជាប្រធានបទដ៏ធ្ងន់ធ្ងរ និងគួរឲ្យខ្លាច ត្រង់ថាវាមិនមានប្រយោជន៍ទេក្នុងការសញ្ជឹងគិតលើវា។ ដូច្នេះការនេះគួរតែជំរុញឲ្យពួកគេកាន់តែកោតខ្លាចព្រះជាម្ចាស់ តែពួកគេបែរជាមិនកោតខ្លាចទ្រង់ទៅវិញ។ មានមនុស្សមួយចំនួនទៀតបានគិតអំពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់បែបខុសឆ្គង៖ ពួកគេគិតថាសេចក្តីក្រោធរបស់ព្រះជាម្ចាស់មិនស៊ីសង្វាក់គ្នានឹងសេចក្តីសប្បុរសរបស់ទ្រង់ទេ ហេតុដូច្នេះហើយបានជាពួកគេព្យាយាមបំភ្លេចសេចក្តីក្រោធរបស់ទ្រង់ចេញពីខួរក្បាលរបស់ខ្លួនចោល។

## ព្រះជាម្ចាស់មិនលាក់សេចក្តីពិត

ពិតណាស់ មានមនុស្សជាច្រើននាក់មិនចង់គិតអំពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់ ហើយនៅពេលមានអ្នកណាម្នាក់មកសូមឲ្យពួកគាត់គិតអំពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់ នោះធ្វើហាក់ដូចជាថាគេនោះបានសូមឲ្យពួកគាត់មើលលើចំណុចសៅហ្មងខ្លះនៃលក្ខណសម្បត្តិរបស់ទ្រង់ ឬមើលលើចំណុចមិនស្អាតស្អំណាមួយក្នុងការកាត់ទោសរបស់ទ្រង់។ ប៉ុន្តែ តើព្រះគម្ពីរបានថែងយ៉ាងដូចម្តេចខ្លះ

អំពីចំណុចនេះ? នៅពេលដែលយើងងាកទៅមើលព្រះគម្ពីរ យើងនឹងឃើញថា ព្រះជាម្ចាស់មិនបានបិទបាំង ឬក៏លាក់សេចក្ដីក្រោធរបស់ទ្រង់ពីយើងនោះទេ។ ទ្រង់មិនខ្មាសក្នុងការបើកសម្ដែងឲ្យយើងឃើញថា ការសងសឹក និងសេចក្ដីឃោរឃៅគឺជាកម្មសិទ្ធិរបស់ទ្រង់នោះទេ។ ព្រះជាម្ចាស់បានមានព្រះបន្ទូលយ៉ាងច្បាស់ថា «ដូច្នេះចូរឯងដឹងថា គឺអញនេះហើយដែលជាព្រះ គ្មានព្រះឯណាទៀតក្រៅពីអញទេឡើយ អញជាអ្នកសម្លាប់ ហើយជាអ្នកប្រោសឲ្យរស់ អញជាអ្នកវាយឲ្យមានរបួស ហើយជាអ្នកមើលឲ្យជាផង គ្មានអ្នកណានឹងដោះឲ្យរួចពីកណ្ដាប់ដៃអញបានឡើយ ដ្បិតអញលើកដៃអញទៅឯស្ថានសួគ៌ ស្បថដោយនូវព្រះជន្មអញដ៏នៅអស់កល្បជានិច្ចថា បើសិនជាអញសំលៀងដាវរបស់អញដ៏ភ្លឺផ្លេកៗ ហើយដៃអញចាប់កាន់សេចក្ដីយុត្តិធម៌វេលាណា នោះអញនឹងសងសឹកចំពោះពួកអ្នកដែលតតាំងនឹងអញ ហើយនឹងសងដល់ពួកអ្នក ដែលស្អប់អញជាមិនខាន» (ចោទិយកថា ៣២:៣៩-៤១)។

ប្រសិនបើយើងមើលសៀវភៅវិជ្ជាសមោធាន នោះយើងនឹងឃើញថា ព្រះបន្ទូលបានចែងអំពីសេចក្ដីកំហឹង សេចក្ដីឃោរឃៅ និងសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ច្រើនជាងសេចក្ដីស្រឡាញ់ និងភាពទន់ភ្លន់របស់ទ្រង់ទៅទៀត។ ដោយសារព្រះជាម្ចាស់បរិសុទ្ធ ហេតុ

ដូច្នេះហើយបានជាទ្រង់ស្អប់អំពើបាប ហើយដោយសារទ្រង់ស្អប់អំពើបាប ដូច្នេះហើយបានជាទ្រង់មានសេចក្ដីខ្ញាល់យ៉ាងខ្លាំងចំពោះអស់អ្នកដែលប្រព្រឹត្តអំពើបាប (ទំនុកតម្កើង ៧:១១)។

សេចក្ដីក្រោធក៏ជាលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់ ដូចជាភាពស្មោះត្រង់ ភាពពេញដោយអំណាចព្រះចេស្ដា និងសេចក្ដីមេត្តាករុណារបស់ទ្រង់ដែរ។ ប្រាកដណាស់ ព្រះអង្គត្រូវតែមានពេញដោយសេចក្ដីក្រោធ ដ្បិតទ្រង់គ្មានកន្លែងបន្ទោសបានឡើយ សូម្បីតែតូចបំផុតក៏គ្មានផងដែរ។ ប៉ុន្តែ បើទ្រង់គ្មាន «សេចក្ដីក្រោធ» ទេ នោះមានន័យថា ទ្រង់ក៏នៅមានកន្លែងដែលយើងអាចបន្ទោសបានដែរ។ ការព្រងើយកន្តើយនឹងអំពើបាបមានន័យថា យើងមិនបានប្រព្រឹត្តត្រឹមត្រូវតាមសីលធម៌ ហើយអស់អ្នកណាដែលមិនស្អប់អំពើបាបគឺជាមនុស្សមានពុតក្នុងសីលធម៌។ ដោយសារព្រះជាម្ចាស់ទ្រង់ល្អឥតខ្ចោះ ហើយគ្មានអ្នកណាល្អលើសទ្រង់ដូច្នេះហើយបានជាទ្រង់មិនអាចរាប់អំពើអាក្រក់ និងអំពើល្អ ឬក៏ប្រាជ្ញា និងសេចក្ដីល្ងង់ខ្លៅថាល្អស្មើគ្នាបានឡើយ។ ព្រះជាម្ចាស់ដែលជាព្រះដ៏បរិសុទ្ធឥតដែនកំណត់ ទ្រង់មិនអាចមើលរំលងអំពើបាបបានទេ ហើយទ្រង់ក៏មាន «សេចក្ដីប្រិតប្រៀប» ក្នុងការដាក់ទោសចំពោះអំពើបាបបានដែរ (រ៉ូម ១១:២២)។ ព្រះជាម្ចាស់ដ៏ជាព្រះសព្វព្រះហឫទ័យតែនឹងអ្វីៗ

ដែលបរិសុទ្ធ ហើយគួរឲ្យស្រឡាញ់ប៉ុណ្ណោះ ដូច្នេះទ្រង់ត្រូវតែស្អប់អ្វីៗដែលមិនបរិសុទ្ធ ឬក៏អាក្រក់។ ភាពជាព្រះរបស់ព្រះជាម្ចាស់បង្ហាញថា ត្រូវតែមានស្ថាននរកដូចជាមានស្ថានសួគ៌ដ៏អស់កល្បជានិច្ចដែរ។ ព្រះជាម្ចាស់ទ្រង់ល្អឥតខ្ចោះ ហើយគ្មានអ្នកណាផ្សេងទៀតល្អលើសទ្រង់ឡើយ។

សេចក្តីក្រោធរបស់ព្រះជាម្ចាស់ គឺជាសេចក្តីសម្អប់របស់ទ្រង់ចំពោះអំពើទុច្ចរិត តាំងពីអស់កល្បរៀងមកម្ល៉េះ។ សេចក្តីក្រោធគឺជាការមិនសព្វព្រះហឫទ័យ និងជាព្រះពិរោធរបស់ទ្រង់ទាស់នឹងអំពើអាក្រក់។ សេចក្តីក្រោធគឺជាភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ដែលបណ្តាលឲ្យទ្រង់ជំទាស់នឹងអំពើបាប។ សេចក្តីក្រោធគឺជាហេតុផលដ៏យុត្តិធម៌ ដែលធ្វើឲ្យទ្រង់កាត់ទោសអស់អ្នកដែលប្រព្រឹត្តអំពើអាក្រក់។ ព្រះជាម្ចាស់ខ្ទាល់ចំពោះអំពើបាប ពីព្រោះអំពើបាបទាស់ប្រឆាំងនឹងអំណាចព្រះចេស្តាក្នុងការគ្រប់គ្រងរបស់ទ្រង់ ហើយអំពើបាបក៏ជាការបំពានលើអធិបតេយ្យភាពរបស់ទ្រង់ផងដែរ។ ព្រះជាម្ចាស់នឹងប្រដៅអស់ពួកឧទ្ទាមដែលប្រព្រឹត្តទាស់នឹងការសោយរាជ្យរបស់ទ្រង់ ដើម្បីឲ្យពួកគេស្គាល់ថា ទ្រង់ជាព្រះអម្ចាស់។ ដោយព្រោះគេស្អប់អានុភាពដ៏អស្ចារ្យរបស់ព្រះ នោះទ្រង់នឹងប្រដៅគេឲ្យស្គាល់បទពិសោធន៍ដោយផ្ទាល់ ហើយទ្រង់ក៏នឹងឲ្យគេភ្លក់

រសជាតិនៃសេចក្ដីក្រោធដ៏ខ្លាំងក្លារបស់ទ្រង់ដែរ ព្រោះពួកគេមើលងាយទ្រង់។ នេះមិនមែនមានន័យថា សេចក្ដីក្រោធរបស់ព្រះជាម្ចាស់ គឺជាការឆ្លើយតបដ៏សាហាវព្រៃផ្សៃចំពោះអំពើបាប ឬថា ទ្រង់ធ្វើឲ្យមានការឈឺចាប់ គឺគ្រាន់តែ ដើម្បីឲ្យមានការឈឺចាប់ប៉ុណ្ណោះនោះទេ ក៏មិនមែនមានន័យថាទ្រង់ធ្វើឲ្យមានការឈឺចាប់ ព្រោះតែពួកគេបានធ្វើឲ្យទ្រង់ឈឺចាប់នោះឡើយ។ វាមិនមែនដូច្នោះទេ! ខណៈដែលព្រះជាម្ចាស់បង្ហាញថា ទ្រង់ជាព្រះដែលសោយរាជ្យនៅលើចក្រវាលទាំងមូល ទ្រង់នឹងមិនដោះសាឲ្យតែរួចខ្លួនប៉ុណ្ណោះទេ។

យើងមិនត្រឹមតែមើលឃើញថា សេចក្ដីក្រោធរបស់ព្រះជាម្ចាស់ គឺជាលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះរបស់ទ្រង់តាមរយៈការពណ៌នាខាងលើនេះប៉ុណ្ណោះឡើយ ប៉ុន្តែព្រះបន្ទូលរបស់ទ្រង់ក៏បានពណ៌នាយ៉ាងច្បាស់ផងដែរ។ “សេចក្ដីក្រោធរបស់ព្រះ បានសម្ដែងមកពីស្ថានសួគ៌” (រ៉ូម ១:១៨)។ លោកគ្រូ រ៉ូប៊ឺត ហ៊ាលឌីន (Robert Haldane) បានមានប្រសាសន៍ទាក់ទងនឹងខគម្ពីរខាងលើនេះដូចតទៅ៖

“យើងបានមើលឃើញសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ នៅពេលដែលទ្រង់បានដាក់បណ្ដាសាឲ្យមានជាសេចក្ដីស្លាប់ ដាក់បណ្ដាសាផែនដី បណ្ដេញ លោក អ័ដាម និងនាង អេវ៉ា ដែលជាមនុស្សដំបូង

បង្អស់ចេញពីសួនច្បារអេដែន ហើយក្រោយមកទៀត នៅពេលដែលទ្រង់ធ្វើឲ្យមានទឹកជំនន់មក និងបំផ្លាញទីក្រុងនៅស្រុកវាលដោយភ្លើងមកពីស្ថានសួគ៌ ប៉ុន្តែពិសេសជាងនេះទៅទៀត គឺនៅពេលដែលទ្រង់បណ្តាលឲ្យមានសេចក្តីស្លាប់នៅលើផែនដីទាំងមូល។ នៅក្នុងកណ្ឌគម្ពីរ រ៉ូម ជំពូក៨ សាវ័ក ប៉ុល បានរៀបរាប់អំពីសេចក្តីពិតដល់អ្នកជឿថា ជីវិតទាំងឡាយបានជាប់នៅក្នុងចំណងនៃសេចក្តីពុករលួយ ទាំងស្រែកថ្ងូរ ក៏ដូចជាឈឺចាប់ជាមួយគ្នាផងដែរ។ ជីវិតទាំងនេះក៏បានប្រកាសដែរថា មានព្រះ មានការពណ៌នាអំពីសិរីល្អរបស់ទ្រង់ ហើយថាទ្រង់ជាខ្មាំងសត្រូវនៃអំពើបាប និងជាអង្គដែលសងសឹកដល់អស់អ្នកដែលបានប្រព្រឹត្តល្មើស...

ប៉ុន្តែ លើសពីនោះទៅទៀត យើងអាចមើលឃើញសេចក្តីក្រោធរបស់ព្រះជាម្ចាស់នៅពេលដែលព្រះរាជបុត្រារបស់ទ្រង់បានយាងមកពីស្ថានសួគ៌ ដើម្បីបង្ហាញអំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ និងនៅពេលដែលទ្រង់បានសម្តែងសេចក្តីក្រោធនោះមកលើព្រះរាជបុត្រារបស់ទ្រង់តាមរយៈការរងទុក្ខ និងការសុគតរបស់ទ្រង់ ពោលគឺព្រះជាម្ចាស់បានសម្តែងសេចក្តីក្រោធនោះតាមរបៀបមួយដែលទ្រង់មិនធ្លាប់បានសម្តែងចំពោះអំពើបាបឡើយ។ ក្រៅពីនេះព្រះគម្ពីរបានពណ៌នាដោយប្រើពាក្យពេចន៍ធ្ងន់ៗ និងច្បាស់លាស់

ជាងមុនអំពីការដែលព្រះជាម្ចាស់នឹងដាក់ទោសអស់កល្បជានិច្ច នៅថ្ងៃអនាគត។ ក្រោមការរៀបចំរបស់ព្រះជាម្ចាស់ ទ្រង់បានបើកសម្តែងសេចក្តីពីរយ៉ាងអំពីស្ថានសួគ៌៖ ១) សេចក្តីក្រោធ និង២) ព្រះគុណ»។

ជាថ្មីម្តងទៀតកណ្ឌគម្ពីរ ទំនុកតម្កើង ៩៥:១១ ក៏បានរៀបរាប់អំពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់ដល់យើងយ៉ាងច្បាស់ដែលថា «អញបានស្បថដោយសេចក្តីក្រោធរបស់អញ»។ មានកាលៈទេសៈពីរយ៉ាងដែលនាំឲ្យព្រះជាម្ចាស់ «ស្បថ»៖ ១) នៅពេលដែលទ្រង់សន្យា (លោកុប្បត្តិ ២២:១៦) និង២) នៅពេលដែលប្រកាសការថ្កោលទោស (ចោទិយកថា ១:៣៤)។ នៅក្នុងចំណុចទីមួយ យើងមើលឃើញថា ទ្រង់សន្យាប្រទានសេចក្តីមេត្តាករុណាដល់បុត្រាបុត្រីរបស់ទ្រង់។ នៅក្នុងចំណុចទីពីរ ព្រះអង្គបានស្បថថា ទ្រង់នឹងបង្អត់ជំនាន់នៃមនុស្សអាក្រក់ពីកេរ្តិ៍មរតករបស់ពួកគេ ដោយសារពួកគេបានរទូរទាំ ហើយមិនមានជំនឿ។ សេចក្តីសម្បថគឺធ្វើឡើងសម្រាប់ជាអំណះអំណាងដ៏ជាក់លាក់ (ហេព្រើរ ៦:១៦)។ នៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ២២:១៦ ព្រះជាម្ចាស់បានមានព្រះបន្ទូលថា «អញបានស្បថដោយនាមរបស់អញ»។ នៅក្នុងកណ្ឌគម្ពីរ ទំនុកតម្កើង ៨៩:៣៥ ទ្រង់បានប្រកាសថា «អញបានស្បថ

ម្ដងហើយ ដោយនូវសេចក្ដីបរិសុទ្ធរបស់អញ»។ នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង ៩៥:១១ ទ្រង់បានអះអាងថា «អញបានស្បថដោយសេចក្ដីក្រោធរបស់អញ»។ សរុបសេចក្ដីមក ព្រះយេហូវ៉ាដ៏ជាព្រះអស្ចារ្យពឹងអាងលើ «សេចក្ដីក្រោធ» ដែលជាលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះមួយរបស់ទ្រង់ ហើយសេចក្ដីនោះស្មើនឹង «ភាពបរិសុទ្ធ» របស់ទ្រង់៖ នៅពេលដែលទ្រង់ស្បថដោយពឹងលើ «សេចក្ដីក្រោធ» របស់ទ្រង់ គឺស្មើនឹងទ្រង់ពឹងលើ «ភាពបរិសុទ្ធ» ហើយនៅពេលដែលទ្រង់ស្បថដោយពឹងលើ «ភាពបរិសុទ្ធ» របស់ទ្រង់ គឺស្មើនឹងទ្រង់ពឹងលើ «សេចក្ដីក្រោធ» ផងដែរ។ ជាថ្មីម្ដងទៀត ព្រះគ្រីស្ទ «មានគ្រប់ទាំងសេចក្ដីពោរពេញរបស់ព្រះ» (កូឡូស ២:៩) ហើយតាមរយៈទ្រង់យើងក៏បានមើលឃើញអំពីភាពល្អឥតខ្ចោះរបស់ព្រះជាម្ចាស់ផងដែរ (យ៉ូហាន ១:១៨)។ ដូច្នេះហើយបានជាយើងអាន «អំពីសេចក្ដីក្រោធរបស់កូនចៀម» ដែលមានចែងនៅក្នុងកណ្ឌគម្ពីរ វិវរណៈ ៦:១៦។

## សារៈសំខាន់នៃការសញ្ជឹងគិតលើសេចក្ដីក្រោធរបស់ព្រះជាម្ចាស់

សេចក្ដីក្រោធរបស់ព្រះជាម្ចាស់ គឺជាលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះមួយរបស់ទ្រង់ដែលយើងត្រូវសញ្ជឹងគិតជារឿយៗ។ ហេតុផល

ទី១ ដែលយើងត្រូវធ្វើដូច្នោះ គឺដើម្បីឲ្យចិត្តរបស់យើងយល់បានយ៉ាងត្រឹមត្រូវអំពីការដែលព្រះអង្គស្អប់អំពើបាប។ យើងទំនងជាងាយនឹងរាប់អំពើបាបថាជារឿងតូចតាច ហើយមើលរំលងភាពដែលគួរឲ្យស្អប់ខ្ពើមរបស់វា ព្រមទាំងរកលេសឲ្យវានៅពេលដែលយើងប្រព្រឹត្តបាបផង។ ប៉ុន្តែ នៅពេលដែលយើងកាន់តែសិក្សា ហើយសញ្ជឹងគិតអំពីការដែលព្រះជាម្ចាស់ស្អប់អំពើបាប និងការដែលទ្រង់នឹងដាក់ទោសចំពោះអំពើបាប នោះយើងនឹងកាន់តែទទួលស្គាល់ ហើយមើលឃើញពីភាពអាក្រក់របស់អំពើបាប។ ហេតុផលទី២ ដែលយើងត្រូវធ្វើដូច្នោះ គឺដើម្បីធ្វើឲ្យចិត្តរបស់យើងដែលនៅខាងក្នុងចេះគោរពកោតខ្លាចព្រះយ៉ាងពិតប្រាកដ៖ «ត្រូវឲ្យយើងដឹងគុណ ហើយគោរពបម្រើព្រះ តាមរបៀបដែលព្រះអង្គសព្វព្រះហឫទ័យ ទាំងមានចិត្តគោរពប្រតិបត្តិ ហើយកោតខ្លាចព្រះអង្គទៅ ដ្បិតព្រះរបស់យើងទ្រង់ជាភ្លើងដែលឆេះបន្សុស» (ហេព្រើរ ១២:២៨-២៩)។ យើងមិនអាចបម្រើទ្រង់តាមរបៀបដែលទ្រង់ «សព្វព្រះហឫទ័យ» បានទេ ប្រសិនបើយើងមិន «មានចិត្តគោរពប្រតិបត្តិ» ដល់អានុភាពដ៏អស្ចារ្យរបស់ទ្រង់ និងមិនមានចិត្ត «កោតខ្លាចព្រះអង្គ» ដោយយល់អំពីសេចក្តីក្រោធដ៏សុចរិតរបស់ទ្រង់ទេនោះ។ សរុបមក យើងអាចមានចិត្តបែបនោះបាន នៅពេលដែលយើងព្យាយាមរម្លឹកខ្លួនឯងថា «ព្រះរបស់

យើងទ្រង់ជាភ្លើងដែលឆេះបន្សុស»។ ហេតុផលទី៣ ដែលយើងត្រូវធ្វើដូច្នោះ គឺដើម្បីបង្រៀនចិត្តយើងឲ្យចេះច្រៀងសរសើរតម្កើងព្រះជាម្ចាស់ឲ្យបានលាន់រំពង ពីព្រោះទ្រង់បានរំដោះ «យើងឲ្យរួចពីសេចក្ដីក្រោធដែលត្រូវមក» (១ថែស្សាឡូនីច ១:១០)។

ការដែលយើងចង់សញ្ជឹងគិត ឬក៏ស្ទាក់ស្ទើរមិនចង់សញ្ជឹងគិតអំពីសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ សរបញ្ជាក់ឲ្យឃើញថា ចិត្តរបស់យើងបានទទួលការប៉ះពាល់ពីព្រះជាម្ចាស់ខ្លាំងប៉ុណ្ណា។ ប្រសិនបើយើងពិតជាគ្មានអំណរនៅក្នុងទ្រង់ដោយពឹងលើលក្ខណសម្បត្តិរបស់ទ្រង់ទាំងស្រុង និងពឹងលើលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះដែលទ្រង់មានតាំងពីអស់កល្បរៀងមកទេ នោះតើឲ្យយើងនិយាយថាយើងមានសេចក្ដីស្រឡាញ់របស់ទ្រង់នៅក្នុងយើងយ៉ាងដូចម្ដេចបាន? យើងទាំងអស់គ្នាត្រូវអធិស្ឋាន ហើយការពារចិត្តរបស់យើងកុំឲ្យគិតអំពីព្រះជាម្ចាស់ដោយពឹងលើគំនិតខ្លួនឯងឡើយ ពីព្រោះជាទូទៅ គំនិតរបស់យើងមានពេញទៅដោយភាពខុសឆ្គង។ កាលពីដើម ព្រះជាម្ចាស់បានត្អូញត្អែរថា «ឯងបានគិតស្មានថា អញដូចឯងតែប៉ុណ្ណោះ» (ទំនុកតម្កើង ៥០:២១)។ ប្រសិនបើយើងគ្មានសេចក្ដីអំណរនៅពេលដែលយើង «រឭកដល់សេចក្ដីបរិសុទ្ធរបស់ទ្រង់» (ទំនុកតម្កើង ៩៧:១២) ប្រសិនបើយើងគ្មានសេចក្ដីអំណរខណៈ

ពេលដែលយើងដឹងថា នៅពេលអនាគតដែលទ្រង់យាងមក ទ្រង់នឹងសម្ដែងសេចក្តីក្រោធដ៏អស្ចារ្យរបស់ទ្រង់ ដោយសងសឹកដល់អស់អ្នកដែលទាស់ប្រឆាំងនឹងទ្រង់ទេនោះ មានន័យថា ចិត្តរបស់យើងមិនបានចុះចូលនៅក្រោមទ្រង់ទាំងស្រុងនៅឡើយទេ ហើយយើងក៏នៅក្រោមអំណាចនៃអំពើបាបរបស់យើងដែរ។ ចំណុចនេះក៏មានន័យថា យើងកំពុងធ្វើដំណើរទៅបឹងភ្លើងដ៏អស់កល្បជានិច្ចដែរ។

## ការប្រើប្រាស់សេចក្តីយុត្តិធម៌របស់ព្រះជាម្ចាស់តាមរយៈសេចក្តីក្រោធរបស់ទ្រង់

កណ្ឌគម្ពីរ ចោទិយកថា ៣២:៤៣ បានចែងថា “ឱអស់ទាំងសាសន៍អើយ ចូរសរសើរដល់រាស្ត្រទ្រង់ចុះ ដ្បិតទ្រង់នឹងសងសឹកចំពោះឈាមពួកបាវបម្រើទ្រង់ គឺនឹងសងដល់ពួកអ្នកដែលតតាំងនឹងទ្រង់”។ ជាថ្មីម្តងទៀត យើងក៏ឃើញដែរថា៖

“ក្រោយមក ខ្ញុំបានហាក់ដូចជាឮសំឡេងយ៉ាងខ្លាំងរបស់មនុស្សច្រើនកុះករនៅស្ថានសួគ៌ថា៖ “ហាលេលូយ៉ា!” ការសង្គ្រោះ សិរីល្អ និងព្រះចេស្ដា ជារបស់ព្រះនៃយើង ដ្បិតការជំនុំជម្រះរបស់ព្រះអង្គសុទ្ធតែពិតត្រង់ ហើយសុចរិត ព្រោះព្រះអង្គបានជំនុំជម្រះស្ត្រីពេស្យាដ៏ធំ ដែលបង្ខូចផែនដីដោយអំពើសហាយស្មន់របស់នាង ហើយ

ព្រះអង្គក៏បានសងសឹក ដោយព្រោះឈាមពួកអ្នកបម្រើរបស់ព្រះអង្គ ដែលនាងបានកម្ចាយនោះដែរ។ ពួកគេក៏ពោលពាក្យម្ដងទៀតថា៖ “ហាលេលូយ៉ា!”» (វិវរណៈ ១៩:១-៣ គកស)។

ពួក បរិសុទ្ធ នឹង មាន អំណរ យ៉ាង ធំ ក្រៃលែង នៅ ថ្ងៃ ដែល ព្រះជាម្ចាស់សងសឹក ដើម្បីបង្ហាញអំពីភាពវិសេសវិសាលរបស់ទ្រង់ និងបើកសម្ដែងពីអំណាចដ៏អស្ចារ្យ ព្រមទាំងភាពយុត្តិធម៌របស់ទ្រង់ ហើយនិងទម្លាក់អស់ពួកមនុស្សអួតអាង ដែលទាស់ប្រឆាំងនឹងទ្រង់ផង ជាពួកអ្នកដែលបំបាក់មុខទ្រង់។

«ឱព្រះយេហូវ៉ាអើយ បើសិនជាទ្រង់កត់ចំណាំអស់ទាំងអំពើទុច្ចរិតនោះ ឱព្រះអម្ចាស់អើយ តើអ្នកណានឹងធន់នៅបាន?» (ទំនុកតម្កើង ១៣០:៣)។ ជាការល្អណាស់ដែលយើងសួរសំណួរនោះមកកាន់ខ្លួនឯង ដ្បិតកណ្ឌគម្ពីរ ទំនុកតម្កើង ១:៥ បានចែងថា «ពួកមនុស្សអាក្រក់នឹងមិនធន់នៅក្នុងគ្រាជំនុំជំរះទេ»។ ព្រលឹងរបស់ព្រះយេស៊ូវឈឺចាប់យ៉ាងខ្លាំង ក្រោមទម្ងន់នៃការគិតអំពីការដែលព្រះជាម្ចាស់ដាក់អំពើបាបរបស់រាស្ត្រទ្រង់លើព្រះអង្គ នៅពេលដែលព្រះជាម្ចាស់បានដាក់អំពើបាបនោះនៅលើព្រះយេស៊ូវ។ «ទ្រង់ចាប់តាំងមានព្រះហឫទ័យភាំងជាខ្លាំង ហើយតប់ប្រមល់ណាស់» (ម៉ាកុស ១៤:៣៣)។ ទ្រង់ឈឺចាប់យ៉ាងខ្លាំង រហូតដល់ញើសរបស់

ទ្រង់ស្រក់មកជាឈាម រួចទ្រង់ព្រះកន្សែង ទាំងទទូចអង្វរយ៉ាងខ្លាំងផង (ហេព្រើរ ៥:៧)។ ទ្រង់បានអធិស្ឋានម្ដងហើយម្ដងទៀតថា «បើសិនជាបាន នោះសូមឲ្យពែងនេះកន្លងហួសពីទូលបង្គំទៅ» ប៉ុន្តែពាក្យដែលគួរឲ្យស្ញែងខ្លាចចុងក្រោយរបស់ទ្រង់គឺ «ឱព្រះអង្គៗនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ» (ម៉ាថាយ ២៦:៣៩; ២៧:៤៦)។ តាមរយៈការទាំងអស់នេះ យើងមើលឃើញអំពីការយល់ដឹងដ៏គួរឲ្យភ័យខ្លាចដែលព្រះយេស៊ូវជ្រាបអស់ទាំងអំពើទុច្ចរិតដែលព្រះជាម្ចាស់បាន «កត់ចំណាំ»។ ដូច្នេះហើយបានជានៅពេលដែលមនុស្សមានបាបស្រែកយំឡើងថា «ឱព្រះអម្ចាស់អើយ តើអ្នកណានឹងធន់នៅបាន» គឺជាការល្អ ដ្បិតសូម្បីតែព្រះរាជបុត្រានៃព្រះជាម្ចាស់ក៏មានពេញទៅដោយការភ័យខ្លាច និងញ័ររន្ធត់ដែរខណៈពេលដែលទ្រង់ឈរនៅក្រោមទម្ងន់នៃសេចក្ដីក្រោធរបស់ព្រះជាម្ចាស់។ ប្រសិនបើមិត្តអ្នកអានរបស់យើងខ្ញុំ មិនបានរត់ទៅឯព្រះគ្រីស្ទដែលជាទីជ្រកកោន និងជាព្រះអង្គសង្គ្រោះតែមួយទេ «នោះតើឯងនឹងធ្វើដូចម្ដេច ក្នុងកាលដែលទន្លេយ័រដាន់ជន់ពេញកម្លាំងឡើង» (យេរេមា ១២:៥; ហេព្រើរ ៦:១៨)។

«នៅពេលដែលខ្ញុំសញ្ជឹងគិត អំពីការដែលមនុស្សជាច្រើននាក់បានមើលងាយ មើលថោកសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ ខ្ញុំមិន

អាចគិតអំពីអ្វីលើសពីគំនិតដ៏ខ្ពស់របស់គាត់ដែលថា ការអស្ចារ្យដ៏ធំក្រៃលែងបំផុតនៅលើលោកនេះគឺ សេចក្តីសប្បុរស និងការអត់ធ្មត់របស់ព្រះជាម្ចាស់ចំពោះលោកីយ៍ដែលមិនចេះដឹងគុណនេះ។ ប្រសិនបើស្តេចណាម្នាក់ទៅវាយខ្មាំងសត្រូវមួយក្រុមដោយចង់យកទីក្រុងរបស់ពួកគេ នោះទ្រង់នឹងមិនផ្គត់ផ្គង់ចំណីអាហារដល់ទីក្រុងនោះឡើយ ប៉ុន្តែទ្រង់នឹងឡោមព័ទ្ធទីក្រុងនោះយ៉ាងជិត ព្រមទាំងធ្វើអ្វីៗគ្រប់យ៉ាងដែលទ្រង់អាចធ្វើទៅបាន ដើម្បីនឹងបង្អត់បាយឲ្យពួកគេដាច់ពោះស្លាប់។ ប៉ុន្តែ ព្រះជាម្ចាស់នៃយើងជាព្រះដ៏អស្ចារ្យ និងជាព្រះដែលអាចនឹងបំផ្លិចបំផ្លាញខ្មាំងសត្រូវរបស់ទ្រង់បាន ដោយគ្រាន់តែញាក់ព្រះនេត្ររបស់ទ្រង់ដាក់គេតែប៉ុណ្ណោះ ទ្រង់មិនបានប្រព្រឹត្តដូចជាអ្វីដែលព្រះអម្ចាស់ធ្វើនៅក្នុងឧទាហរណ៍ខាងលើនេះទេ ប៉ុន្តែទ្រង់បែរជាទ្រាំទ្រចំពោះគេ ហើយផ្គត់ផ្គង់ និងថែរក្សាពួកគេជារៀងរាល់ថ្ងៃវិញ។ នេះជាការត្រឹមត្រូវណាស់ដែលទ្រង់បង្គាប់ឲ្យយើងឲ្យពរដល់អស់អ្នកដែលប្រទេចផ្តាសាយើង ពីព្រោះទ្រង់ប្រព្រឹត្តល្អចំពោះមនុស្សអាក្រក់ និងមនុស្សដែលមិនអរព្រះគុណទ្រង់។ ប៉ុន្តែ ឱមនុស្សមានបាបទាំងអស់គ្នាអើយ! ចូរកុំប្រទូរំថា អ្នកអាចនឹងគេចរួចផុតពីសេចក្តីក្រោធរបស់ទ្រង់បានឡើយ។ បើទោះបីជាម៉ាស៊ីនកិនរបស់ទ្រង់វិលយឺតៗក៏ដោយ ក៏វានឹងកិនបានយ៉ាងម៉ត់ដែរ។ ដែល

ទ្រង់មានសេចក្តីអត់ធ្មត់បរិបូរជាយ៉ាងណានៅពេលឥឡូវនេះ នោះសេចក្តីក្រោធរបស់ទ្រង់ក៏នឹងកាន់តែខ្លាំងឡើងៗចំពោះអស់អ្នកដែលមើលងាយ ហើយជាន់ឈ្លីសេចក្តីសប្បុរសរបស់ទ្រង់យ៉ាងនោះដែរ។ គ្មានអ្វីមួយដែលមានភាពស្ងប់ស្ងាត់ដូចជាទឹកសមុទ្រទេ ប៉ុន្តែនៅពេលដែលវាបោកបក់ឡើងជាព្យុះសង្ឃរាវិញ នោះក៏គ្មានអ្វីមួយដែលកាចសាហាវដូចជាសមុទ្រដែរ។ ដូចគ្នានេះដែរ គ្មានអ្វីណាមួយដែលផ្អែមល្ហែមដូចជាសេចក្តីអត់ធ្មត់ និងសេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ទេ ហើយក៏គ្មានអ្វីមួយ ឬក៏អ្នកណាម្នាក់ ដែលគួរឲ្យរន្ធត់ជាងសេចក្តីក្រោធរបស់ទ្រង់ដែរ នៅពេលដែលទ្រង់បញ្ឆេះវាដោយភ្លើង» (William Gurnall, ១៦៦០)។

ដូច្នេះ មិត្តអ្នកអានទាំងអស់គ្នាអើយ! ចូររត់ទៅរកព្រះគ្រីស្ទ «រត់ចេញពីសេចក្តីក្រោធដែលត្រូវមក» ចូររត់ខណៈពេលដែលលោកអ្នកមិនទាន់អស់ឱកាសនៅឡើយ! យើងខ្ញុំសូមអង្វរលោកអ្នកដោយអស់ពីចិត្តថា ចូរកុំគិតថាសារនេះសម្រាប់អ្នកដទៃឡើយ តែផ្ទុយទៅវិញសារនេះគឺសម្រាប់លោកអ្នកផ្ទាល់! ដូច្នេះ ចូរកុំទាន់អាលសប្បាយចិត្តដោយគិតថា លោកអ្នកបានរត់ទៅរកព្រះគ្រីស្ទរួចហើយឲ្យសោះ ប៉ុន្តែលោកអ្នកត្រូវតែដឹងឲ្យប្រាកដជាមុនសិន។ ចូរទទូចសូមដល់ព្រះជាម្ចាស់ឲ្យទតមើលដួងចិត្តរបស់លោកអ្នក និងបង្ហាញ

ឲ្យលោកអ្នកបានមើលឃើញកាន់តែច្បាស់។

## បណ្ដាំទៅកាន់គ្រូគង្វាល

ឱបងប្អូនអើយ! នៅក្នុងព័ន្ធកិច្ចនៃការប្រើបបូរមាត់របស់យើង តើយើងបានអធិប្បាយអំពីប្រធានបទដ៏ឱឡារិកនេះបានយ៉ាងច្បាស់តាមលទ្ធភាពដែលយើងគួរធ្វើបានហើយឬនៅ? ពួកហោរានៅក្នុងព្រះគម្ពីរសញ្ញាចាស់តែងតែប្រាប់អស់អ្នកដែលស្ដាប់ពួកគេម្ដងហើយម្ដងទៀតថា អំពើអាក្រក់ដែលពួកគេប្រព្រឹត្ត បានចាក់រុកឲ្យព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែលខ្ញាល់នឹងពួកគេ ហើយថាពួកគេកំពុងប្រមូលផ្ដុំសេចក្ដីក្រោធរបស់ព្រះជាម្ចាស់មកដាក់លើជីវិតខ្លួនគេផ្ទាល់ សម្រាប់ថ្ងៃដែលទ្រង់នឹងកាត់ទោសពួកគេហើយ។ ហើយស្ថានការណ៍នៅលើលោកីយ៍សព្វថ្ងៃនេះក៏នៅអាក្រក់ដូចពីមុនដែរ! គ្មានអ្វីដែលអាចនឹងចាក់ចុចអស់អ្នកដែលគ្រាន់តែរាប់ខ្លួនថាជាអ្នកជឿដោយមិនបានគិតគូរជាមុន ឲ្យស្វែងយល់ពីចិត្តខ្លួនឯង ជាជាងការដែលយើងរៀបរាប់ឲ្យច្បាស់ថា «អើ ទ្រង់ជាព្រះដែលមានសេចក្ដីខ្ញាល់ ចំពោះមនុស្សអាក្រក់រាល់តែថ្ងៃ» (ទំនុកតម្កើង ៧:១១) នោះទេ។ លោក យ៉ូហាន-បាទីស្ទ ដែលព្រះជាម្ចាស់បានចាត់ឲ្យមកមុនព្រះគ្រីស្ទ បានដាស់តឿនអស់អ្នកដែលស្ដាប់ឲ្យ៖ «រត់ចេញពីសេចក្ដី

ក្រោធដែលត្រូវមក» (ម៉ាថាយ ៣:៧)។ ព្រះសង្គ្រោះបានមានបន្ទូលទៅកាន់អស់អ្នកដែលស្ដាប់ទ្រង់ថា «ត្រូវឲ្យខ្លាចដល់ព្រះវិញ ដែលកាលណាទ្រង់សម្លាប់ នោះក៏មានអំណាចបោះចោលទៅក្នុងនរកបានផង។ អើ ខ្ញុំប្រាប់អ្នករាល់គ្នាថា ត្រូវឲ្យខ្លាចដល់ព្រះអង្គចុះ» (លូកា ១២:៥)។ សាវ័ក ប៉ុល បានលើកឡើងថា «ដោយយើងបានស្គាល់ការគោរពកោតខ្លាចព្រះជាម្ចាស់ហើយ យើងក៏ខិតខំណែនាំមនុស្សលោកឲ្យជឿដែរ» (២កូរិនថូស ៥:១១ គខប)។ សេចក្ដីស្មោះត្រង់ ទាមទារឲ្យយើងបង្រៀនអំពីស្ថាននរក និងស្ថានសួគ៌ឲ្យបានច្បាស់លាស់ដូចគ្នា។

ជំពូកទី១៧

# ការសញ្ជឹងគិតអំពីព្រះជាម្ចាស់

យើង បាន សិក្សា អំពី លក្ខណ សម្បត្តិ ដ៏ ល្អ ឥត ខ្ចោះ របស់ព្រះជាម្ចាស់ជាច្រើនមកហើយនៅក្នុងជំពូកមុនៗ។ យោងតាមការពណ៌នាដ៏ខ្សត់ខ្សោយរបស់យើងអំពីលក្ខណសម្បត្តិរបស់ទ្រង់ គឺយើងត្រូវតែទទួលស្គាល់ជាមុនថា យើងមិនអាចយល់អំពីព្រះជាម្ចាស់បានទាំងស្រុងឡើយហើយខណៈពេលដែលយើងព្យាយាមយល់ពីទ្រង់ នោះយើងនឹងលង់ក្នុងភាពល្អឥតខ្ចោះដែលគ្មានដែនកំណត់របស់ទ្រង់។ យើងត្រូវតែលើកឡើងដូចជាលោកសូផារ (Zophar) ដែលថា "បើអ្នកខំស្វែងរក តើអាចនឹងស្គាល់សភាពនៃព្រះបាន ឬយល់ដល់សេចក្តីគ្រប់លក្ខណ៍របស់ព្រះដ៏មានគ្រប់ព្រះចេស្តាបានដែរឬ នោះខ្ពស់ជាងស្ថានសួគ៌ទៅទៀត តើអ្នកអាចនឹងធ្វើយ៉ាងណាបាន ក៏ជ្រៅជាងស្ថានឃុំព្រលឹងមនុស្សស្លាប់

ផង ធ្វើដូចម្ដេចឲ្យអ្នកយល់បាន បើនឹងវាស់ នោះក៏វែងជាងផែនដី ហើយធំជាងសមុទ្រទៅទៀត?» (យ៉ូប ១១:៧-៩)។ នៅពេលដែលយើងគិតអំពីភាពដ៏អស់កល្បជានិច្ចរបស់ទ្រង់ ភាពមិនមានរូបរាងកាយរបស់ទ្រង់ និងអំពីការដែលទ្រង់គង់នៅគ្រប់ទីកន្លែង ព្រមទាំងអំពីសព្វានុភាពរបស់ទ្រង់ នោះយើងនឹងឃើញថា ការទាំងអស់នោះលើសពីគំនិតដែលខួរក្បាលដ៏តូចរបស់យើងអាចគិតដល់ទៅទៀត។

## ការសិក្សាអំពីភាពជាព្រះ

ប៉ុន្តែ សូមកុំភាន់ច្រឡំថា ទោះបើយើងមិនអាចយល់អំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់បានទាំងស្រុងក៏ដោយ ក៏នោះមិនមែនមានន័យថា យើងមិនគួរស្វែងយល់ដោយចិត្តកោតខ្លាច ឬក៏ស្វែងយល់ដោយអធិស្ឋាន ដើម្បីឲ្យកាន់តែយល់នូវអ្វីដែលទ្រង់បានបើកសម្ដែងដល់យើងតាមរយៈព្រះបន្ទូលរបស់ទ្រង់នោះឡើយ។ ប្រសិនបើយើងគិតថា ដោយសារយើងមិនអាចយល់អំពីព្រះជាម្ចាស់បានទាំងស្រុង នោះយើងមិនគួរនឹងស្វែងយល់អំពីទ្រង់ សូម្បីតែបន្តិចគឺមានន័យថា យើងជាមនុស្សល្ងីល្ងើហើយ។ លោកគ្រូ (ស៊ី. អេឆ. ស្ពើចិន) បានមានប្រសាសន៍យ៉ាងសមហេតុផលថា៖

“គ្មានអ្វីអាចនឹងពង្រីកចំណេះដឹងរបស់យើង ក៏ដូចជាបើក

សម្តែងឲ្យយើងយល់អំពីព្រលឹងរបស់យើងបាន ជាជាងការដែលយើងបន្តព្យាយាមស្វែងយល់អំពីព្រះជាម្ចាស់ឡើយ។ ការសិក្សាដ៏ល្អបំផុតដែលនឹងពង្រឹង ហើយពង្រីកព្រលឹងរបស់យើងគឺ ការដែលយើងសិក្សាស្វែងយល់អំពីព្រះគ្រីស្ទ ការដែលទ្រង់ត្រូវគេឆ្កាង និងចំណេះដឹងអំពីព្រះត្រៃឯកទាំងមូល»។

ចូរអានសម្រង់សម្តីបន្ថែមទៀតរបស់លោកគ្រូ (ស៊ី. អេឆ. ស្ពើចិន) ដែលគេបានឲ្យរហស្សនាមគាត់ថាជា កំពូលអ្នកអធិប្បាយ៖

«នេះជាការដ៏ប្រពៃ ហើយត្រឹមត្រូវណាស់ ប្រសិនបើគ្រីស្ទបរិស័ទគ្រប់រូបព្យាយាមស្វែងយល់ និងកាន់តែស្គាល់ព្រះត្រៃឯក។ ការសិក្សាដ៏ប្រសើរ ការប៉ាន់ស្មានដ៏អស្ចារ្យ និងទស្សនវិជ្ជាដែលពោរពេញដោយឫទ្ធានុភាពដែលបុត្រាបុត្រីរបស់ព្រះជាម្ចាស់អាចមានចំណែកជាមួយគឺជាការដែលពួកគេព្យាយាមស្វែងយល់អំពីព្រះនាម លក្ខណសម្បត្តិ បុគ្គលិកលក្ខណៈ និងការប្រព្រឹត្តរបស់ទ្រង់ ព្រមទាំងការដែលទ្រង់មានព្រះជន្មគង់នៅពោលគឺការដែលពួកគេស្គាល់ព្រះដែលពួកគេហៅថាជាព្រះវរបិតារបស់ខ្លួន។ ការដែលយើងសញ្ជឹងគិតអំពីព្រះជាម្ចាស់ នោះពិតជាជួយឲ្យខួរក្បាលរបស់យើងមានភាពល្អប្រសើរជាងមុនមែន ហើយការដែលយើងព្យាយាមសញ្ជឹងគិតអំពីប្រធានបទដ៏ធំធេងនេះ នោះនឹងនាំឲ្យយើងលង់ក្នុង

ភាពដ៏ឧត្តុង្គឧត្ដមរបស់ទ្រង់។ ប្រធានបទនេះមានជម្រៅយ៉ាងជ្រៅ ដែលអាចនឹងពន្លិចអំនួតរបស់យើងនៅក្នុងភាពដ៏អស់កល្បជានិច្ចបាន។ ចំពោះប្រធានបទផ្សេងៗទៀត យើងអាចយល់ និងអាចមានវិធីស្វែងយល់បាន ហើយយើងក៏អាចមានអារម្មណ៍ស្កប់ស្កល់ព្រមទាំងអាចគិតថា “ខ្ញុំពិតជាមនុស្សដ៏ឆ្លាតវៃម្នាក់មែន”។ ប៉ុន្តែ ចំពោះការដែលយើងព្យាយាមស្វែងយល់អំពីព្រះជាម្ចាស់ គឺយើងគ្មានរង្វាស់អ្វីដែលអាចវាស់ស្ទង់ពីជម្រៅរបស់ទ្រង់បានឡើយ ហើយយើងក៏គ្មានភ្នែកដែលអាចមើលដល់កម្ពស់របស់ទ្រង់បានដែរ។ ដូច្នេះហើយបានជាយើងនឹងដើរចេញដោយមានគំនិតថា “ខ្ញុំទើបតែកើតពីម្សិលមិញទេ ហើយខ្ញុំក៏មិនចេះអ្វីដែរ”»។ (ដកស្រង់ចេញពីការអធិប្បាយនៃកណ្ឌគម្ពីរ ម៉ាឡាគី ៣:៦)។

ប្រាកដណាស់! ចំណុចដែលយើងមិនអាចយល់អំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់បានទាំងស្រុង គួរតែបង្រៀនឲ្យយើងចេះបន្ទាបខ្លួន ចេះប្រុងប្រយ័ត្ន និងចេះកោតខ្លាចទ្រង់។ បន្ទាប់ពីយើងបានព្យាយាមស្វែងយល់ ហើយសញ្ជឹងគិតកន្លងមក ការនោះគួរតែឲ្យយើងហ៊ាននិយាយដូចជាលោក យ៉ូប ថា «មើល ការទាំងនេះគ្រាន់តែជាកិច្ចខាងក្រៅរបស់ទ្រង់ទេ...តើអ្នកណានឹងយល់បាន?» (យ៉ូប ២៦:១៤)។ នៅពេលដែលលោក ម៉ូសេ ទទូចអង្វរព្រះជាម្ចាស់ឲ្យទ្រង់

បង្ហាញសិរីល្អរបស់ទ្រង់ដល់គាត់ ទ្រង់បានមានព្រះបន្ទូលថា “អញនឹង...ប្រកាសពីព្រះនាម “យេហូវ៉ា” នៅមុខឯង» (និក្ខមនំ ៣៣:១៩)។ ហើយក៏មានអ្នកនិពន្ធម្នាក់ទៀតដែលបានលើកឡើងផងដែរថា “នៅក្នុងព្រះនាមរបស់ទ្រង់ប្រមូលផ្តុំនូវគ្រប់លក្ខណសម្បត្តិទាំងអស់”។ លោកគ្រូ (ចន ហូវ) ដែលជាសមាជិកពួកព្យូរីតិន (The Puritan) បានមានប្រសាសន៍យ៉ាងត្រឹមត្រូវថាៈ

“អ្វីៗដែលយើងបានដឹង ហើយអាចសន្និដ្ឋានអំពីសិរីល្អរបស់ព្រះអង្គគឺគ្រាន់តែជាសៀវភៅដ៏ធំមួយដែលរៀបរាប់ត្រួសៗអំពីទ្រង់ ឬក៏គ្រាន់តែជាទីធ្លាដីដ៏ធំមួយដែលមានការអភិវឌ្ឍបន្តិចបន្តួចតែប៉ុណ្ណោះ។ ព្រះជាម្ចាស់ពិតជាបានបើកសម្តែងឲ្យយើងដឹងអំពីទ្រង់ ប៉ុន្តែទ្រង់មិនបានបើកសម្តែងឲ្យយើងដឹងអំពីទ្រង់ទាំងស្រុងនោះទេ។ អ្វីៗដែលទ្រង់បានបើកសម្តែងគឺគ្រប់គ្រាន់សម្រាប់ការពារយើង ដើម្បីកុំឲ្យយើងយល់ខុសអំពីទ្រង់ ឬមិនយល់អ្វីសោះពីទ្រង់តែម្តង។ យើងអាចប្រើប្រាជ្ញារបស់យើង ដើម្បីសញ្ជឹងគិតអំពីលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះមួយចំនួនរបស់ព្រះដែលពោរពេញដោយព្រះពរ ដែលទ្រង់បានបើកសម្តែងដល់យើង។ បន្ទាប់មក យើងអាចថ្វាយនូវអ្វីៗដែលយើងបានស្វែងរកទៅដល់ទ្រង់វិញ ទោះបីជាការនោះគ្រាន់តែជាផ្នែកតូចមួយ និងមើលទៅមិនស័ក្តិសមក៏ដោយ។ ការយល់ដឹង

ដែលយើងអាចស្វែងរកឃើញតាមរយៈអ្វីដែលទ្រង់បានបើកសម្តែងដល់យើងអំពីលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះមួយចំនួនរបស់ទ្រង់នោះ គឺជាចំណេះដឹងដែលយើងមានអំពីសិរីល្អរបស់ទ្រង់»។

ការយល់ដឹងអំពីព្រះជាម្ចាស់ដែលពួកបរិសុទ្ធដ៏ជារាស្ត្ររបស់ទ្រង់បានយល់ដឹងនៅលើផែនដីនេះ គឺខុសគ្នាឆ្ងាយណាស់ពីការយល់ដឹងដែលពួកគេនឹងមាននៅឯស្ថានសួគ៌។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តីក៏ពួកគេមិនត្រូវបន្ទាបតម្លៃនៃការយល់ដឹងនៅបច្ចុប្បន្ននេះដោយសារតែការយល់ដឹងនេះមិនល្អឥតខ្ចោះនោះឡើយ ហើយពួកគេក៏មិនត្រូវឲ្យតម្លៃខ្ពស់ពេកទៅលើការយល់ដឹងនៅពេលអនាគតដែរ ព្រោះវាខ្ពស់ជាងធាតុពិតដែលពួកគេអាចយល់បានឆ្ងាយណាស់។ ពិតណាស់ ព្រះបន្ទូលបានប្រកាសថា យើងនឹងឃើញព្រះជាម្ចាស់ «មុខទល់នឹងមុខ» ហើយយើងក៏នឹង «ស្គាល់» ទ្រង់ «ដូចជាព្រះទ្រង់ស្គាល់» យើង ប៉ុន្តែប្រសិនបើយើងគិតថា យើងនឹងស្គាល់ទ្រង់ច្បាស់ដូចទ្រង់ស្គាល់យើងគឺយើងយល់ខុសទាំងស្រុងហើយ (១កូរិនថូស ១៣:១២)។ បើយើងគិតបែបនេះមានន័យថា យើងមិនបានយល់អំពីពាក្យពេចន៍នៅក្នុងកណ្ឌគម្ពីរបានត្រឹមត្រូវទេ ហើយក៏មានន័យថា យើងភ្លេចថាការគិតរបស់យើងមានព្រំដែនដែរ ពោលគឺព្រំដែនដែលព្រះជាម្ចាស់មិនស្ថិតនៅក្រោម។ ការដែលរូបកាយពួកបរិសុទ្ធ

នឹងទទួលបានការបំផ្លាស់បំប្រែគឺមានលក្ខណៈខុសគ្នាឆ្ងាយណាស់ពីការដែលរូបកាយរបស់គេក្លាយជាព្រះ។ ទោះបីជារូបកាយរបស់គ្រីស្ទបរិស័ទបានទទួលការបំផ្លាស់បំប្រែរួចហើយក៏ដោយ ក៏ការយល់ដឹងរបស់ពួកគេនៅតែមានដែនកំណត់ដែរ ហេតុដូច្នេះហើយបានជាពួកគេមិនអាចស្គាល់ព្រះដ៏គ្មានដែនកំណត់បានទាំងស្រុងឡើយ។

«ពួកបរិសុទ្ធនៅស្ថានសួគ៌នឹងមើលឃើញព្រះជាម្ចាស់ដោយប្រើភ្នែកខាងក្នុងចិត្តរបស់ពួកគេ ដ្បិតពួកគេមិនអាចមើលទ្រង់ឃើញដោយប្រើភ្នែកខាងសាច់ឈាមរបស់គេឡើយ។ នៅពេលនោះ ពួកគេនឹងមើលទ្រង់ឃើញច្បាស់ជាងជំនឿ និងតក្កនៅពេលឥឡូវនេះ។ ពួកគេនឹងមើលឃើញទ្រង់យ៉ាងទូលំទូលាយ ជាងអ្វីដែលទ្រង់បានបើកសម្ដែងឲ្យឃើញពីមុនៗ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ចិត្តគំនិតរបស់ពួកគេមិនធំល្មមនឹងឲ្យពួកគេអាចស្គាល់ទ្រង់បានទាំងស្រុងក្នុងពេលតែមួយ ឬក៏ស្គាល់ទ្រង់បានយ៉ាងលម្អិត ក៏ដូចជាស្គាល់គ្រប់លក្ខណសម្បត្តិទាំងអស់របស់ទ្រង់បាននោះដែរ។ ដើម្បីឲ្យពួកគេអាចនឹងយល់អំពីលក្ខណសម្បត្តិដ៏គ្មានដែនកំណត់របស់ព្រះអង្គបាន គឺពួកគេត្រូវតែមានលក្ខណៈដែលគ្មានដែនកំណត់ដែរ។ ប៉ុន្តែ ដោយសារពួកគេមិនមានលក្ខណៈបែបនោះ ពួកគេមិនអាចយល់បានឡើយ។ ទោះបីជាពួកគេនៅស្ថានសួគ៌ ក៏ពួកគេមិន

អាចយល់បានទាំងស្រុងដែរ ប៉ុន្តែក្នុងពេលតែមួយនោះពួកគេនឹងមានអំណរយ៉ាងពេញលេញ ពីព្រោះពួកគេនឹងមានចំណេះដឹងយ៉ាងពេញលេញអំពីលក្ខណសម្បត្តិនេះ៖ ពួកគេនឹងស្គាល់ទ្រង់បានយ៉ាងពេញលេញតាមសមត្ថភាពដែលពួកគេអាចស្គាល់ទ្រង់បាន ប៉ុន្តែពួកគេនឹងមិនអាចស្គាល់ទ្រង់លើសពីលក្ខណៈដ៏ឧត្តមរបស់ទ្រង់បានឡើយ។ យើងជឿថាការយល់ដឹងរបស់យើងអំពីព្រះជាម្ចាស់នឹងមានការកើនឡើងពីមួយកម្រិតទៅមួយកម្រិត នៅពេលដែលយើងកាន់តែយល់អំពីទ្រង់ ហើយយើងក៏នឹងកាន់តែទទួលបានព្រះពរដែរ។ ប៉ុន្តែ គ្មានពេលវេលាណាមួយដែលយើងអាចស្គាល់ទ្រង់លើសពីកម្រិតដែលយើងអាចស្វែងយល់បាននោះទេ ទោះបីជាប៉ុន្មានសតវត្សរ៍ទៀតក៏ដោយ ក៏យើងនៅតែមិនអាចយល់ដឹងអំពីព្រះជាម្ចាស់បានទាំងស្រុងដែរ» (ចន ដិក, ឆ្នាំ១៨៤០ John Dick)។

ទី២ តាមរយៈការរម្លឹកអំពីលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់យើងអាចមើលឃើញថា ទ្រង់ជាព្រះដែលមានអ្វីៗគ្រប់គ្រាន់រួចទៅហើយ។ ព្រះអង្គជាព្រះដែលមានគ្រប់គ្រាន់នៅក្នុងអង្គទ្រង់ផ្ទាល់ និងចំពោះទ្រង់ផ្ទាល់ ហើយទ្រង់មិនត្រូវការអ្វីក្រៅពីរូបអង្គទ្រង់នោះទេ។ ដោយសារទ្រង់ជាបុត្រច្បងនៅក្នុងចំណោមអ្វីៗទាំងអស់ដែលមានជីវិត នោះទ្រង់មិនអាចទទួលអ្វីមួយបានពីអ្នក

ណាម្នាក់ឡើយ ហើយក៏គ្មានអ្នកណាខ្លាំងជាងទ្រង់ដែរ។ ដោយសារទ្រង់ជាព្រះដែលគ្មានដែនកំណាត់ ដូច្នេះហើយបានជាគ្រប់លក្ខណសម្បត្តិដែលទ្រង់មានគឺសុទ្ធតែល្អឥតខ្ចោះ។ នៅពេលដែលព្រះត្រៃឯកគង់នៅតែអង្គឯង គឺទ្រង់មានអ្វីៗគ្រប់គ្រាន់នៅក្នុងអង្គទ្រង់ផ្ទាល់រួចទៅហើយ។ ប្រាជ្ញារបស់ទ្រង់ សេចក្តីស្រឡាញ់របស់ទ្រង់ និងថាមពលរបស់ទ្រង់ គឺទ្រង់មានគ្រប់គ្រាន់អស់ហើយ។ ប្រសិនបើព្រះជាម្ចាស់មានតម្រូវការដែលមានអ្នកផ្សេងអាចបំពេញបាន នោះមានន័យថា ទ្រង់មិនមែនជាព្រះដែលប្រកបដោយអធិបតេយ្យភាពទៀតទេ ហើយវាបញ្ជាក់ឲ្យយើងឃើញថា ទ្រង់មិនមែនជាព្រះឡើយ។ ទ្រង់បានបង្កើតគ្រប់អ្វីៗទាំងអស់មក ហើយការនោះគឺ "សម្រាប់ព្រះអង្គ" ប៉ុន្តែ ទ្រង់មិនបានធ្វើការនោះដើម្បីបំពេញតម្រូវការណាមួយរបស់ទ្រង់ទេ តែទ្រង់បានធ្វើដើម្បីប្រទានជីវិត និងសេចក្តីអំណរដល់ពួកទេវតា និងមនុស្សវិញ ព្រមទាំងដើម្បីឲ្យពួកគេទទួលបានការសម្តែងពីសិរីល្អរបស់ទ្រង់ (កូឡុស ១:១៦ គកស)។ នេះជាការពិតណាស់ដែលថាទ្រង់ទាមទារឲ្យយើងដែលមានចំណេះដឹងធ្វើការបម្រើ និងសម្តែងភក្តីភាពចំពោះទ្រង់ ប៉ុន្តែ សូមកុំច្រឡំថា ទ្រង់ទទួលបានប្រយោជន៍អ្វីមួយពីយើងឲ្យសោះ ដ្បិតផលទាំងអស់គឺសម្រាប់ជាប្រយោជន៍ដល់យើងទេដូចដែលកណ្ឌគម្ពីរ យ៉ូប

២២:២-៣ បានបញ្ជាក់ហើយ។ ទ្រង់ប្រើវិធីសាស្ត្រ និងឧបករណ៍ផ្សេងៗ ដើម្បីសម្រេចផែនការរបស់ទ្រង់ ហើយទ្រង់មិនបានធ្វើដូច្នោះដោយសារទ្រង់គ្មានអំណាចព្រះចេស្ដាគ្រប់គ្រាន់នោះទេ ប៉ុន្តែភាគច្រើនគឺទ្រង់ធ្វើបែបនោះដើម្បីសម្ដែងពីអំណាចព្រះចេស្ដារបស់ទ្រង់តាមរយៈឧបករណ៍ដ៏ទន់ខ្សោយវិញ។

## សេចក្ដីសប្បុរសនៃទ្រង់ នោះវិសេសជាងជីវិត

ភាពគ្រប់គ្រាន់របស់ព្រះជាម្ចាស់បង្ហាញថាទ្រង់ជាព្រះដ៏ឧត្តុង្គឧត្ដមក្រៃលែង ហើយយើងត្រូវតែសង្វាតតាមទ្រង់ជានិច្ច! អំណរដ៏ពិតប្រាកដមានតែនៅក្នុងសេចក្ដីអរសប្បាយរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ គុណប្រយោជន៍របស់ព្រះជាម្ចាស់គឺជាជីវិត ហើយសេចក្ដីស្រឡាញ់ដែលពោរពេញដោយសេចក្ដីសប្បុរសរបស់ទ្រង់ គឺប្រសើរជាងជីវិតទៅទៀត។ «ព្រលឹងខ្ញុំបានពោលថា ព្រះយេហូវ៉ាជាចំណែកនៃខ្ញុំ ហេតុនោះខ្ញុំនឹងសង្ឃឹមដល់ទ្រង់» (បរិទេវ ៣:២៤)។ ពួកបរិសុទ្ធរបស់ទ្រង់ប្រាថ្នាចង់បានសេចក្ដីស្រឡាញ់ ព្រះគុណ និងសិរីល្អរបស់ទ្រង់ ពីព្រោះចំណុចទាំងនោះនាំឲ្យពួកគេមានភាពស្កប់ស្កល់ទាំងស្រុង។

“មានមនុស្សជាច្រើនដែលនិយាយថា តើអ្នកណានឹងសម្ដែងឲ្យ

យើងឃើញសេចក្ដីល្អ ឱព្រះយេហូវ៉ាអើយ សូមទ្រង់ប្រោសឲ្យរស្មីនៃព្រះភក្ត្រទ្រង់ បានភ្លឺមកលើយើងខ្ញុំរាល់គ្នា ទ្រង់បានប្រោសឲ្យចិត្តទូលបង្គំមានសេចក្ដីអំណរលើសជាងពួកទាំងនោះ ក្នុងកាលដែលស្រូវ និងទឹកទំពាំងបាយជូររបស់គេបានសម្បូរផង» (ទំនុកតម្កើង ៤:៦-៧)។

ប្រាកដណាស់! នៅពេលដែលគ្រីស្ទបរិស័ទណាម្នាក់មានគំនិតត្រឹមត្រូវ នោះគាត់នឹងអាចពណ៌នាថា៖

«ទោះបីដើមល្វាមិនមានផ្កា ក៏ឥតមានផ្លែទំពាំងបាយជូរ ហើយផលនៃដើមអូលីវក៏ខានមាន ស្រែចំការឥតបង្កើតបានអាហារ ហ្វូងចៀមត្រូវបាត់ចេញពីក្រោល ហើយគ្មានគោនៅក្នុងឃ្លងក៏ដោយ គង់តែខ្ញុំនឹងរីករាយ ដោយសារព្រះយេហូវ៉ា ខ្ញុំនឹងអរសប្បាយក្នុងព្រះដ៏ជួយសង្គ្រោះខ្ញុំដែរ» (ហាបាគុក ៣:១៧-១៨)។

## ព្រះនៃរបស់សព្វសារពើ

ទី៣ តាមរយៈការរម្លឹកអំពីលក្ខណសម្បត្តិដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់ នោះយើងឃើញថា ទ្រង់ជាព្រះដ៏ឧត្ដុង្គឧត្ដមដែលគ្រងរាជ្យលើចក្រវាលទាំងមូល។ មានគេលើកឡើងយ៉ាងត្រឹមត្រូវថា៖

«គ្មានអ្នកណាអាចសោយរាជ្យបានយ៉ាងល្អជាងព្រះជាម្ចាស់

ឡើយ ដោយសារទ្រង់សោយរាជ្យលើអ្វីៗទាំងអស់ដែលជាស្នាព្រះហស្តរបស់ទ្រង់នោះទេ។ ពីព្រោះមិនមានអ្នកណាបង្ខំឲ្យព្រះជាម្ចាស់បង្កើតអ្វីមួយ នៅពេលដែលទ្រង់បង្កើតគ្រប់អ្វីៗទាំងអស់ នោះទ្រង់មានសិទ្ធិក្នុងការបង្កើតវា តាមដែលព្រះអង្គសព្វព្រះហឫទ័យក្នុងការបង្កើតវា។ ព្រះជាម្ចាស់ទ្រង់ប្រើប្រាស់អំណាចព្រះចេស្តារបស់ទ្រង់ដែលគ្មានអ្នកណាអាចបង្ក្រាបបានមកបង្កើតអ្វីៗគ្រប់យ៉ាង។ ទ្រង់បានបង្កើតរបស់ខ្លះមកឲ្យអាចកម្រើកបាន និងខ្លះទៀតមិនអាចកម្រើកបានខ្លះស្អាត និងខ្លះទៀតមិនស្អាត ហើយរបស់ទាំងអស់នោះសុទ្ធតែមានគុណសម្បត្តិខុសៗគ្នា ប៉ុន្តែគ្មាននិចលភាព ឬក៏ស្មារតីសោះឡើយ។ របស់ខ្លះទ្រង់បានបង្កើតមកឲ្យមានចលនា អាចដុះដាលឬក៏រីកធំឡើង ប៉ុន្តែវានៅតែគ្មានជីវិតក្នុងអត្ថន័យដ៏ត្រឹមត្រូវដដែល។ ចំពោះរបស់ខ្លះទ្រង់មិនគ្រាន់តែឲ្យវាមានចលនាប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ថែមទាំងបានឲ្យវាមានស្មារតីមានសរីរាង្គដែលយល់ដឹង និងអំណាចដែលអាចជំរុញខ្លួនឯងបាន។ ចំពោះមនុស្សវិញ ទ្រង់បានប្រទានវិចារណញ្ញាណដល់ពួកគេទុកជាអំណោយទាន ហើយក៏ប្រទានឲ្យពួកគេមានព្រលឹងដែលមិនចេះស្លាប់ដែរ ដែលធ្វើឲ្យពួកគេមានឋានៈខ្ពស់ជាងរបស់ផ្សេងៗ។

ទ្រង់បានសោយរាជ្យលើពិភពលោកដែលទ្រង់បានបង្កើតមក

នេះដោយព្រះដំបងមាសរបស់ទ្រង់ ដែលប្រកបដោយសព្វានុភាព។ កណ្ឌគម្ពីរ ដានីយ៉ែល ៤:៣៤-៣៥ បានចែងថា៖ “លុះដល់ផុតពេលកំណត់ហើយ នោះនេប៊ូក្នេសាយើងបានងើបភ្នែកឡើងទៅលើមេឃ ហើយសតិស្មារតីក៏ត្រឡប់មកឯយើងវិញ រួចយើងបានក្រាបថ្វាយបង្គំដល់ព្រះដ៏ខ្ពស់បំផុត ព្រមទាំងសរសើរ ហើយលើកតម្កើងព្រះដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ចផង ដោយព្រោះអំណាចគ្រប់គ្រងរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប ហើយរាជ្យទ្រង់ក៏នៅអស់ទាំងតំណមនុស្សតរៀងទៅ ឯអស់ទាំងមនុស្សលោកក៏រាប់ទុកជាឥតការទទេ ទ្រង់ធ្វើតាមតែព្រះហឫទ័យក្នុងពួកពលបរិវារនៃស្ថានសួគ៌ ហើយនៅកណ្ដាលពួកមនុស្សលោកផង ឥតមានអ្នកណាអាចនឹងឃាត់ទប់ព្រះហស្តទ្រង់ ឬនឹងទូលសួរទ្រង់ថា ទ្រង់ធ្វើអ្វីដូច្នេះបានឡើយ”» (លោកគ្រូ ចន ដិក)។

ការដែលយើងគិតបែបនេះបង្ហាញឲ្យឃើញថា មនុស្សគ្មានសិទ្ធិឡើយ។ យើងគ្មានសិទ្ធិនឹងទាមទារអ្វីពីព្រះដែលបានបង្កើតយើងមកនោះទេ ហើយមិនថាព្រះជាម្ចាស់ប្រព្រឹត្តចំពោះយើងបែបណាក៏ដោយ ក៏យើងគ្មានសិទ្ធិរអ៊ូរទាំដាក់ទ្រង់ដែរ។ ប៉ុន្តែ នៅពេលដែលយើងគិតអំពីការដែលព្រះជាម្ចាស់សោយរាជ្យនោះ សូមកុំឲ្យយើងភ្លេចថាទ្រង់ជាព្រះដែលមានព្រះហឫទ័យប្រកបដោយសីលធម៌ដ៏ល្អ

ឥតខ្ចោះ។ ព្រះជាម្ចាស់ទ្រង់ជាព្រះដែលប្រកបដោយភាពយុត្តិធម៌ និងសេចក្ដីសប្បុរស ហើយអ្វីៗដែលទ្រង់ធ្វើ គឺសុទ្ធតែត្រឹមត្រូវទាំងអស់។ តែទោះជាយ៉ាងណាក៏ដោយ ក៏ទ្រង់សោយរាជ្យប្រកបដោយអធិបតេយ្យភាព និងទៅតាមព្រះហឫទ័យដ៏សុចរិតរបស់ទ្រង់ដែរ។ ព្រះជាម្ចាស់ចាត់ចែងនិងរៀបចំឋានៈឲ្យយើងគ្រប់ៗគ្នាតាមដែលទ្រង់ឃើញថាល្អនៅក្នុងព្រះនេត្ររបស់ទ្រង់។ ព្រះអង្គបង្គាប់បញ្ជាគ្រប់កាលៈទេសៈទាំងអស់ទៅតាមព្រះតម្រិះរបស់ទ្រង់។ គ្រប់គ្រឿងប្រដាប់ទាំងអស់ដែលទ្រង់បានសូនគឺសុទ្ធតែធ្វើឡើងដោយចេញពីការប្ដេជ្ញារបស់ទ្រង់ដោយមិនមានឥទ្ធិពលពីខាងក្រៅឡើយ។ ទ្រង់ប្រទានសេចក្ដីមេត្តាករុណាដល់អស់អ្នកណាដែលទ្រង់សព្វព្រះហឫទ័យ ហើយទ្រង់ក៏ពង្រឹងចិត្តអស់អ្នកណាដែលទ្រង់សព្វព្រះហឫទ័យនឹងពង្រឹងដែរ។ ទោះបីជាយើងនៅទីណាក៏ដោយ ក៏ព្រះនេត្ររបស់ទ្រង់នៅតែមើលយើងឃើញដែរ។ ទោះយើងជាអ្នកណាក៏ដោយ ក៏ទ្រង់នៅតែមានអំណាចព្រះចេស្ដាលើជីវិតយើង ក៏ដូចជាអ្វីៗទាំងអស់នៅក្នុងជីវិតរបស់យើងដែរ។ ព្រះជាម្ចាស់គឺជាព្រះវរបិតាដ៏ទន់ភ្លន់ចំពោះគ្រីស្ទបរិស័ទ តែទ្រង់គឺជាព្រះដែលឆេះបន្សុសចំពោះមនុស្សមានបាបដែលទាស់ប្រឆាំងនឹងទ្រង់។ “រីឯស្ដេចនៃអស់ទាំងកល្ប ដែលទ្រង់មិនចេះសុគត ហើយមើល

ទ្រង់មិនឃើញ គឺជាព្រះតែ១ព្រះអង្គ នោះសូមឲ្យទ្រង់បានល្បី ព្រះនាម នឹងសិរីល្អអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន» (១ធីម៉ូថេ ១:១៧)។

# កំណត់យោង

**ជំពូកទី២**

១. មានន័យថា “ គំនិត ”។

២. លោកគ្រូ ចនណាថាន់ អេដវ៉ាដស៍ (Jonathan Edwards)។

**ជំពូកទី៥**

១. លោកគ្រូ ចេមស៍ ហើវី James Hervey, ១៧៨៩។

**ជំពូកទី៧**

១. ត្រចៀក

២. លោកគ្រូ ចន ដិក (John Dick), ១៨៥០។

**ជំពូកទី៩**

១. ព្រះពាហុ = កំភួនដៃ។

**ជំពូកទី១០**

១. ដកស្រង់ចេញពី “*God Moves in a Mysterious Way*”

និពន្ធដោយលោក៖ William Cowper, ឆ្នាំ១៧៧៤ ។

**ជំពូកទី១៤**

១. ចម្រៀង “*When All Thy Mercies, O My God*”
និពន្ធដោយ៖ លោក Joseph Addison, ឆ្នាំ១៦៧២-១៧១៩។

**ជំពូកទី១៥**

១. មិនស្គាល់អ្នកនិពន្ធ

# មានធនធានជាច្រើនទៀតនៅ៖

ផ្លូវពិត plovpit.com

**For ordering information please visit:**

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖

http://www.attributesofgodkhmer.com

# ហើយទាញយកសៀវភៅជា ច្រើនទៀតដោយឥតគិតថ្លៃនៅ៖

CambodianChristianResources.com

ផ្លូវពិត plovpit.com

## គេហទំព័រដែលមានព្រះគ្រីស្ទ ជាគោលដើម្បីលើកទឹកចិត្តអ្នកជឿ ទាំងអស់។

- វីដេអូ
- សៀវភៅ
- សៀវភៅជាសំឡេង
- កំណត់ហេតុបណ្ដាញ







ចូលរួមក្រុម

# Telegram

ដើម្បីទទួលមេរៀនព្រះបន្ទូល រៀងរាល់ថ្ងៃ

**t.me/plovpit**

ផ្លូវពិត
plovpit.com

សេចក្ដីបង្រៀនដ៏គួរឲ្យទុកចិត្តបានអំពីព្រះយេស៊ូវ
មាននៅ www.plovpit.com ក្នុងទម្រង់ជាកំណត់
ហេតុបណ្ដាញ វីដេអូ សំឡេង និងសៀវភៅ



# ទីក្រុងថ្មី

The New City Catechism

៥២ សំណួរ & ចម្លើយ
សម្រាប់ចិត្ត & គំនិតយើង




**លោកអ្នកក៏អាចចូលទៅ**
**ស្តាប់ដោយឥតគិតថ្លៃតាមរយៈ៖**

**www.khmerqanda.com**